# កតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិ
# សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

*ដោយ ហ្វីលីព អលស្តុន*

កតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌(តទៅហៅថា កតិកាសញ្ញា) ត្រូវបានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ(អ.ស.ប)ក្នុងសេចក្តីសំរេចចិត្តរបស់លេខ ២.២០០ A (XX1) នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។ កតិកាសញ្ញានេះ ត្រូវបានចូលជាធរមាននៅថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៧៦ ដោយអនុលោមតាមមាត្រា ២៧ នៃកតិកាសញ្ញា។ នៅខែកញ្ញា ឆ្នាំ១៩៩៦ រដ្ឋចំនួន១៣៥ បានផ្តល់សច្ចាប័ន ឬបានចូលជាសមាជិក។

## ក. ដំណើរការធ្វើបាយការណ៍

### (ក) កតិកាសញ្ញា និងល័ក្ខខ័ណ្ឌតំរូវឱ្យធ្វើរបាយការណ៍នៃកតិកាសញ្ញានេះ

កតិកាសញ្ញានេះជាកូនភ្លោះនឹងកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិមនុស្សពលរដ្ឋ និង នយោបាយ។ កតិកាសញ្ញានីមួយៗនៃកតិកាសញ្ញាទាំងពីរបរិយាយលំអិតសិទ្ធិខ្លះ ដែលមាននៅក្នុងសេចក្តីថ្លែងការណ៍ជាសាកល ស្តីពីសិទ្ធិមនុស្ស ហើយកតិកាសញ្ញាទាំងពីរមានខ្លឹមសារជាន់គ្នា។ ប៉ុន្តែការសំខាន់នោះ គឺថា បុព្វកថានៃកតិកាសញ្ញា ស្តីពីសេដ្ឋកិច្ច សង្គម និងវប្បធម៌ ទទួលស្គាល់ថា ឧត្តមគតិ នៃសិទ្ធិមនុស្សនឹងអាចសំរេចបាន "បើសិនជាលក្ខខ័ណ្ឌ ត្រូវបានបង្កើតសំរាប់ឱ្យមនុស្សម្នាក់ៗ អាស្រ័យផលនៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ក៏ដូចជាសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយរបស់គេ" (គំនិតដូចគ្នានេះត្រូវបានចែងនៅក្នុងបុព្វកថានៃកតិកាសញ្ញាទាក់ទងទៅនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ប៉ុន្តែលំដាប់នៃសិទ្ធិទាំងពីរក្រុមនេះត្រូវបានរាយបញ្ច្រាស់គ្នាទៅវិញ)។ ដូច្នេះ គេមិនអាច បំបែកកតិកាសញ្ញាទាំងពីរនេះដាច់ចេញពីគ្នាទេ ហើយគប្បីចាំនូវមធ្យោបាយ និងគោលដៅដែលបានចែងក្នុង កតិកាសញ្ញាទាក់ទងទៅនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅពេលតាក់តែងរបាយការណ៍ទាក់ទងនឹងកតិកា សញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

ក្នុងពាក្យសំដីនៃកឋាខ័ណ្ឌ ១ មាត្រា ២ នៃកតិកាសញ្ញារដ្ឋជាភាគីនីមួយៗ"សន្យាថានឹងចាត់វិធានការ ដើម្បីសំរេចឱ្យបានជាលំដាប់និងពេញលេញនូវសិទ្ធិដែលត្រូវបានទទួលស្គាល់ "។ កាតព្វកិច្ចនេះ ត្រូវអាស្រ័យលើ ការមានធនធាន ក៏ប៉ុន្តែ ទំហំនៃការលើកលែងនេះត្រូវមានកំរិត(ដូចដែលយើងនឹងពិភាក្សាខាងក្រោមទាក់ទងនឹង មាត្រា ២)។ ម្យ៉ាងទៀត ការគោរពបទបញ្ញត្តិនៅកថាខ័ណ្ឌ ២ នៃមាត្រា ២ ដែលថា រដ្ឋទាំងឡាយត្រូវធានាថា សិទ្ធិដែលទាក់ទងនឹងត្រូវបានប្រើដោយឥតមានការរើសអើងនោះ មិនត្រូវផ្តេកផ្តួលលើការគ្មានធនធាននោះទេ។ ពោលមួយបែបទៅវិញគឺថា បើសិនជាធនធានមានសំរាប់ឱ្យមនុស្សប្រើសិទ្ធិរបស់គេបានក្នុងកំរិតណាមួយនោះ សិទ្ធិ

នេះត្រូវស្ថិតក្នុងកាលៈទេសៈមួយដែលគ្មានការរើសអើង។ ដូចគ្នាដែរ មាត្រា ៣ ដែលចែងអំពីវិធានការវិជ្ជមានទាំងឡាយ ដើម្បីធានារ៉ាប់រងសិទ្ធិបុរស និងស្ត្រី ក៏ផ្តោតផ្តេកផ្តួលទៅលើការមានធនធានដែរ។

មុននឹងសិក្សាធាតុពិតនៃកាតព្វកិច្ចត្រូវធ្វើរបាយការណ៍នោះ យើងគប្បីរំលឹកថា អង្គការដែលត្រួតពិនិត្យការគោរពកាតព្វកិច្ចដែលរដ្ឋទាំងឡាយត្រូវប្រព្រឹត្តស្របទៅតាមពាក្យសំដីនៃកតិកាសញ្ញា គឺ គណៈកម្មាធិការនៃសិទ្ធិ សេដ្ឋកិច្ច សង្គមនិងវប្បធម៌ (តទៅហៅថា "គណៈកម្មាធិការ")។ គណៈកម្មាធិការនេះ ធ្វើការក្រោមការគាំពារនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច របស់អង្គការសហប្រជាជាតិ(អ.ស.ប) ដែលជាអង្គការដែលគេប្រគល់អំណាចឱ្យទទួលខុសត្រូវជាផ្លូវការតាមកតិកាសញ្ញា។ មុនពេលដែលគណៈកម្មាធិការចាប់ផ្តើមការងាររបស់ខ្លួននាឆ្នាំ ១៩៨៧ ក្រុមប្រឹក្សាត្រូវបានជួយក្នុងការងាររបស់ខ្លួនដោយក្រុមការងាររួមប្រជុំអ្នកជំនាញការខាងរដ្ឋាភិបាលទាំងឡាយ(តទៅហៅថា ក្រុមការងាររួមប្រជុំ)។

កាតព្វកិច្ចសំខាន់របស់បណ្តារដ្ឋជាភាគីនៃកតិកាសញ្ញា គឺត្រូវអនុវត្តបទបញ្ញត្តិរបស់កតិកាសញ្ញានៅក្នុងលំដាប់ជាតិ។ កាតព្វកិច្ចធ្វើរបាយការណ៍ជូនទៅអង្គការអន្តរជាតិមួយ - កម្មវត្ថុនៃសៀវភៅនេះ - ជាសំខាន់គឺជាមធ្យោបាយមួយសំរាប់លើកទឹកចិត្តការគោរពកាតព្វកិច្ចនេះ។ នៅកថាខ័ណ្ឌ ១ នៃមាត្រា ១៦ កាតព្វកិច្ចនៃការដាក់ជូនរបាយការណ៍ត្រូវបានចែងក្នុងពាក្យសំដីដូច្នេះ :

***អត្ថបទនៃកថាខ័ណ្ឌ ១ មាត្រា (១៦)***

> បណ្តារដ្ឋជាភាគីនៃកតិកាសញ្ញានេះ ដោយអនុលោមទៅតាមបទបញ្ញត្តិនៃផ្នែកនេះរបស់កតិកាសញ្ញាសន្យាថា នឹងជូនរបាយការណ៍អំពីវិធានការ ដែលគេទាំងឡាយនឹងបានអនុម័តយក និង អំពីវឌ្ឍនភាពបានទទួលក្នុងទិសដៅរ៉ាប់រង........សិទ្ធិទទួលស្គាល់ក្នុងកតិកាសញ្ញា។

ធាតុពិតនៃរបាយការណ៍ដែលនឹងត្រូវដាក់ជូន ត្រូវបានបញ្ជាក់លំអិតនៅកថាខ័ណ្ឌ ២ នៃមាត្រា ១៧ ដែលចែងថា "របាយការណ៍អាចគូសបញ្ជាក់ពីកត្តា និងការលំបាក ដែលប៉ះពាល់ដល់កំរិតនៃការបំពេញកាតព្វកិច្ចចែងក្នុងកតិកាសញ្ញានេះ"។ បទបញ្ញត្តិទាំងពីរនេះ បញ្ចេញឱ្យឃើញយ៉ាងច្បាស់ថា របាយការណ៍របស់រដ្ឋជាភាគីត្រូវនិយាយអំពីវឌ្ឍនភាពដែលបានសំរេច ទាំងករណីដែលវឌ្ឍនភាពដែលមានមិនគ្រប់គ្រាន់។ គណៈកម្មាធិការបានចង្អុលបង្ហាញបញ្ហានេះយ៉ាងច្បាស់ជាច្រើនលើកច្រើនសា ពិសេស កាលបើបណ្តារដ្ឋគិតតែធ្វើរបាយការណ៍អំពីអ្វីដែលវិជ្ជមាននៅក្នុងប្រទេស។ របាយការណ៍បែបនេះ មិនឆ្លើយទៅនឹងល័ក្ខខ័ណ្ឌចែងក្នុងកតិកាសញ្ញាទេ។

នៅឆ្នាំ ១៩៧៦ ក្រោយពីការចូលជាធរមាននៃកតិកាសញ្ញាមក ក្រុមប្រឹក្សាខាងសេដ្ឋកិច្ច និងសង្គមកិច្ចបានបង្កើតរបបធ្វើរបាយការណ៍វិលជុំជាបីដំណាក់ តាមរបបនោះបណ្តារដ្ឋជាភាគីត្រូវតែ ធ្វើរបាយការណ៍ដើមដំបូងរាល់រយៈពេល៣ឆ្នាំម្តងស្តីអំពីក្រុមសិទ្ធិ (មាត្រា ៦ ទៅ ៩, មាត្រា១០ ទៅ ១២ និង មាត្រា ១៣ ទៅ ១៥)។ ដូច្នេះ ការវិលមួយជុំនៃការដាក់ជូនរបាយការណ៍ដើមដំបូងគេ មានថេរវេលា៩ឆ្នាំ។ មួយជុំពេលវេលាសំរាប់

របាយការណ៍ក្រោយៗ មានថេរវេលាត្រឹមតែ ៦ ឆ្នាំ ប៉ុណ្ណោះ បានសេចក្ដីថា រដ្ឋជាភាគីនីមួយៗត្រូវតែធ្វើរបាយការណ៍ពីរឆ្នាំម្ដងៗ។ គណៈកម្មាធិការបានប្រមាណថា កម្មវិធីនៃការដាក់ជូនរបាយការណ៍មុននេះ មានលក្ខណៈធ្ងន់ធ្ងរទៅលើបណ្ដារដ្ឋនានា ហើយឆ្លុះបញ្ចាំងនូវទស្សនៈដាក់ខ័ណ្ឌផ្ដាច់ពីគ្នានូវសិទ្ធិដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញាជ្រុលហួសហេតុពេក។

ហេតុដូច្នេះហើយ បានជាក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ក្នុងការសំរេចចិត្តរបស់ខ្លួនលេខ ១៩៨៨/៤ បានអនុម័តជុំពេលថ្មីមួយនៃការដាក់ជូនរបាយការណ៍ គឺថាឥឡូវនេះ បណ្ដារដ្ឋជាភាគីត្រូវបានសុំឱ្យដាក់ជូនរបាយការណ៍ដើមដំបូងមួយដោយបរិយាយអំពីកតិកាសញ្ញាទាំងមូលក្នុងថេរវេលាពីរឆ្នាំ រាប់ពីពេលដែលកតិកាសញ្ញាចូលជាធរមានក្នុងរដ្ឋសាមី។ តមក របាយការណ៍តែមួយនិងទូលំទូលាយត្រូវបានធ្វើឡើងប្រាំឆ្នាំម្ដងៗនៅថ្ងៃខែកំណត់។ ចាប់ពីឆ្នាំ១៩៨៨ មកទល់ឆ្នាំ១៩៩៤ គណៈកម្មាធិការបានគូសបញ្ជាក់ថា ដើម្បីសំរួលការឆ្លងឱ្យស្រួលទៅរកប្រព័ន្ធថ្មី គណៈកម្មាធិការនៅបន្ដពិចារណាលើរបាយការណ៍ដែលធ្វើតាមរបៀបចាស់ ដែលបរិយាយតែអំពីសិទ្ធិបីយ៉ាងដែលទទួលស្គាល់ក្នុងកតិកាសញ្ញា។ ក៏ប៉ុន្ដែ នៅថ្ងៃទី១ មេសា ឆ្នាំ១៩៩៥ គណៈកម្មាធិការបានបញ្ជាក់ថា មានតែរបាយការណ៍ទូលំទូលាយប៉ុណ្ណោះដែលត្រូវដាក់ជូនចាប់ពីពេលនេះទៅ។

ការរៀបចំទាំងនេះ មិនបដិសេធលទ្ធភាពរបស់គណៈកម្មាធិការដើម្បីស្នើសុំ ឱ្យរដ្ឋជូនពតិមានបន្ថែមដើម្បីបង្គ្រប់លើពតិមានដែលផ្ដល់ឱ្យក្នុងរបាយការណ៍មួយរបស់រដ្ឋសាមីទេ។

### (ខ) គោលការណ៍ណែនាំសំរាប់ការតាក់តែងរបាយការណ៍ក្នុងកិច្ចអនុវត្តកតិកាសញ្ញា

ការណែនាំទូទៅទាក់ទងនឹងទំរង់ព្រមទាំងខ្លឹមសារនៃរបាយការណ៍ ត្រូវបានតាក់តែងក្រោយពេលដែលកតិកាសញ្ញាចូលជាធរមាននាឆ្នាំ ១៩៧៦។ ក៏ប៉ុន្ដែ ឆ្លងតាមការពិសោធន៍របស់ខ្លួន និងបន្ទាប់ពីការពិភាក្សាយ៉ាងតឹងតែងមក គណៈកម្មាធិការអនុម័តយកគោលការណ៍ណែនាំថ្មី នៅសម័យប្រជុំលើកទី៥ របស់ខ្លួន។ នៅសម័យប្រជុំលើកទី ១៤ គណៈកម្មាធិការបានសំរេចធ្វើការសើរើបន្ដទៅទៀតនូវគោលការណ៍ណែនាំទាំងនេះ ដើម្បីធានាថា លទ្ធផលដែលលេចចេញពីកម្មវិធីទាំងឡាយដែលអនុម័តយកដោយសន្និសីទ ក្រុងប៉េកាំង ក្រុងកូប៉ិនហាកក្រុងគែរ និងសន្និសីទអន្ដរជាតិដែលទាក់ទងដទៃទៀតព្រមទាំងផលវិបាកនៃសេចក្ដីអធិប្បាយទូទៅ អនុម័តដោយគណៈកម្មាធិការចាប់តាំងពីឆ្នាំ១៩៩០ ត្រូវបានគេយកមកគិតឱ្យបានពេញទំហឹង។

សេចក្ដីណែនាំមានគោលដៅជួយបណ្ដារដ្ឋជាភាគីឱ្យតាក់តែងរបាយការណ៍របស់ខ្លួន។ ដោយអនុវត្តតាមគោលការណ៍ណែនាំទាំងនេះយ៉ាងប្រិតប្រៀន អស់អ្នកម្ចាស់របាយការណ៍នឹងបន្ថយនូវផលអាក្រក់ដែលបណ្ដាលមកពីការបំពេញហួស និងការលំអិតមិនគ្រប់គ្រាន់។ គោលការណ៍ណែនាំទាំងនេះ ផ្ដល់នូវក្របខ័ណ្ឌជាឯកសណ្ឋានមួយសំរាប់ឱ្យគណៈកម្មាធិការធ្វើការ និងបង្ហាញនូវភាពទៀតទាត់ស៊ីគ្នាពីរបាយការណ៍មួយទៅរបាយការណ៍មួយ។ ជាចុងក្រោយបង្អស់ គោលការណ៍ណែនាំនេះមានគោលដៅកាត់បន្ថយការត្រួតគ្នានៃពតិមាន ស្នើសុំដោយអង្គការផ្សេងៗបង្កើតឡើងដោយសន្ធិសញ្ញា។

គោលការណ៍ណែនាំរបស់គណៈកម្មាធិការ ឥតមានបែងចែករវាងការខុសគ្នារវាងរបាយការណ៍ដើមដំបូង និងរបាយការណ៍តាមខួបទេ។ ពត៌មានដដែល ត្រូវបានស្នើសុំ ទោះបីគ្មានអ្វីចាំបាច់ត្រូវនិយាយឡើងវិញក្នុងរបាយការណ៍ខួបនូវពត៌មានដែលបានពោលនៅក្នុងរបាយការណ៍មុន ហើយនៅពេលមានសុពលភាពទាំងស្រុងរួចហើយនោះក៏ដោយ។ នៅក្នុងស្ថានភាពបែបនេះ គេគ្រាន់តែនិយាយយោងទៅកថាខ័ណ្ឌដែលពាក់ព័ន្ធនៃរបាយការណ៍មុននោះក៏គ្រប់គ្រាន់ណាស់ទៅហើយ។

គោលការណ៍ណែនាំត្រូវចែកជាពីរផ្នែក។ នៅក្នុងផ្នែកទីមួយដែលនិយាយពីទិដ្ឋភាពទូទៅត្រូវមាននិយាយពីទិដ្ឋភាពសង្ខេបរបស់ប្រទេស ដែលទាក់ទងនឹងពត៌មានអំពីដែនដី និងប្រជារាស្ត្រ (ប្រជាជន ប្រជាពលរដ្ឋ) អំពីរចនាសម្ព័ន្ធនយោបាយទូទៅ លក្ខណៈពិសេសខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ហើយនិងក្របខ័ណ្ឌគតិយុត្តិទូទៅនៃការការពារសិទ្ធិមនុស្ស។ បច្ចុប្បន្ននេះផ្នែកនៃគោលការណ៍ណែនាំនេះ គេឃើញមានជាទូទៅសំរាប់គោលការណ៍ណែនាំទាំងឡាយដែលតាក់តែងសំរាប់អង្គការទាំងអស់ ដែលបានបង្កើតឡើងទៅតាមឧបករណ៍អន្តរជាតិទាក់ទងទៅនឹងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ហើយត្រូវផលិតឡើងវិញនៅក្នុងឯកសារស្នូលរបស់ប្រទេសដែលមានជាស្រេចសំរាប់ឱ្យអង្គភាពដែលបង្កើតឡើងក្រោមសន្ធិសញ្ញានានា។ (ចំពោះអត្ថបទគោលការណ៍ណែនាំពួតផ្គុំសំរាប់ផ្នែកដំបូងនៃរបាយការណ៍រដ្ឋជាភាគី សូមអានក្នុងឧបសម្ព័ន្ធនៃផ្នែកទីមួយនៃសៀវភៅនេះ។ ផ្នែកទីមួយនៃគោលការណ៍នេះមានដូចតទៅនេះ :

**អត្ថបទនៃផ្នែកទីមួយនៃគោលការណ៍ណែនាំសំរាប់ធ្វើរបាយការណ៍ទាក់ទងនឹងទំរង់ និងខ្លឹមសារនៃរបាយការណ៍ ដែលបណ្តារដ្ឋជាភាគីត្រូវដាក់ជូន ដោយអនុលោមទៅតាមមាត្រា ១៦ និងមាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិ ទាក់ ទងទៅនឹង សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។**

**<u>ផ្នែកទូទៅនៃរបាយការណ៍</u>**

១. ទិដ្ឋភាពសង្ខេបនៃប្រទេស

(ក) *ទឹកដី និង ប្រជារាស្ត្រ*

ផ្នែកនេះត្រូវមានពត៌មានអំពីលក្ខណៈពិសេសសំខាន់ខាងភូមិសាស្ត្រ ខាងជនជាតិ ខាងភាសា ខាងប្រជាសាស្ត្រ និងខាងសាសនារបស់ប្រទេស និង ប្រជារាស្ត្ររបស់ប្រទេស។

(ខ) រចនាសម្ព័ន្ធទូទៅខាងនយោបាយ

ផ្នែកនេះអាចពិពណ៌នាដោយត្រួសៗ អំពីប្រវត្តិ និងក្របខ័ណ្ឌនយោបាយ អំពីប្រភេទនៃ រដ្ឋាភិបាល និងការចាត់ចែងអំណាចនីតិប្រតិបត្តិ និងនីតិបញ្ញត្តិ និងតុលាការ។

(គ) *លក្ខណៈសេដ្ឋកិច្ច សង្គម និងវប្បធម៌*

ផ្នែកនេះត្រូវផ្តល់ពត៌មាន អំពីសន្ទស្សន៍ទាំងឡាយដូចជា អំពីផលិតផលជាតិសរុប ចំណូលរបស់ប្រជារាស្ត្រម្នាក់ៗ ការចែករំលែកចំណូលប្រៀបធៀប (ឧទាហរណ៍ ផលធៀបចំណូលពីការងារ/

ចំណូលពីដើមទុននៅក្នុងផ្នែកសាធារណៈ និងឯកជននៃសេដ្ឋកិច្ច) អត្រានៃអតិផរណា ជញ្ជីងពាណិជ្ជកម្ម និងជញ្ជីងទូទាត់បំណុលក្រៅប្រទេស អត្រានៃភាពឥតការធ្វើ និងអត្រាអក្ខរកម្ម ។

ឃ. ក្របខ័ណ្ឌគតិយុត្តិទូទៅដែលបាននៅក្នុងក្របខ័ណ្ឌនោះសិទ្ធិមនុស្សត្រូវ បានការពារ ផ្នែកនេះត្រូវមានពតិមានឆ្លើយទៅនឹងចំណុចដូចតទៅ :

i) តើអាជ្ញាធរខាងតុលាការ ខាងរដ្ឋបាល ឬបណ្តាអាជ្ញាធរដទៃទៀតណា ដែលមានសមត្ថភាពទាក់ទងរឿងសិទ្ធិមនុស្ស?

ii) តើដំណោះស្រាយណាខ្លះ ដែលចំហឱ្យប្រជាជនពឹង កាលបើគេយល់ថា សិទ្ធិរបស់គេត្រូវបានរំលោភ ហើយជនរងគ្រោះអាចមានប្រព័ន្ធជួសជុលការខូចខាតណាខ្លះ?

iii) សិទ្ធិនៅក្នុងអនុសញ្ញាផ្សេងៗ ត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ ឬដោយនីតិកម្មផ្សេងទៀតឬទេ? បើមាន តើមានបទបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ ឬក្នុងនីតិកម្មនោះ ទុកសំរាប់កាត់បន្ថយសិទ្ធិទាំងនោះឬទេ? ហើយបើមាន តើនៅក្នុងកាលៈទេសៈណា?

iv) បទបញ្ញត្តិនៃឧបករណ៍ផ្សេងៗទាក់ទងទៅនឹងសិទ្ធិមនុស្ស មកប្រើនៅមុខសាលាក្តី នៅមុខសាលាដទៃទៀត ឬនៅមុខអាជ្ញាធររដ្ឋបាល ហើយអាចត្រូវបានអនុវត្តផ្ទាល់ដោយអាជ្ញាធរ ឬក៏ត្រូវប្រែក្លាយទៅជាច្បាប់ជាតិ ឬបទបញ្ជារដ្ឋបាលសិន ដើម្បីអាចឱ្យអាជ្ញាធរដែលពាក់ព័ន្ធអាចអនុវត្តបាន? ។

## ២. <u>ការផ្សព្វផ្សាយដំណឹង និងការផ្សាយកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ហើយនិងរបាយការណ៍ ដែលប្រទេសនានាដាក់ជូនទៅគណៈកម្មការ</u>

(ក) តើតាមវិធីណា ហើយក្នុងកំរិតណា ដែលអត្ថបទរបស់កតិកាសញ្ញាត្រូវបានផ្សព្វផ្សាយ? តើអត្ថបទត្រូវបានបកប្រែជាភាសាក្នុងប្រទេសដែរឬទេ? ហើយអត្ថបទបកប្រែនោះ ត្រូវបានចែកចាយឬទេ? ។ តើការជួយពីអង្គការសហប្រជាជាតិចាំបាច់ឬទេ? (បើសិនជាចាំបាច់ សូមមេត្តាបញ្ជាក់) ។

(ខ) តើរបាយការណ៍ ត្រូវបានតាក់តែងដោយក្រសួងណាមួយនៃរដ្ឋាភិបាល? ។ តើមានការស្វែងរកឬទទួលការផ្តល់គំនិតពីប្រភពផ្សេងៗ ក្រៅពីរដ្ឋាភិបាលដែរឬទេ? ។

(គ) តើគេអាចរករបាយការណ៍នៅក្នុងស្រុកបានដោយងាយឬទេ? តើខ្លឹមសារនៃរបាយការណ៍បានជាកម្មវត្ថុនៃការជជែកពិភាក្សាជាសាធារណៈដែរឬទេ?

## ៣. ស្ថានភាពគតិយុត្តិ និងការអនុវត្តន៍នូវកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

(ក្នុងករណីដែលរបាយការណ៍នេះ ឆ្លើយទៅនឹងសំណួរទាំងឡាយនៃផ្នែក ១ វគ្គ ឃ ខាងលើ នេះ)។

(ក) តើសិទ្ធិស្វ័យសំរេចត្រូវបានអនុវត្តតាមបែបណាដែរ ? ។

(ខ) តើកតិកាសញ្ញាមានស្ថានភាពយ៉ាងណាដែរនៅចំពោះមុខច្បាប់ផ្ទៃក្នុង ? តើបទបញ្ញត្តិ ដែលទាក់ទងនឹងសិទ្ធិដែលចែងក្នុងកតិកាសញ្ញានេះត្រូវបានអនុវត្តដោយត្រង់ៗដោយតុលាការ និង អាជ្ញាធរដទៃទៀតដែរឬទេ? សូមពិពណ៌នាឱ្យល្អិតល្អន់ចំពោះការអនុវត្តនេះ?

(គ) តើសិទ្ធិណាខ្លះ ចែងក្នុងកតិកាសញ្ញាដែលត្រូវបានទទួលស្គាល់ក្នុងរដ្ឋធម្មនុញ្ញ និងក្នុងច្បាប់ឯទៀតៗ។ សូមភ្ជាប់មកនូវអត្ថបទនៃបទបញ្ញត្តិ ដែលឆ្លើយទៅនឹងរឿងនេះហើយផ្តល់សេចក្តីបញ្ជាក់លើការអនុវត្តន៍បទបញ្ញត្តិទាំងនេះដោយសាលាក្តី និងអាជ្ញាធរដទៃ។

(ឃ) ក្នុងបណ្តាសិទ្ធិទាំងនោះ សិទ្ធិណាខ្លះត្រូវបានសរសេរដាក់ចូលទៅក្នុងបណ្តាបទបញ្ញត្តិនៃច្បាប់ជាតិ ទាក់ទងទៅនឹងការមិនរើសអើង? ។ សូមភ្ជាប់នូវអត្ថបទនៃបញ្ញត្តិទាំងនោះ។

(ង) តើការឱ្យសច្ចាប័នលើកតិកាសញ្ញាបាននាំឱ្យមានការកែប្រែណាមួយក្នុងច្បាប់ផ្ទៃក្នុងដែលពាក់ព័ន្ធដែរឬទេ?

(ច) តើក្នុងក៏រិតណា និងរបៀបណា ដែលបណ្តាសិទ្ធិចែងក្នុងកតិកាសញ្ញាឥតត្រូវបានរ៉ាប់រងដល់អ្នកដែលមិនមានសញ្ជាតិរបស់រដ្ឋជាភាគី? តើអ្វីទៅដែលជាហេតុផលនៃការបែងចែករវាងពលរដ្ឋ និង អ្នកគ្មានសញ្ជាតិរបស់រដ្ឋនោះ?

## ៤. តួនាទីនៃសហប្រតិបត្តិការអន្តរជាតិក្នុងការអនុវត្តន៍កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

បើសិនជាប្រទេសរបស់អ្នកចូលរួមក្នុងសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍ តើប្រទេសរបស់អ្នកបានប្រឹងធ្វើអ្វីខ្លះជាអាទិភាព ដើម្បីធ្វើឱ្យសហប្រតិបត្តិការនោះដើរឆ្ពោះទៅរកការជំរុញលើកស្ទួយ ការប្រើសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌? ។

ក្នុងផ្នែកទីពីរនៃគោលការណ៍ណែនាំ គេលើកយកមាត្រាមួយម្តងៗ មកសិក្សាអំពីសិទ្ធិជាមូលដ្ឋានដែលបានទទួលស្គាល់នៅក្នុងមាត្រាទាំងឡាយពី ៦ទៅ ១៥ នៃកតិកាសញ្ញា។ (សំរាប់អត្ថបទនៃគោលការណ៍ណែនាំ សូមអានមាត្រាទាំងឡាយដែលពាក់ព័ន្ធនៅផ្នែក(គ)ខាងក្រោម ដែលមានចំណងជើងថា "ការរាយការណ៍អំពីបទបញ្ញត្តិជាមូលដ្ឋាន")។ បញ្ហា ៤ ដែលគណៈកម្មាធិការបានភ្ជាប់សារសំខាន់ទៅនឹងការរាយការណ៍អំពីមាត្រាទាំងនេះ។ បញ្ហាទីមួយគឺថា បញ្ហាដែលគេត្រូវបរិយាយឱ្យបានគ្រប់គ្រាន់ ក្រោមការរៀបចំដើម្បីធ្វើរបាយ

ការណ៍ទៅទីភ្នាក់ងារ អ.ស.ប ឬអង្គការដែលបង្កើតឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្ស មិនចាំបាច់បរិយាយម្តងទៀតដោយវែងអន្លាយទេ នៅក្នុងរបាយការណ៍ដែលតម្រូវដោយកតិកាសញ្ញានេះទេ។ ការយោងទៅរករបាយការណ៍ពាក់ព័ន្ធ និង(បើសិនជាសមស្រប) ការធ្វើអត្ថាធិប្បាយលើលទ្ធផលនៃការពិនិត្យរបាយការណ៍នោះអាចជាការគ្រប់គ្រាន់ណាស់ទៅហើយ។ ការធ្វើដូច្នេះ គឺក្នុងគោលបំណងកាត់បន្ថយបន្ទុកត្រូវធ្វើរបាយការណ៍អំពីបញ្ហាដូចគ្នាទៅឱ្យអង្គការស្របតាមបទបញ្ញត្តិនៃមាត្រា១៧(៣) នៃកតិកាសញ្ញា។

**អត្ថបទមាត្រា ១៧(៣)**

៣. ក្នុងករណីបើពតិមានដែលទាក់ទិន ដែលបានផ្ញើជូនអង្គការសហប្រជាជាតិ ឬទីភ្នាក់ងារឯកទេសណាមួយកាលពីមុនមកក៏ដោយ រដ្ឋជាភាគីនៃកតិកាសញ្ញានេះ ពុំចាំបាច់ធ្វើសេចក្តីរាយការណ៍ ដដែលសារជាថ្មីឡើងវិញទៀតទេ ផ្ទុយទៅវិញ គឺគ្រាន់តែយោងពតិមានដែលផ្តល់រួចហើយឱ្យបានច្បាស់លាស់នោះ គឺជាការគ្រប់គ្រាន់ហើយ។

ដូចគ្នាដែរ ការព្រមព្រៀងតាមរបៀបថ្មីនេះ មិនមែនមានន័យថា រារាំងមិនឱ្យលើកយកបញ្ហាមួយដែលមាននៅក្នុងរបាយការណ៍មួយដែលបានដាក់ជូនទៅអង្គការសមស្របមួយទៀតរួចហើយ មកឱ្យគណៈកម្មាធិការពិនិត្យមើលនោះទេ។ ធាតុផ្សំនានាដូចជា ការកន្លងទៅនៃពេលវេលា ការបានពតិមានថ្មី ការមើលឃើញ ការប្រើប្រាស់វិធីខុសគ្នារវាងបទបញ្ញត្តិនៃកតិកាសញ្ញានេះ និងបទបញ្ញត្តិនៃឧបករណ៍មួយទៀត ឬយកចិត្តទុកដាក់ជាពិសេសពីសំណាក់គណៈកម្មាធិការ ទាំងអស់នេះអាចនាំឱ្យគណៈកម្មាធិការចង់ពិនិត្យមើលបញ្ហាទាំងនេះ។

បញ្ហាទី២ ដែលគណៈកម្មាធិការយល់ថាជាការសំខាន់ជាពិសេសនោះ គឺការចាំបាច់ត្រូវរាយការណ៍មិនត្រឹមតែកត្តាពាក់ព័ន្ធប៉ុណ្ណោះទេ តែត្រូវរាយការណ៍អំពីការពិបាកណាមួយដែលបានជួបប្រទះក្នុងការធ្វើឱ្យបានសំរេចនូវសិទ្ធិដែលទទួលស្គាល់ក្នុងកតិកាសញ្ញានេះ។ គោលការណ៍ណែនាំគូសបញ្ជាក់ថា រឿងនេះទាមទារឱ្យមានការពិពណ៌នាលំអិតមិនត្រឹមតែលើស្ថានភាពគតិយុត្តិ និងរដ្ឋបាលប៉ុណ្ណោះទេ តែលើស្ថានការណ៍ជាក់ស្តែងផងដែរ។ ព្រឹត្តិការណ៍ជាអវិជ្ជមានសេចក្តីប្រាថ្នាមិនបានសំរេច ឬការលំបាកដទៃទៀតត្រូវរាយការណ៍ផងដែរដែលទៅលើព្រឹត្តការណ៍ជាវិជ្ជមាន។ ជាការពិត គណៈកម្មាធិការហាក់ដូចជាចង់ឃើញរបាយការណ៍ណាដែលនិយាយត្រង់ៗ ហើយទទួលស្គាល់ការខ្វះខាតក្នុងការបំពេញកិច្ចការ ឬខ្វះខាតមិនបានសំរេចផល ជាងរបាយការណ៍ណាដែលបង្ហាញតែ"ដំណឹងល្អ"។

បញ្ហាទីបី គឺការផ្តល់ស្ថិតិដ៏សមស្រប កាលណាមាន។ បើមិនមានទេ ក៏ត្រូវប្រាប់គណៈកម្មាធិការឱ្យបានដឹងថាហេតុអ្វីបានជាគ្មាន។ គណៈកម្មាធិការបានកត់សំគាល់ថា ពតិមានបែបនោះត្រូវបង្ហាញនៅក្នុងបរិបទណាមួយ ដើម្បីផ្តល់ជាសញ្ញានៃការជឿនលឿន ព្រមទាំងគោលដៅដែលមិនទាន់បានទៅដល់។

បញ្ហាទីបួន ទាក់ទងនឹងការបង្ហាញឱ្យស្គាល់ពីគោលចំណាំសមស្រប ទាក់ទងនឹងសិទ្ធិណាមួយ។ គោលបំណងនៃគោលចំណាំនេះ ដែលត្រូវកំណត់ដោយរដ្ឋជាភាគីមួយទាក់ទងនឹងសិទ្ធិនានា ដូចជា សិទ្ធិមានការធ្វើ សិទ្ធិមានសុខភាព ទីលំនៅ ចំណីអាហារ និងការអប់រំជាដើម) គឺដើម្បីធ្វើជាមូលដ្ឋានសំរាប់ឱ្យប្រជាជននៃប្រទេសនោះ និងគណៈកម្មា-ធិការអាចវាយតម្លៃការជឿនលឿនដែលប្រទេសនីមួយៗបានសំរេច។

ដើម្បីជំរុញការយល់ដឹងកាន់តែប្រសើរឡើងនូវបទបញ្ញត្តិផ្សេងៗនៃកតិកាសញ្ញា គណៈកម្មាធិការបានបង្កើតវិធីពីរយ៉ាង ដែលមន្ត្រីធ្វើរបាយការណ៍ត្រូវដឹង។ វិធីទីមួយ គឺការអនុម័តសេចក្តីអធិប្បាយទូទៅ ទៅតាមពេលវេលា។ គោលបំណងនៃសេចក្តីអធិប្បាយនេះ ដែលអាចប្រៀបធៀបបានជាមួយគោលបំណងរបស់គណៈកម្មាធិការសិទ្ធិមនុស្សក្នុងទិដ្ឋភាពភាគច្រើន នឹងត្រូវពិភាក្សាទៅទៀតនៅខាងក្រោមនេះ។ វិធីទីពីរ គឺការពិភាក្សាទូទៅ ដែលគណៈកម្មាធិការទូទៅព្យាយាមធ្វើនៅសម័យប្រជុំនីមួយៗ ដែលនៅក្នុងការពិភាក្សានេះ គណៈកម្មាធិការផ្តោតលើសិទ្ធិណាមួយ ដូចជាសិទ្ធិទទួលបានចំណីអាហារ ឬសិទ្ធិមានទីលំនៅ ឬបញ្ហាជាក់លាក់ដទៃទៀត។ ការពិភាក្សាទាំងនេះ ត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍របស់គណៈកម្មាធិការ ហើយមានគោលដៅបំភ្លឺបញ្ហាខ្លះដែលកើតឡើង ដោយយោងទៅតាមសេចក្តីតំរូវនានាជាប់មកជាមួយបទបញ្ញត្តិជាក់លាក់នៃកតិកាសញ្ញា។ កិច្ចពិភាក្សាទាំងនេះ ផ្តល់ឱកាសឱ្យអ្នកជំនាញការផ្តល់គំនិតយ៉ាងទូលំទូលាយដល់កិច្ចការរបស់គណៈកម្មាធិការ ហើយជារឿយៗ ការពិភាក្សានេះ ជាចំណុចចាប់ផ្តើមសំរាប់ការព្រាងសេចក្តីអធិប្បាយទូទៅ។

## (ត) ការរាយការណ៍អំពីបទបញ្ញត្តិជាមូលដ្ឋាន

## មាត្រា ១

### អត្ថបទនៃមាត្រា ១

១. មនុស្សទាំងអស់មានសិទ្ធិធ្វើការប្តេជ្ញាចិត្តដោយខ្លួនឯង ។ អាស្រ័យទៅលើសិទ្ធិនេះ មនុស្សមានសេរីភាពពេញលេញក្នុងការប្រកាន់យកគោលជំហរនយោបាយ ព្រមទាំងការអភិវឌ្ឍន៍ផ្នែកសេដ្ឋកិច្ច, សង្គម និងវប្បធម៌ ។

២. ដើម្បីជាផលប្រយោជន៍របស់ខ្លួន មនុស្សទាំងអស់មានសេរីភាពពេញទីក្នុងការចាត់ចែងលើសម្បត្តិ និងធនធានធម្មជាតិរបស់ខ្លួនដោយមិនទាន់គិតដល់កាតព្វកិច្ចនានា ដែលកើតមកអំពីសហប្រតិបត្តិការសេដ្ឋកិច្ចអន្តរជាតិ ដែលផ្អែកលើគោលការណ៍ផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមក និងច្បាប់អន្តរជាតិ។ គ្មានករណីណាមួយ ដែលអនុញ្ញាតឱ្យមានការដកហូតនូវមធ្យោបាយរកស៊ីចិញ្ចឹមជីវិតផ្ទាល់ខ្លួនរបស់មនុស្សណាម្នាក់បានឡើយ ។

៣. រដ្ឋជាភាគីទាំងឡាយនៃកតិកាសញ្ញានេះ ដោយរាប់ទាំងរដ្ឋនានា ដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រងទៅលើដែនដីទាំងឡាយណាដែលមិនអាចគ្រប់គ្រងខ្លួនដោយខ្លួនឯង (គ្មានអធិបតេយ្យភាព) ហើយនិងទឹកដីដែលគេជួយរក្សាសន្តិសុខ ត្រូវខំលើកស្ទួយនូវសមិទ្ធិកម្មនៃសិទ្ធិស្វ័យសំរេច ហើយត្រូវគោរពសិទ្ធិនោះឱ្យបានស្របតាមបញ្ញត្តិដែលមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។

### សេចក្តីអធិប្បាយ

មាត្រានេះ ដូចគ្នាបេះបិទនិងមាត្រាមួយនៃកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ហេតុនេះហើយ បានជាកាលណារដ្ឋណាមួយធ្វើរបាយការណ៍លំអិតលើមាត្រានេះជូនទៅគណៈកម្មា-ធិការសិទ្ធិមនុស្ស គេត្រូវតែយោងទៅមាត្រានេះ។ បណ្តារដ្ឋជាភាគីដែលមិនបានឱ្យសច្ចាប័នលើកតិកាសញ្ញា

អន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចាំបាច់ត្រូវធ្វើរបាយការណ៍លើសិទ្ធិស្វ័យសំរេច ហើយចំពោះរឿងនេះ រដ្ឋទាំងនេះអាចពិចារណាដល់បញ្ហាដែលបង្ហាញឱ្យឃើញក្នុងសេចក្តីអធិប្បាយទូទៅលេខ១២(២១) ស្តីពីមាត្រា ១ នៃកតិកាសញ្ញាអន្តរជាតិទាក់ទងនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (សូមអាចជំពូករបស់សាស្រ្តាចារ្យប៉ូកា ក្នុងសៀវភៅនេះ។

ក៏ប៉ុន្តែ ត្រូវតែចងចាំថា សិទ្ធិស្វ័យសំរេចដូចមានចែងក្នុងមាត្រា ១ ក្តោបត្រឹមតែសិទ្ធិស្វ័យសំរេចផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែសិទ្ធិដើម្បីស្វែងរក"ដោយសេរីនូវការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌"ផងដែរ។ ដូចគ្នា ដែរ មាត្រា ១(២) ហាមឃាត់យ៉ាងចំៗការដកហូតមធ្យោបាយដើម្បីទ្រទ្រង់ជីវិតមនុស្ស។ បញ្ញត្តិទាំងនេះអាចមានសារសំខាន់ពិសេសនៅក្នុងបរិបទនៃកតិកាសញ្ញានេះ ហើយក្នុងករណីដែលបទបញ្ញត្តិទាំងនេះមិនបានបរិយាយបានគ្រប់គ្រាន់នៅពេលរាយការណ៍ទាក់ទងនឹងកតិកាសញ្ញាផ្សេងទៀតទេនោះ បទបញ្ញត្តិទាំងនេះត្រូវបញ្ជាក់ឱ្យបានច្បាស់ក្នុងរបាយការណ៍ក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

## មាត្រា២

**អត្ថបទមាត្រា ២:**

១. រដ្ឋជាភាគីនិមួយៗនៃកតិកាសញ្ញានេះ ទទួលយល់ព្រមនិងចាត់វិធានការទាំងអស់ដែលមានដោយខ្លួនឯងផ្ទាល់ផង និងតាមរយ:ជំនួយអន្តរជាតិនិងសហប្រតិបត្តិការ ជាពិសេសផ្នែកសេដ្ឋកិច្ច និងបច្ចេកទេស ដោយការប្រើប្រាស់ជាអតិបរមានូវធនធានរបស់ខ្លួនដែលមាន ដើម្បីសំរេចអោយបានពេញលេញជាលំដាប់នូវសិទ្ធិទាំងឡាយដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះតាមមធ្យោបាយសមស្របផ្សេងៗ ដោយមានរួមបញ្ចូលជាពិសេសនូវការអនុម័តនូវវិធានការខាងផ្នែកច្បាប់ ។

២. រដ្ឋនានាជាភាគីនៃកតិកាសញ្ញានេះត្រូវធានាថា សិទ្ធិទាំងឡាយដែលបានកំណត់ក្នុងកតិកាសញ្ញានេះត្រូវតែប្រតិបត្តិតាមដោយគ្មានការរើសអើងអ្វីទាំងអស់ តាំងពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ភាសា មតិនយោបាយ ឬ មតិផ្សេងៗទៀត ដើមកំណើតនៃជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬឋានៈឡើយ។

៣. ប្រទេសកំពុងអភិវឌ្ឍន៍ទាំងឡាយ ដែលយកចិត្តទុកដាក់លើវិស័យសិទ្ធិមនុស្ស និងសេដ្ឋកិច្ចជាតិ ផងនោះ អាចសំរេចថា តើគេត្រូវធានាសិទ្ធិផ្នែកសេដ្ឋកិច្ចដែលទទួលស្គាល់ដោយកតិកាសញ្ញានេះដល់កំរិតណាជូនចំពោះអាណិកជន ។

**អត្ថបទនៃសេចក្តីអធិប្បាយ លេខ ៣ (១៩៩០)**

**លក្ខណៈធម្មជាតិនៃកាតព្វកិច្ចរបស់រដ្ឋជាភាគី (មាត្រា ២, វាក្យខ័ណ្ឌ ១)**

១. មាត្រា ២ មានសារសំខាន់បំផុតដោយបានផ្តល់ការយល់យ៉ាងពេញលេញពីកតិកាសញ្ញា ហើយត្រូវយល់ថាមាត្រានេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនិងបញ្ញត្តិផ្សេងៗទៀតនៃកតិកាសញ្ញានេះ។ មាត្រានេះ ពណ៌នា

អំពីលក្ខណៈនៃកាតព្វកិច្ចខាងផ្លូវច្បាប់ ដែលត្រូវអនុវត្តន៍ដោយរដ្ឋជាភាគីនៃកតិកាសញ្ញានេះ។ កាតព្វកិច្ចទាំងនេះរាប់បញ្ចូលទាំងអ្វីដែលអាចកំណត់ហៅថា (តាមការងាររបស់គណៈកម្មការច្បាប់អន្តរជាតិ) ជាកាតព្វកិច្ចខាងអាកប្បកិរិយា និងកាតព្វកិច្ចខាងការធ្វើឱ្យបានលទ្ធផល។ ពេលខ្លះដោយសារមានការសង្កត់ខ្លាំងទៅលើភាពខុសគ្នារវាងរូបមន្តដែលបានប្រើនៅក្នុងបទបញ្ញត្តិនេះ ហើយដែលរូបមន្តនេះមានលក្ខណៈដូចគ្នានិងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ តែជានិច្ចកាលគេមិនដែលទទួលស្គាល់ថាវាមានភាពស្រដៀងគ្នាជាធំដុំនោះទេ។ ជាពិសេស ថ្វីបើកតិកាសញ្ញាចែងពីការសំរេចបានជាលំដាប់ៗ និងទទួលស្គាល់ឧបសគ្គដោយសារកំរិតនៃធនធាន មាត្រានេះក៏បង្គាប់ឱ្យមានកាតព្វកិច្ចផ្សេងៗទៀត ដែលមានអានុភាពជាបន្ទាន់។ ក្នុងបណ្តាកាតព្វកិច្ចទាំងនេះ កាតព្វកិច្ចពីរមានសារសំខាន់ខ្លាំង ដើម្បីធ្វើឱ្យយល់ដឹងអំពីលក្ខណៈនៃកាតព្វកិច្ចរបស់រដ្ឋជាភាគី។ កាតព្វកិច្ចមួយក្នុងចំណោមកាតព្វកិច្ចទាំងពីរ គឺ " ការសន្យាថានឹងធានា " ថាសិទ្ធិដែលជាប់ទាក់ទងនឹងត្រូវបានអនុវត្តដោយគ្មានការរើសអើង..."

២. កាតព្វកិច្ចមួយទៀតគឺការប្តេជ្ញាចិត្ត ក្នុងមាត្រា ២(១) ថា "នឹងចាត់វិធានការផ្សេងៗ" ដែលជាកាតព្វកិច្ចគេមិនអាចកែប្រែ ឬរិតត្បិតដោយផ្អែកលើកត្តាកំណត់ដទៃទៀតឡើយ។ អត្ថន័យទាំងមូលនៃឃ្លានេះ អាចវិនិច្ឆ័យបានដោយធ្វើការកត់សំគាល់ទៅលើការប្រើភាសាខុសៗគ្នា។ ភាសាអង់គ្លេស ពាក្យប្តេជ្ញាចិត្តនេះមានន័យថា "ចាត់វិធានការ" ក្នុងភាសាបារាំងមានន័យថា "ចាត់ការ" ហើយភាសា អេស្ប៉ាញ មាននយ័ថា "អនុម័តវិធានការ"។ ដូច្នេះ ថ្វីបើការសំរេចបានទាំងស្រុងនូវសិទ្ធិដែលពាក់ព័ន្ធអាចទទួលបានជាលំដាប់ៗ ក៏ដោយក៏វិធានការឆ្ពោះទៅរកគោលដៅនោះ ត្រូវតែអនុវត្តក្នុងរយៈពេលខ្លីសមស្របបន្ទាប់ពីការចូលជាធរមាននៃកតិកាសញ្ញានេះចំពោះរដ្ឋដែលពាក់ព័ន្ធ។ វិធានការទាំងនេះ ត្រូវមានលក្ខណៈជាក់ស្តែងមានបំណង និងផ្តោតទៅរកទីដៅឱ្យបានច្បាស់លាស់បំផុតដែលអាចធ្វើទៅបាន ដើម្បីបំពេញតាមកាតព្វកិច្ចដែលបានទទួលស្គាល់ក្នុងកតិកាសញ្ញានេះ។

៣. មធ្យោបាយដែលត្រូវប្រើដើម្បីបំពេញកាតព្វកិច្ចក្នុងការចាត់វិធានការ ដូចមានចែងនៅក្នុងមាត្រា ២(១) គឺ "រាល់មធ្យោបាយសមស្របទាំងអស់ ជាពិសេសរាប់ទាំងការអនុម័តវិធានការខាងនីតិបញ្ញត្តិទាំងឡាយ ផង"។ គណៈកម្មាធិការទទួលស្គាល់ថា ក្នុងករណីខ្លះការអនុម័តច្បាប់ជាកត្តាគួរតែមានតែករណីខ្លះទៀត ការអនុមត្ត័ច្បាប់កត្តាចាំបាច់ខានមិនបាន។ ឧទាហរណ៍ អាចជាការពិបាកក្នុងការប្រយុទ្ធប្រឆាំងនឹងអំពើរើសអើងឱ្យមានប្រសិទ្ធិភាពប្រសិនបើគ្មានមូលដ្ឋានច្បាប់ល្អសំរាប់អនុវត្តវិធានការចាំបាច់នេះទេ។ ក្នុងវិស័យដូចជាសុខាភិបាល កិច្ចគាំពារកុមារនិងមាតា ការអប់រំ ព្រមទាំងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងមាត្រា ៦ ដល់ ៩ ការអនុម័តច្បាប់អាចជាកត្តាចាំបាច់ខានមិនបានសំរាប់គោលបំណងជាច្រើន។

៤. គណៈកម្មាធិការកត់សំគាល់ថា រដ្ឋជាភាគីបានយកចិត្តទុកដាក់ ជាទូទៅក្នុងការបរិយាយលំអិតយ៉ាងហោច ណាស់លើវិធានការខាងនីតិបញ្ញាតិមួយចំនួន ដែលរដ្ឋជាភាគីបានអនុវត្តទាក់ទងនិងបញ្ហានេះ។ ប៉ុន្តែគណៈកម្មាធិការគូសបញ្ជាក់ថា ការអនុម័តវិធានការណ៍ខាងនីតិបញ្ញាតិ ដូចដែលកតិកាសញ្ញាបានប្រមាណទុកមិនមែនមានន័យថា រដ្ឋជាភាគីអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានអស់ទេនោះ។ ផ្ទុយទៅវិញ ឃ្លាដែលចែងថា "តាមគ្រប់មធ្យោបាយសមស្របទាំងអស់" ត្រូវតែផ្តល់តាមអត្ថន័យពេញលេញនិងធម្មជាតិរបស់វា។ ថ្វីបើរដ្ឋជាភាគីនិមួយៗ ត្រូវតែសំរេចដោយខ្លួនឯងនូវមធ្យោបាយណាមួយដែលសមស្របបំផុតទៅតាមកាលៈទេសៈចំពោះសិទ្ធិនិមួយៗក៏ដោយ ក៏"ភាពសមស្រប"នៃមធ្យោបាយដែលបានជ្រើសរើសមិនមែនសុទ្ធតែជាក់ស្តែងថាសមស្របនោះទេ។ ដូច្នេះ គេចង់បានរបាយការណ៏របស់រដ្ឋជាភាគីទាំងឡាយគប្បីចង្អុលបង្ហាញមិនត្រឹមតែវិធានការដែលបានប្រកាន់យកនោះទេ តែត្រូវពន្យល់ថាហេតុអ្វីបានជាចាត់ទុកវិធានការនោះ"សមស្រប"ទៅតាមកាលៈទេសៈ។ តែទោះយ៉ាងណាដោយ សេចក្តីសំរេចចុងក្រោយថា តើរាល់វិធានការ សមស្របទាំងឡាយដែលបានប្រកាន់យកដោយរដ្ឋជាភាគី វាជាភារៈរបស់គណៈកម្មាធិការជាអ្នកសំរេច ។

៥. ក្នុងចំណោមវិធានការដែលអាចចាត់ទុកថាសមប្រកប ក្រៅពីវិធានការនីតិកម្ម គឺការផ្តល់ការដោះស្រាយតាមផ្លូវតុលាការចំពោះសិទ្ធិណាដែលអាចចាត់ទុកថា អាចទាមទារតាមផ្លូវតុលាការបាន យោងតាមប្រព័ន្ធច្បាប់របស់ប្រទេសនោះ។ ឧទាហរណ៏ គណៈកម្មាធិការកត់សំគាល់ថា ការទទួលបានសិទ្ធិដែលទទួលស្គាល់ដោយគ្មានការរើសអើងត្រូវបានគេលើកកំពស់យ៉ាងសមស្រប មួយផ្នែកតាមរយៈការដំណោះស្រាយតាមផ្លូវតុលាការ ឬ ដំណោះស្រាយផ្សេងៗទៀតដែលមានប្រសិទ្ធិភាព។ តាមពិត រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ជាប់កាតព្វកិច្ចរួចជាស្រេច (តាមមាត្រា ២ (១) និង(៣) មាត្រា ៣ និង មាត្រា ២៦ នៃកតិកាសញ្ញានេះ) ក្នុងការធានាថា បុគ្គលណាដែលសិទ្ធិ ឬ សេរីភាពរបស់ខ្លួន(រាប់បញ្ចូលទាំងសិទ្ធិទទួលបាននូវសមភាព និងគ្មានការរើសអើង) ដូចដែលបានទទួលស្គាល់ក្នុងកតិកាសញ្ញានោះត្រូវបានរំលោភ "ត្រូវតែមានដំណោះស្រាយដ៏មានប្រសិទ្ធិភាពមួយ"(មាត្រា២ (៣)(ក))។ លើសពីនេះ មានបទបញ្ញត្តិមួយចំនួនផ្សេងទៀតដែលចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធមិ ដូចជាមានមាត្រា ៣, មាត្រា ៧ (ក)(១), មាត្រា ៨, មាត្រា ១0 (៣), មាត្រា ១៣ (២)(ក), (៣) និង (៤) និងមាត្រា ១៥ (៣) ដែលបទបញ្ញាត្តិទាំងនេះមានលក្ខណៈគ្រប់គ្រាន់អាចយកមកអនុវត្តបានភ្លាមតែម្តង ដោយស្ថាប័នតុលាការ និងស្ថាប័នផ្សេងទៀតនៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសផ្សេងៗ។ ការយល់ណាមួយថា បទបញ្ញត្តិដែលបានចង្អុលបង្ហាញមកនេះមិនអាចយកទៅអនុវត្តដោយស្វ័យប្រវត្តិនោះ ការយល់របៀបនេះមិនត្រឹមត្រូវទេ ។

៦.	ក្នុងករណីដែលមានគោលនយោបាយជាក់លាក់ក្នុងទិសដៅដើម្បីធ្វើឱ្យបានសំរេចបាននូវសិទ្ធិទាំងឡាយដូច ដែលកតិកាសញ្ញាបានទទួលស្គាល់ត្រូវបានអនុម័តជាទម្រង់ច្បាប់ គណៈកម្មាធិការចង់អោយគេផ្តល់ពត៌មាន ជាអាទិ៍ពីបញ្ហានេះថា តើច្បាប់ទាំងនេះបានបង្កើតសិទ្ធិប្តឹងតាមផ្លូវតុលាការជំនួសឱ្យបុគ្គល ឬក្រុម ដែលយល់ថា សិទ្ធិរបស់គេមិនត្រូវបានគោរពពេញលេញ ។ ក្នុងករណីដែលសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ត្រូវបាន ទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬនៅពេលដែលបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះត្រូវបានបញ្ចូលផ្ទាល់ទៅ ក្នុងច្បាប់ជាតិ គណៈកម្មាធិការចង់បានពត៌មាន ពីករណីបទបញ្ញត្តិធម្មនុញ្ញបច្ចុប្បន្នទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ត្រូវធ្វើបានឱ្យចុះថយ ឬផ្លាស់ប្តូរយ៉ាងច្រើន។

៧.	វិធានការផ្សេងៗទៀតដែលអាចចាត់ទុកថា "សមស្រប" តាមគោលបំណងនៃមាត្រា ២ (១) រួមមានជា អាទិ៍ វិធានការខាងរដ្ឋបាល ខាងហិរញ្ញវត្ថុ ខាងការអប់រំ និងខាងសង្គម។

៨.	គណៈកម្មាធិការកត់សំគាល់ថាការប្តេជ្ញាចិត្ត "ដើម្បីចាត់វិធានការ....តាមគ្រប់មធ្យោបាយសមស្រប រាប់ បញ្ចូលជាពិសេសទាំងការអនុម័តវិធានការនីតិបញ្ញត្តិ"ឥតតម្រូវ ឬហាមឃាត់នូវទំរង់នៃរដ្ឋាភិបាល ឬប្រព័ន្ធ សេដ្ឋកិច្ចដែលបានប្រើរួចមកហើយជាយានសំរាប់វិធានការទាំងនោះទេឱ្យតែមានប្រជាធិបតេយ្យ ហើយបញ្ហាសិទ្ធិ មនុស្សត្រូវបានគោរព។ ដូច្នេះ ពេលនិយាយដល់ប្រព័ន្ធនយោបាយ និងសេដ្ឋកិច្ច កតិកាសញ្ញាស្ថិតក្នុងភាព អព្យាក្រិត្យ ហើយគោលការណ៍នៃកតិកាសញ្ញាគឺមិនអាចបរិយាយដោយជាក់ច្បាស់ថា ត្រូវប្រកាន់ប្រព័ន្ធសង្គម និយម ឬប្រព័ន្ធមូលធននិយម ឬប្រព័ន្ធចំរុះ ឬសេដ្ឋកិច្ចផែនការ ឬសេដ្ឋកិច្ច ទីផ្សារសេរី ឬប្រព័ន្ធ ពិសេសណាមួយឡើយ។ ក្នុងន័យនេះ គណៈកម្មាធិការបញ្ជាក់ឡើងវិញថា សិទ្ធិទាំងឡាយដែលកតិកាសញ្ញាបាន ទទួលស្គាល់ គឺអាចត្រូវបានធានាក្នុងបរិបទដ៏ធំទូលាយមួយនៃប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធនយោបាយដរាបណាភាព ទាក់ទងគ្នាទៅវិញទៅមក និងភាពមិនអាចចែកដាច់ពីគ្នានៃសិទ្ធិទាំងពីរផ្នែកដូចចែងនៅក្នុងបុព្វកថានៃកតិកាសញ្ញា គឺត្រូវបានគេទទួលស្គាល់ ហើយនិងឆ្លុះបញ្ចាំងនៅក្នុងប្រព័ន្ធដែលគេជ្រើសរើស។ គណៈកម្មាធិការក៏កត់សំគាល់ ផងដែរថា សិទ្ធិមនុស្សដទៃទៀត ជាពិសេសសិទ្ធិដើម្បីអភិវឌ្ឍន៍ក៏ត្រូវគិតគូរក្នុងបរិបទនេះដូចគ្នាដែរ។

៩.	កាតព្វកិច្ចចំបងក្នុងការធ្វើឱ្យបានលទ្ធផល ដូចមានចែងក្នុងមាត្រា ២ (១) គឺត្រូវចាត់វិធានការ "ក្នុងទិស ដៅដើម្បីធ្វើឱ្យសំរេចបានជាលំដាប់នូវការទទួលបានសិទ្ធិទាំងឡាយដូចដែលបានទទួលស្គាល់"ក្នុងកតិកាសញ្ញា។ ពាក្យថា"ការសំរេចបានជាលំដាប់" ជាញឹកញយត្រូវបានគេប្រើដើម្បីពណ៌នាពីបំណងនៃឃ្លានេះ។ គោលគំនិត នៃការសំរេចបានជាលំដាប់ គឺជាការទទួលស្គាល់ថា ការសំរេចបានទាំងស្រុងនូវសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាទូទៅមិនអាចសំរេចបានក្នុងរយៈពេលខ្លីទេ។ តាមន័យនេះ កាតព្វកិច្ចនេះខុសគ្នាឆ្ងាយពីកាតព្វកិច្ច ដែលចែងក្នុងមាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលតំរូវឱ្យមានកាតព្វកិច្ច

ភ្លាមៗ ដើម្បីគោរពនិងធានារ៉ាប់រងលើគ្រប់សិទ្ធិទាំងអស់ដែលទាក់ទិន។ យ៉ាងណាក៏ដោយ ប្រការដែលថា ការសំរេចបានឆ្លងតាមពេលវេលា ឬក្នុងន័យម៉្យាងទៀតថាជាការសំរេចបានជាលំដាប់ដូច កតិកាសញ្ញាបានប្រមាណ ទុកមិនត្រូវបកស្រាយក្នុងរបៀបម៉្យាងដែលដកហូតយកអស់នូវខ្លឹមសារដែលមានន័យពីកាតព្វកិច្ចនោះទេ។ ម៉្យាង ឃ្លានេះអាចការពារភាពបត់បែនជាចាំបាច់ដោយយោងទៅតាមភាពជាក់ស្តែងក្នុងពិភពលោក និងភាពលំបាក របស់ប្រទេសណាមួយក្នុងការធានារ៉ាប់រងនូការសំរេចបានទាំងស្រុងនូវ សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ ម៉្យាងវិញទៀត ឃ្លានេះត្រូវតែបកស្រាយដោយគិតទៅដល់គោលដៅរួម និយាយឱ្យចំគឺគិតទៅដល់មូលហេតុដែល នាំឱ្យមានកតិកាសញ្ញានេះឡើង ពោលគឺដើម្បីបង្កើតកាតព្វកិច្ចមួយជាក់លាក់ទៅឱ្យរដ្ឋជាភាគីទាក់ទិននឹង ការធ្វើឱ្យសំរេចបានទាំងស្រុងនូវសិទ្ធិទាំងឡាយនេះ។ ដូច្នេះ កតិកាសញ្ញាដាក់កាតព្វកិច្ចឱ្យរដ្ឋជាភាគីអនុវត្តឱ្យ បានឆាប់រហ័ស និងមានប្រសិទ្ធិភាពតាមដែលអាចធ្វើទៅបានដើម្បីទៅដល់ទីដៅនោះ។ ម៉្យាងវិញទៀត រាល់ វិធានការថយក្រោយដោយចេតនាណាមួយក្នុងវិស័យនេះតំរូវឱ្យមានការពិចារណាដោយប្រុងប្រយ័ត្នបំផុត និងត្រូវ មានហេតុផលសមស្របគ្រប់គ្រាន់ ដោយគិតទៅដល់ភាពរួមគ្នានៃសិទ្ធិទាំងឡាយដែលមានចែងក្នុងកតិកាសញ្ញា និងក្នុងបរិបទនៃការប្រើប្រាស់នូវធនធានអតិបរមាដែលមាន។

១០. ផ្អែកតាមបទពិសោធន៍ទូលំទូលាយដែលគណៈកម្មាធិការបានទទួល ក៏ដូចគ្នា អង្គការមុនៗបានទទួលក្នុង រយៈពេលជាងមួយទសវត្សនៃការពិនិត្យបាយការណ៍របស់រដ្ឋជាភាភាគី គណៈកម្មាធិការមានទស្សនៈថា រដ្ឋជា ភាគីនីមួយៗមានកាតព្វកិច្ចស្នូលជាអប្បបរមា ដើម្បីធានារ៉ាប់រងនូវការបំពេញបានយ៉ាងហោចណាស់នូវកំរិត សំខាន់អប្បរមានៃសិទ្ធិនីមួយៗ។ ឧទាហរណ៍ ក្នុងរដ្ឋជាភាគី បើមានមនុស្សមួយចំនួនធំខ្វះខាតយ៉ាងខ្លាំងនូវ ចំណីអាហារ ការថែទាំសុខភាពបឋម ទីជម្រកនិងផ្ទះសំបែ្បង ឬមិនមានការអប់រំជាមូលដ្ឋានការណ៍ នេះជា ភស្តុតាងជាក់ស្តែងនៃការខកខានមិនបានអនុវត្តកាតព្វកិច្ចដូចមានចែងក្នុងកតិកាសញ្ញា។ ការបកស្រាយណាមួយ ដែលថា កតិកាសញ្ញានេះមិនបានបង្កើតកាតព្វកិច្ចស្នូលជាអប្បបរិមាទេនោះ ការយល់បែបនេះនឹងនាំឱ្យបាត់ នូវមូលហេតុដែលនាំអោយមានកតិកាសញ្ញានេះ។ ដូចគ្នាដែរ គប្បីកត់សំគាល់ថា ដើម្បីវាយតម្លៃថា តើរដ្ឋជា ភាគីបានបំពេញកាតព្វកិច្ចស្នូលជាអប្បបរិមា ឬយ៉ាងណានោះ គប្បីត្រូវគិតដល់កំហិតធនធានដែលមានក្នុង ប្រទេសនោះ។ មាត្រា ២ (១) បង្គាប់ឱ្យរដ្ឋជាភាគីនិមួយៗចាត់វិធានការចាំបាច់ "ឱ្យបានដល់កំរិតអតិប្បរមា នៃធនធានរបស់ខ្លួនដែលមាន"។ ដើម្បីឱ្យរដ្ឋជាភាគីណាមួយ អាចលើកមូលហេតុខ្វះធនធានមកដោះសាបាន កាលបើមិនបានបំពេញកាតព្វកិច្ចស្នូលអប្បបរិមារបស់ខ្លួន រដ្ឋជាភាគីត្រូវតែ បញ្ជាក់ថា ខ្លួនបានខំប្រឹងប្រែងអស់វិធី ក្នុងការប្រើធនធានទាំងអស់ដែលខ្លួនមាន ដើម្បីបំពេញកាតព្វកិច្ចស្នូល អប្បបរមាទាំងនោះទៅតាមអាទិភាព។

១១. តែទោះយ៉ាងណាក្តី គណៈកម្មាធិការចង់បញ្ជាក់ថា ទោះបីជាធនធានដែលមាននោះត្រូវបានបង្ហាញឱ្យ ឃើញថាមិនគ្រប់គ្រាន់ក្តី រដ្ឋជាភាគីត្រូវតែព្យាយាមដើម្បីធានាអោយបាននូវការប្រើប្រាស់សិទ្ធិដែលពាក់ព័ន្ធឱ្យ

បានទទួលទូលាយតាមដែលអាចធ្វើទៅបានក្នុងកាលៈទេសៈនោះ។ ម្យ៉ាងវិញទៀត ការខ្វះខាតធនធានមិនលុបចោលនូវកាតព្វកិច្ចតាមឃ្លាំមើលលើទំហំនៃការសំរេចបាន ឬការមិនទាន់សំរេចបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឡើយ ហើយការខ្វះធនធានក៏មិនបានលុបចោលនូវកាតព្វកិច្ចក្នុងការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធីសម្រាប់លើកស្ទួយសិទ្ធិទាំងឡាយនេះដែរ។ គណៈកម្មាការបាននិយាយរួចមកហើយលើបញ្ហាទាំងនេះ ក្នុងសេចក្តីអធិប្បាយទូទៅលេខ ១ (១៩៨៩)។

១២. ដូចគ្នានេះដែរ គណៈកម្មាធិការបានគូសបញ្ជាក់ថា ទោះជាស្ថិតក្នុងពេលមានកង្វះធនធានធ្ងន់ធ្ងរបណ្តាលមកពីដំណើរការ ការស្រុតចុះនៃសេដ្ឋកិច្ច ឬដោយកត្តាផ្សេងៗទៀតក្តី សមាជិកក្នុងសង្គមដែលទន់ខ្សោយអាចហើយត្រូវតែទទួលបានការពារតាមរយៈការបង្កើតកម្មវិធីដែលចំណាយតិច។ ក្នុងកិច្ចគាំទ្រវិធីនេះ គណៈកម្មាធិការលើកឡើងនូវការវិភាគរបស់ UNICEF ដែលមានចំណងជើងថា "ការកែតម្រូវដើម្បីគោរពនូវតម្លៃជាមនុស្ស : ការការពារដល់ជនទន់ខ្សោយ និងការជំរុញកិច្ចអភិវឌ្ឍន៍" ការវិភាគរបស់ UNDP ក្នុងរបាយការណ៍ស្តីពីការអភិវឌ្ឍន៍មនុស្សឆ្នាំ១៩៩០ និងការវិភាគរបស់ធានាគារពិភពលោកក្នុងរបាយការណ៍ ស្តីពីការអភិវឌ្ឍន៍ពិភពលោកឆ្នាំ ១៩៩០។

១៣. ចំណុចចុងក្រោយមួយនៃមាត្រា ២(១) ដែលត្រូវយកចិត្តទុកដាក់នោះ គឺថារដ្ឋជាភាគីនិមួយៗបានសន្យា "ចាត់គ្រប់វិធានការដោយខ្លួនឯង និងតាមរយៈជំនួយនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាពិសេសគឺក្នុង វិស័យសេដ្ឋកិច្ច និងបច្ចេកទេស..."។ គណៈកម្មាធិការគូសបញ្ជាក់លើឃ្លាថា "ធនធានអតិបរមាដែលមាន" គឺអ្នកព្រាងកតិកាសញ្ញាមានបំណងសំដៅយកទាំងធនធានផ្ទាល់របស់រដ្ឋ និងធនធានទទួលបានពីសហគមន៍អន្តរជាតិតាមរយៈជំនួយ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ លើសពីនេះ បទបញ្ញត្តិក្នុងមាត្រា ១១, ១៥, ២២ និង ២៣ សង្កត់លើតួនាទីយ៉ាងសំខាន់នៃកិច្ចសហប្រតិបត្តិការបែបនោះផងដែរ ក្នុងការជួយធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិទាំងឡាយដែលពាក់ព័ន្ធ។ ចំពោះមាត្រា ២២ គណៈកម្មាធិការក្នុងសេចក្តីអធិប្បាយលេខ ២ (១៩៩០) បានទាញអារម្មណ៍ឱ្យយកចិត្តទុកដាក់លើឱកាស និងការទទួលខុសត្រូវនានាដែលមានទាក់ទងនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ចំណែកឯមាត្រា ២៣ បានបង្ហាញថា "ការផ្តល់ជំនួយបច្ចេកទេស" ព្រមទាំងសកម្មភាពដទៃទៀតជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានានៃវិធានការអន្តរជាតិដើម្បី ធ្វើឱ្យបានសំរេចនូវសិទ្ធិទាំងឡាយដែលបានទទួលស្គាល់..."។

១៤. គណៈកម្មាធិការចង់បញ្ជាក់ថា ស្របតាមមាត្រា ៥៥ និង៥៦ នៃធម្មនុញ្ញអង្គការសហប្រជាជាតិ ស្របតាមគោលការណ៍គ្រឹះនៃច្បាប់អន្តរជាតិ និងស្របតាមបទបញ្ញត្តិមួយចំនួននៃកតិកាសញ្ញានេះ កិច្ចសហប្រតិបត្តិការអន្តរជាតិដើម្បីអភិវឌ្ឍន៍ និងដើម្បីសំរេចបាននូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ គឺជាកាតព្វកិច្ចមួយ

របស់រដ្ឋទាំងអស់។ ជាពិសេស កាតព្វកិច្ចនេះត្រូវធ្លាក់ទៅលើរដ្ឋទាំងឡាយណាដែលស្ថិតក្នុងស្ថានភាពជាអ្នកជួយរដ្ឋដទៃទៀតចំពោះបញ្ហានេះ។ គណៈកម្មាធិការគូសបញ្ជាក់ជាពិសេសទៅលើសារៈសំខាន់នៃសេចក្តីប្រកាសស្តីពីសិទ្ធិទទួលការអភិវឌ្ឍន៍ដែលបានអនុម័តក្នុងមហាសន្និបាតតាមសេចក្តីសំរេចលេខ ៤/១២៨ ចុះ ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ១៩៨៦ និងទាមទារដើម្បីឱ្យរដ្ឋជាភាគីទាំងឡាយពិចារណាអោយបានពេញលេញលើគោលការណ៍ទាំងអស់ដូចបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសនេះ។ គណៈកម្មាធិការបញ្ជាក់ថា បើបណ្តារដ្ឋដែលស្ថិតក្នុងស្ថានភាពជាអ្នកជួយ ហើយមិនបានអនុវត្តនូវកម្មវិធីសហប្រតិបត្តិការអន្តរជាតិ និងជំនួយអន្តរជាតិយ៉ាងសកម្មទេនោះ ដូច្នេះការសំរេចបានពេញលេញនូវសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នឹងនៅជាសេចក្តីប្រាថ្នាដែលនៅតែមិនទាន់សំរេចបាន។ ក្នុងន័យនេះ គណៈកម្មាធិការក៏រំលឹកឡើងវិញនូវខ្លឹម សារនៅក្នុងសេចក្តីអធិប្បាយទូទៅរបស់ខ្លួនលេខ ២ (១៩៩០) ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅលេខ ៥ (១៩៩៤)**
**មនុស្សដែលមានពិការភាព**

...

## ២. មធ្យោបាយនៃការអនុវត្តន៍

១៣. វិធីសាស្ត្រដែលត្រូវប្រើដោយរដ្ឋជាភាគី ក្នុងការអនុវត្តន៍កាតព្វកិច្ចរបស់ខ្លួនក្រោមកតិកាសញ្ញាចំពោះបុគ្គលមានពិការភាព គឺមានភាពដូចគ្នាទៅនឹងវិធីសាស្ត្រដែលពាក់ព័ន្ធនឹងកាតព្វកិច្ចឯទៀតដែរ (សូមមើលសេចក្តីអធិប្បាយទូទៅលេខ ១ (សម័យប្រជុំលើកទី ៣ ឆ្នាំ ១៩៨៩)។ តាមរយៈការតាមដានជាទៀងទាត់ វិធីសាស្ត្រទាំងនោះ រួមមានការចាំបាច់ត្រូវរកឱ្យឃើញនូវប្រភេទនិងវិសាលភាពនៃបញ្ហាដែលកើតមានក្នុងរដ្ឋ, ការចាំបាច់ត្រូវអនុម័តគោលនយោបាយ និងកម្មវិធីសមស្របដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការដែលបានរកឃើញ, ការចាំបាច់ត្រូវរៀបចំច្បាប់ដែលចាំបាច់ និងការចាំបាច់ត្រូវលុបចោលច្បាប់ណាដែលមានលក្ខណៈរើសអើង, និងការចាំបាច់ត្រូវផ្តល់ថវិកាអោយបានសមស្រប ឬក្នុងករណីចាំបាច់ស្វែងរកកិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ។ ចំពោះចំណុចចុងក្រោយនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិអនុលោមតាមមាត្រា ២២ និង ២៣ នៃកតិកាសញ្ញា គឺជាធាតុផ្សំមួយដ៏មានសារសំខាន់សំដៅជួយឱ្យប្រទេសកំពុងអភិវឌ្ឍន៍មួយចំនួន អាចមានលទ្ធភាពបំពេញកាតព្វកិច្ចរបស់ខ្លួនតាមកតិកាសញ្ញា ។

១៤. លើសនេះ សហគមន៍អន្តរជាតិបានទទួលស្គាល់ជាបន្តបន្ទាប់ថា ការធ្វើគោលនយោបាយ និងការអនុវត្តន៍កម្មវិធីលើផ្នែកនេះគួរតែត្រូវបានធ្វើឡើងដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ និងចូលរួមពីតំណាងនៃក្រុមដែលពាក់ព័ន្ធ។ ក្នុងន័យនេះ វិធានជាបទដ្ឋានបានផ្តល់អនុសាសន៍ថាត្រូវមានការប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីសំរួលដល់ការបង្កើត គណៈកម្មាធិការសំរបសំរួលថ្នាក់ជាតិ ឬក៏ស្ថាប័នប្រហាក់ប្រហែល ប្រយោជន៍

ធ្វើជាចំណុចទាក់ទងកណ្ដាលរបស់ប្រទេសលើបញ្ហាពិការភាពនេះ។ ដើម្បីធ្វើដូចនេះបាន រដ្ឋាភិបាលត្រូវគិតដល់"សេចក្ដីណែនាំឆ្នាំ ១៩៩០ សំរាប់ការបង្កើត និងការអភិវឌ្ឍន៏គណៈកម្មាធិការសំរបសំរួលថ្នាក់ជាតិស្ដីពីពិការភាព ឬក៏ស្ថាប័ន ប្រហាក់ប្រហែល" ។

## ៣. កាតព្វកិច្ចដើម្បីលុបបំបាត់ការរើសអើងដោយមូលហេតុពិការភាព

១៥. ការរើសអើងចំពោះបុគ្គលមានពិការភាពទាំងតាមផ្លូវច្បាប់ឬក្រៅផ្លូវច្បាប់ក្ដី គឺមានប្រវត្តិយូរលង់ និងមានទម្រង់ផ្សេងៗ។ មានការរើសអើងយ៉ាងអយុត្តិធម៌ ដូចជាការបដិសេធនូវឱកាសទទួលបានការអប់រំរហូតដល់ទម្រង់នានា"ដែលពិបាកយល់"នៃការរើសអើងដូចជា វិយោគកម្ម (ការបំបែកក្រុមផ្សេងៗពីគ្នាដោយសារមូលហេតុពូជសាសន៏ ឬ ពណ៌សម្បុរ) និងការដាក់ឱ្យនៅដាច់ពីគេ តាមរយៈការដាក់របាំងរូបវន្ត និងសង្គម។ សំរាប់គោលបំណងនៃកតិកាសញ្ញានេះ"ការរើសអើងដោយសារពិការភាព" អាចមាននិយមន័យថា រាល់ការបែងចែក ការបដិសេធ ការរិតត្បិត ឬបុរិមា (ការចូលចិត្តមួយជាងមួយ) ឬការបដិសេធមិនផ្ដល់ការសំរួលដ៏សមគួរដោយសារតែពិការភាព ហើយដែលមានអនុភាពធ្វើឱ្យរលាយ ឬធ្វើឱ្យអន់ថយនូវការទទួលស្គាល់ការទទួលបាន ឬអនុវត្តនូវសិទ្ធិ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។ តាមរយៈការមិនយកចិត្តទុកដាក់ ការមិនអើពើឥរិយាបថអគតិ និង ការសន្មត់ខុស ព្រមទាំងតាមរយៈការបដិសេធ ការបែងចែក ឬការបំបែក ចេញបុគ្គលមានពិការភាពជារឿយៗត្រូវបានគេរារាំងមិនឱ្យអនុវត្តសិទ្ធិ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយស្មើភាពគ្នាជាមួយបុគ្គលគ្មានពិការភាព។ អនុភាពនៃការរើសអើងដោយសារពិការភាពមានទំហំធ្ងន់ធ្ងរលើវិស័យអប់រំ ការងារ លំនៅដ្ឋាន ការដឹកជញ្ជូន ជីវភាពវប្បធម៌ ព្រមទាំងលទ្ធភាពទទួលផលប្រយោជន៏ពីទីកន្លែងសាធារណៈ និង សេវានានា ។

១៦. ទោះបីជាមានការចំរើនខ្លះៗតាមរយៈការធ្វើច្បាប់ក្នុងទសវត្សកន្លងទៅក៏ដោយ[១៦/] ក៏ស្ថានភាពផ្នែកច្បាប់របស់បុគ្គលមានពិការភាពស្ថិតនៅមិនទៀងទាត់ដដែល។ ដើម្បីកែបញ្ហាការរើសអើងទាំងពេលអតីតនិង បច្ចុប្បន្ន និងបង្ការការរើសអើងនាពេលអនាគត ការរៀបចំច្បាប់គ្រប់ជ្រុងជ្រោយមួយដើម្បីប្រឆាំងនឹងការរើសអើងចំពោះពិការភាព ហាក់បីដូចជាភាពចាំបាច់មួយសំរាប់រដ្ឋជាភាគីស្ទើរតែទាំងអស់។ ច្បាប់នោះនឹងមិនគ្រាន់តែផ្ដល់ឱ្យបុគ្គលមានពិការភាពនូវការជួសជុលតាមផ្លូវតុលាការដែលសមស្រប និងអាចធ្វើបានប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្ដល់នូវកម្មវិធីគោលនយោបាយសង្គម ដែលជួយឱ្យបុគ្គលមានពិការភាពរស់នៅក្នុងជីវភាពមួយដែលរួមរស់ក្នុង សង្គមដូចគេដូចឯង មានសិទ្ធិសំរេច និងឯករាជ្យ ។

១៧. វិធានការប្រឆាំងនឹងការរើសអើងត្រូវឈរលើគោលការណ៍សិទ្ធិស្មើគ្នានៃបុគ្គលមានពិការភាព និង បុគ្គលមិនពិការ ដែលតាមការចែងរបស់កម្មវិធីសកម្មភាពពិភពលោកពាក់ព័ន្ធនឹងជនពិការថា "សេចក្ដីត្រូវការរបស់

បុគ្គលម្នាក់ៗមានសារសំខាន់ស្មើៗគ្នា ហើយសេចក្តីត្រូវការនេះគឺជាមូលដ្ឋានសំរាប់ការធ្វើផែនការនៃសង្គម និងធនធានទាំងអស់ត្រូវប្រើប្រាស់សំដៅធានានូវឱកាសចូលរួមបានស្មើៗគ្នាសំរាប់បុគ្គលម្នាក់ៗ។ គោលនយោបាយសំរាប់ពិការភាព ត្រូវធានានូវលទ្ធភាព(នៃបុគ្គលមានពិការភាព) ទទួលបានផលប្រយោជន៍ពីសេវា សហគមន៍។

១៨. ដោយហេតុថាវិធានការសមស្របត្រូវចាត់ឡើងដើម្បីបំបាត់ចោលនូវការរើសអើង និងដើម្បីបង្កើតនូវឱកាសប្រកបដោយសមធម៌សំរាប់បុគ្គលមានពិការភាព សកម្មភាពបែបនេះមិនត្រូវចាត់ទុកថាមានលក្ខណៈរើសអើងតាមស្មារតីនៃមាត្រា ទី២ (២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ឡើយ ដរាបណាវាឈរលើគោលការណ៍ស្មើភាព និង ត្រូវអនុវត្តតែក្នុងកំរិតដែលចាំបាច់សំដៅសំរេចបាននូវគោលបំណងនេះតែប៉ុណ្ណោះ ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់មនុស្សចាស់**

**៣. សិទ្ធិរបស់មនុស្សចាស់ទាក់ទងនឹងកតាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌**

៩. ពាក្យបច្ចេកទេសដែលប្រើសំរាប់សំគាល់មនុស្សចាស់ប្រែប្រួលយ៉ាងច្រើន សូម្បីតែនៅក្នុងឯកសារអន្តរជាតិជាដើម។ ពាក្យនេះរាប់បញ្ចូលៈ "មនុស្សចាស់" "មនុស្សចាស់ខ្លាំង" "មនុស្សចូលវ័យចំណាស់" "មនុស្សកំពុងចាស់" ហើយនិងដើម្បីសំគាល់មនុស្សមានអាយុច្រើនជាង ៨0 គឺមនុស្សចូលដល់"យុគទី ៤ នៃអាយុ"។ គណៈកម្មាធិការជ្រើសរើសពាក្យយក "មនុស្សចាស់" (ពាក្យបារាំងហៅថា “personnes âgées”) ជាពាក្យដែលប្រើក្នុងសេចក្តីសំរេចលេខ ៤៧/៥ និង ៤៨/៩៨ របស់មហាសន្និបាត។ យោងតាមការអនុវត្តន៍ជាទម្លាប់នៅក្នុងសេវាស្ថិតិរបស់ អ.ស.ប. ពាក្យទាំងនេះគ្របដណ្តប់លើមនុស្សអាយុ ៦0ឆ្នាំ ឬច្រើនជាងនេះ (សេវាស្ថិតិរបស់សហភាពអឺរ៉ុប ចាត់ថា"មនុស្សចាស់"គឺមនុស្សអាយុ ៦៥ ឬ លើសពីនេះ ព្រោះអាយុ៦៥ ជាអាយុទូទៅសំរាប់ចូលនិវត្តន៍ ហើយឥឡូវនេះមាននិន្នាការចូលនិវត្តន៍ក្រោយអាយុ ៦៥ទៀត)។

១០. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌មិនបានពោលចំៗអំពីសិទ្ធិមនុស្សចាស់ទេ ថ្វីបើមាត្រា ៩ ដែលនិយាយអំពី" សិទ្ធិផ្នែកសន្តិសុខសង្គមសំរាប់មនុស្សគ្រប់រូប រួមមាន ការធានារ៉ាប់រងសង្គម" ទទួលស្គាល់ដោយប្រយោលនូវសិទ្ធិត្រូវបានអត្ថប្រយោជន៍ពីអាយុចាស់។ ទោះបីយ៉ាងនេះក្តី ដោយហេតុថាបទបញ្ញត្តិនៃកតិកាសញ្ញានេះអនុវត្តពេញទំហឹងចំពោះសមាជិកទាំងអស់នៃសង្គម គេឃើញច្បាស់ថាមនុស្សចាស់ត្រូវតែទទួលបាននូវសិទ្ធិសព្វបែបយ៉ាងដែលទទួលស្គាល់ដោយកតិកាសញ្ញា។ គោលការណ៍នេះក៏ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញទាំងស្រុងនៅក្នុងផែនការសកម្មភាពអន្តរជាតិទីក្រុងវីយែនទាក់ទងនឹងមនុស្សចាស់។

ម្យ៉ាងទៀត ដោយហេតុថា ការគោរពសិទ្ធិមនុស្សចាស់តម្រូវឱ្យមានវិធានការពិសេស កតិកាសញ្ញាទាមទារឱ្យរដ្ឋភាគីទាំងអស់ចាត់វិធានការបែបនោះ ដោយប្រើធនធានដែលមានឱ្យដល់កំរិតអតិបរមា ។

១១. បញ្ហាសំខាន់មួយទៀត គឺថាតើការរើសអើងផ្អែកទៅលើអាយុនោះត្រូវបានហាមឃាត់ដោយកតិកាសញ្ញាដែរឬយ៉ាងណា។ កតិកាសញ្ញានេះក្តី ឬ សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្សក្តី មិនបាននិយាយឱ្យចំៗថា អាយុជាមូលហេតុមួយក្នុងបណ្តាមូលហេតុរើសអើងនានាដែលត្រូវហាមឃាត់ទេ។ គេមិនបានមើលឃើញថា ការមិនបាននឹកនាចែងបញ្ហាមនុស្សនៅក្នុងឧបករណ៍ទាំងពីរថាជាការបដិសេធមនុស្សចាស់ដោយចេតនាទេ តែផ្ទុយទៅវិញ គេប្រហែលជាអាចពន្យល់បានថា ការភ្លេចនេះគឺមកពីបញ្ហាទាក់ទងទៅនឹងលក្ខណៈប្រជាសាស្ត្រនៃអាយុចាស់នៅពេលដែលឧបករណ៍ទាំងនោះត្រូវបានអនុម័តមិនទាន់មានលក្ខណៈជាក់ស្តែង ឬបន្ទាន់ដូចជាពេលបច្ចុប្បន្ននេះ។

១២. ក៏ប៉ុន្តែបញ្ហានេះនៅមិនទាន់ដាច់ស្រេចនៅឡើយទេ ដោយហេតុថា ការហាមឃាត់មិនឱ្យមានការរើសអើងសំអាងលើហេតុផលនៃ"ស្ថានភាពផ្សេងទៀត"នោះ អាចបកស្រាយបានដើម្បីអនុវត្តលើបញ្ហាអាយុដែរ។ គណៈកម្មាធិការបានសង្កេតឃើញថា ថ្វីបើគេមិនអាចសន្និដ្ឋានថា ការរើសអើងដោយសំអាងលើអាយុត្រូវបានហាមឃាត់យ៉ាងទូលំទូលាយដោយសន្ធិសញ្ញានោះ មានតែបញ្ហាមួយចំនួនតូចបំផុតដែលការរើសអើងដោយសំអាងលើអាយុការរើសអើងគេព្រមទទួលយក។ ម្យ៉ាងទៀត គេគួរកត់ចំណាំថា ភាពមិនអាចទទួលយកបាននូវការរើសអើងប្រឆាំងនឹងមនុស្សចាស់មានគូសបញ្ជាក់នៅក្នុងឯកសារជាច្រើនខាងគោលការណ៍នយោបាយអន្តរជាតិ ហើយមានប្រទេសមួយចំនួនធំបានបញ្ចូលគោលការណ៍នយោបាយនោះទៅក្នុងច្បាប់របស់ខ្លួន។ នៅក្នុងវិស័យតិចតួចដែលការរើសអើងទទួលការអនុគ្រោះបន្តទៅទៀត ដូចជាវិស័យទាក់ទងនឹងអាយុចូលនិវត្តន៍ដោយបង្ខំ ឬ ការចូលរៀនឧត្តមសិក្សា គេហាក់ដូចជាឃើញច្បាស់ថា មាននិន្នាការឆ្ពោះទៅរកការបំបាត់របាំងទាំងនោះ។ គណៈកម្មាធិការមានទស្សនៈថា រដ្ឋទាំងអស់ត្រូវតែប្រឹងប្រែងជំរុញនិន្នាការនេះឱ្យបានលឿនបំផុតតាមដែលអាចធ្វើទៅបាន ។

១៣. អាស្រ័យហេតុនេះ គណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ពិចារណាឃើញថា រដ្ឋភាគីទាំងអស់មានកាតព្វកិច្ចយកចិត្តទុកដាក់ជាពិសេសលើការលើកស្ទួយ និង ការការពារសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់។ តួនាទីរបស់គណៈកម្មាធិការផ្ទាល់ចំពោះរឿងនេះរិតតែសំខាន់ណាស់ទៅទៀត ដោយហេតុថា មិនទាន់មានអនុសញ្ញាអន្តរជាតិទូលំទូលាយនៅឡើយទាក់ទងនឹងសិទ្ធិមនុស្សចាស់ ហើយក៏

គ្មានលិខិតបទដ្ឋានសំរាប់ត្រួតពិនិត្យដែលត្រូវតែអនុវត្តតាមដែលអមទៅជាមួយគោលការណ៍នានារបស់សហប្រជាជាតិក្នុងវិស័យនេះ ដែលជាការផ្ទុយគ្នាពីករណីក្រុមមនុស្ស ដទៃទៀត ដូចជាស្ត្រីនិងកុមារជាដើម ។

១៤. នៅចុងបញ្ចប់នៃសម័យប្រជុំលើកទី ១៣ របស់ខ្លួន គណៈកម្មាធិការ ហើយនិងបុព្វាធិការី (គឺក្រុមការងារនៃអ្នកជំនាញការរដ្ឋាភិបាលសំរាប់ត្រៀមសម័យប្រជុំ) របស់គណៈកម្មាធិការនៅមុនសម័យប្រជុំនេះគឺ បានពិនិត្យរបាយការណ៍ដំបូងចំនួន ១៤៤ របាយការណ៍ខួបវគ្គទី ២ ចំនួន ៧០ ហើយនិង របាយការណ៍ដំបូងនិងរបាយការណ៍ខួបរួមចំនួន ២០ ស្តីពីការអនុវត្តមាត្រា ១ ដល់ ១៥ ។ ការពិនិត្យលើរបាយការណ៍នេះ បានធ្វើឱ្យគណៈកម្មាធិការអាចរកឃើញនូវបញ្ហាជាច្រើន ដែលបានជួបប្រទះនៅក្នុងការអនុវត្តកតិកាសញ្ញាពីសំណាក់រដ្ឋភាគីមួយចំនួនធំដែលតំណាងឱ្យគ្រប់តំបន់នៃពិភពលោកនិងដែលមានប្រព័ន្ធនយោបាយ សេដ្ឋកិច្ចសង្គម និងវប្បធម៌ ខុសគ្នា។ របាយការណ៍ដែលបានពិនិត្យមកដល់ឥឡូវនេះ មិនបានផ្តល់ពត៌មានដោយមានបែបផែនណាមួយអំពីស្ថានការណ៍មនុស្សចាស់ទាក់ទងនឹងការប្រតិបត្តិតាមកតិកាសញ្ញាទេ ក្រៅតែពីពត៌មានដែលមានកំរិតពេញ លេញខុសៗគ្នា ស្តីពីការអនុវត្តមាត្រា ៩ ដែលទាក់ទងនឹងសិទ្ធិខាងសន្តិសុខសង្គម ។

១៥. នៅឆ្នាំ ១៩៩៣ គណៈកម្មាធិការបានចំណាយពេលចំនួនមួយថ្ងៃនៃកិច្ចពិភាក្សាទូទៅដើម្បីធ្វើផែនការសកម្មភាពអនាគតរបស់ខ្លួនក្នុងវិស័យនេះ។ ហើយម្យ៉ាងទៀត នៅក្នុងសម័យប្រជុំថ្មីៗរបស់ខ្លួន គណៈកម្មាធិការបានចាប់ផ្តើមឱ្យសារសំខាន់ដល់ពត៌មានស្តីពីសិទ្ធិមនុស្សចាស់ ហើយការចោទសួររបស់គណៈកម្មាធិការបានធ្វើឱ្យលេចចេញជាពត៌មានដ៏មានតម្លៃខ្លះនៅក្នុងករណីខ្លះ។ តែទោះជាយ៉ាងណាក្តី គណៈកម្មាធិការកត់សំគាល់ឃើញថា របាយការណ៍របស់រដ្ឋភាគីមួយភាគធំនៅតែនិយាយយោងតិចតួចទៅដល់បញ្ហាសំខាន់នេះ។ ហេតុដូចនេះ គណៈកម្មាធិការចង់គូសបញ្ជាក់ថា នៅពេលអនាគត គណៈកម្មាធិការនឹងទទូចសុំឱ្យគេនិយាយឱ្យបានគ្រប់គ្រាន់នៅក្នុងរបាយការណ៍ទាំងអស់ អំពីស្ថានការណ៍របស់មនុស្សចាស់ទាក់ទងទៅនឹងសិទ្ធិនិមួយៗដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា។ ភាគបន្តទៅទៀតនៃសេចក្តីអធិប្បាយនេះបង្ហាញឱ្យឃើញនូវបញ្ហាជាក់លាក់ទាក់ទងនឹងរឿងនេះ ។

## ៤. កាតព្វកិច្ចទូទៅនៃរដ្ឋភាគី

១៦. មនុស្សចាស់ក្នុងឋានៈជាក្រុម មានសមាសភាពចំរុះគ្នាហើយប្លែកៗគ្នាដូចជាក្រុមមនុស្សដទៃទៀតដែរ ហើយស្ថានភាពរបស់មនុស្សចាស់អាស្រ័យលើស្ថានភាពសេដ្ឋកិច្ច និង វប្បធម៌នៃប្រទេស លើកត្តាប្រជាសាស្ត្រ

បរិដ្ឋាន វប្បធម៌ ការងារ ហើយនៅក៏រិតបុគ្គលម្នាក់ គឺអាស្រ័យលើស្ថានភាព គ្រួសារ កំរិតអប់រំ បរិដ្ឋាន នៅទីក្រុង ឬជនបទ និងលើមុខរបររបស់កម្មករ និង អ្នកចូលនិវត្តន៍។

១៧. ទន្ទឹមនឹងមនុស្សចាស់ខ្លះដែលមានសុខភាពល្អ និង ស្ថានភាពហិរញ្ញវត្ថុអាចទទួលបាននោះ ក៏មានមនុស្សចាស់ជាច្រើនទៀតទោះបីក្នុងប្រទេសលូតលាស់ក៏ដោយ ដែលមិនមានមធ្យោបាយគាំទ្រគ្រប់គ្រាន់ ហើយដែលបង្ហាញឱ្យឃើញថាជាមនុស្សស្ថិតក្នុងចំណោមអ្នកដែលទន់ខ្សោយយ៉ាប់យ៉ឺន និងគ្មានការការពារជាងគេបំផុត។ នៅក្នុងពេលមានការអន់ថយខាងសេដ្ឋកិច្ច និងក្នុងពេលរៀបចំសេដ្ឋកិច្ចឡើងវិញ មនុស្សចាស់ងាយនឹងរងគ្រោះបំផុត។ ដូចដែលគណៈកម្មាធិការបានបញ្ជាក់ពីមុន (សេចក្តីអធិប្បាយទូទៅលេខ ៣ ឆ្នាំ ១៩៩០ វាក្យខ័ណ្ឌ ១២) រដ្ឋភាគីទាំងអស់មានករណីយកិច្ចការពារសមាជិកទន់ខ្សោយនៅក្នុងសង្គម ទោះបីក្នុងពេលជួបនូវការខ្វះខាតខាងធនធានធ្ងន់ធ្ងរយ៉ាងណាក៏ដោយ។

១៨. វិធីធានាដែលរដ្ឋភាគីត្រូវប្រើ ដើម្បីបំពេញកាតព្វកិច្ចដែលគេបានសន្យានៅក្រោមកតិកាសញ្ញាទាក់ទងនឹងមនុស្សចាស់ ជាគោលការណ៍គឺដូចជាវិធីនានាដែលប្រើដើម្បីបំពេញកាតព្វកិច្ចផ្សេងៗទៀតដែរ (សូមអានសេចក្តីអធិប្បាយទូទៅលេខ ១ ឆ្នាំ១៩៨៩)។ វិធីទាំងនោះរួមមានការចាំបាច់ត្រូវកំណត់ប្រភេទ និងវិសាលភាពនៃបញ្ហាដែលមានក្នុងរដ្ឋដោយមានការតាមដានជាប្រចាំ ការចាំបាច់ត្រូវអនុម័តគោលនយោបាយ និងកម្មវិធីត្រឹមត្រូវដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនានា ការចាំបាច់ត្រូវអនុម័តច្បាប់កាលណាចាំបាច់និងត្រូវលុបចោលច្បាប់ដែលរើសអើង ហើយនិងការចាំបាច់ត្រូវធានាឱ្យបានថវិកាដែលទាក់ទង ឬបើសិនជាសមស្របត្រូវស្នើសុំកិច្ចសហប្រតិបត្តិការអន្តរជាតិ។ ក្នុងករណីចុងក្រោយនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិស្របតាមមាត្រា ២២ និង ២៣ នៃកតិកាសញ្ញានេះ អាចជាវិធីសំខាន់ជាពិសេសដើម្បីធ្វើឱ្យប្រទេសកំពុងអភិវឌ្ឍន៏អាចបំពេញកាតព្វកិច្ចរបស់គេក្រោមកតិកាសញ្ញា។

១៩. ទាក់ទងបញ្ហានេះ ត្រូវយកចិត្តទុកដាក់លើទិសដៅពិភពលោកលេខ ១ អនុម័តដោយមហាសន្និបាត នៅឆ្នាំ ១៩៩២ ក្នុងនោះ គេបានអំពាវនាវឱ្យបង្កើតហេដ្ឋារចនាសម្ព័ន្ធគាំទ្រជាតិ ដើម្បីលើកស្ទួយគោលនយោបាយ និងកម្មវិធីសំរាប់ភាពចាស់ជរានៅក្នុងផែនការ និងកម្មវិធី អភិវឌ្ឍន៏ជាតិ និងអន្តរជាតិ។ ទាក់ទងបញ្ហានេះដែរ គណៈកម្មាធិការកត់សំគាល់ឃើញថា គោលការណ៏មួយក្នុងបណ្តាគោលការណ៏នានាស្តីពីមនុស្សចាស់របស់សហប្រជាជាតិ ដែលបានលើកទឹកចិត្តដល់រដ្ឋាភិបាលនានា ឱ្យដាក់ចូលទៅក្នុងកម្មវិធីជាតិរបស់ខ្លួននោះ គឺថាមនុស្សចាស់ត្រូវតែអាចបង្កើតជាចលនា ឬ សមាគមមនុស្សចាស់បាន។

**សេចក្តីអធិប្បាយ**

បទបញ្ញត្តិនៃមាត្រានេះ ប្រហែលជាស្មុគ្រស្មាញជាងគេនៅក្នុងកតិកាសញ្ញាទាំងមូល។ បទបញ្ញត្តិនៃមាត្រានេះមានសារសំខាន់ខ្លាំង ដោយសារវាថែងពីលក្ខណៈនៃកាតព្វកិច្ចទូទៅធ្លាក់លើរដ្ឋជាភាគីទាំងអស់ ទាក់ទងនឹងកាតព្វកិច្ចមូលដ្ឋាននីមួយៗដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ។

លក្ខណៈមួយនៃមាត្រា២(១) សមនឹងត្រូវបានគេគូសបញ្ជាក់។ លក្ខណៈទីមួយ គឺព្រំដែនពេលវេលា។ រដ្ឋជាភាគីត្រូវបានទាមទារឱ្យ"ចាត់វិធានការ...ដើម្បីធ្វើឱ្យបានសំរេចជាលំដាប់..."នូវសិទ្ធិនានា។ ជួនកាលសេចក្តីនេះនាំឱ្យអ្នកធ្វើអត្ថាធិប្បាយគិតឃើញថា កាតព្វកិច្ចមិនមានព្រំដែនខាងពេលវេលាទេ ហើយទាក់ទងតែនឹងសេចក្តីប្រាថ្នាខ្លះនៅអនាគតដែលបានបញ្ជាក់។ គណៈកម្មាធិការបានគូសបញ្ជាក់ថា ការបកស្រាយនេះគ្មានហេតុផលអ្វីមកសំអាងទេ។ សិទ្ធិជាច្រើន (ដែលបរិយាយនៅខាងក្រោម) គឺត្រូវបានអនុវត្តជាបន្ទាន់ ហើយរូបមន្តដែលប្រើដើម្បីបញ្ជាក់សិទ្ធិទាំងនោះ បង្ហាញឱ្យឃើញថា គោលគំនិតនៃការសំរេចបានជាលំដាប់ មិនអាចអនុវត្តបាននៅក្នុងករណីទាំងនោះទេ។ ក៏ប៉ុន្តែ សំខាន់ណាស់ទៅទៀតគឺ ប្រការដែលថា កាតព្វកិច្ច"ដើម្បីចាត់វិធានការ" នេះតែម្តង គឺជាកាតព្វកិច្ចបន្ទាន់។ និយាយម្យ៉ាងទៀត មិនថាមានឧបសគ្គខាងធនធាន ឬឧបសគ្គដទៃទៀតនោះទេ រដ្ឋជាភាគីត្រូវចាត់ជាបន្ទាន់នូវវិធានការអ្វីសព្វបែបយ៉ាងខ្លួនអាចឆ្ពោះទៅរកការធ្វើឱ្យបានសំរេចគោលដៅដែលទាក់ទង។ យ៉ាងហោចបំផុត វិធានការនេះទាក់ទងនឹងការធ្វើផែនការសកម្មភាពលំអិតសំរាប់ធ្វើឱ្យបានសំរេចជាលំដាប់នូវសិទ្ធិ ដែលត្រូវបានពិនិត្យ។

គោលដៅដែលប៉ងនៅក្នុងកតិកាសញ្ញានេះគឺ "ការសំរេចបានពេញលេញ" សូម្បីតែគេត្រូវធ្វើឱ្យសំរេចដោយសន្សឹមៗក៏ដោយ។ ដូច្នេះ រដ្ឋជាភាគីត្រូវធ្វើរបាយការណ៍ប្រាប់ឱ្យដឹងពីការជឿនលឿនដែលខ្លួនបានធ្វើឆ្ពោះទៅរកចំណុចគោលដៅនោះ។

ធាតុផ្សំមួយដែលសំខាន់ដែលបែងចែកកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ឱ្យខុសពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ គឺ ការនិយាយដល់ការមានធនធាននៅក្នុងមាត្រា ២(១)។ រដ្ឋមានកាតព្វកិច្ច ដើម្បីឈានទៅរកការសំរេចដោយពេញលេញ ដោយប្រើ"កំរិតអតិបរិមា...នៃធនធានដែលមាន"។ ថ្វីបើបញ្ហាថវិកាចោទជាបញ្ហាដោយមិនអាចប្រកែកបានចំពោះរដ្ឋជាភាគីនោះ របាយការណ៍ត្រូវបញ្ជាក់ថាឧបសគ្គអ្វីខ្លះដែលមានដោយសារការគ្មានធនធាន ហើយរាយការណ៍យ៉ាងលំអិតអំពីកិច្ចប្រឹងប្រែងរបស់រដ្ឋជាភាគីដើម្បីធានាការគោរពសិទ្ធិទ្រទ្រង់ជីវិតសំរាប់មនុស្សគ្រប់គ្នា ទោះបីក្នុងកំរិតអប្បរមាក៏ដោយ។ ឃ្លា "ធនធានដែលមាន" បានដល់ធនធានរបស់រដ្ឋខ្លួនឯងផង និង ធនធានបានមកពីសហគមន៍អន្តរជាតិផង"តាមរយៈការជួយឧបត្ថម្ភនិងសហប្រតិបត្តិការអន្តរជាតិ"។ ចំពោះរឿងនេះគណៈកម្មាធិការបានទាញអារម្មណ៍ជាពិសេស នៅក្នុងសេចក្តីអធិប្បាយរបស់ខ្លួន លេខ ២ (១៩៩០)"ទៅលើឱកាសដ៏សំខាន់ដែលផ្តល់ឱ្យរដ្ឋជាភាគី ស្របតាមមាត្រា ២២ នៃកតិកាសញ្ញានេះ ដើម្បីបង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួននូវសេចក្តីត្រូវការណាមួយខាងជំនួយបច្ចេកទេស ឬសហប្រតិបត្តិការខាងការអភិវឌ្ឍន៍"។

ប្រភេទនៃវិធានការដែលរដ្ឋជាភាគីត្រូវប្រកាន់យកដើម្បីបំពេញកាតព្វកិច្ច ក្រោមកតិកាសញ្ញានេះ គឺជាបញ្ហាដែលរដ្ឋត្រូវសំរេច ដោយពិចារណាលើគ្រប់កាលៈទេសៈទាំងអស់ដែលទាក់ទង។ កាតព្វកិច្ចជាមូលដ្ឋាន គឺត្រូវចាត់វិធានការដោយប្រើ"មធ្យោបាយទាំងអស់ដែលសមស្រប"។ វិធានការទាំងនេះអាចរួមមាន វិធានការធម្មនុញ្ញ នីតិបញ្ញត្តិ រដ្ឋបាល តុលាការ សេដ្ឋកិច្ច សង្គម ឬការអប់រំ ឬវិធានការរួមផ្សំទាំងអស់នេះ។ ទោះបីមាត្រានេះ គូសបញ្ជាក់ថា "ការអនុម័តវិធានការនីតិបញ្ញត្តិ" ត្រូវតែបានពិចារណាឱ្យច្បាស់លាស់ រដ្ឋគ្មានកាតព្វកិច្ចត្រូវធ្វើច្បាប់ទេ លើកលែងតែក្នុងករណីដែលច្បាប់ដែលមានមកហើយផ្ទុយនឹងការចែង ឬ ស្មារតីនៃកតិកាសញ្ញានេះ ឬកាលណាច្បាប់នោះ ហាក់ដូចជាវិធានការចាំបាច់ខានមិនបានក្នុងដំណើរការអនុវត្ត។ មកទល់ពេលនេះ គណៈកម្មាធិការបានយកចិត្តទុកដាក់យ៉ាងខ្លាំងលើវិធានការជាក់ស្តែង ហើយមិនបានគិតថាច្បាប់មានសារសំខាន់ជាពិសេសនោះទេ លើកលែងតែច្បាប់បំបាត់ការរើសអើង។ ទោះបីបទបញ្ញត្តិស្តីពី មធ្យោបាយជួសជុលយ៉ាងមានប្រសិទ្ធិភាព និងស្តីពីការជួសជុលតាមផ្លូវតុលាការ បើសិនជាសមស្រប(ដូចចែងក្នុងមាត្រា ២(៣)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ) មិនបានចែងចំៗថាចាំបាច់ នៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ក៏ដោយ គណៈកម្មាធិការបានបង្ហាញពីការយកចិត្តទុកដាក់ឥតល្ហែរក្នុងការធ្វើឱ្យប្រាកដថា តើសិទ្ធិណាមួយដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញា អាចទាមទារបានឬមិនបាននៅក្នុងតុលាការ។ ពត៌មានបែបនេះត្រូវផ្តល់ទៅតាមការគួរ។

មាត្រា ២(២) ដែលទាក់ទងនឹងការមិនរើសអើង គឺជាបទបញ្ញត្តិមួយនៃបទបញ្ញត្តិនានានៃកតិកាសញ្ញាដែលមិនស្ថិតក្រោមរបបនៃការធ្វើឱ្យបានសំរេចជាលំដាប់ ដូចមានពោលនៅក្នុងមាត្រា ២(១)។ ផ្ទុយទៅវិញ ការសន្យាក្នុងនៅមាត្រា២(២) គឺត្រូវ"ធានា"ការមិនរើសអើងដោយសារមូលហេតុទាំងអស់ដែលរៀបរាប់។ ម្យ៉ាងវិញទៀត មូលហេតុដែលចែងបញ្ជាក់នោះរាប់មិនអស់ទេ ដោយសារបទបញ្ញត្តិនេះ ក៏ហាមឃាត់ផងដែរនូវការរើសអើងដោយសំអាងលើ "ឋានៈអ្វីផ្សេងៗទៀត"។ ទោះបីគណៈកម្មាធិការ បានចាត់ធ្វើការពិនិត្យយ៉ាងមានបែបផែននូវប្រភេទផ្សេងៗនៃការរើសអើងដែលអាចចូលក្នុងពពួក"ឋានៈផ្សេងៗ"នោះក្តី គណៈកម្មាធិការបានឱ្យសំខាន់ជាពិសេសដល់កិច្ចប្រឹងប្រែងដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងមនុស្សមានពិការភាព និងប្រឆាំងនឹងមនុស្សចាស់។ ក្នុងករណី ទាំងពីរយ៉ាង គណៈកម្មាធិការបានប្រើវាក្យស័ព្ទ និង និយមន័យដែលត្រូវទទួលយកយ៉ាងទូលំទូលាយនៅក្នុងរង្វង់វេទិកាដែលទាក់ទងនៅក្នុងអ.ស.ប។ នៅក្នុងសេចក្តីអធិប្បាយពីរទូទៅដោយឡែកពីគ្នា គណៈកម្មា-ធិការគូសបញ្ជាក់ថា ការប្រតិបត្តិស្របតាមកតិកាសញ្ញានេះ តំរូវឱ្យប្រកាន់យកវិធានការទូលំទូលាយសំរាប់គោលបំណងទាំងនេះ ហើយគណៈកម្មាធិការបានគូសបញ្ជាក់ទៀតថា រដ្ឋជាភាគីត្រូវបញ្ចូលក្នុងរបាយការណ៍របស់ខ្លួននូវពត៌មានអំពីវិធានការដែលត្រូវបានប្រកាន់យក និងបញ្ហាដែលនៅតែមានបន្តនៅក្នុងវិស័យទាំងនេះ។ គេអាចកត់សំគាល់ថា អនុសាសន៍ទូទៅលេខ ១៨ (សម័យប្រជុំលើកទី១០ ឆ្នាំ១៩៩១) ដែលអនុម័តដោយគណៈកម្មាធិការបំបាត់ការ រើសអើងប្រឆាំងនឹងស្ត្រីក៏មានបរិយាយពី"ស្ត្រីពិការដែរ"។

នៅក្នុងសេចក្ដីអធិប្បាយទូទៅលេខ ៥(១៩៩៤)ទាក់ទងនឹងមនុស្សមានពិការភាព គណៈកម្មាធិការកត់សំគាល់ថា ទាំងមហាសន្និបាត ទាំងគណៈកម្មការសិទ្ធិមនុស្ស បានស្នើសុំឱ្យគណៈកម្មាធិការតាមដានមើលរដ្ឋជាភាគីឱ្យប្រតិបត្តិតាមកាតព្វកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យជនមានពិការភាពបានអាស្រ័យផលពេញលេញនូវសិទ្ធិដែលពាក់ព័ន្ធរបស់គេ។ ក៏ប៉ុន្តែ គណៈកម្មាធិការមកទល់ពេលនេះ នៅក្នុងរបាយការណ៍របស់រដ្ឋ គេបានយកចិត្តទុកដាក់តិចណាស់ចំពោះរឿងនេះ។ កតិកាសញ្ញានេះ មិនបានពោលច្បាស់ៗទៅរកមនុស្សដែលមានពិការភាពទេ ប៉ុន្តែ ដោយហេតុថា បទបញ្ញត្តិរបស់កតិកាសញ្ញាអនុវត្តពេញលេញចំពោះសមាជិកទាំងអស់នៃសង្គម ក្រុមនេះក៏ចូលក្នុងដែនអនុវត្តនេះដែរ។ ជាងនេះទៀត គណៈកម្មាធិការគត់សំគាល់ថា ឧបករណ៍សិទ្ធិមនុស្សអន្តរជាតិថ្មីៗបំផុតនេះ ពិតជានិយាយទៅដល់ក្រុមនេះដោយចំៗ។ ឧបករណ៍ទាំងនោះរួមមាន អនុសញ្ញាស្ដីពីសិទ្ធិកុមារ (មាត្រា២៣) ធម្មនុញ្ញអាហ្វ្រិក ស្ដីពីសិទ្ធិរបស់ប្រជាជន(មាត្រា១៨(៤)) និងពិធីសារបន្ថែមអមអនុសញ្ញាទ្វីបអាហ្វ្រិកស្ដីពីសិទ្ធិមនុស្សក្នុងវិស័យសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌។

តាមរយៈនិយមន័យ គណៈកម្មាធិការអនុវត្តវិធីដែលអនុម័តនៅក្នុងវិធានបទដ្ឋាននៃការធ្វើឱ្យមានសមភាពខាងឱកាសចំពោះមនុស្សមានពិការភាព ដែលអនុម័តដោយមហាសន្និបាតក្នុងឆ្នាំ ១៩៩៣ ដែលពង្រីកការអនុវត្តនីដល់មនុស្សទាំងអស់"ដែលពិការដោយសារការអន់ថយខាងផ្លូវកាយ ផ្លូវបញ្ញា វិញ្ញាណ ដោយសារសភាពផ្លូវពេទ្យ ឬជំងឺសៃប្រសាទ។ ការអន់ថយ សភាព ឬជំងឺទាំងនោះអាចមានលក្ខណៈជាអចិន្ត្រៃយ៍ ឬមួយរយៈ"។ សេចក្ដីអធិប្បាយទូទៅផ្អែកលើមូលមតិគ្នាក្នុងរឿងនេះដែលឆ្លុះបញ្ចាំងនៅក្នុងវិធានបទដ្ឋាន។

ជាងនេះទៀត ក្នុងករណីចាំបាច់ត្រូវមានការព្យាបាលពិសេស រដ្ឋជាភាគីត្រូវចាត់វិធានការសមស្រប ដោយប្រើប្រាស់ធនធានក្នុងកំរិតអតិបរមាដែលមាន ដើម្បីធ្វើឱ្យមនុស្សទាំងនោះអាចពុះពារយកឈ្នះលើការបាត់បង់ប្រៀបដែលកើតចេញពីពិការភាពរបស់គេ ដែលជាហេតុធ្វើឱ្យមិនបានទទួលសិទ្ធិដែលចែងក្នុងកតិកាសញ្ញានេះ។ លើសពីនេះទៅទៀត សេចក្ដីតំរូវដែលមាននៅក្នុងមាត្រា ២(២)នៃកតិកាសញ្ញា ដែលថា សិទ្ធិទាំងឡាយ"ដែលបានប្រកាស...នឹងត្រូវបានអនុវត្ត ដោយគ្មានការរើសអើងអ្វីទាំងអស់" ផ្អែកលើមូលហេតុមួយចំនួន "ឬ ឋានៈផ្សេងទៀត" គឺអនុវត្តយ៉ាងច្បាស់លើការរើសអើងដោយសារមូលហេតុមានពិការភាព។

គណៈកម្មាធិការកត់សំគាល់ថា ថ្វីបើមធ្យោបាយដែលជ្រើសរើសដើម្បីជំរុញឱ្យបានសំរេចពេញលេញនូវសិទ្ធិរបស់ក្រុមនេះ ខុសគ្នាច្រើនពីប្រទេសមួយទៅប្រទេសមួយទៀតក៏ដោយ ក៏មិនមែនមានន័យថា ប្រទេសណាមួយមិនប្រឹងប្រែងធ្វើគោលនយោបាយកម្មវិធីដើម្បីឱ្យបានសំរេចសិទ្ធិទាំងនេះយ៉ាងពេញលេញនោះទេ។ ដូច្នេះ ទាំងប្រទេសអភិវឌ្ឍន៍ ទាំងប្រទេសកំពុងអភិវឌ្ឍន៍ មានកាតព្វកិច្ចត្រូវអនុម័តយកវិធានការនានាដែលសមស្រប។ កិច្ចការនេះ ចាប់ផ្ដើមពីកាតព្វកិច្ចចៀសវាង មិនចាត់វិធានការណាដែលអាចមានផលអវិជ្ជមានលើមនុស្សដែលមានពិការភាព។ រដ្ឋក៏ត្រូវមានកាតព្វកិច្ចចាត់វិធានការជាវិជ្ជមាន ដើម្បីកាត់បន្ថយការចាញ់ប្រៀបខាងរចនាសម្ព័ន្ធ ហើយនឹងផ្ដល់ភាពអនុគ្រោះមុនគេដល់មនុស្សដែលមានពិការភាព។ គណៈកម្មាធិការកត់សំគាល់ឃើញថា ដើម្បីឱ្យបានសំរេចគោលបំណងនេះ រដ្ឋត្រូវលៃលករកធនធានបន្ថែមឱ្យបាន និងត្រូវមានវិធានការមួយចំនួនធំ

សំរាប់ដោះស្រាយរឿងនេះ។ សេចក្តីអធិប្បាយទូទៅ យល់ឃើញថា រដ្ឋជាភាគីត្រូវមានកាតព្វកិច្ចដើម្បីធានាថា មិនមែនត្រឹមតែមជ្ឈដ្ឋានសាធារណៈទេ តែមជ្ឈដ្ឋានឯកជនផងដែរ ដែលត្រូវស្ថិតក្រោមការដាក់បញ្ញត្តិច្បាប់នៅក្នុងព្រំដែនក៏សមស្រប ដើម្បីធានាឱ្យបានការយកចិត្តទុកដាក់ដោយសមធមិដល់ជនដែលមានពិការភាព។ ដូច្នេះការធ្វើឯកជនូបនីយកម្មនៃសេវាកម្ម និងទីកន្លែងណាមួយមិនត្រូវបំបាត់កាតព្វកិច្ចរបស់រដ្ឋាភិបាលទេ។

នៅក្នុងសេចក្តីអធិប្បាយទូទៅ លេខ ៦(១៩៩៥)ទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់មនុស្សចាស់ គណៈកម្មាធិការយកចិត្តទុកដាក់នឹងបាតុភូតនៃការកាន់តែចាស់នៃប្រជាជនពិភពលោក ហើយរាយលំអិតវិធានការជាក់លាក់ដែលត្រូវប្រកាន់យក ដើម្បីធានាសិទ្ធិរបស់ក្រុមនោះ។

ថ្វីបើពាក្យ"រើសអើង" មិនបានកំណត់នៅក្នុងកតិកាសញ្ញានេះ គេអាចយល់ច្បាស់ន័យរបស់វាដោយយោងទៅការប្រើពាក្យនោះនៅក្នុងបរិបទនៃសន្ធិសញ្ញាសិទ្ធិមនុស្ស។ សំរាប់គោលបំណងនេះ បទបញ្ញត្តិដែលពាក់ព័ន្ធរួមមាន មាត្រា២(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ(សូមមើលសេចក្តីអធិប្បាយទូទៅ លេខ ១៨ (៣៧) របស់គណៈកម្មាធិការសិទ្ធិមនុស្ស) ដែលដកស្រង់នៅក្នុងផ្នែកមួយនៃសៀវភៅនេះទាក់ទងនឹងមាត្រា២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ មាត្រា ១ នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងពូជសាសន៍ ហើយនិងមាត្រា ១ នៃអនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី។ ដោយគិតដល់បទបញ្ញត្តិទាំងនោះ ពាក្យ"រើសអើង" សំរាប់គោលបំណងនៃកតិកាសញ្ញានេះ អាចបកស្រាយបានថា ជាការបែងចែក ការបដិសេធ ការរិតត្បិត ឬការឱ្យអាទិភាព ណាមួយដែលផ្អែកលើមូលហេតុណាមួយ ដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃទៀត ហើយមានគោលបំណង ឬមានអនុភាពធ្វើឱ្យសាបសូន្យ ឬធ្វើឱ្យអន់ថយការទទួលស្គាល់ ការអាស្រ័យផល ឬការអនុវត្តសិទ្ធិទាំងអស់ដែលចែងក្នុងកតិកាសញ្ញានេះ ពីសំណាក់មនុស្សទាំងអស់ ដោយស្មើគ្នា។

វិធានការជាគុណប្រយោជន៍ដល់ជនបាត់បង់ប្រៀបដែលប្រកាន់យកក្នុងទស្សនៈបំបាត់ការរើសអើងមិនផ្ទុយនឹងកតិកាសញ្ញានេះទេ។ បញ្ហានេះ ត្រូវបានពន្យល់នៅក្នុងមាត្រា ៣ ខាងក្រោម។

ថ្វីបើ រដ្ឋជាភាគីនិមួយៗមានភារកិច្ចសំរេចថា វិធានការណាដែលសមស្របដើម្បីអនុវត្តការធានារ៉ាប់រងនេះ គណៈកម្មាធិការសន្មតថា ដើម្បីសំរេចគោលដៅនេះ រដ្ឋជាភាគីមិនត្រឹមតែធ្វើច្បាប់ប៉ុណ្ណោះទេ តែត្រូវធ្វើអ្វីហួសពីច្បាប់ទៅទៀត។ ដូច្នេះ របាយការណ៍របស់រដ្ឋជាភាគីត្រូវតែសបញ្ជាក់មិនត្រឹមតែវិធានការធម្មនុញ្ញនីតិបញ្ញត្តិ និងរដ្ឋបាល ប៉ុណ្ណោះទេ ប៉ុន្តែត្រូវរៀបរាប់ពីវិធានការនយោបាយសមស្របដែលបានប្រកាន់យកទៀតផង។ គណៈកម្មាធិការក៏បានស្នើសុំជាទ្បេងទាត់ឱ្យរដ្ឋជាភាគីផ្តល់ពត៌មានមកខ្លួនអំពីបញ្ហារើសអើង ដែលអាចនៅតែមាន ហើយអាចអនុវត្តដោយអាជ្ញាធរសាធារណៈ ដោយសហគមន៍ទាំងមូល ឬដោយបុគ្គលស្ថាប័នឯកជន។

មាត្រាខ្លះនៃឧបករណ៍អន្តរជាតិដទៃទៀត គ្របដណ្តប់លើការមិនរើសអើង និងសមភាពនៅចំពោះមុខច្បាប់។ ដូច្នេះ នៅពេលណាប្រមូលពត៌មានអំពីបញ្ហាដែលលើកឡើងក្នុងមាត្រា ២(២) និងមាត្រា ៣

នៃកតិកាសញ្ញានេះ មន្ត្រីធ្វើរបាយការណ៍ត្រូវពិចារណាដល់ភាពមានប្រយោជន៍នៃពតិមានដែលមានមកហើយស្តីពី មាត្រា ២(១)៣ និង២៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា២(១) និង ៥ នៃ អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងនឹងពូជសាសន៍ មាត្រា ២និង៩ដល់១៦ នៃអនុសញ្ញាស្តីពីការរើស អើងប្រឆាំងនឹងស្ត្រី និងមាត្រា ២ និង ២៣ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ក្នុងវិស័យនេះ គេអាចគិតទៅដល់ អនុសាសន៍ទូទៅ លេខ ១៤ (ឆ្នាំ១៩៩៣) ដែលអនុម័តដោយគណៈកម្មាធិការបំបាត់ការរើសអើងនឹងពូជសាសន៍។ បន្ទាប់មក គេអាចយោងពតិមាននេះទៅរបាយការណ៍ដែលស្ថិតក្រោមកតិកាសញ្ញានេះ។

មាត្រា ២ ៣) នៃកតិកាសញ្ញានេះ រៀបរាប់ពីការកំរិតព្រំដែនដែលអាចមានទៅលើសិទ្ធិមនុស្សដែលមិន មែនជាពលរដ្ឋរបស់ប្រទេសធ្វើរបាយការណ៍។ ជាទូទៅ កតិកាសញ្ញានេះ មិនបែងចែកឱ្យខុសគ្នារវាងអ្នកជាពលរដ្ឋ និងអ្នកដែលជាមិនមែនពលរដ្ឋទេ។ បទបញ្ញត្តិនេះ គឺជាការលើកលែងតែមួយនៅក្នុងរឿងនេះ ហើយអនុវត្តចំពោះ តែ"ប្រទេសកំពុងអភិវឌ្ឍន៍"ប៉ុណ្ណោះ ដូចគេបានយល់នៅក្នុងបរិបទនៃសកម្មភាពរបស់ អ.ស.ប ជាទូទៅ។ ប្រទេស ទាំងនោះ អាចអនុវត្តការរិតត្បិតចំពោះតែ "សិទ្ធិសេដ្ឋកិច្ច"ប៉ុណ្ណោះ ហើយមិនអាចរិតត្បិតចំពោះសិទ្ធិសង្គម ឬសិទ្ធិ វប្បធម៌ទេ។ តទៅទៀត ការរិត្បិតនោះអាចដាក់បានតែក្នុងករណីមានការពិចារណាត្រឹមត្រូវដល់សិទ្ធិមនុស្ស ហើយត្រូវបង្ហាញឱ្យឃើញ វាជាការចាំបាច់ខាន់មិនបានដោយសារលក្ខខ័ណ្ឌនៃសេដ្ឋកិច្ចជាតិ។ ប្រការដែលថា គ្មានរដ្ឋជាភាគីណាមួយបានប្រឹងប្រែងបង្ហាញថា វិធានការបែបនោះ ជាវិធានការត្រូវស្របតាមកតិកាសញ្ញានេះទេ នោះ អាចជាភស្តុតាងនៃការលំបាកក្នុងការប្រឹងប្រែងធ្វើកិច្ចការនោះ។

## មាត្រា៣

***អត្ថបទមាត្រា ៣***

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះត្រូវធានាធ្វើឱ្យមានភាពស្មើគ្នារវាងបុរស និងស្ត្រី ដើម្បីឱ្យ ទទួលបាននូវសិទ្ធិទាំងអស់ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងផ្នែកវប្បធម៌ ដូចដែលមានចែងក្នុងកតិកាសញ្ញានេះ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)**

**មនុស្សដែលមានពិការភាព**

១៩. បុគ្គលមានពិការភាព ជួលកាលត្រូវបានគេចាត់ទុកជាមនុស្សដែលគ្មានលក្ខណៈភេទ(ឬគ្មានយៃនឌ័រ)។ ដោយហេតុនេះ ជារឿយៗគេតែងតែមិនយកចិត្តទុកដាក់លើស្ត្រីដែលរងគ្រោះដោយការរើសអើងទ្វេ។ ទោះបីជា មានការអំពាវនាវជាញឹកញាប់ពីសំណាក់សហគមន៍អន្តរជាតិ ឱ្យមានការគិតគូរយ៉ាងពិសេសចំពោះស្ថានភាពរបស់ ពួកគេក៏ដោយ ក៏មានការប្រឹងប្រែងយ៉ាងតិចតួចក្នុងអំឡុងទសវត្សមកនេះ។ ការមិនយកចិត្តទុកដាក់ដល់ស្ត្រីមាន ពិការភាពត្រូវបានគេលើកឡើងជាច្រើនលើកច្រើនសាក្នុងរបាយការណ៍របស់អគ្គលេខាធិការ ស្តីពីការអនុវត្តន៍

កម្មវិធីសកម្មភាពពិភពលោក។ អាស្រ័យហេតុនេះ គណៈកម្មាធិការរំលឹករដ្ឋជាភាគីឱ្យដោះស្រាយបញ្ហារបស់ស្ត្រីមានពិការភាព ដោយផ្តល់អាទិភាពខ្ពស់ដល់ការអនុវត្តកម្មវិធីនានាដែលទាក់ទងនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ នៅពេលអនាគត។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)**

***សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់***

២០. អនុលោមតាមមាត្រា ៣ នៃសន្ធិសញ្ញា (ដែលបានបញ្ជាក់ថា រដ្ឋភាគីទាំងអស់សន្យាធានាធ្វើឱ្យមានភាពស្មើៗគ្នារវាងបុរស និង ស្ត្រីក្នុងការប្រើសិទ្ធិទាំងអស់ផ្នែកខាង សេដ្ឋកិច្ច សង្គម និង វប្បធម៌) គណៈកម្មាធិការពិចារណាឃើញថា រដ្ឋជាភាគីត្រូវតែយកចិត្តទុកដាក់ជាពិសេសចំពោះស្ត្រីចាស់ដែលស្ថិតក្នុងសភាពពិបាកបំផុតដោយសារគេមិនបានធ្វើការងារ ដែលអាចឱ្យគេមានសិទ្ធិទទួលបានប្រាក់សោធនសំរាប់មនុស្សចាស់ ព្រោះតែគេជាប់រវល់ចំណាយពេលមួយជីវិត ឬមួយចំណែកនៃជីវិតរបស់គេដើម្បីថែទាំគ្រួសារ ព្រមទាំងមិនមានសិទ្ធិទទួលសោធនសំរាប់ស្ត្រីមេម៉ាយ។

២១. ដើម្បីប្រឈមនឹងស្ថានការណ៍បែបនេះ និង ដើម្បីប្រតិបត្តិដោយពេញលេញតាមមាត្រា ៩ នៃកតិកាសញ្ញានេះ និងតាមវាក្យខ័ណ្ឌ ២(ជ) នៃសេចក្តីថ្លែងការណ៍ស្តីពីជរាភាព រដ្ឋជាភាគី ត្រូវផ្តើមធ្វើកម្មវិធីអត្ថប្រយោជន៍សំរាប់មនុស្សចាស់ដែលមិនបាច់បង់ភាគទាន ឬជំនួយផ្គត់ផ្គង់ដទៃទៀតជាគុណប្រយោជន៍ដល់មនុស្សទាំងអស់ដែលខ្លួនគេមិនអាចមានធនធានអ្វីនៅពេលគេឈានដល់អាយុមួយដែលបញ្ជាក់នៅក្នុងច្បាប់ជាតិ ដោយគ្មានការបែងចែកខាងភេទអ្វីទាំងអស់។ ដោយគេមានប្រវែងអាយុវែងជាង ហើយដោយសារជារឿយៗគេគ្មានប្រាក់សោធនតាមរយៈការបង់ភាគទាន ដូច្នេះស្ត្រីគួរតែជាអ្នកត្រូវទទួលអត្ថប្រយោជន៍ដ៏សំខាន់ពីផែនការនេះ។

***សេចក្តីអធិប្បាយ***

បទបញ្ញត្តិនេះគូសបញ្ជាក់នូវសារៈសំខាន់ពិសេសនៃកាតព្វកិច្ចរ៉ាប់រងសិទ្ធិស្មើគ្នាដែលបុរស និងស្ត្រី មានក្នុងការទទួលផលពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ទាំងអស់។ ដូចគ្នាដែរ នៅក្នុងកថាខ័ណ្ឌ ២ នៃមាត្រា ២ កាតព្វកិច្ច "រ៉ាប់រង" លទ្ធផលនេះគឺជាកាតព្វកិច្ចបន្ទាន់ ហើយមិនជាកម្មវត្ថុនៃការសំរេចបានជាសន្សឹមៗឡើយ។ គេបកស្រាយបទបញ្ញត្តិនេះថា ជាការទាមទារឱ្យមានវិធានការទាំងឡាយដែលអាចចាត់ទុកជាវិធានការមានលក្ខណៈជាអវិជ្ជមានផង វិជ្ជមានផង។ វិធានការប្រភេទទីមួយ ត្រូវបានបង្កើតឡើងដើម្បីលុបបំបាត់ចោលករណីនៃការរើសអើង ឯវិធានការប្រភេទទីពីរវិញ ត្រូវមានទីដៅ និងជំរុញការគោរពសិទ្ធិស្មើគ្នាពិតប្រាកដ។ ក្នុងចំណោមវិធានការ

វិជ្ជមាន គេអាចរាប់វិធានការដែលស្តាក្រុមអ្នកបាត់បង់ប្រៀប ដែលបង្កើតឡើងដើម្បីបន្ថយ ឬបំបាត់នូវលក្ខខ័ណ្ឌទាំងឡាយ ដែលជាដើមកំណើតនៃការរើសអើង ឬដែលជួយការរើសអើងឱ្យមាននិរន្តរភាព ដែលជាការរើសអើងហាមឃាត់ដោយកតិកាសញ្ញា។ ដរាបណាវិធានការបែបនេះជាការចាំបាច់ ដើម្បីកែការរើសអើងតាមផ្លូវជាក់ស្តែងណាមួយ វិធានការទាំងនោះអាចត្រូវបានចាត់ទុកដូចជាវិធានការត្រឹមត្រូវក្នុងន័យរបស់កតិកា-សញ្ញា។

វិធានការវិជ្ជមានចាំបាច់ទាំងឡាយដើម្បីធ្វើឱ្យមាត្រា ៣ មានអនុភាព មិនមែនស្ថិតត្រឹមតែការអនុម័តច្បាប់ទេ។ ហេតុនេះ របាយការណ៍ទាំងឡាយត្រូវតែមានពតិមានពីស្ថានភាពស្ត្រីនៅក្នុងជីវិតជាក់ស្តែងទាក់ទងនឹងការអាស្រ័យផលនៃសិទ្ធិទាំងអស់ដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញា។ ដោយគិតទៅដល់ការប្តេជ្ញាយ៉ាងខ្លាំងក្លារបស់សន្និសិទពិភពលោកស្តីពីសិទ្ធិមនុស្សនៅក្រុងវីយែនក្នុងឆ្នាំ១៩៩៣ ថានឹងធានារ៉ាប់រងដល់ស្ថានភាពស្មើគ្នារវាងបុរសនិងស្ត្រីនិងដល់ការគោរពពេញទំហឹងនូវសិទ្ធិមនុស្សទាំងអស់របស់គេ ជាការសំខាន់ដ៏ពិសេសដែលរដ្ឋជាភាគីនៃកតិកាសញ្ញាត្រូវផ្តល់ពតិមានតាមរបៀបផ្តោតនិងបែងប្រភេទ រួមមាន ពតិមានជាស្ថិតិ និងជាអ្វីផ្សេងទៀតដែលមិនត្រឹមតែបង្ហាញពីស្ថានភាពកុមារីនិងស្ត្រីក្នុងសង្គមនីមួយៗដែលមាននៅក្នុងច្បាប់ប៉ុណ្ណោះទេ តែត្រូវបង្ហាញស្ថានភាពនេះនៅក្នុងផ្លូវប្រតិបត្តិផងដែរ។ របៀបនេះ អនុវត្តចំពោះសិទ្ធិមូលដ្ឋាននីមួយៗដែលមាននៅក្នុងកតិកាសញ្ញាផងដែរ។

## មាត្រា ៤

### *អត្ថបទនៃមាត្រា ៤*

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថាក្នុងការទទួលបាននូវសិទ្ធិ ដែលរដ្ឋបានផ្តល់អោយអនុលោមតាមបញ្ញត្តិនៃកតិកាសញ្ញានេះ រដ្ឋអាចទទួលស្គាល់សិទ្ធិទាំងនេះគឺតែក្នុងរង្វង់ព្រំដែន ដូចដែលច្បាប់បានចែងកំណត់ប៉ុណ្ណោះ ដែលអាចស្របគ្នាទៅនឹងលក្ខណៈធម្មជាតិនៃសិទ្ធិអស់ទាំងនេះ ហើយនិងដើម្បីគោលបំណងតែម្យ៉ាងគត់គឺការ លើកស្ទួយសុខុមាលភាពជាទូទៅនៅក្នុងសង្គមប្រជាធិបតេយ្យ។

### *សេចក្តីអធិប្បាយ*

ថ្វីបើមាត្រា ៥ និងមាត្រា ៨ របស់កតិកាសញ្ញានិយាយខ្លះៗផងដែរពីបណ្តាកាលៈទេសៈដែលក្នុងនោះការកំណត់ព្រំដែនលើការអាស្រ័យផលពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ អាចអនុញ្ញាតឱ្យធ្វើបានដែរនោះ មាត្រា៤ មានអនុភាពអនុវត្តបានចំពោះសិទ្ធិទាំងអស់ដែលកតិសញ្ញាទទួលស្គាល់។ ផ្ទុយពីអ្វីដែលចែងក្នុងកតិសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គ្មានសិទ្ធិណាមួយដែលត្រូវបានបញ្ជាក់ដោយច្បាស់ៗថា ពុំអាចបន្ថយអនុភាពនៃសិទ្ធិទាំងនោះទេ។ ក៏ប៉ុន្តែ លក្ខខ័ណ្ឌជាក់លាក់សំរាប់យកមកបង្ហាញហេតុផលនៃការកំណត់ព្រំដែនស្របទៅតាមមាត្រា ៤ មិនងាយនឹងបំពេញបានទេ នៅក្នុងករណីភាគច្រើន។

ជាដំបូង រាល់ការដាក់ព្រំដែនត្រូវបាន"កំណត់ដោយច្បាប់" ដោយអនុលោមទៅតាមបណ្តានីតិវិធីជាតិដែលសមស្រប ហើយមិនត្រូវមានលក្ខណៈធ្វើតាមទំនើងចិត្ត ឬគ្មានហេតុផលឬប្រតិសកម្មឡើយ។ រាល់ការដាក់ព្រំដែនត្រូវតែមាន"សមិតភាពជាមួយនឹងលក្ខណៈធម្មជាតិ"នៃសិទ្ធិទាំងនេះ។ ឧទាហរណ៍ ការក៏រិតព្រំដែនក្នុងគោលបំណងកុំឱ្យប្រជាជនមួយផ្នែកមានលទ្ធភាពបានចំណីអាហារ ប្រហែលជាមិនអាចចាត់ទុកថាមានសមតិភាពជាមួយនឹងទស្សនៈជាមូលដ្ឋាននៃសេចក្តីថ្លៃថ្នូរជាមនុស្ស ដែលជាមូលដ្ឋានគ្រឹះនៃកតិកាសញ្ញាទេ។ ម្យ៉ាងវិញទៀត ការក៏រិតព្រំដែនត្រូវតែមានហេតុផលមកបង្ហាញឱ្យឃើញថា បានធ្វើឡើងដើម្បីលើកស្ទួយ"សុខមាលភាពទូទៅ នៅក្នុងសង្គមប្រជាធិបតេយ្យ"។ តែបើការក៏រិតព្រំដែនធ្វើឡើងគ្រាន់តែជាវិធានការរើសអើង ប្រឆាំងនឹងប្រជាជនមួយភាគ តែអនុគ្រោះប្រជាជនមួយភាគទៀតនៃសង្គមទេនោះ ការក៏រិតព្រំដែនបែបនេះមិនអាចធ្វើបានទេ។

រាល់រដ្ឋជាភាគីទាំងឡាយ គប្បីថែងក្នុងរបាយការណ៍របស់ខ្លួននូវរាល់សេចក្តីលំអិតចំពោះការក៏រិតព្រំដែនដែលបានធ្វើ ដោយភ្ជាប់មកជាមួយនូវពតិមានទាំងឡាយអំពីវិធានការដែលនៅក្នុងនោះ លក្ខខ័ណ្ឌនៅមាត្រា ៤ ត្រូវបានបំពេញ។ ថេរវេលានៃការក៏រិតព្រំដែន គួរតែកំណត់ឱ្យនៅត្រឹមក៏រិតអប្បបរមា ហើយរបាយការណ៍គប្បីមានពតិមានលើចំណុចនេះ។

## មាត្រា ៥

### អត្ថបទមាត្រា ៥

១. គ្មានបទបញ្ញត្តិណាមួយនៃកតិកាសញ្ញានេះ ដែលត្រូវអាចបានបកស្រាយថា ភ្ជាប់សំរាប់រដ្ឋណាមួយ ក្រុមណា ឬ បុគ្គលណាម្នាក់ នូវសិទ្ធិណាមួយឱ្យធ្វើសកម្មភាព ឬបំពេញអំពើណាមួយឆ្ពោះទៅរកការបំផ្លិចបំផ្លាញសិទ្ធិ ឬសេរីភាពដែលទទួលស្គាល់ក្នុងកិកាសញ្ញានេះ ឬឆ្ពោះទៅរកការដាក់កំហិតទាំងឡាយធំទូលាយជាងការដាក់កំហិតប្រមាណទុកនៅក្នុងកតិកាសញ្ញាស្តីមកនេះ។

២. មិនអនុញ្ញាតឱ្យមានការរិតត្បិត ឬ ការធ្វើឱ្យអន់ថយលើសិទ្ធិសំខាន់ៗរបស់មនុស្សដែលត្រូវបានទទួលស្គាល់ ឬដែលនៅជាធរមានក្នុងរាល់ប្រទេសអាស្រ័យដោយច្បាប់ទាំងឡាយ ដោយអនុសញ្ញា ដោយបទបញ្ជា ឬទំនៀមទំលាប់ ដោយលើកលេសថា កតិកាសញ្ញានេះមិនបានទទួលស្គាល់សិទ្ធិទាំងនោះ ឬក៏ទទួលស្គាល់ដែរតែក៏រិតទាបណាមួយ។

### សេចក្តីអធិប្បាយ

មាត្រានេះ ដូចគ្នាបេះបិទនឹងមាត្រា ៥ នៃកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ។ មាត្រានេះមានភាពសំខាន់ដូចគ្នានៅក្នុងកតិកាសញ្ញាទាំងពីរ ហើយដូច្នេះ គេគួរតែយោងទៅការវិភាគរបស់សាស្ត្រាចារ្យ ប៉ូកា នៅក្នុងជំពូកមួយរបស់គាត់ស្តីពីកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ នៅក្នុងសៀវភៅនេះទាក់ទងបទបញ្ញត្តិចុងក្រោយ។

មាត្រានេះ មានលក្ខណៈ និងមានវិសាលភាពទូទៅ។ កថាខ័ណ្ឌ១ នៃមាត្រានេះ ប្រាថ្នារារាំងរាល់ការបកស្រាយភ័ន្តច្រឡំនូវមាត្រាណាមួយរបស់កតិកាសញ្ញា ដែលអាចបណ្តាលឱ្យមានការបំផ្លាញដល់សិទ្ធិ ឬការរឹតព្រំដែនដល់សេរីភាព និងសិទ្ធិទាំងឡាយក្នុងករណីមួយធំជាងកតិកាសញ្ញាអនុញ្ញាតឱ្យ។ កថាខ័ណ្ឌ ២ បរិយាយអំពីទំនាស់ដែលអាចមានរវាងកតិកាសញ្ញានេះ និងវិធានទាំងឡាយជាធរមាននៅក្នុងរដ្ឋជាភាគី ទោះបីវិធានទាំងនោះត្រូវបានអនុម័តយកដោយផ្ទាល់ដោយរដ្ឋជាភាគី ឬកើតចេញពីលទ្ធផលនៃកិច្ចព្រមព្រៀងអន្តរជាតិដទៃទៀតក៏ដោយ។ កតិកាសញ្ញានេះ ទទួលស្គាល់អាទិភាពនៃបទបញ្ញត្តិទាំងឡាយដែលអនុគ្រោះឱ្យមានការការពារសិទ្ធិបានច្រើនជាង។

ក្នុងករណីដែលមាត្រានេះ មានលក្ខណៈវិនិច្ឆ័យសំរាប់បកស្រាយបទបញ្ញត្តិនានានៃកតិកាសញ្ញា មាត្រានេះមិនទាមទារឱ្យមានការអនុវត្តន៍ជាក់លាក់ និងដោយឡែកនៅករណីជាតិទេ លើកលែងតែលក្ខណៈវិនិច្ឆ័យនោះត្រូវតែមានសុពលភាពនៅចំពោះមុខច្បាប់ក្នុងស្រុក ទាក់ទងនឹងការអនុវត្តន៍វិធានណាមួយទាក់ទងនឹងវិសាលភាពនៃកតិកាសញ្ញានេះ។

បណ្តារបាយការណ៍ត្រូវបង្ហាញជាទូទៅថា តើលក្ខណៈវិនិច្ឆ័យសំរាប់បកស្រាយទាំងនោះ អាចអនុវត្តបានយ៉ាងណាខ្លះនៅក្នុងរដ្ឋជាភាគី ហើយត្រូវយោងទៅលក្ខណៈវិនិច្ឆ័យទាំងនេះសំរាប់រាល់មាត្រាណាដែលការអនុវត្តន៍ជាក់ស្តែងអាចបណ្តាលឱ្យមានការបកស្រាយមាត្រានេះខុស ឬផ្ទុយនឹងច្បាប់ក្នុងស្រុកក្នុងន័យដែលបញ្ជាក់ខាងលើ។ សូមរំលឹកម្តងទៀត មាត្រា៤ នៃកតិកាសញ្ញា បទបញ្ញត្តិនៃមាត្រា ៥ កំរមានលើកឡើងដោយរដ្ឋដែលរាយការណ៍ណាស់។

## មាត្រា ៦

***អត្ថបទមាត្រា ៦***

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់នូវសិទ្ធិមានការងារធ្វើ ហើយត្រូវចាត់វិធានការថែរក្សាសិទ្ធិនេះឱ្យបានសមរម្យ ។ សិទ្ធិនេះមានរួមបញ្ចូលនូវសិទ្ធិរបស់មនុស្សគ្រប់ៗរូប ដើម្បីមានឱកាសរស់នៅចិញ្ចឹមជីវិតដោយធ្វើការងារ ដែលគេអាចធ្វើការជ្រើសរើស ឬទទួលយលព្រមដោយសេរី ។

២. វិធានការដែលរដ្ឋនិមួយៗ ជាភាគីនៃកតិកាសញ្ញានេះប្រកាន់យក ដើម្បីឱ្យបានសំរេចលទ្ធផលពេញលេញនៃសិទ្ធិនេះ ត្រូវរួមបញ្ចូលផងដែរ នូវកម្មវិធីហ្វឹកហ្វឺន និងណែនាំខាងវិស័យបច្ចេកទេស និងវិជ្ជាជីវៈ គោលការណ៍និងបច្ចេកវិធីនានា ដើម្បីសំរេចអោយបាននូវការអភិវឌ្ឍន៍ជាលំដាប់ខាងវិស័យសេដ្ឋកិច្ច វិស័យសង្គមកិច្ច និងវប្បធម៌ ព្រមទាំងមានការងារសំរាប់ឱ្យមនុស្សធ្វើអោយបានគ្រប់គ្រាន់ និងប្រកបដោយផលប្រយោជន៍ផង។ ហើយការងារទាំងនោះ ត្រូវស្ថិតនៅក្នុងល័ក្ខខ័ណ្ឌដើម្បីរក្សាការពារមូលដ្ឋានគ្រឹះនៃសេរីភាពរបស់មនុស្ស ក្នុងផ្នែកនយោបាយ និងសេដ្ឋកិច្ច ។

**អត្ថបទនៃគោលការណ៍ណែនាំអំពីមាត្រា ៦ នៃ កតិកាសញ្ញា**

១. បើសិនជាប្រទេសរបស់អ្នកជាភាគីមួយនៃអនុសញ្ញាណាមួយក្នុងបណ្តាអនុសញ្ញាដូចតទៅនេះ :

អនុសញ្ញាស្តីពីគោលនយោបាយការងារនៃអង្គការការងារអន្តរជាតិ ឆ្នាំ១៩៦៤ ( លេខ១២២)

អនុសញ្ញា ស្តីពីការរើសអើងនៃអង្គការការងារអន្តរជាតិ( ការងារ និងមុខរបរ) ឆ្នាំ១៩៥៨ ( លេខ ១១)

អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់ចោលរាល់ទំរង់ទាំងអស់នៃការរើសអើងពូជសាសន៍

អនុសញ្ញាស្តីពីការបំបាត់ចោលរាល់ទំរង់ទាំងអស់នៃការរើសអើងចំពោះស្ត្រីភេទ

ហើយបើសិនជាប្រទេសរបស់អ្នកបានដាក់ជូនរបាយការណ៍ទាំងឡាយ ជូនទៅគណកម្មាធិការត្រួតពិនិត្យ ដែលជារបាយការណ៏មានការពាក់ព័ន្ធទៅនឹងបណ្តាបទបញ្ញត្តិនៃមាត្រា ៦ អ្នកអាចនិយាយយោងទៅតាមផ្នែករៀងៗខ្លួន នៃរបាយការណ៍ទាំងនោះ ជាជាងនិយាយច្រំដែលនៅក្នុងរបាយការណ៏នេះ អំពីពតិមានដែលបានផ្តល់រួចហើយ ។ ក៏ប៉ុន្តែ គ្រប់បញ្ហាដែលកើតឡើងក្រោមកតិកាសញ្ញានេះ ហើយពុំទាន់បានថែងដោយពិស្តារនៅក្នុងរបាយការណ៍ពីមុននោះ ត្រូវតែបានរៀបរាប់នៅក្នុងរបាយការណ៏នេះ ។

២. ក. សូមផ្តល់ពតិមានអំពីស្ថានភាព អំពីកំរិត និងអំពីនិន្នាការនៃការងារ ភាពឥតការងារធ្វើ និងភាពធ្វើការងារមិនពេញកំរិតនៅក្នុងប្រទេសរបស់អ្នក ដោយបង្ហាញទាំងប្រភេទទូទៅ ទាំងប្រភេទពិសេសនៃកម្មករ ដូចជាស្ត្រី មនុស្សក្មេង ឬកម្មករចាស់ៗ ឬកម្មករពិការ ។ ក្នុងប្រភេទនីមួយៗ ចូរប្រៀបធៀប ស្ថានភាពកាលពី ១០ ឆ្នាំមុន និង ៥ ឆ្នាំមុន។ តើបណ្តាជនណា ក្រុមណា ភូមិភាគណា ឬតំបន់ណា ដែលអ្នកសន្និដ្ឋានថាទន់ខ្សោយ ឬបាត់ប្រៀបក្នុងបញ្ហាការងារនេះ ។

ខ. សូមពិពណ៌នានូវនយោបាយ និងវិធានការសំខាន់ៗដែលបានអនុម័តយក ដើម្បីធានាឱ្យមានការងារសំរាប់មនុស្សទាំងអស់ដែលនៅរង់ចាំការងារ និងកំពុងដើររកការងារ ។

គ. សូមបញ្ជាក់ពីវិធានការណ៏ទាំងឡាយដែលត្រូវបានចាត់ ដើម្បីធ្វើយ៉ាងណាឱ្យការងារផ្តល់ផលជាអតិបរមាតាមដែលអាចធ្វើបាន ។

ឃ. សូមបញ្ជាក់ថា តើបទបញ្ញត្តិណាខ្លះដែលធានាថា មានសេរីភាពក្នុងការជ្រើសរើសការងារ ហើយនិងធានាថា ល័ក្ខខ័ណ្ឌនៃការងារឥតធ្វើឱ្យប៉ះពាល់ដល់សេរីភាពខាងនយោបាយ និងខាងសេដ្ឋកិច្ចជាមូលដ្ឋានរបស់បុគ្គល ។

ង. សូមពិពណ៌នានូវកម្មវិធីនៃការហ្វឹកហ្វឺនបច្ចេកទេស និងខាងវិជ្ជាជីវៈដែលមានមកហើយនៅក្នុងប្រទេសរបស់អ្នក របៀបដំណើរការមានប្រសិទ្ធិភាពនៃកម្មវិធីទាំងនោះ និងការមានជាស្រេចហើយយកជាការបាននូវរបស់កម្មវិធីទាំងនោះ ។

ច. សូមប្រាប់ថា តើមានការជួបប្រទះនឹងការលំបាកអ្វីពិសេសដែរឬទេ ក្នុងការធ្វើឱ្យបានសំរេចគោលដៅនៃការងារពេញលេញ បានផល និងដែលជ្រើសរើសយកដោយសេរី ហើយសូមបញ្ជាក់ថា តើយើងបានពុះពារការលំបាកទាំងនេះបានដល់កំរិតណាហើយ? ។

៣. ក. សូមប្រាប់ថា តើនៅក្នុងប្រទេសរបស់អ្នក មានការបែងចែក ការបដិសេធ ការរិតត្បិត ឬ ការឱ្យអាទិភាពដល់មនុស្សណាម្នាក់ ឬក្រុមមនុស្សណាមួយ ទោះបីដោយសារការកំណត់របស់ច្បាប់ ការអនុវត្តន៏ខាងរដ្ឋបាល ឬដោយសារទំនាក់ទំនងជាក់ស្តែង ដោយមកពីពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា មតិនយោបាយ សញ្ជាតិ ឬដើមកំណើតសង្គម ដែលមានអនុភាពបំបាត់ចោល ឬធ្វើឱ្យខូចដល់ការទទួលស្គាល់ ការទទួល ឬការអនុវត្តន៏សមភាពនៃឱកាស ឬការរាប់រកក្នុងការងារ ឬក្នុងអាជីព។ តើវិធានការណាខ្លះ ដែលបានចាត់ដើម្បីបញ្ចប់រូបភាពនៃការរើសអើងទាំងនោះ? ។

ខ. សូមផ្តល់ពត៌មានអំពីស្ថានភាពជាក់ស្តែងនៅក្នុងប្រទេសរបស់អ្នក ទាក់ទងនឹងការណែនាំនិងការហ្វឹកហ្វឺនខាងវិជ្ជាជីវៈ ការងារ និងមុខរបររបស់មនុស្ស យោងទៅតាមពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា និងសញ្ជាតិ តើយ៉ាងណា? ។

គ. សូមបញ្ជាក់ប្រាប់ករណីសំខាន់ៗ នៃការបែងចែក ការបដិសេធ ឬការឱ្យអាទិភាព ផ្អែកលើល័ក្ខខ័ណ្ឌណាមួយខាងលើដែលនៅក្នុងប្រទេសរបស់អ្នកឥតត្រូវបានចាត់ទុកថា ជារូបភាពមួយនៃការរើសអើង ដោយហេតុថាវាជាលក្ខណៈតម្រូវពិសេសសំរាប់ការងារណាមួយ។ សូមបញ្ជាក់អំពីការលំបាកដែលមាន នៅក្នុងការអនុវត្តន៏ ជម្លោះ ឬវិវាទកម្ម ដែលបានកើតឡើងទាក់ទងនឹងល័ក្ខខ័ណ្ឌបែបនោះ។

៤. សូមបញ្ជាក់អំពីសមាមាត្រនៃប្រជាជនមានការងារធ្វើរបស់ប្រទេសរបស់អ្នក ដែលធ្វើការពេញពេលលើសពីមួយមុខការ ដើម្បីធានាកំរិតជីវភាពគ្រប់គ្រាន់សំរាប់ជីវភាពខ្លួនឯង និងគ្រួសារ។ សូមពិពណ៌នាការវិវត្តន៏នេះទៅតាមពេលវេលាកន្លងទៅ។

៥. សំរាប់របាយការណ៍ក្រោយៗ សូមផ្តល់សេចក្តីសង្ខេបខ្លីៗបើសិនជាមាន ពីការកែប្រែច្បាប់របស់ប្រទេសអ្នក សេចក្តីសំរេចតុលាការ ព្រមទាំងវិធាន នីតិវិធី និងការអនុវត្តផ្នែករដ្ឋបាល នៅក្នុងរយៈពេលរបាយការណ៍ ដែលមានផលប៉ះពាល់ដល់សិទ្ធិដើម្បីធ្វើការងារ។ សូមបញ្ជាក់ពីតួនាទីនិងជំនួយអន្តរជាតិដើម្បីធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិចែងនៅក្នុងមាត្រា ៦។

៦. សូមបញ្ជាក់ពីតួនាទីរបស់ជំនួយអន្តរជាតិក្នុងការធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិដែលមានចែងក្នុងមាត្រា៦។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)

## មនុស្សដែលមានពិការភាព

២០. វិស័យការងារជាវិស័យមួយដែលគេឃើញការរើសអើងដោយសារពិការភាពមានលក្ខណៈលេចធ្លោ និងមិនបាត់។ នៅក្នុងប្រទេសភាគច្រើនអត្រាគ្មានការងារធ្វើរបស់បុគ្គលមានពិការភាពខ្ពស់ជាងពីរទៅបីដងអត្រាគ្មានការងារធ្វើរបស់អ្នក គ្មានពិការភាព។ ទីណាដែលមានការផ្តល់ការងារឱ្យដល់បុគ្គលមានពិការភាពធ្វើ ពួកគេជារឿយៗធ្វើការងារដែលមានកំរៃទាប និងមានសន្តិសុខសង្គមនិងសន្តិសុខគតិយុត្តតិចតួច ហើយជាញឹកញាប់ត្រូវបានគេបំបែកចេញពីទីផ្សារពលកម្មទូទៅ។ ការធ្វើសមាហរណកម្មបុគ្គលមានពិការភាពចូលក្នុងទីផ្សារពលកម្ម រៀបរយគប្បីត្រូវបានការគាំទ្រយ៉ាងសកម្មពីរដ្ឋ។

២១. "សិទ្ធិមានឱកាសគ្រប់ៗ គ្នាក្នុងការប្រកបជីវភាពរស់នៅដោយការងារដែលគេជ្រើសរើស ឬទទួលយកដោយសេរី" (មាត្រា ៦ (១) ) គឺមិនត្រូវបានធ្វើឱ្យសំរេចឡើយ កាលណាជនពិការភាពត្រូវបានបើកឱកាសពិតប្រាកដឱ្យធ្វើការតែក្នុងទីកន្លែងដែលគេហៅថា "មជ្ឈមណ្ឌលក្រោមការឧបត្ថម្ភ" ដែលមានលក្ខខ័ណ្ឌក្រោមកំរិតស្តង់ដា។ គំរោងទាំងឡាយដែលរៀបចំឱ្យបុគ្គលមានពិការភាពមួយប្រភេទណាបានធ្វើតែមុខរបរខ្លះ ឬផលិតតែរបស់ខ្លះ អាចជាការរំលោភនូវសិទ្ធិនេះ។ ដូចគ្នាដែរ យោងតាមគោលការណ៍ទី ១៣ (៣ )នៃគោលការណ៍គាំពារជនមានជំងឺប្រសាទ និងការធ្វើឱ្យប្រសើរ ការថែទាំសុខភាពប្រសាទ"វិធីព្យាបាលរោគ" ក្នុងមន្ទីរនានាដែលស្មើនឹងពលកម្មដោយបង្ខំក៏មិនស្របជាមួយកតិកាសញ្ញានេះដែរ។ ក្នុងន័យនេះ ការហាមឃាត់ចំពោះពលកម្មដោយបង្ខំដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិស្តីពី សិទ្ធិពលរដ្ឋ និង នយោបាយ ក៏អាចមានការទាក់ទងនឹងបញ្ហាពិការភាពដូចបានពោលមកនេះដែរ។

២២. អនុលោមទៅតាមវិធានជាបទដ្ឋាន បុគ្គលមានពិការភាព ទោះបីនៅជនបទក្តី ឬទីក្រុងក្តី ត្រូវមានឱកាសស្មើគ្នាចំពោះការងារដែលមានផលិតភាព និងមានកំរៃជាប្រាក់កាសក្នុងទីផ្សារពលកម្ម។ ដើម្បីឱ្យប្រការនេះអាចសំរេចបាន ជាការសំខាន់គេត្រូវដករបាំងសិប្បនិម្មិតដើម្បីជាគុណប្រយោជន៏ដល់សមាហរណកម្ម និងសំរាប់ជាគុណប្រយោជន៏ដល់ការងារ។ ដូចដែលបានកត់សំគាល់ដោយអង្គការការងារអន្តរជាតិថា ជារឿយៗ ឧបសគ្គផ្នែករូបវន្តដែលសង្គមបានកសាងឡើងដូចជាក្នុងវិស័យដឹកជញ្ជូន, លំនៅដ្ឋាន និងកន្លែងធ្វើការ ត្រូវបានគេលើកជាមូលហេតុសំរាប់ការមិនផ្តល់ការងារអោយបុគ្គលមានពិការភាព។ ឧទាហរណ៍ កន្លែងធ្វើការដែលគេរៀបចំប្លង់និងកសាងក្នុងរបៀបម្យ៉ាងដែលធ្វើឱ្យរទេះអង្គុយចូលមិនបាននោះ និយោជកអាចមាន"មូលហេតុ" មកពន្យល់អំពីការដែលគេមិនអាចជួលអ្នកពិការដែលមានរទេះអង្គុយ។ រដ្ឋាភិបាលក៏គប្បីរៀបចំគោលនយោបាយដែលលើកស្ទួយ និងកែតំរូវទីកន្លែងឱ្យមានភាពបត់បែន និងជំនួសបានដែលជួយសំរួលឱ្យបានសមស្របទៅតាមសេចក្តីត្រូវការរបស់កម្មករមានពិការភាព។

២៣. ការខកខានរបស់រដ្ឋាភិបាលក្នុងការធានាធ្វើឱ្យមធ្យោបាយដឹកនាំ អាចប្រើប្រាស់បានដោយបុគ្គលមានពិការភាព គឺជាការកាត់បន្ថយយ៉ាងធ្ងន់ធ្ងរដល់ឱកាសសំរាប់បុគ្គលនោះក្នុងការស្វែងរកការងារដែលសមស្របនៅជាមួយអ្នកដទៃទៀតដែលមិនពិការ, ក្នុងការទទួលអត្ថប្រយោជន៍ពីការអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ ឬក្នុងការធ្វើដំណើរទៅមក។ ពិតមែនហើយ ការផ្តល់លទ្ធភាពប្រើប្រាស់ទំរង់ដឹកជញ្ជូនពិសេសសំរាប់អ្នកពិការ គឺជាការសំខាន់ និងចាំបាច់ ដើម្បីអោយបុគ្គលមានពិការភាពសំរេចបានស្ទើរតែទាំងអស់នូវសិទ្ធិដែលមានចែងក្នុងកតិកាសញ្ញានេះ។

២៤. "ការណែនាំបច្ចេកទេស និងវិជ្ជាជីវៈនិងកម្មវិធីបណ្តុះបណ្តាល" ដែលតំរូវនៅក្នុងមាត្រាទី ៦ (២ )នៃកតិកាសញ្ញានេះ ត្រូវឆ្លុះបញ្ចាំងនូវសេចក្តីត្រូវការរបស់បុគ្គលមានពិការភាពទាំងអស់, ត្រូវមាននៅទីកន្លែងធ្វើការរួមគ្នាទាំងអ្នកពិការនិងអ្នកមិនពិការ, និងត្រូវធ្វើផែនការព្រមទាំងអនុវត្តដោយមានការចូលរួមយ៉ាងពេញលេញ ពីតំណាងនៃបុគ្គលមានពិការភាព។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់**

២២. មាត្រា ៦ នៃកតិកាសញ្ញាតម្រូវឱ្យរដ្ឋជាភាគីចាត់វិធានការដ៏សមស្របនានា ដើម្បីធានាការពារសិទ្ធិរបស់មនុស្សរាល់ឱ្យបានឱកាសរកប្រាក់កាសដើម្បីចិញ្ចឹមជីវិតរបស់គេតាមរយៈការងារ ដែលគេជ្រើសរើស ឬទទួលយកដោយសេរី។ ក្នុងន័យនេះ គណៈកម្មាធិការដោយគិតឃើញថា កម្មករចាស់ៗ ដែលពុំទាន់ឈានដល់អាយុចូលនិវត្តន៍តែងតែជួបប្រទះនឹងបញ្ហាស្វែងរកនិងរក្សាការងារ ដូច្នេះក៏សង្កត់ធ្ងន់លើសេចក្តីត្រូវការឱ្យមានវិធានការដើម្បីទប់ស្កាត់ការរើសអើង ដោយសារមូលហេតុខាង អាយុ នៅក្នុងវិស័យការងារនិងមុខរបរ។

***សេចក្តីអធិប្បាយ***

សិទ្ធិដើម្បីធ្វើការមានសារសំខាន់ជាគ្រឹះមិនមែនត្រឹមតែសំរាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែព្រោះវាអាចគន្លឹះសំរាប់ការអាស្រ័យផលសិទ្ធិជាច្រើនដទៃទៀតរបស់សាមីបុគ្គលផងដែរ។ មាត្រានេះចែកចេញជាពីរផ្នែក។ ផ្នែកទីមួយពិណ៌នាអំពីសិទ្ធិដើម្បីធ្វើការខ្លួនឯង ចំណែកឯផ្នែកទីពីរវិញផ្តោតទៅលើវិធានការជាក់លាក់ផ្សេងៗ ដែលតាមរយៈវិធានការទាំងនេះ រដ្ឋជាភាគីអាចរួមចំណែកដល់ការធ្វើឱ្យបានសំរេចសិទ្ធិនេះ។

គោលការណ៍ណែនាំចែងថារដ្ឋជាភាគីនៃកតិកាសញ្ញានេះ ហើយដែលជាភាគីនៃអនុសញ្ញាអង្គការការងារអន្តរជាតិ (អ.ក.អ)លេខ ១២២ ឆ្នាំ ១៩៦៤ (អនុសញ្ញាស្តីពីគោលនយោបាយការងារ) និងលេខ ១១១ ឆ្នាំ ១៩៥៨ (អនុសញ្ញា ស្តីពីការរើសអើង, ការងារនិងមុខរបរ) ចាំបាច់ត្រូវដាក់ជូនរបាយការណ៍ទូលំទូលាយទៅគណៈកម្មាធិការទាក់ទងនឹងមាត្រានេះ។ ក្នុងករណីបែបនេះ រដ្ឋគ្រាន់តែសុំឱ្យគណៈកម្មាធិការយោងទៅសេចក្តី

អធិប្បាយណាមួយដែលរៀបរៀងដោយ គណៈកម្មាធិការអ្នកជំនាញរបស់អ.ក.អ.ទទួលបន្ទុកការអនុវត្តន៍អនុសញ្ញានិងអនុសាសន៍ (តទៅហៅថា"គណកម្មាធិការអ្នកជំនាញរបស់អ.ក.អ.)ក៏ជាការគ្រប់គ្រាន់ណាស់ទៅហើយ ដើម្បីជាកិច្ចឆ្លើយតបទៅនឹងរបាយការណ៍ដែលបាន ឬត្រូវតែបាន ដាក់ជូនទៅអ.ក.អ ដោយរដ្ឋាភិបាល។

ក្នុងករណីរដ្ឋជាភាគីមួយនៃកតិកាសញ្ញាដែលមិនបានធ្វើសច្ចាប័នអនុសញ្ញា អ.ក.អ លេខ ១២២ នោះ គណៈកម្មាធិការ ចង់បានពត៌មានអំពីកំរិតនៃអត្រាមានការងារធ្វើ អត្រាគ្មានការងារ និងអត្រាមានការងារមិនពេញលេញ។ ដើម្បីធ្វើឱ្យពត៌មាន បែបនេះចូលក្នុងបរិបទ តួលេខត្រូវតែបំបែកទៅតាមប្រភេទនានាដូចជា ស្ត្រី មនុស្សក្មេង មនុស្សចាស់ មនុស្សមានពិការភាព ហើយបើសិនជាមាន បំបែកទៅតាមសមាជិកក្រុមជនជាតិភាគតិច និងជនអន្តោគ្រាម ហើយនិងមនុស្ស ក្រុម ភូមិភាគ ឬ តំបន់ដែលត្រូវបានចាត់ទុកថាទន់ខ្សោយ ឬបាត់បង់ប្រៀបខាងការងារក៏ត្រូវបង្ហាញឱ្យឃើញដែរ។

គណៈកម្មាធិការក៏ចង់បានពត៌មានទាក់ទងនឹង យុទ្ធសាស្ត្រទូទៅដែលត្រូវបានអនុម័តយកដើម្បីកែលំអស្ថានភាពការងារ។ ដោយហេតុថាសិទ្ធិដើម្បីធ្វើការអាចត្រូវបានបដិសេធ ដោយសារគ្មានសេរីភាពជ្រើសរើស ឬទទួលយកការងារ ពត៌មានអំពីបទបញ្ញត្តិនីតិកម្ម ឬបទបញ្ញត្តិដទៃទៀតបង្កើតឡើងដើម្បីលើកស្ទួយសេរីភាពនេះក៏ត្រូវបានស្នើសុំដែរ។ ដូចគ្នាដែរ របាយការណ៍ត្រូវផ្តល់ពត៌មានលំអិតអំពីការរិតត្បិតណាមួយដែលបានដាក់បង្គាប់លើការធ្វើចលនាដោយសេរីរបស់កម្មករពីការងារមួយទៅការងារមួយទៀត និងពីកន្លែងមួយទៅកន្លែងមួយ។ ក្នុងន័យនេះ កថាខ័ណ្ឌ ១ សង្កត់ធ្ងន់ថា គោលនយោបាយ និងកម្មវិធីរបស់រដ្ឋាភិបាលត្រូវប្រព្រឹត្តទៅក្នុងលក្ខខ័ណ្ឌដែលការពារសេរីភាពនយោបាយនិងសេដ្ឋកិច្ចជាមូលដ្ឋានរបស់បុគ្គល។

កថាខ័ណ្ឌ ២ បង្ហាញឱ្យឃើញនូវវិធានការជាក់លាក់ដែលរដ្ឋជាភាគីត្រូវប្រកាន់យក ដើម្បីលើកស្ទួយការអនុវត្តឱ្យបានសំរេចនូវសិទ្ធិដើម្បីធ្វើការ។ ដូច្នេះ សូម្បីតែរដ្ឋរាយការណ៍ថាមានកំរិតអត្រាគ្មានការងារធ្វើ និងមានការងារមិនពេញលេញខ្ពស់គ្រាន់បើក៏ដោយ ហើយបន្ទោសថាបញ្ហាទាំងនេះកើតមានដោយសារស្ថានការណ៍សេដ្ឋកិច្ចពិបាកដោះស្រាយជាដើម ក៏គេនៅតែត្រូវការពត៌មានលំអិតអំពីវិធានការជាក់លាក់ដែលត្រូវបានប្រកាន់យកដើម្បីកែលំអស្ថានការណ៍នេះដែរ។ ក្នុងការផ្តល់សេចក្តីលំអិតអំពីវិធានការដែលត្រូវបានប្រកាន់យកស្របទៅតាមការតម្រូវរបស់កថាខ័ណ្ឌ ២ រដ្ឋដែលរាយការណ៍ត្រូវគូសបញ្ជាក់ពីកំរិតដែលកម្មវិធីនិងគោលនយោបាយទាំងនេះត្រូវបានបង្កើតក្នុងគោលដៅជាក់លាក់ដើម្បីឆ្លើយតបទៅនឹងបញ្ហា ពិសេសរបស់ក្រុមដែលស្ថិតក្រោមទម្រង់ណាមួយនៃការរើសអើង ឬផ្ទុយទៅវិញដែលត្រូវបាត់បង់ប្រៀប។ ដោយសារ គណៈកម្មាធិការឱ្យសារសំខាន់ដល់វិធានការដើម្បីបំបាត់ និងដោះស្រាយទម្រង់នានានៃការរើសអើង ជាពិសេសការរើសអើងចំពោះស្ត្រី មនុស្សមានពិការភាព និងមនុស្សចាស់ ហើយនិងដោយសារសិទ្ធិដែលចែងក្នុងមាត្រា ៦ ជាសិទ្ធិស្នូល បញ្ហានេះត្រូវទទួលបានការយកចិត្តទុកដាក់ជាពិសេសក្នុងការរាយការណ៍ពីមាត្រា ៦។

## មាត្រា ៧

## អត្ថបទមាត្រា ៧

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិមនុស្សរាល់រូប ក្នុងការទទួលបាននូវល័ក្ខខ័ណ្ឌការងារដែលត្រឹមត្រូវនិងអាចទទួលយកបាន ហើយដែលធានាជាពិសេសនូវ :

ក/ ប្រាក់បំណាច់ដែលជាអប្បបរមា ត្រូវផ្តល់ជូនដល់កម្មករ គ្រប់រូបនូវ :

១. ប្រាក់ថ្លៃឈ្នួលត្រឹមត្រូវយុត្តិធម៌ និងប្រាក់បំណាច់ការងារស្មើគ្នា ចំពោះការងារដែលមានតំលៃស្មើៗគ្នាដោយមិនមានការបែងចែក ជាប្រភេទការងារណាមួយឡើយ ជាពិសេសគឺត្រូវធានាឱ្យនារីបានទទួលលក្ខខ័ណ្ឌការងារដូចគ្នានិងបុរសដែរ ដោយឱ្យប្រាក់ខែស្មើគ្នានឹងបុរសចំពោះការងារដូចគ្នា ។

២. ជីវភាពរស់នៅយ៉ាងសមរម្យសំរាប់ខ្លួនឯងផង និងសំរាប់គ្រួសារផង ស្របតាមបញ្ញត្តិនៃកតិកាសញ្ញានេះ ។

ខ/ ល័ក្ខខ័ណ្ឌការងារដែលប្រកបដោយសុវត្ថិភាព និងធានាដល់សុខភាព ។

គ/ គ្រប់រូបមានឱកាសស្មើគ្នាក្នុងការទទួលបាននូវការតំលើងឋានៈនៅក្នុងការងារ សមស្របទៅតាមកំរិតកាំថ្នាក់ដោយមិនត្រូវពិចារណាទៅលើអ្វីផ្សេងក្រៅពីអតីតភាព និងសមត្ថភាពឡើយ ។

ឃ/ ការសំរាក, ការលំហែ, ការកំរិតម៉ោងពេលធ្វើការសមហេតុសមផលត្រឹមត្រូវ ការឈប់សម្រាកក្នុងថ្ងៃបុណ្យដោយមានប្រាក់កំរៃ ព្រមទាំងប្រាក់បំណាច់នៅក្នុងឱកាសថ្ងៃបុណ្យជាតិផង ។

## អត្ថបទនៃគោលការណ៍ណែនាំស្តីពីមាត្រា ៧ នៃកតិកាសញ្ញា

១. បើប្រទេសរបស់អ្នកជាភាគីណាមួយនៃអនុសញ្ញានៃអង្គការការងារអន្តរជាតិ ខាងក្រោមនេះ :

អនុសញ្ញាអំពីការកំណត់ប្រៀវត្សរអប្បបរមា ១៩៧០ (លេខ១៣១)
អនុសញ្ញាអំពីសមភាពនៃប្រាក់ឈ្នួល ១៩៥១ (លេខ ១០០)
អនុសញ្ញាអំពីការសំរាកប្រចាំសប្តាហ៍ (ឧស្សាហកម្ម) ១៩២១ (លេខ១៤)
អនុសញ្ញាអំពីការសំរាកប្រចាំសប្តាហ៍ (ពាណិជ្ជកម្ម និងការិយាល័យ) ១៩៥៧ (លេខ ១០៧)
អនុសញ្ញាអំពីថ្ងៃឈប់សំរាកដោយមានប្រាក់ឈ្នួល (សេវីរិញ) ១៩៧០ (លេខ ១៣២)
អនុសញ្ញាអំពីអធិការកិច្ចការងារ ១៩៤៧ (លេខ ៨១)
អនុសញ្ញាអំពីអធិការកិច្ចការងារ (កសិកម្ម) ១៩៦៩ (លេខ ១២៩)
អនុសញ្ញាអំពីសុវត្ថិភាព សុខភាព ក្នុងមុខរបរ ១៩៨១ (លេខ ១៥៥)

ហើយ បើប្រទេសអ្នកបានដាក់របាយការណ៍ជូនគណៈកម្មការនៃអ្នកជំនាញការទទួលបន្ទុកការអនុវត្តន៍អនុសញ្ញានិងអនុសាសន៍ របស់អង្គការការងារអន្តរជាតិ ដែលជារបាយការណ៍ទាក់ទងទៅនឹងបទបញ្ញត្តិនៃ មាត្រា ៧ រួច ហើយ អ្នកគ្រាន់តែយោងទៅផ្នែករៀងៗនៃរបាយការណ៍នោះដែលបានផ្តល់ហើយនោះទេ ជាជាងលើកពតិមាន

ដដែល១ឡើងវិញ។ ក៏ប៉ុន្តែ ចំពោះបញ្ហាទាំងអស់ដែលកើតឡើងនៅក្នុងក្របខ័ណ្ឌនៃកតិកាសញ្ញានេះ ហើយជាបញ្ហាដែលមិនបានពិពណ៌នាពេញលេញនៅក្នុងរបាយការណ៍ទាំងនោះ អ្នកត្រូវអធិប្បាយនៅក្នុងរបាយការណ៍នេះ។

២. ក. សូមផ្តល់ពតិមានអំពីវិធីសំខាន់ៗ ដែលប្រើដើម្បីកំណត់ប្រាក់ឈ្នួល។

ខ. សូមបញ្ជាក់ថា តើមានបង្កើតរបបប្រាក់ឈ្នួលអប្បបរមាដែរឬទេ ហើយបញ្ជាក់ថា តើរបបនេះអនុវត្តទៅលើក្រុមអ្នកទទួលបៀវត្សណាខ្លះ តើក្រុមនីមួយៗមានមនុស្សប៉ុន្មាននាក់ តើអាជ្ញាធរមានសមត្ថកិច្ចណាជាអ្នកកំណត់ក្រុមទាំងនោះ។ តាមច្បាប់ ឬតាមការជាក់ស្តែង តើមានអ្នកស៊ីប្រាក់ឈ្នួលណាដែលឥតត្រូវបានការពារដោយ របបប្រាក់ឈ្នួលអប្បបរមាដែរឬទេ?។

(i) តើប្រាក់ឈ្នួលអប្បបរមាទាំងនេះមានអនុភាពខាងផ្លូវច្បាប់ដែរឬទេ ហើយតើមានមធ្យោបាយអ្វីខ្លះដែល រ៉ាប់រងកុំឱ្យតម្លៃប្រាក់ឈ្នួលនេះរលាយទៅវិញ?

(ii) នៅក្នុងករិតណា ហើយដោយវិធីណាខ្លះ ដែលសេចក្តីត្រូវការរបស់កម្មករនិងគ្រួសាររបស់គេ ព្រមទាំងកត្តាសេដ្ឋកិច្ចទាំងឡាយត្រូវបានគិតដល់និងសំរបសំរួល ដើម្បីក៏រិតប្រាក់ឈ្នួលអប្បរមា?។ តើបទដ្ឋានគោលដៅ ហើយនិងគោលសំរាប់វាស់ណាខ្លះ ត្រូវបានប្រកាន់ទុកចំពោះបញ្ហានេះ?

(iii) សូមពិពណ៌នាត្រួសៗ អំពីយន្តការដែលប្រើសំរាប់កំណត់ តាមដាន និងកែតម្រូវប្រាក់ឈ្នួលអប្បបរមា។

(iv) សូមផ្តល់ពតិមានអំពីការវិវត្តន៍នៃប្រាក់ឈ្នួលមធ្យម អប្បបរមា ប្រៀបធៀបទៅនឹងការវិវត្តន៍តម្លៃជីវិតរស់នៅក្នុងរយះពេល ១០ ឆ្នាំចុងក្រោយ ៥ ឆ្នាំចុងក្រោយ និងនាបច្ចុប្បន្នកាល។

(v) សូមបញ្ជាក់ថា តើនៅការអនុវត្តន៍ របបប្រាក់ឈ្នួលអប្បបរមាត្រូវបានត្រួតពិនិត្យដោយមានប្រសិទ្ធិភាពដែរឬទេ?

គ. សូមបញ្ជាក់ថា តើនៅក្នុងប្រទេសរបស់អ្នកមានវិសមភាពក្នុងប្រាក់ឈ្នួលការងារ ចំពោះការងារមានតម្លៃស្មើគ្នា មានការល្មើសលើគោលការណ៍ "ការងារស្មើគ្នា ប្រាក់ឈ្នួលស្មើគ្នា" ហើយជាពិសេស តើល័ក្ខខ័ណ្ឌការងារចំពោះស្ត្រីចាញ់ប្រៀបល័ក្ខខ័ណ្ឌការងារចំពោះបុរសដែរឬទេ។

(i) តើវិធានការអ្វីខ្លះត្រូវបានប្រកាន់យកដើម្បីបំបាត់ការរើសអើងនេះ?។ សូមពិពណ៌នាអំពីជោគជ័យនិងបរាជ័យនៃវិធានការទាំងនោះ ចំពោះក្រុមនានាដែលត្រូវបានរើសអើង។

(ii) សូមបញ្ជាក់ថា តើវិធីអ្វីខ្លះ បើមាន ដែលត្រូវបានអនុម័តយកដើម្បីលើកស្ទួយការវាយតម្លៃការងារដោយសត្យានុម័ត ដោយផ្អែកលើសាច់ការដែលមនុស្សម្នាក់បានធ្វើ ។

ឃ. សូមបញ្ជាក់អំពីការបែងចែកចំណូលនិយោជិត ទាំងនៅក្នុងផ្នែកសាធារណៈ ទាំងផ្នែកឯកជន ដោយគិតដល់អត្ថប្រយោជន៍ជាប្រាក់ឈ្នួល និង អត្ថប្រយោជន៍មិនមែនជាប្រាក់ ។ បើសិនជាមាន សូមផ្តល់ទិន្នន័យអំពីប្រាក់ឈ្នួលនៃការងារដូចគ្នានៅក្នុងផ្នែកសាធារណៈ និង ផ្នែកឯកជន ។

៣. តើមានបទបញ្ញត្តិច្បាប់ រដ្ឋបាល ឬបទបញ្ញត្តិដទៃទៀតដែលបង្គាប់ឱ្យមានលក្ខខ័ណ្ឌអប្បបរមានៃសុខភាព និងសុវត្ថិភាពមុខរបរ ។ តើបទបញ្ញត្តិទាំងនេះត្រូវបានគេអនុវត្តឱ្យបានជាក់ស្តែងដែរឬទេ ហើយវិស័យណាខ្លះ បទបញ្ញត្តិនេះមិនអនុវត្តចំពោះ?

ក. សូមបញ្ជាក់អំពី ប្រភេទកម្មករណាខ្លះ បើសិនជាមាន ដែលត្រូវបានបដិសេធដោយច្បាប់ ចេញពីកម្មវិធីដែលមានមកស្រាប់ ហើយកម្មករប្រភេទអ្វីទៀតដែលទទួលបានអត្ថប្រយោជន៍មិនគ្រប់គ្រាន់ពីកម្មវិធីបែបនោះ ឬក៏មិនបានទទួលទាល់តែសោះ ។

ខ. សូមផ្តល់ពត៌មានជាស្ថិតិ ឬជាអ្វីផ្សេងទៀត អំពីចំនួន ប្រភេទ និងភាពញឹកញាប់នៃគ្រោះថ្នាក់ការងារ (ជាពិសេសដែលនាំឱ្យស្លាប់) និងជម្ងឺដែលបានកើតឡើងក្នុងរយៈពេលកន្លងមក (១០ឆ្នាំមុន ៥ឆ្នាំមុន ប្រៀបធៀបនឹងបច្ចុប្បន្ន) ។

៤. សូមផ្តល់ពត៌មានស្តីពីការសំរេចបានយ៉ាងពិតប្រាកដនូវគោលការណ៍ ឱកាសស្មើគ្នាក្នុងការបានតម្លើងឋានន្តរសក្តិ នៅក្នុងប្រទេសរបស់អ្នក ។

ក. តើកម្មករក្រុមណាដែលបច្ចុប្បន្ននេះ ត្រូវបានគេដកហូតឱកាសនេះ? ជាពិសេស តើស្ថានភាពរបស់ស្ត្រីយ៉ាងណាដែរ ក្នុងរឿងនេះ?

ខ. តើវិធានការអ្វីខ្លះដែលត្រូវបានប្រកាន់យកដើម្បីបំបាត់វិសមភាពនេះ? សូមពិពណ៌នាអំពីជោគជ័យ និងបរាជ័យនៃវិធានការទាំងនេះចំពោះក្រុមនានាដែលបាត់បង់អត្ថប្រយោជន៍នេះ ។

៥. សូមពិពណ៌នាអំពីច្បាប់ និងការអនុវត្តនៅក្នុងប្រទេសរបស់អ្នកអំពីការសំរាក ការលំហែ ការកំណត់ចំនួនម៉ោងធ្វើការសមរម្យ ថ្ងៃសំរាកប្រចាំដោយមានប្រាក់ឈ្នួល និងប្រាក់ថ្លៃឈ្នួលសំរាប់ថ្ងៃបុណ្យសាធារណៈ ។

ក.	សូមបញ្ជាក់ពីកត្តានិងការលំបាកទាំងឡាយដែលដែលមានផលប៉ះពាល់ដល់កំរិតនៃការបានសំរេចសិទ្ធិទាំងនេះ ។

ខ. សូមបញ្ជាក់ថា តើបណ្តាប្រភេទកម្មករណាខ្លះ ត្រូវបានច្បាប់ ឬការអនុវត្តន៍ ឬទាំងពីរយ៉ាងបដិសេធមិនឱ្យបានទទួលសិទ្ធិណាមួយក្នុងបណ្តាសិទ្ធិទាំងនេះ ។ តើវិធានការណាខ្លះដែលត្រូវបានចាត់ ឬត្រូវបានប្រមើលទុកដើម្បីកែស្ថានការណ៍បែបនេះ ។

៦. ចំពោះរបាយការណ៍ក្រោយៗ សូមផ្តល់ពតិមានត្រួសៗអំពីការកែប្រែ បើសិនជាមាន នូវច្បាប់ សេចក្តីសំរេចរបស់ តុលាការ ឬវិធាន នីតិវិធី និង ការអនុវត្តន៍ផ្នែករដ្ឋបាលក្នុងកម្លុងពេលត្រូវរាយការណ៍នេះ ហើយដែលមានផលប៉ះពាល់ដល់សិទ្ធិដើម្បីបានល័ក្ខខ័ណ្ឌការងារត្រឹមត្រូវ និងមានអំណោយផល ។

៧.	សូមបញ្ជាក់អំពីតួនាទីរបស់ជំនួយអន្តរជាតិ ដើម្បីធ្វើឱ្យបានការសំរេចពេញលេញនូវសិទ្ធិចែងក្នុងមាត្រា ៧ ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅលេខ ៥ (១៩៩៤)**

**មនុស្សដែលមានពិការភាព**

២៥.	សិទ្ធិ "ទទួលបាននូវលក្ខខ័ណ្ឌការងារយុត្តិធមិ និង អំណោយផល" (មាត្រា៧) គឺអនុវត្តចំពោះកម្មករពិការគ្រប់រូប ទោះបីជាពួកគេធ្វើការក្នុងកន្លែងស្ថិតក្នុងការឧបត្ថម្ភ ឬ ក្នុងទីផ្សារពលកម្មចំហក៏ដោយ ។ កម្មករពិការនឹងមិនអាចរងការរើសអើងអំពីប្រាក់បៀវត្ស ឬលក្ខខ័ណ្ឌការងារឯទៀតទេ បើសិនជាការងាររបស់ពួកគេស្មើគ្នាជាមួយអ្នកមិនពិការ ។ រដ្ឋជាភាគីមានការទទួលខុសត្រូវមួយដែលធានាថាពិការភាពនឹងមិនត្រូវបានគេប្រើជាលេសដើម្បីបង្កើតឱ្យមានបទដ្ឋានទាបសំរាប់ពលកម្ម ឬ សំរាប់ការផ្តល់កំរៃក្រោមប្រាក់បៀវត្សអប្បបរមាឡើយ ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅលេខ ៦ (១៩៩៥)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធមិរបស់មនុស្សចាស់**

២២.	សិទ្ធិ"ដើម្បីទទួលបាននូវលក្ខខ័ណ្ឌការងារត្រឹមត្រូវ និង មានអំណោយផល" (មាត្រា ៧ នៃកតិកាសញ្ញា) មានសារៈសំខាន់ជាពិសេសក្នុងការធានាថា កម្មករចាស់ៗត្រូវទទួលបានលក្ខខ័ណ្ឌការងារដែលមានសុវត្ថិភាពរហូតដល់ចូលនិវត្តន៍។ ជាពិសេស គេគួរតែប្រើកម្មករចាស់ៗក្នុងកាលៈទេសៈ ដែលគេអាចទាញយកផលប្រយោជន៍ឱ្យបានប្រសើរបំផុតពីបទពិសោធន៍ និង សមត្ថភាពរបស់កម្មករទាំងនោះ ។

២៣. កម្មវិធីរៀបចំសំរាប់ចូលនិវត្តន៍ត្រូវតែបានអនុវត្តនៅច្រើនឆ្នាំមុនពេលចូលនិវត្តន៍ ដោយមានការចូលរួមពីអង្គការតំណាងឱ្យនិយោជក និង កម្មករ និង អង្គភាពដទៃទៀតដែលពាក់ព័ន្ធ ដើម្បីរៀបចំកម្មករចាស់ៗ ឱ្យគេត្រៀមប្រឈមមុខនឹងស្ថានការណ៍ថ្មីរបស់គេ។ កម្មវិធីបែបនោះត្រូវផ្តល់ឱ្យកម្មករចាស់ៗជាពិសេសនូវពត៌មានស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ជនចូលនិវត្តន៍, ពីឱកាស និងលក្ខខ័ណ្ឌផ្សេងៗសំរាប់បន្តសកម្មភាពមុខរបរ ឬសំរាប់ធ្វើការងារដោយស្ម័គ្រចិត្ត, ពីមធ្យោបាយ ប្រយុទ្ធនឹងអានុភាពមិនអំណោយផលនៃជរាភាព, ពីមជ្ឈមណ្ឌល សំរាប់ការអប់រំមនុស្សធំ និង សំរាប់សកម្មភាពវប្បធម៌, និងពីការប្រើប្រាស់ពេលវេលាសំរាប់លំហែ។

## សេចក្តីអធិប្បាយ

មាត្រានេះដែលបំពេញបន្ថែមលើសិទ្ធិការងារទទួលស្គាល់នៅក្នុងមាត្រាមុន មានគោលដៅធានាថា អ្នកដែលធ្វើការត្រូវមានសិទ្ធិធ្វើការនៅក្រោមលក្ខខ័ណ្ឌត្រឹមត្រូវ និងមានអំណោយផល។ ដោយហេតុថា បញ្ហាជាក់លាក់ដែលអធិប្បាយក្នុងមាត្រានេះ ភាគច្រើនជាបញ្ហាស្ថិតក្រោមកម្មវត្ថុនៃបទដ្ឋានលំអិតរបស់ ILO គោលការណ៍ណែនាំសំរាប់ធ្វើរបាយការណ៍ចៀសវាងមិនឱ្យមានការជាន់គ្នាក្នុងការរាយការណ៍។ បណ្តាអនុសញ្ញាជាប់ទាក់ទិននេះ គឺមានអនុសញ្ញាលេខ ១៤ ឆ្នាំ១៩២១, លេខ ៨១ ឆ្នាំ ១៩៤៧, លេខ ១០០ នាឆ្នាំ១៩៥១, លេខ ១០៦ នាឆ្នាំ ១៩៥៧, លេខ១៣១ នាឆ្នាំ១៩៧០, លេខ ១៣២ នាឆ្នាំ ១៩៧០ និង លេខ ១៥៥ នាឆ្នាំ១៩៨១។ អាស្រ័យហេតុនេះ រាល់រដ្ឋដែលបានឱ្យសច្ចាប័នលើអនុសញ្ញាខ្លះ ឬទាំងអស់នៃអនុញ្ញាទាំងនេះ អាចនៅក្នុងរបាយការណ៍របស់ខ្លួន គ្រាន់តែយោងទៅវិញទៅមកលើពត៌មានដែលបានជូនទៅ គណៈកម្មការនៃអ្នកជំនាញការរបស់ ILO ហើយ អាចឆ្លើយតបទៅនឹងរាល់សេចក្តីសង្កេតធ្វើឡើងដោយគណៈកម្មាធិការនោះ។ ក៏ប៉ុន្តែ ដោយរដ្ឋជាច្រើនឥតបានឱ្យសច្ចាប័នលើអនុសញ្ញាទាំងអស់របស់ ILO រដ្ឋទាំងនោះចាំបាច់ត្រូវតែឆ្លើយ តបទៅនឹងបញ្ហាដែលលើកឡើងក្នុងសេចក្តីណែនាំទាក់ទងនឹងបញ្ហាដែលមិនបានអធិប្បាយនៅក្នុងអនុសញ្ញាដែលបានឱ្យសច្ចាប័ន។

ចំពោះបណ្តាលក្ខខ័ណ្ឌនៃការងារ បញ្ហាជាក់លាក់ទីមួយ ដែលត្រូវគិតគូរនៅក្នុងកតិកាសញ្ញាគឺបញ្ហាប្រាក់ឈ្នួល។ ជាពិសេស បណ្តារដ្ឋដែលជូនរបាយការណ៍ត្រូវ គូសបញ្ជាក់ថា តើមានប្រព័ន្ធបៀវត្សអប្បបរមា ឬទេ ហើយបើមាន តើប្រព័ន្ធនោះមានដំណើរការយ៉ាងណាដែរ និងអនុវត្តចំពោះមនុស្សណាខ្លះ។ ទំនាក់ទំនងរវាងបៀវត្សអប្បបរមា និងទឹកប្រាក់ អប្បបរមាចាំបាច់ដើម្បីដោះស្រាយសេចក្តីត្រូវការសំខាន់ៗរបស់និយោជិតម្នាក់ និងគ្រួសាររបស់គេ គឺជាចំណាប់អារម្មណ៍ពិសេសរបស់គណៈកម្មាធិការ។ ស្ថានភាពគតិយុត្តនៃការត្រូវបានបៀវត្សអប្បបរមា គប្បីត្រូវបញ្ជាក់ផងដែរ ដើម្បីអនុញ្ញាតឱ្យគណៈកម្មាធិការអាចវាយតម្លៃបានថា តើប្រព័ន្ធនោះទទួលស្គាល់សិទ្ធិមនុស្សបានដល់កំរិតណា។

បញ្ហាមួយទៀត ពិពណ៌នានៅកថាខ័ណ្ឌ ក (i) នៃមាត្រា ៧ គឺបញ្ហានៃការរើសអើង ឬក៏ថា"ការបែងចែកគ្រប់ប្រភេទ"ក្នុងល័ក្ខខ័ណ្ឌនៃការងារ។ បទបញ្ញត្តិនេះ ជាពិសេសមានគោលដៅ និងស្វែងធ្វើយ៉ាងណាឱ្យ

ស្ត្រីមាន "ការធានាថា ល័ក្ខខ័ណ្ឌការងាររបស់គេមិនអន់ជាងល័ក្ខខ័ណ្ឌការងារដែលបុរសបានទទួលនោះឡើយ" ហើយនិងធានាថា អ្នកធ្វើការទាំងអស់ពិសេសស្ត្រី ទទួលកំរៃស្មើគ្នាចំពោះការងារស្មើគ្នា។ និយាយក្នុងន័យម្យ៉ាងទៀតគឺថា គេមិនត្រូវយករឿងភេទមកធ្វើជាមូលដ្ឋានដើម្បីឱ្យប្រៀវត្សទៅបុរសបានច្រើនជាងស្ត្រីដែលធ្វើការតែមួយឬការងារស្មើគ្នានោះទេ។

បទដ្ឋានអន្តរជាតិ ខាងវិស័យការងារដែលគេមានការយកចិត្តទុកដាក់ជាយូរលង់មកហើយនោះគឺ ធ្វើយ៉ាងណាឱ្យអ្នកធ្វើការទទួលបាននូវលក្ខខ័ណ្ឌការងារដែលមានសុវត្ថិភាព និងមានសុខភាពល្អ។ វិធានការ នីតិបញ្ញត្តិ តែម្យ៉ាងនឹងមិនអាចធានាបានលក្ខខ័ណ្ឌទាំងនេះទេ ហើយដូច្នេះ រដ្ឋជាភាគីត្រូវបញ្ជាក់ថា តើវិធានការបែបនេះត្រូវបានជំរុញឱ្យមានតាមរយៈគោលនយោបាយនិងកម្មវិធីផ្សេងទៀតដែរឬទេ។ បើនិយាយតាមផ្លូវច្បាប់ របាយការណ៍ត្រូវបញ្ជាក់ថា តើមានកម្មករប្រភេទណាខ្លះ ដែលត្រូវបានបដិសេធមិនឱ្យទទួលអត្ថប្រយោជន៍ពីរបបសុវត្ថិភាពការងារ និងសុខភាព ឬក៏ទទួលតែភាគខ្លះប៉ុណ្ណោះ។ បើនិយាយពីផ្លូវជាក់ស្តែងវិញ របាយការណ៍ ត្រូវបញ្ជាក់ពីប្រភេទ និងភាពញឹកញាប់នៃគ្រោះថ្នាក់ការងារ និងជំងឺកើតចេញពីកន្លែងធ្វើការ ហើយត្រូវផ្តល់តួលេខប្រៀបធៀបគ្នាក្នុងរយៈពេលមួយ ដើម្បីបង្ហាញឱ្យឃើញពីការវិវត្តន៍នៃស្ថានការណ៍។

គោលការណ៍នៃឱកាសស្មើគ្នាដើម្បីបានតម្លើងឋានន្តរសក្តិត្រូវបានបង្កើតឡើងដើម្បីធានាថា កត្តាខាងក្រៅនិងមិនសមស្រប ដូចជាកត្តាផ្នែកភេទ ឬដើមកំណើតពូជសាសន៍ គឺមិនត្រូវធ្វើជាឧបសគ្គធ្វើឱ្យបាត់បង់កម្មករទូទៅបាត់បង់លទ្ធភាពដើម្បីបានគេតម្លើងឋានន្តរសក្តិឱ្យនោះទេ។ ដោយសារមានការពិបាកក្នុងការវាស់វែងបញ្ហានេះតាមរយៈសកម្មភាពនីតិបញ្ញត្តិ របាយការណ៍ត្រូវផ្តោតជាពិសេសទៅលើការវាយតម្លៃស្ថានការណ៍ជាក់ស្តែងទាក់ទងនឹងស្ត្រី ក្រុមជនភាគតិច និងក្រុមដទៃទៀតដែលអាចបាត់បង់ប្រៀបក្នុងរឿងនេះ។

ផ្ទុយទៅវិញ ពតិមានអំពីបទបញ្ញត្តិគតិយុត្តិ និងរដ្ឋបាល ទាក់ទងនឹងមាត្រា ៧ (ឃ)--គឺបានដល់ការសំរាក ការលំហែ ចំនួនម៉ោងធ្វើការសមស្រប ថ្ងៃឈប់សំរាកដោយមានប្រាក់ឈ្នួល និងថ្លៃឈ្នួលសំរាប់បុណ្យជាតិជាដើម--គឺជាពតិមានមានតំលៃសម្បើមណាស់។ ជាពិសេស របាយការណ៍ត្រូវបញ្ជាក់ថា តើមានកម្មករប្រភេទណាខ្លះដែលមិនបានទទួលផលប្រយោជន៍ពីបទបញ្ញត្តិក៏សមស្រប។

សិទ្ធិដើម្បីបានលក្ខខ័ណ្ឌត្រឹមត្រូវនិងមានអំណោយផលខាងការងារ ក៏ត្រូវបានការពារដោយមាត្រា ៥ (ង)(i)នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងខាងពូជសាសន៍ និងមាត្រា ១១(១)(ឃ និង ច) និងមាត្រា១១(២) និង១១(៣) នៃអនុសញ្ញាស្តីពីការរើសអើងប្រឆាំងនឹងស្ត្រី។ មន្ត្រីធ្វើរបាយការណ៍ត្រូវចងចាំទុកក្នុងចិត្តនូវបទបញ្ញត្តិទាំងនេះ ក្នុងការសំរេចថា តើរបាយការណ៍របស់រដ្ឋជាភាគីអាចយោងមួយភាគទៅឯពតិមានដែលបានផ្តល់រួចហើយនៅក្នុងរបាយការណ៍ដទៃដែរឬទេ។

## មាត្រា ៨

**អត្ថបទមាត្រា ៨**

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះ ត្រូវធានាអោយបាននូវ :

ក/ សិទ្ធិចំពោះជនគ្រប់រូបក្នុងការបង្កើតសហជីព ឬចូលរួមនៅក្នុងសហជីពពាណិជ្ជកម្មណាមួយតាមការជ្រើសរើសរបស់គេ ដោយផ្អែកតាមតែវិធានការរបស់អង្គការសាម៉ីតែប៉ុណ្ណោះ ដើម្បីលើកស្ទួយ និងការពារផលប្រយោជន៍របស់គេក្នុងវិស័យសង្គម និងសេដ្ឋកិច្ច ។ មិនត្រូវមានការរឹតត្បិតលើការអនុវត្តសិទ្ធិខាងលើនេះ ក្រៅអំពីលក្ខខ័ណ្ឌដែលច្បាប់បានចែង ហើយដែលជាការចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីផលប្រយោជន៍ ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសម្រាប់ការពារដល់សិទ្ធិ និងសេរីភាពអ្នកដទៃតែប៉ុណ្ណោះ ។

ខ/ សិទ្ធិនៃសហជីពពាណិជ្ជកម្មនានា ក្នុងការបង្កើតជាសហព័ន្ធជាតិ ឬសហព័ន្ធរួម ព្រមទាំងសិទ្ធិរបស់សហព័ន្ធក្នុងការបង្កើត ឬចូលរួមនៅក្នុងអង្គការសហជីពពាណិជ្ជកម្មអន្តរជាតិនានាផងដែរ ។

គ/ សិទ្ធិនៃសហជីពដើម្បីដំណើរការដោយសេរី និងគ្មានការិតត្បិតដែនអ្វីក្រៅអំពីល័ក្ខខ័ណ្ឌដែលច្បាប់កំណត់ ហើយដែលជាការចាំបាច់ នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីជាប្រយោជន៍ដល់សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសំរាប់ ការពារ ដល់សិទ្ធិ និងសេរីភាពអ្នកដទៃ ។

ឃ/ សិទ្ធិដើម្បីធ្វើកូដកម្ម អោយតែកូដកម្មនេះប្រព្រឹត្តទៅ អនុលោមតាមច្បាប់របស់ប្រទេសណាមួយ ។

២. មាត្រា ៨ នេះ មិនអាចខាឃាំងនូវការដាក់ល័ក្ខខ័ណ្ឌតាមផ្លូវច្បាប់ ដើម្បីហាមឃាត់សមាជិកនៃកងទ័ព ឬភ្នាក់ងារនគរបាល ឬភ្នាក់ងាររដ្ឋការ មិនអោយប្រើប្រាស់សិទ្ធិអស់ទាំងនេះបានឡើយ ។

៣. គ្មានប្រការណាមួយក្នុងមាត្រា ៨ នេះ អនុញ្ញាតអោយរដ្ឋទាំងឡាយដែលជាភាគីនៃអនុសញ្ញាអង្គការការងារអន្តរជាតិឆ្នាំ ១៩៤៨ ស្តីពីសេរីភាពក្នុងការរួមគ្នាជាសមាគម និងការពារសិទ្ធិក្នុងការរៀបចំជាសមាគមដាក់វិធានខាងផ្លូវច្បាប់ណាដែលមានការប៉ះពាល់ ឬយកច្បាប់ទៅប្រើតាមរបៀបណា ដែលអាចប៉ះពាល់ដល់ការធានាដូចដែលមានចែងនៅក្នុងកតិកាសញ្ញានេះឡើយ ។

## អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ៨ នៃតិកាសញ្ញា

១. បើប្រទេសរបស់អ្នកជាភាគីនៃអនុសញ្ញាខាងក្រោមនេះ :

កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

អនុសញ្ញានៃអង្គការការងារអន្តរជាតិស្តីពីសេរីភាពខាងការបង្កើតសមាគម និងការពារសិទ្ធិ រៀបចំ ១៩៤៨ ( លេខ ៨៧ )

អនុសញ្ញានៃអង្គការការងារអន្តរជាតិ ស្តីពីសិទ្ធិចាត់តាំងនិងចរចាជាសមូហភាព១៩៤៩ ( លេខ៩៨ )

អនុសញ្ញានៃអង្គការការងារអន្តរជាតិ ស្តីពីទំនាក់ទំនងការងារ ( សេវាសាធារណៈ ) ១៩៧៨ ( លេខ១៥១ )

ហើយបើប្រទេសរបស់អ្នកបានដាក់ជូនរបាយការណ៍ទាំងឡាយ ជូនគណៈកម្មាធិការត្រួតពិនិត្យដែលពាក់ព័ន្ធ ហើយដែលជារបាយការណ៍ពាក់ព័ន្ធទៅនឹងបទបញ្ញត្តិមាត្រា ៨ រួចដែរហើយនោះ អ្នកគ្រាន់តែយោងទៅផ្នែកនានាដែលទាក់ទងនៃរបាយការណ៍នោះបានហើយ មិនចាំបាច់និយាយដដែលៗនៅទីនេះអំពីពត៌មានដែលបានផ្តល់រួចហើយនោះទេ។ ក៏ប៉ុន្តែ រាល់បញ្ហាដែលចោទឡើងអំពីកត់តិកាសញ្ញានេះ ហើយពុំទាន់ត្រូវបានអភិប្រាយយ៉ាងពេញលេញនៅក្នុងរបាយការណ៍ទាំងនោះនៅឡើយទេនោះ អ្នកត្រូវអត្ថាធិប្បាយនៅក្នុងរបាយការណ៍នេះ។

២. សូមបញ្ជាក់ បើសិនជាមាន ថាតើ ល័ក្ខខ័ណ្ឌជាខ្លឹមសារ ឬជាទម្រង់អ្វីខ្លះដែលត្រូវបំពេញដើម្បីបង្កើតសហជីព ឬដើម្បីចូលជាសមាជិកសហជីពដែលខ្លួនពេញចិត្ត។

ក) សូមបញ្ជាក់ ថាតើ មានបទបញ្ញត្តិពិសេសខាងច្បាប់ដែលឃុំគ្រងលើការបង្កបង្កើតសហជីពដោយកម្មករប្រភេទខ្លះដែរឬទេ ហើយសូមបញ្ជាក់ដែរថា តើបទបញ្ញត្តិពិសេសនោះជាទូទៅ គេបានអនុវត្តយ៉ាងណាដែរក្នុងផ្លូវជាក់ស្តែង ព្រមទាំងចំនួនមនុស្សដែលស្ថិតក្រោមបទបញ្ញត្តិទាំងនោះ។

ខ) តើមានការរិតត្បិតទៅលើការអនុវត្តសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពដោយកម្មករដែរឬទេ?។ សូមរៀបរាប់យ៉ាងល្អិតល្អន់ពីបទបញ្ញត្តិខាងច្បាប់ដែលបង្គាប់ឱ្យមានការរិតត្បិតទាំងនោះ ព្រមទាំងការអនុវត្តន៍បទបញ្ញត្តិទាំងនោះនៅក្នុងការជាក់ស្តែងក្នុងរយៈពេលកន្លងមក។

គ) សូមផ្តល់ពត៌មាន ពីរបៀបដែលរដ្ឋាភិបាលរបស់អ្នកធានាសិទ្ធិរបស់សហជីពដើម្បីបង្កើតជាសហព័ន្ធ និងសិទ្ធិចូលរួមក្នុងអង្គការសហជីពអន្តរជាតិ។ តើមានការរិតត្បិតខាងច្បាប់ និងខាងការអនុវត្តន៍អ្វីខ្លះដែលដាក់ទៅលើការប្រើប្រាស់សិទ្ធិនេះ?។

ឃ) សូមបញ្ជាក់យ៉ាងល្អិតល្អន់នូវល័ក្ខខ័ណ្ឌ ឬការរិតត្បិតដែលដាក់លើសិទ្ធិរបស់សហជីពក្នុងការប្រព្រឹត្តទៅដោយសេរី។ តើសហជីពណាខ្លះ ដែលក្នុងការជាក់ស្តែងត្រូវបានប៉ះពាល់ដោយការរិតត្បិត ឬល័ក្ខខ័ណ្ឌទាំងនេះ?។ តើមានវិធានការអ្វីខ្លះ ដែលកំពុងចាត់ដើម្បីលើកស្ទួយការចរចាជាសមូហភាព?។

ង) សូមផ្តល់ទិន្នន័យស្តីពី ចំនួន និង រចនាសម្ព័ន្ធនៃសហជីពទាំងឡាយដែលបានរៀបចំរួចនៅក្នុងប្រទេសរបស់អ្នក ព្រមទាំងសមាជិកភាពនៃសហជីពនីមួយៗ។

៣. សូមបញ្ជាក់ថា តើនៅក្នុងប្រទេសរបស់អ្នក សិទ្ធិធ្វើកូដកម្មរបស់កម្មករត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ ឬដោយច្បាប់ដែរឬទេ។ បើសិនជាឥតមានការទទួលស្គាល់ទេ តើមានច្រកដោះស្រាយតាមផ្លូវច្បាប់ ឬជាក់ស្តែងដទៃទៀត ដើម្បីធានាការអនុវត្តន៍សិទ្ធិនេះដែរឬទេ?។

ក) តើមានការដាក់កំហិតលើការអនុវត្តន៍សិទ្ធធ្វើកូដកម្មដែរឬទេ?។ សូមពិពណ៌នាដោយល្អិត ល្អន់ពីបទបញ្ញត្តិខាងច្បាប់ដែលឃុំគ្រងការដាក់កំហិតនោះ ហើយនិងការអនុវត្តន៍បទបញ្ញត្តិនោះនៅក្នុងការជាក់ស្តែងក្នុងរយៈពេលកន្លងមក។

ខ) សូមបញ្ជាក់ថា តើមានបទបញ្ញត្តិខាងច្បាប់ពិសេសទាក់ទងនឹងការប្រើប្រាស់សិទ្ធិធ្វើកូដកម្មដោយប្រភេទកម្មករខ្លះៗដែរឬទេ? ហើយបទបញ្ញត្តិទាំងនេះជាអ្វីខ្លះ តើបទបញ្ញត្តិទាំងនេះត្រូវបានអនុវត្តយ៉ាងណាដែរក្នុងផ្លូវជាក់ស្តែង ព្រមទាំងបញ្ជាក់ពីចំនួនកម្មករដែលស្ថិតក្រោមបទបញ្ញត្តិទាំងនេះ។

៤. សូមបញ្ជាក់ថា តើកងប្រដាប់អាវុធ ប៉ូលីស ឬរាជការសាធារណៈរបស់រដ្ឋ កំហិតលើការប្រើប្រាស់សិទ្ធិទាំងឡាយដែលចែងនៅកថាខ័ណ្ឌ ៣ និង ៣ ខាងលើដែរឬទេ? នៅក្នុងការជាក់ស្តែង តើគេអនុវត្តការរិតត្បិតនេះយ៉ាងណាដែរ?។

៥. ចំពោះរបាយការណ៍ក្រោយៗ សូមផ្តល់ពត៌មានគ្រួសៗអំពីការកែប្រែ បើសិនជាមាន នូវច្បាប់ជាតិ សេចក្តីសំរេចរបស់តុលាការ ឬវិធាន នីតិវិធី និង ការអនុវត្តន៍ផ្នែករដ្ឋបាលក្នុងកម្លុងពេលត្រូវរាយការណ៍នេះ ដែលមានផលដល់សិទ្ធិចែងក្នុងមាត្រា ៨។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)

## មនុស្សដែលមានពិការភាព

២៦. សិទ្ធិពាក់ពន្ធ័នឹងសហជីព (មាត្រា៨) ត្រូវអនុវត្តស្មើភាពគ្នាចំពោះអ្នកធ្វើការមានពិការភាព និងដោយមិនថាគេធ្វើការនៅមណ្ឌលពិសេស ឬនៅក្នុងទីផ្សារពលកម្មទូទៅឡើយ។ បន្ថែមពីនេះ មាត្រាទី ៨ ដោយអានរួមជាមួយសិទ្ធិផ្សេងទៀត ដូចជាសិទ្ធិស្តីអំពីសេរីភាពក្នុងការបង្កើតសមាគមជាដើម យកចិត្តទុកដាក់លើសារៈសំខាន់នៃសិទ្ធិបុគ្គលមានពិការភាពក្នុងការបង្កើតអង្គការផ្ទាល់របស់គេ។ បើសិនជាចង់អោយអង្គការទាំងនេះ មានប្រសិទ្ធភាពក្នុងការ" លើកស្ទួយនិងការពារផលប្រយោជន៍សេដ្ឋកិច្ច និងសង្គម" (មាត្រាទី៨ (១)(៩) នៃអ្នកទាំងនោះ អង្គការរដ្ឋាភិបាល និងអង្គការដទៃត្រូវពិគ្រោះយោបល់ជាទៀងទាត់ជាមួយពួកគេលើបញ្ហាដែលប៉ះពាល់ដល់ពួកគេ។ វាជាការចាំបាច់ផងដែរដែលអង្គការទាំងនោះគេត្រូវទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ និងផ្នែកផ្សេងទៀតសំដៅធានាការរស់រានរបស់ខ្លួន។

២៧. អង្គការពលកម្មអន្តរជាតិបានរៀបចំឧបករណ៍ដ៏មានតំលៃ និងគ្រប់ជ្រុងជ្រោយពាក់ពន្ធ័និងសិទ្ធិការងារ របស់បុគ្គលមានពិការភាពរួមមានអនុសញ្ញាលេខ ១៥៩ (១៩៨៣) ទាក់ទងនឹងការស្តារវិជ្ជាជីវៈ និងការងារ របស់បុគ្គលមានពិការភាព។ គណៈកម្មាធិការជំរុញលើកទឹកចិត្តរដ្ឋជាភាគីនៃកតិការសញ្ញាឱ្យពិចារណាផ្តល់សច្ចាប័នដល់អនុសញ្ញានោះ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)**

២៥. សិទ្ធិទាំងឡាយដែលត្រូវបានការពារដោយមាត្រា ៨ នៃកតិកាសញ្ញា ពោលគឺសិទ្ធិខាងការបង្កើតសហជីព ដោយរាប់បញ្ចូលក្រោយពីអាយុចូលនិវត្តន៍ផងដែរនោះ ត្រូវតែអនុវត្តបានចំពោះកម្មករចាស់ៗដែរ។

**សេចក្តីអធិប្បាយ**

សិទ្ធិដើម្បីបង្កើតនិងចូលរួមសហជីពដែលទទួលស្គាល់នៅក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ គឺបានការ"ធានា"ពីរដ្ឋជាភាគីដែរ ហើយដូច្នេះ សិទ្ធិនេះមិនស្ថិតនៅក្រោមគោលការណ៍នៃការសំរេចបានសិទ្ធិជាលំដាប់នោះទេ។ ការបញ្ចូលសិទ្ធិនេះ នៅក្នុងកតិកាសញ្ញានេះ ផ្តល់នូវឧទាហរណ៍ដ៏ល្អមួយនៃការពឹងផ្អែកគ្នាទៅវិញទៅមកនៃសំណុំសិទ្ធិទាំងពីរយ៉ាង(គឺសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ និងសិទ្ធិពលរដ្ឋនិងនយោបាយ) ព្រមទាំងជាឧទាហរណ៍នៃភាពសប្បនិមិត្តនៃការប៉ុនប៉ងចាត់សំណុំមួយឱ្យមានលក្ខណៈខុសគ្នានឹងសំណុំមួយទៀត។

នៅក្នុងគោលការណ៍ណែនាំធ្វើរបាយការណ៍របស់ខ្លួន គណៈកម្មាធិការបានកត់សំគាល់ឃើញថា រដ្ឋជាភាគីនានានៃកតិកាសញ្ញា ហើយដែលជាភាគីនៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ និង/ឬ អនុសញ្ញា ILO លេខ ៨៧ ឆ្នាំ១៩៥៨ ឬលេខ ៩៨ ឆ្នាំ១៩៤៩ ផងដែរនោះ អាចនិយាយយោងទៅរបាយការណ៍នានាទាក់ទងនឹងកតិកាសញ្ញានិង/ឬ អនុសញ្ញាទាំងនោះ ជាជាងរាយការណ៍ឡើងវិញនូវពត៌មានដដែលនៅក្នុងបរិបទនេះ។ ដូចគ្នាដែរ មន្ត្រីធ្វើរបាយការណ៍ក៏អាចគិតថាមាត្រា ៥ (ង)(ii) នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ ការរើសអើងពូជសាសន៍ក៏មានពណ៌នាអំពីសិទ្ធិសហជីពដែរ។

ក៏ប៉ុន្តែ សូម្បីតែរដ្ឋនានាជាភាគីនៃឧបករណ៍ទាំងអស់នោះទៀតក៏ដោយ រដ្ឋទាំងនោះនៅតែចាំបាច់ត្រូវផ្តល់ពត៌មានស្តីពីបញ្ហាមួយចំនួនដែលទាក់ទងនឹងបញ្ហាទាំងនេះ បទបញ្ញត្តិនៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ខុសគ្នាពីបទបញ្ញត្តិនៃឧបករណ៍ទាំងនោះ។ ជាពិសេស ករណីនេះមានចំពោះសិទ្ធិធ្វើកូដកម្មដែលទទួលស្គាល់នៅក្នុងមាត្រា ៨ (១)(ឃ) ដែលមិនបានចែងជាក់ច្បាស់នៅក្នុងកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឬនៅក្នុងអនុសញ្ញា ILO ទាំងឡាយដែលទាក់ទង។ ដូច្នេះ រដ្ឋដែលធ្វើរបាយការណ៍ទាំងអស់ត្រូវបញ្ជាក់ថា តើសិទ្ធិធ្វើកូដកម្មទទួលបានកិច្ចគាំពារខាងធម្មនុញ្ញ ខាងនីតិបញ្ញត្តិ ឬផ្នែកដទៃទៀតដែរឬទេ ហើយបើ

បានទទួល តើមានក្រុមណាដែលត្រូវបានបដិសេធ មិនឱ្យទទួលអត្ថប្រយោជន៍ពីកិច្ចគាំពារនេះដែរឬ ទេ?។ ក្នុងករណីដែលអាចមានការរិតត្បិតលើការអនុវត្តសិទ្ធិធ្វើកូដកម្ម របាយការណ៍ត្រូវបញ្ជាក់ពីមូលដ្ឋាន និងលក្ខណៈនៃការរិតត្បិតនោះព្រមទាំងផ្តល់សេចក្តីលំអិតនោះក្នុងកម្លុងពេលនៃការពិនិត្យមើលនេះ។ បើសិនជា សិទ្ធិធ្វើកូដកម្មរបស់សមាជិកកម្លាំងប្រដាប់អាវុធ ប៉ូលីស មន្ត្រីសាធារណៈ ឬនិយោជិត នៃសហគ្រាសសាធារណៈ ត្រូវបានរិតត្បិតតាមវិធីណាមួយនោះ សូមផ្តល់ពត៌មានលំអិតពីរឿងនេះនៅក្នុងរបាយការណ៍ផងដែរ។ ពត៌មានត្រូវគ្របដណ្តប់ទាំងស្ថានភាពនៅក្នុងច្បាប់ ទាំងស្ថានភាពនៅក្នុងការអនុវត្តន៍ជាក់ស្តែង។

ក្នុងករណីដែលរដ្ឋជាភាគីមិនទាន់បានផ្តល់ពត៌មានអំពីសិទ្ធិបង្កើត និងចូលរួមសហជីពនៅឡើយតាមរយៈរបាយការណ៍ទាំងឡាយដែលដាក់ជូនតាមការតំរូវរបស់កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ ឬអនុសញ្ញា ILO នានាដែលទាក់ទងនោះ រដ្ឋជាភាគីត្រូវបញ្ចូលពត៌មានមួយចំនួនធំទាក់ទងខាងផ្លូវច្បាប់ និងខាងផ្លូវអនុវត្តជាក់ស្តែង នៅពេលធ្វើរបាយការណ៍ទាក់ទងនឹងមាត្រានេះ។

ត្រូវផ្តល់ពតិមានអំពីលក្ខខ័ណ្ឌដែលត្រូវតែបំពេញមុននឹងបុគ្គលនានាត្រូវបានអនុញ្ញាតឱ្យចូលរួម ឬបង្កើតសហជីពតាមការជ្រើសរើសរបស់គេ។ បើមានសហជីពតែមួយ ឬតែមួយចំនួនតូចនៅក្នុងប្រទេស នេះជាភស្តុតាងចំពោះមុខដែលបង្ហាញឱ្យឃើញថា មានការរិតត្បិតជាដុំកំភួន តាមបែបផ្លូវការ ឬមិនផ្លូវការ ឬទាំងពីរ។ ដូច្នេះពតិមានឆ្លើយតបនឹងបញ្ហានេះ ត្រូវបញ្ចូលក្នុងរបាយការណ៍ដែរ។ ស្ថានភាពខាងផ្លូវច្បាប់ និងខាងផ្លូវអនុវត្តជាក់ស្តែងនៃផ្នែកសាធារណៈ និងនិយោជិតប្រភេទពិសេសដទៃទៀតទាក់ទងនឹងសិទ្ធិបង្កើត និងចូលរួមសហជីពក៏ត្រូវបញ្ជាក់ដែរ។ កតិកាសញ្ញានេះ ចែងបញ្ជាក់ថា ការអនុវត្តសិទ្ធិនេះ មិនត្រូវស្ថិតក្រោមការរិតត្បិតអ្វីទាំងអស់លើកលែង តែការរិតត្បិតនោះត្រូវតាមលក្ខណៈវិនិច្ឆ័យនានាដែលចែងនៅក្នុងមាត្រា ៤ និងមាត្រា ៨(១)(ក)នៃកតិកាសញ្ញានេះ។ ដូច្នេះ ការរិតត្បិតត្រូវតែ : (១) បញ្ញត្តិដោយច្បាប់ហើយមិនមែនដោយមធ្យោបាយណាក្រៅច្បាប់ ឬមិនស្របតាមធម្មនុញ្ញនោះទេ ហើយនិង(២)ចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ដើម្បីឱ្យបានសំរេចគោលដៅមួយចំនួនតូចប៉ុណ្ណោះ។ គោលដៅទាំងនោះគឺ : (១)ការពារសន្តិសុខជាតិ (២)ការពារសណ្តាប់ធ្នាប់សាធារណៈ (៣)ការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ។ ពាក្យសំខាន់នៅទីនេះគឺពាក្យ"ចាំបាច់"។ និយាយម្យ៉ាងទៀត គឺថា ការដែលរដ្ឋជាភាគីគ្រាន់តែលើកយកហេតុផលខ្លះនៃហេតុផលទាំងអស់ដែលរៀបរាប់ខាងមុននេះ ដើម្បីធ្វើការរិតត្បិតនោះ គឺមិនគ្រប់គ្រាន់ទេ។ ផ្ទុយទៅវិញ របាយការណ៍របស់រដ្ឋត្រូវបង្ហាញឱ្យឃើញថាការរិតត្បិតដែលដាក់នោះត្រូវតែចាំបាច់ ហើយសមាមាត្រទៅនឹងការគំរាមកំហែងដែលគេរកឃើញ។ សេចក្តីតំរូវដូចគ្នានេះអនុវត្តចំពោះ ការរិតត្បិតណាដែលដាក់ដោយរដ្ឋាភិបាលទៅលើសិទ្ធិរបស់សហជីព ដើម្បីដំណើរការមុខងាររបស់គេដោយសេរី។

ជាទីបញ្ចប់ របាយការណ៍ទាក់ទងនឹងមាត្រានេះ ត្រូវផ្តល់ពតិមានអំពីរបៀបដែលរដ្ឋាភិបាលបានស្វែងរកធានាសិទ្ធិរបស់សហជីព ដើម្បីបង្កើតសហព័ន្ធ និងចូលរួមក្នុងអង្គការសហជីពអន្តរជាតិ និងផ្តល់ពតិមានអំពីថាតើមានការរិតត្បិតខាងផ្លូវច្បាប់ ឬផ្លូវអនុវត្តជាក់ស្តែង ឬទេ ក្នុងរឿងនេះ?។

## មាត្រា៩

### អត្ថបទនៃមាត្រា ៩

រដ្ឋជាភាគីទាំងឡាយនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា មនុស្សគ្រប់រូប មានសិទ្ធិដើម្បីមានសន្តិសុខសង្គម រួមទាំង ការធានារ៉ាប់រងសង្គមផង ។

### អត្ថបទនៃគោលការណ៍ណែនាំស៊ីពីមាត្រា ៩ នៃកតិកាសញ្ញា

១. បើសិនជាប្រទេសរបស់អ្នក ជាភាគីនៃអនុសញ្ញានៃអង្គការការងារអន្តរជាតិស្តីពីសន្តិសុខសង្គម (បទដ្ឋានអប្បបរមា)១៩៥២(លេខ១០២) ឬជាភាគីនៃអនុសញ្ញាពាក់ព័ន្ធក្រោយៗមកទៀតនៃអង្គការការងារអន្តរជាតិ (លេខ១២១, ១២៨, ១៣០ និង១៦៨) ហើយបើសិនជាប្រទេសរបស់អ្នកបានបញ្ជូន ទៅសាមីគណៈកម្មការត្រួត

ពិនិត្យនូវរបាយការណ៍ទាក់ទងទៅនឹងបណ្តាបទបញ្ញត្តិនៃមាត្រា៩អ្នកមិនបាច់និយាយដដែលៗនៅទីនេះអំពីពត៌មានណាដែលបានផ្តល់រួចហើយនោះទេ សូមគ្រាន់តែនិយាយយោងទៅផ្នែកនានាដែលទាក់ទងនៃរបាយការណ៍ទាំងនោះ។ ប៉ុន្តែ ចំពោះបញ្ហាទាំងឡាយណាដែលកើតឡើងនៅក្នុងក្របខ័ណ្ឌនៃកតិកាសញ្ញានេះ ហើយដែលជាបញ្ហាមិនទាន់បរិយាយយ៉ាងពេញលេញនៅក្នុងរបាយការណ៍ទាំងនោះនៅឡើយទេនោះ បញ្ហាទាំងនេះត្រូវតែបាននិយាយនៅក្នុងរបាយការណ៍នេះ។

២. សូមបញ្ជាក់ថា តើក្នុងចំណោមសាខានៃសន្តិសុខសង្គមដែលរាប់ខាងក្រោមនេះ សាខាណាខ្លះដែលមាននៅក្នុងប្រទេសរបស់អ្នក :

- ការថែទាំផ្នែកពេទ្យ
- ប្រាក់បំណាច់ក្នុងពេលមានជម្ងឺ
- ប្រាក់បំណាច់សំរាប់ពេលសំរាលកូន
- ប្រាក់បំណាច់ក្នុងពេលចាស់ជរា
- ប្រាក់បំណាច់នៃពិការភាព
- ប្រាក់បំណាច់សំរាប់អ្នករស់បន្តពីមេគ្រួសារ
- ប្រាក់បំណាច់សំរាប់ការគ្រោះថ្នាក់ការងារ
- ប្រាក់បំណាច់សំរាប់ពេលគ្មានការងារធ្វើ
- ប្រាក់បំណាច់គ្រួសារ។

៣. ចំពោះសាខាមួយៗដែលមាន សូមពិពណ៌នាអំពីលក្ខណៈសំខាន់ៗនៃរបបកំពុងអនុវត្ត ដោយគូសបញ្ជាក់ពីទំហំនៃការគ្របដណ្តប់ទាំងទូទៅដោយគិតជារួម និងបំបែកទៅតាមក្រុមផ្សេងៗក្នុងសង្គមអំពី ប្រភេទ និងកំរិតនៃប្រាក់បំណាច់ និងវិធីហិរញ្ញប្បទានរបបទាំងនេះ។

៤. សូមបញ្ជាក់ថា តើចំណាយសំរាប់សន្តិសុខសង្គមត្រូវជាប៉ុន្មានភាគរយនៃផលិតផលជាតិសារុបរបស់ប្រទេសអ្នក និង/ឬ ប៉ុន្មានភាគរយនៃថវិកាតំបន់។ ចុះបើប្រៀបធៀបទៅនឹង ១០ ឆ្នាំ មុនយ៉ាងណាដែរ? បើសិនជាមានការខុសគ្នា តើមកពីមូលហេតុអ្វី? ។

៥. សូមបញ្ជាក់ថា នៅក្នុងប្រទេសរបស់អ្នក តើរបបសន្តិសុខសង្គមផ្លូវការ(សាធារណៈ)ដែលបានពណ៌នាមកហើយនេះ ត្រូវបានបន្ថែមបំពេញដោយផែនការក្រៅផ្លូវការ(ឯកជន)ដែរឬទេ? ។ បើសិនជាមានករណីដូច្នេះ

មែនសូមពិពណ៌នាអំពីផែនការទាំងនេះ ហើយនិងទំនាក់ទំនងទៅវិញទៅមករវាងផែនការនេះ និងរបបផ្លូវការ (សាធារណៈ) ។

៦. សូមបញ្ជាក់ថា តើនៅក្នុងប្រទេសរបស់អ្នកមានក្រុមណាមួយដែលឥតបានអាស្រ័យផលនៃសិទ្ធិមានសន្តិសុខសង្គមសោះ ឬក៏បានអាស្រ័យដែរ តែតិចហួសបើធៀបទៅនឹងប្រជាជនភាគច្រើន។ ជាពិសេស តើស្ថានភាពស្ត្រីចំពោះបញ្ហានេះយ៉ាងណាដែរ? សូមផ្តល់សេចក្តីជាក់លាក់លើបញ្ហាមិនបានអាស្រ័យផលនៃសិទ្ធិមានសន្តិសុខក្នុងសង្គមនេះ ។

ក) សូមបញ្ជាក់ថា តើវិធានការអ្វីខ្លះដែលរដ្ឋាភិបាលរបស់អ្នកចាត់ទុកថាចាំបាច់ ដើម្បីធ្វើឱ្យបានការសំរេចសិទ្ធិមានសិន្តិសុខសង្គមដល់ក្រុមដែលស្តីខាងលើនេះ ។

ខ) ចូរពន្យល់ពីវិធានការខាងនយោបាយដែលរដ្ឋាភិបាលរបស់អ្នកប្រកាន់យក ដោយប្រើធនធានជាអតិបរមាដែលមាន ដើម្បីរ៉ាប់រងដល់ក្រុមនោះនូវការប្រើប្រាស់សិទ្ធិខាងសន្តិសុខសង្គម ។ សូមប្រាប់ពីគោលដៅនិងគោលចំណាំដែលបានកំណត់ទុកសំរាប់វាស់វែងលទ្ធផលនៅក្នុងរយៈពេលមួយទាក់ទងនឹងរឿងនេះ ។

គ) សូមពិពណ៌នាពីផលដែលវិធានការទាំងនេះទៅលើស្ថានភាពនៃក្រុមទន់ខ្សោយ និងក្រុមចាញ់ប្រៀបដែលពោលមកនេះ ហើយរាយការណ៍ពីការជោគជ័យ បញ្ហា និងការខ្វះខាតនៃវិធានការទាំងនោះ ។

៧. ចំពោះរបាយការណ៍ក្រោយៗទៀត សូមបញ្ជាក់ពីការពិនិត្យមើលត្រួសៗពីការផ្លាស់ប្តូរ បើសិនជាមាននៅក្នុងច្បាប់ជាតិ សេចក្តីសំរេចរបស់តុលាការ ព្រមទាំងវិធាន នីតិវិធី និងការអនុវត្តផ្នែករដ្ឋបាល ក្នុងកម្លុងពេលត្រូវរាយការណ៍ដែលមានផលទៅលើសិទ្ធិសន្តិសុខសង្គម ។

៨. សូមបញ្ជាក់ប្រាប់ តួនាទីនៃជំនួយឧបត្ថម្ភពីអន្តរជាតិដើម្បីធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិដូចមានចែងក្នុងមាត្រា ៩ ។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)

## មនុស្សមានពិការភាព

២៨. គំរោងសន្តិសុខសង្គមនិងការរក្សាលំនឹងប្រាក់ចំណូល គឺមានសារៈសំខាន់ជាពិសេសចំពោះបុគ្គលមានពិការភាព។ ដូចមានចែងក្នុងវិធានជាបទដ្ឋាន" រដ្ឋគប្បីធានាផ្តល់ការគាំទ្រសំរាប់ប្រាក់ចំណូលគ្រប់គ្រាន់ដល់បុគ្គលមានពិការភាពដែលបានបាត់បង់ ឬបានទទួលការកាត់បន្ថយជាបណ្តោះអាសន្ននូវប្រាក់ចំណូលរបស់ពួកគេដោយសារពិការភាព ឬកត្តាពាក់ព័ន្ធនឹងពិការភាព ឬ ក៏ត្រូវគេបដិសេធឱកាសការងារ"។ ការគាំទ្របែបនេះត្រូវឆ្លុះ

បញ្ចាំងនូវសេចក្តីត្រូវការជាពិសេស និងការចំណាយនានាដែលជារឿយៗទាក់ទងនឹងពិការភាព។ បន្ថែមលើនេះ តាមដែលអាចធ្វើទៅបាន ការគាំទ្រនេះគប្បីចំណាយលើបុគ្គល(ភាគច្រើនលើសលប់ជាស្ត្រី) ដែលទទួលការថែទាំបុគ្គលមានពិការភាពផងដែរ។ អ្នកទាំងនោះ រួមមាន សមាជិកគ្រួសារនៃបុគ្គលមានពិការភាព ជាញឹកញាប់ត្រូវការជាបន្ទាន់នូវការគាំទ្រផ្នែកហិរញ្ញវត្ថុ ដោយសារតែតួនាទីជួយថែទាំរបស់ពួកគេ។

២៩. ការទុកដាក់បុគ្គលមានពិការភាពឱ្យនៅក្នុងមណ្ឌលជនពិការ មិនអាចចាត់ទុកជាការជំនួសគ្រប់គ្រាន់ដល់សិទ្ធិមានសន្តិសុខសង្គម និងការជំនួសការគាំទ្រប្រាក់ចំណូលរបស់អ្នកទាំងនោះឡើយ លើកលែងតែមានហេតុផលដទៃទៀតថាចាំបាច់ត្រូវធ្វើដូច្នេះ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់មនុស្សចាស់**

២៦. មាត្រា ៩ នៃកតិកាសញ្ញាបានចែងជាទូទៅថា រដ្ឋជាភាគី "ទទួលស្គាល់សិទ្ធិសន្តិសុខសង្គមសំរាប់មនុស្សរាល់រូប" ដោយមិនបានចែងបញ្ជាក់ពីប្រភេទ ឬ កំរិតនៃការការពារដែលត្រូវបានធានានោះទេ។ ក៏ប៉ុន្តែ ពាក្យ "សន្តិសុខសង្គម" គ្របដណ្តប់ដោយប្រយោលទៅលើហានិភ័យទាំងអស់ទាក់ទងនឹងការបាត់បង់មធ្យោបាយទ្រទ្រង់ជីវភាពដោយសារហេតុផលនានាហួសពីមនុស្សម្នាក់អាចគ្រប់គ្រងបាន។

២៧. ស្របទៅតាមមាត្រា ៩ នៃកតិកាសញ្ញា និង បទបញ្ញត្តិនានាទាក់ទងនឹងការអនុវត្តអនុសញ្ញាផ្សេងៗរបស់ ILO ស្តីពីសន្តិសុខសង្គម (ដូចជាអនុសញ្ញាលេខ ១០២ ទាក់ទងសន្តិសុខសង្គម (បទដ្ឋានអប្បបរិមា) និង អនុសញ្ញាលេខ ១២៨ ទាក់ទងនឹងអត្ថប្រយោជន៍របស់ជនពិការ ជនជរា និង ឧត្តរជីវី) រដ្ឋជាភាគីត្រូវតែចាត់វិធានការសមស្របដើម្បីបង្កើតរបបទូទៅនៃការធានារ៉ាប់រង ដាច់ខាតសំរាប់មនុស្សចាស់ ដោយចាប់ផ្តើមពីអាយុណាមួយដែលត្រូវកំណត់ដោយច្បាប់របស់ជាតិ។

២៨. ស្របជាមួយនឹងអនុសាសន៍ដែលមាននៅក្នុងអនុសញ្ញាពីររបស់ ILO ដែលពោលខាងលើ និងក្នុងអនុសាសន៍លេខ ១៦២ គណៈកម្មាធិការស្វាគមឱ្យរដ្ឋជាភាគីកំណត់អាយុចូលនិវត្តន៍ ដែលមានភាពបត់បែនបាន អាស្រ័យទៅតាមមុខរបរដែលបានអនុវត្ត និងសមត្ថភាពការងាររបស់មនុស្សចាស់ ដោយគិតគូរយ៉ាងល្អិតល្អន់ដល់កត្តាប្រជាសាស្ត្រសេដ្ឋកិច្ច និង សង្គមផងដែរ ។

២៩. ដើម្បីផ្តល់អានុភាពដល់បទបញ្ញត្តិនៃមាត្រា៩ នៃកតិកាសញ្ញានេះ រដ្ឋជាភាគីត្រូវធានាផ្តល់អត្ថប្រយោជន៍នៃឧត្តរជីវី និងអត្ថប្រយោជន៍នៃក្មេងកំព្រា នៅពេលមរណភាពនៃអ្នករកស៊ីចិញ្ចឹម គ្រួសារដែលមានការរ៉ាប់រងខាងសន្តិសុខសង្គម ឬ ដែលមានសិទ្ធិទទួលសោធន។

៣០.  ជាងនេះទៅទៀត ដើម្បីអនុវត្តនូវបទបញ្ញត្តិនៃមាត្រា ៩ នៃកតិកាសញ្ញានេះឱ្យបានពេញលេញ ហើយដូចដែលគណៈកម្មាធិការបានបញ្ជាក់ក្នុងផ្នែកលេខ ២០ និង ២១នៃសេចក្តីអធិប្បាយទូទៅនេះ រដ្ឋជាភាគីត្រូវផ្តល់ក្នុងករិតធនធានដែលមាននូវអត្ថប្រយោជន៍ដែលមិនមែនមកពីការបង់ភាគទាន និងការជួយទំនុកបំរុងដទៃទៀតដល់មនុស្សចាស់ ដែលមិនបានបញ្ចប់រយៈពេលត្រូវបង់ភាគទាន ហើយគ្មានសិទ្ធិទទួលសោធនជរាភាពឬអត្ថប្រយោជន៍សន្តិសុខសង្គមឬជំនួយទំនុកបំរុងដទៃទៀត ហើយក៏គ្មានប្រភពចំណូលដទៃទៀត ពេលណាគេឈានដល់អាយុដែលកំណត់នៅក្នុងច្បាប់ជាតិ ។

**សេចក្តីអធិប្បាយ**

បើរដ្ឋជាភាគីមួយនៃកតិកាសញ្ញានេះ ជាភាគីនៃអនុសញ្ញា ILO លេខ១០២ ឆ្នាំ១៩៥២ ដែរនោះ រដ្ឋនោះចាំបាច់ត្រូវផ្តល់ឱ្យគណៈកម្មាធិការនូវពត៌មានដែលទាក់ទងនឹងរបាយការណ៍ដែលបានផ្តល់ឱ្យ ILO រួចហើយដែរ។ ក៏ប៉ុន្តែ នៅក្នុងករណីនេះ រដ្ឋជាភាគីត្រូវជូនពត៌មានដល់គណៈកម្មាធិការអំពីប្រភេទនៃសេចក្តីសង្កេតឃើញរបស់គណៈកម្មាធិការ អំពីប្រភេទនៃសេចក្តីសង្កេតឃើញរបស់គណៈកម្មាធិការអ្នកជំនាញរបស់ ILO ទាក់ទងនឹងពត៌មាននោះ។

ទោះបីជាមាត្រានេះ ជាមាត្រាខ្លីជាងគេនៅក្នុងកតិកាសញ្ញានេះក៏ដោយ ក៏រដ្ឋជាភាគីត្រូវធ្វើរបាយការណ៍មួយឱ្យគ្រប់គ្រាន់ ដែលឆ្លើយតបនឹងបញ្ហាផ្សេងៗមួយចំនួន។ ការដែលគ្រាន់តែនិយាយថា មានកម្មវិធីសន្តិសុខសង្គម និងការគូសបញ្ជាក់អំពីអត្ថប្រយោជន៍បានពីកម្មវិធីនេះ គឺមិនគ្រប់គ្រាន់ទេ។ ដំបូង របាយការណ៍ត្រូវបញ្ជាក់តើប្រភេទកម្មវិធីសន្តិសុខសង្គមណាមួយ ក្នុងបណ្តាប្រភេទកម្មវិធីដូចតទៅនេះ ដែលមាននៅក្នុងប្រទេសដែលធ្វើរបាយការណ៍ : ការថែទាំផ្នែកពេទ្យ ប្រាក់បំណាច់សំរាប់ពេលឈឺ ប្រាក់បំណាច់ពេលសំរាលកូន ប្រាក់បំណាច់មនុស្សចាស់ ប្រាក់បំណាច់ពេលមានពិការភាព ប្រាក់បំណាច់សំរាប់ឧត្តរជីវី(អ្នករស់នៅបន្តពីមេគ្រួសារដែលស្លាប់) ប្រាក់បំណាច់ពេលមានរបួសក្នុងការងារ ប្រាក់បំណាច់ពេលគ្មានការធ្វើ និងប្រាក់បំណាច់សំរាប់គ្រួសារ។ សំរាប់ប្រភេទនីមួយៗនៃប្រភេទទាំងនេះ របាយការណ៍ត្រូវបញ្ជាក់អំពីប្រភេទ និងទំហំមនុស្សប៉ុន្មាននាក់ដែលបានទទួលអត្ថប្រយោជន៍ពីកម្មវិធីនេះ ជាពិសេសគិតជាភាគរយនៃមនុស្សទាំងអស់ដែលគួរតែទទួលបាន(តាមទ្រឹស្តី)។ របាយការណ៍ត្រូវបញ្ជាក់ឱ្យបានច្បាស់ពីចំនួន មនុស្សដែលមិនបានទទួលអត្ថប្រយោជន៍ពីប្រភេទណាមួយទាំងអស់នៃកម្មវិធីសន្តិសុខសង្គមនេះ។ ក្នុងន័យនេះ គណៈកម្មាធិការយកចិត្តទុកដាក់ជាពិសេសចំពោះស្ថានភាពក្រុមជនទន់ខ្សោយ និងបាត់បង់ប្រៀបខ្លាំងជាងគេនៅក្នុងសង្គម ដូចជា ស្ត្រីនៅជនបទ និងក្រុមជនអន្តោប្រាម និងក្រុមជនភាគតិច។

ចំពោះករណីពិសេសនៃប្រទេសកំពុងអភិវឌ្ឍន៍ ភាគច្រើននៃប្រភេទទាំងនេះ ប្រហែលជាមិនសូវមានប៉ុន្មានទេ ។ ប៉ុន្តែក្នុងករណីនេះ របាយការណ៍ត្រូវផ្តល់ពត៌មានទាក់ទងនឹងផែនការក្រៅផ្លូវការ ដែលអាចគ្របដណ្តប់តាមផ្លូវជាក់ស្តែងដល់ប្រជាជនមួយភាគ។ ការគ្របដណ្តប់ និងភាពគ្រប់គ្រាន់នៃផែនការនេះត្រូវពិពណ៌នា ហើយត្រូវបញ្ជាក់អំពីភាគរយនៃប្រជាជនដែលចាត់ទុកថា គ្មានបានទទួលកិច្ចគាំពារអ្វីទាំងអស់ពីទម្រង់ណាមួយនៃសន្តិសុខសង្គម។

ចំពោះសិទ្ធិទទួលបានសន្តិសុខសង្គម មន្ត្រីធ្វើរបាយការណ៍អាចនឹងធ្វើការពិគ្រោះ ឬនិយាយយោងទៅពត៌មានដែលផ្តល់ឱ្យនៅក្នុងរបាយការណ៍ផ្សេងទៀតទាក់ទងនឹងមាត្រា ៥ (ង)( iv) នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងពូជសាសន៍ មាត្រា ១១ (១)(ង) និងមាត្រា ១៣ (ក) នៃអនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងមាត្រា ២៦ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។ ទាក់ទងនឹងអនុសញ្ញាស្តីពីការបំបាត់ការ

រើសអើងប្រឆាំងនឹងស្ត្រី គេត្រូវយោងទៅសេចក្តីអធិប្បាយទូទៅលេខ ១៦ (សម័យប្រជុំលើកទី១០ ឆ្នាំ១៩៩១) ដែលអនុម័តដោយគណៈកម្មាធិការខាងការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី។

## មាត្រា ១០

**អត្ថបទមាត្រា ១០**

រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញានេះទទួលស្គាល់ថា :

១. កិច្ចការពារ និងការឧបត្ថម្ភដ៏ទូលំទូលាយបំផុត ដែលអាចធ្វើទៅបាន គួរតែផ្តល់ជូនចំពោះគ្រួសារ ព្រោះថាគ្រួសារនេះជាឯកតាក្រុមមូលដ្ឋានគ្រឹះ និងពិធម្មជាតិរបស់សង្គមមនុស្ស ជាពិសេសដើម្បីជួយនៅពេល ដែលរៀបចំគ្រួសារថ្មី និងនៅពេលគ្រួសារនេះមានភារៈទទួលបន្ទុកចំពោះការបីបាច់ថែរក្សា និងការអប់រំបុត្រធីតាក្នុងបន្ទុក។ អាពាហ៍ពិពាហ៍ ត្រូវតែប្រព្រឹត្តឡើងដោយមានការយល់ព្រមដោយសេរីអំពីសំណាក់អនាគតគូស្រករទាំង សងខាង។

២. កិច្ចគាំពារដ៏ពិសេសត្រូវផ្តល់ឱ្យមាតាទាំងឡាយឱ្យបានយូរគ្រប់គ្រាន់ ទាំងមុននិងទាំងក្រោយ ពេលឆ្លងទន្លេ។ ក្នុងដំណាក់កាលដូចពោលខាងលើនេះ មាតាទាំងឡាយដែលជាអ្នកធ្វើការងារ គួរតែបានទទួលការអនុញ្ញាតឱ្យឈប់សំរាកដោយមានប្រាក់ខែ ឬបានទទួលអត្ថប្រយោជន៍យ៉ាងគ្រប់គ្រាន់ សន្តិសុខ សង្គម។

៣. វិធានការពិសេសសំរាប់ការពារ និងសំរាប់ឧបត្ថម្ភ គួរតែរៀបចំឱ្យមានសំរាប់កុមារ និងយុវជនទាំងអស់ដោយឥតរើសមុខ មិនថាដោយមកពីមូលហេតុនៃវង្សត្រកូល ឬស្ថានភាពអ្វីផ្សេងៗទៀតឡើយ។ កុមារ និងយុវជនទាំងឡាយ គួរតែទទួលបាននូវកិច្ចការពារ ដើម្បីកុំឱ្យគេយកទៅប្រើសំរាប់កេងជញ្ជក់យកផលប្រយោជន៍ ទោះតាមផ្នែកសេដ្ឋកិច្ចក្តី តាមផ្នែកសង្គមកិច្ចក្តី។ ច្បាប់ត្រូវផ្តន្ទាទោសដល់បុគ្គលណាដែលជួលក្មេងៗឱ្យបំពេញការងារណាដែលបណ្តាលអោយខូចខាតដល់សីលធម៌ ឬដល់សុខភាព ឬមានគ្រោះថ្នាក់ដល់ជីវិត ឬអាចរំខានដល់ការចំរើនលូតលាស់តាមធម្មតារបស់ពួកគេ។ រដ្ឋ ត្រូវចែងច្បាប់កំរិតអាយុសំរាប់ក្មេងៗធ្វើការ ។ ការជួលក្មេងមិនទាន់គ្រប់អាយុឱ្យធ្វើការត្រូវហាមឃាត់ជាដាច់ខាត ហើយអ្នកប្រព្រឹត្តបទល្មើសនឹងត្រូវផ្តន្ទាទោសតាមច្បាប់។

### អត្ថបទនៃគោលការណ៍ណែនាំស្តីពីមាត្រា ១០ នៃកតិកាសញ្ញា

១. បើប្រទេសរបស់អ្នកបានចូលក្នុងអនុសញ្ញាណាមួយខាងក្រោម :

- កតិកាសញ្ញាអន្តរជាតិស្តីពីនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ
- អនុសញ្ញាស្តីពីនឹងសិទ្ធិរបស់កុមារ
- អនុសញ្ញាអំពីការលុបចោលនូវរាល់រូបភាពនៃការរើសអើងប្រឆាំងស្ត្រីភេទ
- អនុសញ្ញានៃអង្គការការងារអន្តរជាតិ អំពីកិច្ចគាំពារមាតុភាព (ពិនិត្យឡើងវិញ) ១៩៥២ (លេខ ១០៣)
- អនុសញ្ញានៃអង្គការការងារអន្តរជាតិ អំពីអាយុអប្បបរមា ១៩៧៣ (លេខ ១៣៨)

ឬ ចូលក្នុងអនុសញ្ញាផ្សេងណាមួយនៃអង្គការនេះ ចំពោះកិច្ចគាំពារកុមារ និងក្មេងជំទង់ទាំងឡាយទាក់ទងទៅនឹងមុខរបរ និងការងារ ហើយបើរដ្ឋាភិបាលរបស់អ្នកបានធ្វើរបាយការណ៍ជូនទៅសាមីគណកម្មាធិការត្រួតពិនិត្យរួចហើយៗដែលជារបាយការណ៍ទាក់ទងនឹងបទបញ្ញត្តិនៃមាត្រា ១០ នោះ អ្នកអាចនិយាយយោងទៅផ្នែកទាក់ទងនៃរបាយការណ៍ទាំងនោះ មិនចាំបាច់និយាយដដែលៗលើអ្វីដែលបានផ្ដល់ហើយនោះទេ។ ក៏ប៉ុន្តែ រាល់បញ្ហាដែលចោទឡើងនៅក្រោមកតិកាសញ្ញានេះ ហើយដែលពុំទាន់បានថ្លែងពេញលេញនៅក្នុងរបាយការណ៍ទាំងនេះនៅឡើយទេនោះ ត្រូវតែលើកមកបញ្ជាក់នៅក្នុងរបាយការណ៍នេះ។

២. សូមបញ្ជាក់ថា តើនៅក្នុងសង្គមរបស់អ្នក ពាក្យថា "គ្រួសារ" មានន័យដូចម្ដេច?

៣. សូមបញ្ជាក់ នៅក្នុងប្រទេសរបស់អ្នក អាយុប៉ុន្មានទៅដែលគេទុកជាអាយុនីតិជនសំរាប់គោលបំណងផ្សេងៗ។

៤. សូមផ្ដល់ពត៌មានពីរបៀបនិងមធ្យោបាយ ទាំងផ្លូវការនិងទាំងក្រៅផ្លូវការ ដែលគេប្រើនៅក្នុងប្រទេសរបស់អ្នក ដើម្បីផ្ដល់ជំនួយ និងកិច្ចគាំពារដល់គ្រួសារ។ ជាពិសេស :

ក) តើប្រទេសរបស់អ្នកធានាសិទ្ធិបុរស ហើយជាពិសេសសិទ្ធិស្ត្រី ក្នុងការរៀបចំអាពាហ៍ពិពាហ៍ដោយមានការយល់ព្រមពេញលេញ និងសេរី និងការបង្កើតគ្រួសារដែរឬទេ? សូមបញ្ជាក់ ពីករណីជាក់លាក់ ដែលវិធានការប្រកាន់យកនោះ ហើយមិនបានជោគជ័យក្នុងការបំបាត់នូវទម្លាប់ដែលរារាំងដល់ការប្រើប្រាស់សិទ្ធិនេះ។

ខ) តើដោយវិធានការណាខ្លះ ដែលប្រទេសរបស់អ្នកសំរួលការកសាងគ្រួសារ ហើយប្រទេសរបស់អ្នកជួយរក្សា ជួយពង្រឹង និងជួយការពារគ្រួសារ ពិសេសនៅក្នុងពេលដែលគ្រួសារមានការទទួលខុសត្រូវក្នុងការថែរក្សា និងការអប់រំបុត្រធីតាក្នុងបន្ទុក? ថ្វីបើមានវិធានការទាំងនេះក្ដី តើមានគ្រួសារដែលពុំបានទទួលទាល់តែសោះនូវអត្ថប្រយោជន៍កិច្ចការពារ និងជំនួយបែបនោះ ឬបានទទួលដែរតែតិចហួសធៀបទៅនឹងប្រជាជនភាគច្រើនដែរឬទេ។ សូមផ្ដល់ដោយលំអិតនូវស្ថានភាពទាំងនេះ។ តើក្រុមគ្រួសារធំ (គ្រួសារដែលមានសមាជិកជាឪពុកម្ដាយ ជីដូនជីតានិងអ្នករស់ជាមួយផ្សេងៗទៀត) ឬទម្រង់ដទៃនៃគ្រួសារ ត្រូវបានទទួលស្គាល់ឬទេ នៅក្នុងការកំណត់ឱ្យទម្រង់គ្រួសារទាំងអស់នេះបានទទួលអត្ថប្រយោជន៍ពីវិធានការ ឬអាចឱ្យវិធានការទាំងនេះអនុវត្តបានទៅលើទម្រង់គ្រួសារទាំងនេះ ជាពិសេសទាក់ទងទៅនឹង អត្ថប្រយោជន៍បានពីរដ្ឋាភិបាល?

គ) វិធានការណាខ្លះ ដែលត្រូវបានប្រមាណទុកដើម្បីកែការខ្វះខាតសង្កេតឃើញក្នុងស្ថានភាព ដែលលើកឡើងក្នុងវគ្គ "ក" ឬ "ខ" ?។

៥.	សូមផ្តល់ពតិមានពីប្រព័ន្ធគាំពារមាតុភាព នៅក្នុងប្រទេសរបស់អ្នក ។

ក)	ជាពិសេស :

i) ពិពណ៌នាអំពីវិសាលភាពនៃផែនការគាំពារ ។

ii) បញ្ជាក់ពីរយៈពេលសរុបនៃការឈប់សំរាកសំរាលកូន និងរយៈពេលត្រូវឈប់សំរាកដាច់ខាតក្រោយពេលសំរាលកូន

iii) ពិពណ៌នាពី ជំនួយឧបត្ថម្ភជាប្រាក់ ការថែទាំផ្នែកពេទ្យ និងអត្ថប្រយោជន៍នៃសន្តិសុខសង្គមដទៃទៀត ដែលផ្តល់ឱ្យក្នុងកម្លុងពេលទាំងនេះ ។

iv) បញ្ជាក់ពី ការវិវត្តន៍នៃការឧបត្ថម្ភទាំងនោះ ក្នុងកាលកន្លងមក ។

ខ)	សូមបញ្ជាក់ថា តើនៅក្នុងសង្គមរបស់អ្នកមានក្រុមស្រ្តីដែលឥតបានទទួលផលពីផែនការគាំពារមាតុភាពណាមួយសោះដែរឬទេ? ឬក៏ទទួលដែរតែតិចហួសធៀបទៅនឹងស្រ្តីភាគច្រើន ។ សូមផ្តល់ សេចក្តីបញ្ជាក់លំអិតពីស្ថានភាពទាំងនេះ ។ តើវិធានការណាខ្លះ ដែលត្រូវបានប្រកាន់យកដើម្បីដោះស្រាយស្ថានភាពនេះ? ។ សូមពិពណ៌នាអំពីអនុភាពនៃវិធានការទាំងនេះទៅលើស្ថានភាពនៃក្រុមមនុស្សដែលទន់ខ្សោយ និងបាត់បង់ប្រៀបដែលបានគូសបញ្ជាក់មកនេះ ហើយចូររាយការណ៍ពីការជោគជ័យ បញ្ហា និង ការខ្វះខាតនៃវិធានការទាំងនេះ ។

៦.	សូមពិពណ៌នាអំពីវិធានការពិសេសនៃកិច្ចគាំពារ និងការឧបត្ថម្ភជាផលប្រយោជន៍ដល់កុមារ និងក្មេងជំទង់ពិសេសវិធានការដើម្បីការពារគេទល់នឹងគ្រប់រូបភាពនៃការធ្វើអាជីវកម្មខាងសេដ្ឋកិច្ច និងខាង សង្គមកិច្ច ឬក៏ទប់ស្កាត់មិនឱ្យប្រើអ្នកទាំងនោះធ្លាក់ក្នុងការងារដែលធ្វើឱ្យប៉ះពាល់សីលធម៌ ឬសុខភាពរបស់គេ ឬក៏ដែលបណ្តាលគ្រោះថ្នាក់ដល់ជីវិត ឬក៏ធ្វើឱ្យប៉ះពាល់ដល់ការរីកធំធាត់ល្អរបស់គេ ។

ក)	នៅក្នុងប្រទេសរបស់អ្នក តើអាយុប៉ុន្មានជាអាយុទាបបំផុតដែលត្រូវហាមឃាត់មិនឱ្យប្រើកុមារជាឈ្នួល នៅក្នុងមុខរបរផ្សេងៗ?

ខ)	សូមបញ្ជាក់ តើមានក្មេងប៉ុន្មាននាក់ ហើយក្នុងរង្វង់អាយុពីណាដល់ណា ដែលជាប់ធ្វើការយកឈ្នួល ហើយធ្វើការដល់កំរិតណាទៅ? ។

គ)	សូមបញ្ជាក់ តើនៅក្នុងកំរិតណាដែលកុមារត្រូវបានប្រើឱ្យធ្វើការជាជំនួយក្នុងគ្រួសារ ឬក្នុងការងារអាជីវកម្មខាងកសិកម្ម ឬក្នុងអាជីវកម្មគ្រួសារ ។

ឃ)	សូមបញ្ជាក់ថា តើនៅក្នុងប្រទេសរបស់អ្នក មានក្រុមកុមារ និងក្មេងៗ ដែលឥតបានទទួលផលអ្វីមួយពីវិធានការគាំពារ និងឧបត្ថម្ភទាល់តែសោះ ឬបានទទួលតែតិចពេកប្រៀបធៀបទៅនឹងកុមារភាគច្រើន ។ ជាពិសេស តើស្ថានភាពកុមារកំព្រា កុមារដែលឪពុកម្តាយបង្កើតស្លាប់ចោល កុមារីជំទង់ និងក្មេងៗ

ដែលត្រូវគេបោះបង់ ឬដែលបំបែកចេញពីបរិស្ថានគ្រួសារ ព្រមទាំងកុមារដែលពិការខាងសតិ ឬផ្លូវកាយយ៉ាងណាដែរ?

ង) តើបណ្តាមនុស្សដែលរៀបរាប់ខាងលើនេះ ត្រូវបានគេប្រាប់ឱ្យដឹងអំពីសិទ្ធិនីមួយៗរបស់គេយ៉ាងណាដែរ?

ច) សូមផ្តល់សេចក្តីបញ្ជាក់អំពីការលំបាក និង ចំណុចខ្វះខាតណាមួយ។ តើស្ថានភាពលំបាករបស់កុមារទាំងនោះបានវិវត្តន៍យ៉ាងណា? តើវិធានការអ្វីខ្លះដែលប្រកាន់យកដើម្បីកែស្ថានភាពនេះ?។ សូមពិពណ៌នាអំពីអានុភាពនៃវិធានការទាំងនោះក្នុងពេលកន្លងទៅ រួចរាយការណ៍ពីជោគជ័យបញ្ហានិងចំណុចខ្វះ ខាត។

៧. ចំពោះរបាយការណ៍ក្រោយៗ សូមផ្តល់ពតិមានត្រួសៗអំពីការកែប្រែ បើសិនជាមាន នូវច្បាប់ជាតិ សេចក្តីសំរេចរបស់តុលាការ ឬវិធាន នីតិវិធី និង ការអនុវត្តន៍ផ្នែករដ្ឋបាលក្នុងកម្លុងពេលត្រូវរាយការណ៍ដែលមានផលដល់សិទ្ធិចែងក្នុងមាត្រា ១០។

៨. សូមពិពណ៌នាអំពីតួនាទីរបស់ជំនួយអន្តរជាតិ ដើម្បីឱ្យបានការសំរេចពេញលេញនូវសិទ្ធិចែងក្នុងមាត្រា ១០។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)

### មនុស្សដែលមានពិការភាព

៣០. ក្នុងករណីបុគ្គលមានពិការភាព បញ្ញតិនៃកតិកាសញ្ញាដែលថា"ការគាំពារ និងជំនួយ" ត្រូវផ្តល់ឱ្យគ្រួសារនោះមានន័យថា គេត្រូវធ្វើអ្វីគ្រប់យ៉ាងដែលអាចធ្វើទៅបាន ដើម្បីអោយបុគ្គលនោះអាចរស់នៅជួបជុំជាមួយគ្រួសារគេបើសិនជាគេប្រាថ្នាដូច្នេះ។ មាត្រាទី ១០ យោងតាមគោលការណ៍ទូទៅនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនាំឱ្យមានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងមានគ្រួសាររបស់បុគ្គលមានពិការភាព។ សិទ្ធិនេះ ជារឿយៗត្រូវបានគេមិនអើពើ ឬបដិសេធ ជាពិសេសក្នុងករណីបុគ្គលមានពិការភាពក្នុងផ្លូវចិត្ត។ នៅក្នុងបរិបទនេះនិងបរិបទដទៃទៀត ពាក្យថា "គ្រួសារ"គួរមានការបកស្រាយទូលំទូលាយនិងស្របទៅតាមទំនៀមទំលាប់ដ៏សមស្របក្នុងតំបន់។ រដ្ឋជាភាគីគប្បីធានាថាច្បាប់និងគោលនយោបាយ និងការអនុវត្តន៍ជាទម្លាប់របស់សង្គម មិនត្រូវរារាំងដល់ការសំរេចបាននូវសិទ្ធិទាំងនេះឡើយ។ បុគ្គលមានពិការភាពគប្បីមានលទ្ធភាពទទួលបាននូវសេវាពិគ្រោះចាំបាច់ដើម្បីគេអាចបំពេញនូវសិទ្ធិ និងភារកិច្ចរបស់ពួកគេក្នុងគ្រួសារ។

៣១. ស្ត្រីមានពិការភាពក៏មានសិទ្ធិត្រូវបានការគាំពារនិងគាំទ្រពាក់ពន្ធ័នឹងភាពជាម្តាយនិងការមានគភ៌។ ដូចមានចែងក្នុងវិធានជាបទដ្ឋាន "បុគ្គលមានពិការភាពមិនត្រូវគេបដិសេធនូវឱកាសមានទំនាក់ទំនងផ្លូវភេទ និងឆ្លង

កាត់ភាពជាឪពុកម្ដាយឡើយ"សេចក្ដីត្រូវការ និងចំណង់ខាងលើនេះគប្បីត្រូវទទួលស្គាល់ និងដោះស្រាយតាមបរិបទនៃការកំសាន្ត និង ការបង្កកំណើត។ សិទ្ធិទាំងនេះ តែងតែត្រូវបានគេបដិសេធចំពោះបុរស និងស្ត្រីមានពិការភាពទូទាំងពិភពលោក។ វិញ្ញកម្ម(ការធ្វើមិនឱ្យមានកូន) និងការពន្លូតស្ត្រីមានពិការភាព ដោយគ្មានការយល់ព្រម និងជ្រួតជ្រាបអំពីវិធីទាំងពីរនេះជាមុនទេនោះ គឺជាការរំលោភដ៏ធ្ងន់ធ្ងរលើមាត្រា ១០(២)។

៣២. កុមារមានពិការភាព ងាយរងគ្រោះជាពិសេសចំពោះ ការកេងប្រវ័ញ្ច, ការរំលោភ និងការមិនយកចិត្តទុកដាក់ ហើយនិងយោងតាមមាត្រាទី ១០ (៣) នៃកតិកាសញ្ញា (គាំទ្រដោយបទបញ្ញត្តិស្របគ្នានៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ) កុមារទាំងនោះត្រូវទទួលបានការគាំពារយ៉ាងពិសេស។

## សេចក្ដីដកស្រង់ពីអត្ថបទនៃសេចក្ដីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)

## សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់

៣១. ផ្អែកលើវាក្យខ័ណ្ឌ ១ មាត្រា ១០ នៃកតិកាសញ្ញានេះ និង អនុសាសន៍លេខ ២៥ និង ២៩ នៃផែនការសកម្មភាពអន្តរជាតិទីក្រុងវីយែនស្ដីពីជរាភាព រដ្ឋជាភាគីត្រូវប្រឹងប្រែងគ្រប់មធ្យោបាយចាំបាច់ដើម្បីទ្រទ្រង់ការពារ និងពង្រឹងគ្រួសារ និង ជួយគ្រួសារ ស្របទៅតាមប្រព័ន្ធតម្លៃវប្បធម៌ នៃសង្គមនិមួយៗ ដើម្បីឆ្លើយតបទៅនឹងសេចក្ដីត្រូវការនៃសមាជិកចាស់ៗក្នុងបន្ទុក។ អនុសាសន៍លេខ ២៩ ជំរុញឱ្យរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលបង្កើតសេវាកម្មសង្គមដើម្បីគាំទ្រគ្រួសារទាំងមូល កាលណាមានមនុស្សចាស់នៅផ្ទះ និងជំរុញឱ្យអនុវត្តវិធានការ ជាពិសេស សំរាប់គ្រួសារ ណាដែលមានចំណូលតិច ហើយដែលចង់ទុកមនុស្សចាស់នៅផ្ទះ។ ការជួយទំនុកបំរុងនេះក៏គួរ ផ្ដល់ឱ្យមនុស្សដែលរស់នៅតែឯង ឬប្ដីប្រពន្ធចាស់ៗដែលចង់នៅផ្ទះដែរ ។

## សេចក្ដីអធិប្បាយ

មាត្រានេះ បរិយាយពីបញ្ហាមួយចំនួនធំរួមមាន : គ្រួសារ អាពាហ៍ពិពាហ៍ កិច្ចគាំពារមាតុភាព និងសិទ្ធិកុមារ។ ដូច្នេះ រដ្ឋជាភាគីនៃកតិកាសញ្ញាអាចផ្ដល់ពត៌មានដែលទាក់ទងទៅឱ្យអង្គការសន្ធិសញ្ញាដទៃទៀត ដែលធ្វើការដើម្បីឃ្លាំមើលការអនុវត្តឧបករណ៍ដូចតទៅនេះ : កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងនយោបាយជាពិសេសមាត្រា ២៣ និង ២៤ អនុសញ្ញាស្ដីពីសិទ្ធិកុមារ អនុសញ្ញា ILO លេខ ១០៣ ឆ្នាំ១៩៥២ និងលេខ ១៣៨ ឆ្នាំ ១៩៧៣ និងអនុសញ្ញាស្ដីពីការបំបាត់រាល់ទម្រង់នៃការរើសអើងនឹងស្ត្រី ជាពិសេសមាត្រា ១១, ១២, ១៣ និង ១៦។ ពត៌មានទាំងនេះមិនចាំបាច់ផ្ដល់ម្ដងទៀតនៅពេលរាយការណ៍អំពីមាត្រា ១០ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ទេ។ ផ្ទុយទៅវិញគេអាចយោងទៅរបាយការណ៍ដទៃទៀតទាំងនោះ ហើយត្រូវបញ្ជាក់អំពីសេចក្ដីអធិប្បាយរបស់អង្គការពិនិត្យការអនុវត្តសន្ធិសញ្ញាដែលទាក់ទង។

ក្នុងករណីពត៌មានដែលទាក់ទង មិនបានផ្តល់នៅកន្លែងផ្សេងទៀតទេនោះ គណៈកម្មាធិការទាមទារឱ្យផ្តល់ពត៌មានអំពីបញ្ហាដូចតទៅនេះ ។ បញ្ហាទីមួយទាក់ទងនឹងរឿងគ្រួសារ ។ សំរាប់គោលបំណងនេះរដ្ឋភាគីត្រូវរាយការណ៍ថា តើគោលគំនិត និងវិសាភាពនៃពាក្យ "គ្រួសារ" ត្រូវបានគេបកស្រាយឬឱ្យនិយមន័យយ៉ាងណានៅក្នុងសង្គម និងប្រព័ន្ធច្បាប់របស់រដ្ឋនោះ ។ បន្ទាប់មកទៀត ត្រូវផ្តល់ពត៌មានអំពីរបៀប និងមធ្យោបាយ ដែលតាមរយៈវិធី និងមធ្យោបាយទាំងនោះ គ្រួសារត្រូវបានទទួល"កិច្ចគាំពារ និងការជួយឧបត្ថម្ភទូលំទូលាយ បំផុតដែលអាចធ្វើបាន" ។ របាយការណ៍ត្រូវបញ្ជាក់ថាតើគ្រួសារបន្តប្រព្រឹត្តទៅក្នុងកំរិតណា ក្នុងឋានៈជាឯកតាក្រុមជាមូលដ្ឋាននៃសង្គម ។ ចំណុចនេះមានការសំខាន់ជាពិសេស បើគិតទៅដល់ការគំរាមកំហែងជាច្រើនដែលបានលេចឡើងក្នុងប៉ុន្មានទសវត្សថ្មីៗនេះ ចំពោះស្ថានភាពនៃគ្រួសារក្នុងសង្គមជាច្រើន ។

បញ្ហាបន្ទាប់មកទៀត គឺការមានការរិតត្បិតជាផ្លូវការក្តី ឬក្រៅផ្លូវការក្តី លើសិទ្ធិនៃអនាគតសហព័ទ្ធដើម្បីរៀបចំអាពាហ៍ពិពាហ៍ដោយសេរី ។ ជាពិសេស ត្រូវពិពណ៌នាអំពីស្ថានភាពស្ត្រីក្មេងៗ ហើយត្រូវផ្តល់ពត៌មានអំពីការមានបន្តទៅទៀតនូវទម្លាប់ដែលមានផលប៉ះពាល់ដល់ស្ត្រីទាំងនោះក្នុងរឿងជ្រើសរើសគូរស្រករនេះ ។

ទាក់ទងនឹងបទបញ្ញត្តិអំពីការគាំពារពិសេសដល់ម្តាយក្នុងរយៈពេលសមរម្យ មុននិងក្រោយសំរាលកូនត្រូវផ្តល់ពត៌មានអំពីវិធានការទាំងផ្លូវការទាំងក្រៅផ្លូវការ ។ វិធានការក្រៅផ្លូវការមានទម្លាប់ដែលគេបានអនុវត្តជាទូទៅក្នុងសហគមន៍មួយ ដែលប្រហែលជាមិនទាក់ទងនឹងតួនាទីសាធារណៈ ឬរដ្ឋាភិបាលទេ តែជាវិធានការជួយផ្តល់ប្រភេទនៃការការពារដែលគេត្រូវការ ។

កតិកាសញ្ញានេះ មិនសន្មតថា វិធានការទាំងអស់ដើម្បីការពារសិទ្ធិនេះ ឬសិទ្ធិដទៃទៀតដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញានេះ ចាំបាច់ត្រូវតែប្រកាន់យក ឬត្រូវផ្តល់មូលនិធិដោយរដ្ឋាភិបាលមុនធ្វើអ្វីៗផ្សេងទៀតនោះទេ ។ ក៏ប៉ុន្តែកាលណាវិធានការរបស់សហគមន៍ និងវិធានការដទៃទៀតមានការខ្វះខាតច្រើនមិនអាចបំពេញតាមសេចក្តីតំរូវរបស់កតិកាសញ្ញាទេនោះ រដ្ឋាភិបាលត្រូវមានការទទួលខុសត្រូវដើម្បីធ្វើអ្វីម្យ៉ាងដែលអាចធ្វើបានដើម្បីបំបាត់ ឬបន្ថយការខ្វះខាតនេះ ។

របាយការណ៍ត្រូវបញ្ជាក់ថា តើមានវិធានការផ្លូវការអ្វីខ្លះដើម្បីការពារមាតុភាព ហើយត្រូវផ្តល់ពត៌មានទាំងនេះដោយលំអិត ។ ពត៌មានអំពីចំនួននិងភាគរយនៃស្ត្រីដែលមិនបានទទួលអត្ថប្រយោជន៍ពីវិធានការក៏មានសារសំខាន់ជាពិសេសដែរ ។

បទបញ្ញត្តិនៅក្នុងកថាខ័ណ្ឌ ៣ ទាក់ទងនឹងកុមារ និងមនុស្សក្មេងៗ មានវិសាភាពធំធេងជាងអ្វីដែលគេឃើញសើៗ ។ ថ្វីបើបញ្ហាជាក់លាក់ដែលគេរកឃើញនៅក្នុងបទបញ្ញត្តិនេះទាក់ទងនៅនឹងបញ្ហាលក្ខខ័ណ្ឌការងារ និងទម្រង់នៃការកេងយកប្រយោជន៍នានា ប្រយោគទីមួយមានលក្ខណៈទូទៅច្រើនជាង ហើយមានវិសាលភាពធំ

ជាង។ ប្រយោគនេះទាមទារឱ្យមាន"វិធានការពិសេសសំរាប់ការពារ និងជួយឧបត្ថម្ភ" ដែលត្រូវប្រកាន់យកក្នុងនាមនៃកុមារនិងមនុស្សក្មេងទាំងអស់ ហើយតំរូវផងដែរថា វិធានការទាំងនេះត្រូវប្រកាន់យកដោយគ្មានការរើសអើង។ គេឃើញច្បាស់ថា សិទ្ធិទាំងអស់នៅក្នុងកតិកាសញ្ញានេះ អនុវត្តចំពោះកុមារ ទោះបីជាសិទ្ធិខ្លះអាចមានការទាក់ទងតិចជាងសិទ្ធិដទៃទៀត។ ទោះជាយ៉ាងនេះក្តី ដោយសារកតិកាសញ្ញានេះតំរូវឱ្យមានការការពារពិសេសដល់កុមារនិងមនុស្សក្មេង និងដោយសារកុមារនិងមនុស្សក្មេងច្រើនតែងាយរងគ្រោះជាងក្រុមដទៃទៀតនោះ របាយការណ៍ត្រូវបញ្ជាក់ឱ្យច្បាស់ពីកំរិតដែលកុមារអាស្រ័យផល ឬត្រូវបានគេដកហូត សិទ្ធិផ្សេងៗដែលទទួលស្គាល់នៅក្នុងកតិកាសញ្ញា។ ពេលណារដ្ឋជាភាគីនៃកតិកាសញ្ញានេះបានរាយការណ៍រួចហើយអំពីបញ្ហាទាំងនេះនៅក្នុងរបាយការណ៍ថ្មីៗទាក់ទងទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ រដ្ឋដែលធ្វើរបាយការណ៍នោះក៏គ្រប់គ្រាន់ទៅហើយ។

កតិកាសញ្ញានេះ មិនចែងអំពីអាយុប៉ុន្មានជាក់លាក់ ដែលបុគ្គលម្នាក់ត្រូវបានគេឈប់ចាត់ទុកជាកុមារ ឬមនុស្សក្មេងនោះទេ។ អាយុនេះត្រូវកំណត់ដោយរដ្ឋជាភាគីនីមួយៗ ដោយពិចារណាដល់លក្ខខ័ណ្ឌសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលទាក់ទង។ របាយការណ៍ត្រូវគួសបញ្ជាក់អំពីកំរិតអាយុដែលចែងដោយច្បាប់ជាតិទាក់ទងនឹងរឿងនេះ។

ថែមលើសិទ្ធិជាក់លាក់ដែលពោលនៅក្នុងកតិកាសញ្ញានេះ វិធានការដទៃទៀតអាចមានការចាំបាច់ដើម្បីធ្វើឱ្យស្របតាមការទទួលស្គាល់របស់កតិកាសញ្ញាដែលថា គេត្រូវការឱ្យមានវិធានការពិសេសដើម្បីការពារ និងការជួយឧបត្ថម្ភ។ ដូច្នេះ ជាឧទាហរណ៍ កាលណាគេរកឃើញការគំរាមកំហែងពិសេសណាមួយដល់កុមារ និង មនុស្សក្មេង របាយការណ៍ត្រូវពិពណ៌នាអំពីវិធានការចាំបាច់ និងបញ្ជាក់ពីការជឿនលឿននៃការអនុវត្តវិធានការនេះ។ រដ្ឋដែលធ្វើរបាយការណ៍ត្រូវផ្តល់ពត៌មានអំពីកំរិតនៃការរើសអើងប្រឆាំងនឹងកុមាររបស់ប្រទេសនោះ មិនឱ្យគេអាស្រ័យផលនៃសិទ្ធិរបស់គេ។

ជាទីបញ្ចប់ របាយការណ៍ត្រូវផ្តល់ពត៌មានជាក់លាក់អំពីវិធានការដែលត្រូវបានប្រកាន់ដើម្បីបំពេញតាមតំរូវការ ដើម្បីការពារកុមារ និងមនុស្សក្មេង ពីការកេងយកប្រយោជន៏ សេដ្ឋកិច្ច និងសង្គម ដើម្បីផ្តន្ទាទោសតាមច្បាប់នូវការប្រើក្មេង និងមនុស្សក្មេងឱ្យធ្វើការងារដែលប៉ះពាល់ដល់សីលធម៌ ឬសុខភាពរបស់គេ ឬដែលទំនងជាធ្វើឱ្យរាំងស្ទះដល់ការរីកធំធាត់របស់គេ និងដើម្បីកំណត់អាយុ ក្នុងគោលបំណងហាមឃាត់ និងផ្តន្ទាទោសតាមច្បាប់ចំពោះអ្នកណាដែលប្រើក្មេងក្រោមអាយុកំណត់នោះ។ បន្ថែមលើការដោះស្រាយស្ថានការណ៍តាមផ្លូវច្បាប់ រដ្ឋត្រូវផ្តល់ពត៌មានអំពីស្ថានការណ៍តាមផ្លូវជាក់ស្តែងដែរ។

## មាត្រា ១១

**អត្ថបទមាត្រា ១១**

១. រដ្ឋជាភាគីទាំងឡាយ ទទួលស្គាល់នូវសិទ្ធិរបស់មនុស្សម្នាក់ៗ ក្នុងការមានកំរិតជីវភាពរស់នៅយ៉ាងគ្រប់គ្រាន់សំរាប់ខ្លួនគេផ្ទាល់ និងសំរាប់គ្រួសារគេ រួមទាំងចំណីអាហារគ្រប់គ្រាន់ សំលៀកបំពាក់ និងទីលំនៅ ព្រមទាំងសម្ភារៈផ្សេងៗសម្រាប់ធ្វើឱ្យស្ថានភាពជីវភាពបានប្រសើរឡើងជាលំដាប់តទៅ។ រដ្ឋជាភាគីទាំងឡាយត្រូវចាត់វិធានការឱ្យបានសមស្រប ដើម្បីធានានូវសមិទ្ធិកម្មនៃសិទ្ធិនេះដោយការទទួលស្គាល់អំពីសារៈសំខាន់ពិសេសបំផុតនៃកិច្ចសហប្រតិបត្តិការអន្តរជាតិ ផ្អែកលើការស្រុះស្រួលមូលមតិគ្នាដោយសេរី ។

២. រដ្ឋទាំងឡាយជាភាគីនៃកតិកាសញ្ញាដោយ ទទួលស្គាល់នូវសិទ្ធិជាមូលដ្ឋានរបស់មនុស្សគ្រប់រូប ក្នុងការចាកផុតពីសេចក្តីស្រេកឃ្លាន ត្រូវចាត់វិធានការនានា ដោយឯកឯង និងតាមរយៈការសហការជាមួយអន្តរជាតិ។ រួមមានកម្មវិធីជាក់លាក់ដែលត្រូវការចាំបាច់ដើម្បី :

ក/ ធ្វើអោយរីកចំរើនដល់វិធីផលិត ការរក្សាទុកដាក់ និងការចែកចាយម្ហូបអាហារ ដោយប្រើប្រាស់អោយបានពេញទំហឹងនូវចំណេះវិជ្ជាខាងវិស័យបច្ចេកទេស និងវិទ្យាសាស្ត្រ តាមការផ្សព្វផ្សាយមុខវិជ្ជាស្តីអំពីគោលការណ៍នៃការចិញ្ចឹមកាយ ព្រមទាំងតាមការអភិវឌ្ឍន៍ ឬកែប្រែទម្រង់ប្រព័ន្ធកសិកម្មក្នុងរបៀបមួយ ដែលមានប្រសិទ្ធិភាពខ្ពស់បំផុតខាងផ្នែកអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានធម្មជាតិទាំងឡាយ ។

ខ/ ដោយយកចិត្តទុកដាក់ទៅលើបញ្ហានៃបណ្តាប្រទេសទាំងការនាំចេញ និងនាំចូលម្ហូបអាហារ ដើម្បីធានាឱ្យការចែកចាយនូវចំណីអាហារនៅលើពិភពលោកមាន សមធម៌ ស្របទៅតាមសេចក្តីត្រូវការ ។

**អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ១១ នៃកតិកាសញ្ញា**

១. ក. សូមផ្តល់ពត៌មានពីកំរិតជីវភាពបច្ចុប្បន្ននៃប្រជាជនរបស់អ្នកជាទូទៅ ដោយបង្ហាញជារួម និងបំបែកទៅតាមក្រុមសង្គម សេដ្ឋកិច្ច វប្បធម៌ និងក្រុមផ្សេងៗទៀតនៅក្នុងសង្គម។ តើកំរិតជីវភាពមានការប្រែប្រួលយ៉ាងណាទៅតាមការវិវត្តន៍នៃពេលវេលា (ដូចជា ធៀបទៅអ្វីដែលមានកាលពី ១០ ឆ្នាំមុន កាលពី ៥ ឆ្នាំមុន) ចំពោះក្រុមផ្សេងៗទាំងនោះ? តើមានការរីកចំរើនកំរិតជីវភាពជាបន្តបន្ទាប់ចំពោះ ប្រជាជនទូទៅ ឬចំពោះក្រុមណាខ្លះដែរឬទេ? ។

ខ. បើសិនជារដ្ឋាភិបាលរបស់អ្នកបានជូនថ្មីៗនេះនូវរបាយការណ៍អំពីស្ថានភាពនៃសិទ្ធិទាំងអស់ ឬ សិទ្ធិខ្លះ ចែងក្នុងមាត្រា ១១ ទៅអង្គការសហប្រជាជាតិ ឬទៅអង្គការជំនាញណាមួយ អ្នកអាចគ្រាន់តែនិយាយយោងទៅលើផ្នែកដែលពាក់ព័ន្ធនៃរបាយការណ៍ទាំងនោះបាន ហើយមិនចាំបាច់និយាយដដែលៗឡើង វិញពីពត៌មានដែលបានផ្តល់រួចហើយនោះទៀតទេ។

គ. សូមបញ្ជាក់ពីផលិតផលជាតិសរុបគិតក្នុងមនុស្សម្នាក់ៗសំរាប់ក្រុមមនុស្ស ៤០% នៃអ្នកក្របំផុត។ នៅក្នុងប្រទេសរបស់អ្នកមាន"ចំណុចផ្តើមនៃភាពក្រីក្រ" ឬទេ? បើមាន តើអ្វីខ្លះទៅជាលក្ខណៈ វិនិច្ឆ័យសំរាប់កំណត់ចំណុចនេះ? ។

ឃ. សូមបញ្ជាក់ពីសន្ទស្សន៍នៃគុណភាពជីវភាពរូបវន្តនៅក្នុងប្រទេសរបស់អ្នក។

## ២. សិទ្ធិមានចំណីអាហារគ្រប់គ្រាន់

(ក) សូមផ្តល់ពតិមានទូទៅត្រួសៗ អំពីថាតើសិទ្ធិមានអាហារគ្រប់គ្រាន់ សំរេចដល់កំរិតណាហើយនៅក្នុងប្រទេសរបស់អ្នក។ សូមពិពណ៌នាអំពីប្រភពពតិមានដែលមានចំពោះរឿងនេះ ដោយរួមបញ្ចូលការសិក្សាខាងការទ្រទ្រង់នៃអាហារព្រមទាំងវិធានការនៃការតាមដានដទៃទៀត។

(ខ) សូមផ្តល់ពតិមានលំអិត (រួមមានទិន្នន័យជាស្ថិតិបំបែកទៅតាមតំបន់ភូមិសាស្ត្រនានា) អំពីកំរិតការនៃអត់ឃ្លាននិង/ឬ ការទ្រទ្រង់អាហារមិនគ្រប់គ្រាន់ នៅក្នុងប្រទេសរបស់អ្នក។ ពតិមាននេះ ត្រូវពិពណ៌នាជាពិសេសអំពីបញ្ហាដូចតទៅ :

i) ស្ថានភាពនៃបណ្តាក្រុមដែលទន់ខ្សោយ ឬបាត់បង់ប្រៀបដូចជា :

- ប្រជាកសិករឥតមានដីធ្លី
- ប្រជាកសិករដែលខ្វះមុខខ្វះក្រោយ
- កម្មករនៅជនបទ
- អ្នកឥតការងារនៅជនបទ
- អ្នកឥតការងារនៅតំបន់ក្រុង
- អ្នកក្រីក្រនៅតំបន់ក្រុង
- កម្មករពនេចរ
- ជនអន្តោប្រវេសន៍ (ជនអន្តោគ្រាម)
- កុមារា កុមារី
- មនុស្សចំណាស់
- ក្រុមឯទៀតដែលមានការប៉ះពាល់ពិសេស។

ii) ភាពខុសគ្នាច្រើន នៅក្នុងស្ថានភាពបុរស និងស្ត្រី នៅក្នុងក្រុមនីមួយៗខាងលើ

iii) ការប្រែប្រួលដែលកើតមានឡើងក្នុងរយៈ ៥ ឆ្នាំចុងក្រោយទាក់ទងនឹងស្ថានភាពនៃក្រុមនីមួយៗខាងលើ។

(គ) នៅក្នុងកម្លុងពេលដែលត្រូវរាយការណ៍ តើនៅក្នុងនយោបាយជាតិ ច្បាប់ និងការអនុវត្តន៍ ជាក់ស្តែងមានការផ្លាស់ប្តូរដែលមានឥទ្ធិពលអវិជ្ជមាន ទៅលើលទ្ធភាពបានចំណីអាហារនៃក្រុមទាំងនេះ ឬ នៅក្នុងតំបន់ដែលយ៉ាប់យឺនបំផុតដែរឬទេ?។ បើសិនជាមាន សូមពិពណ៌នាអំពីការផ្លាស់ប្តូរទាំងនេះ ព្រមទាំងវាយតម្លៃឥទ្ធិពលបណ្តាលមកពីការផ្លាស់ប្តូរនោះ។

(ឃ) សូមប្រាប់វិធានការដែលរដ្ឋាភិបាលរបស់អ្នកចាត់ទុកថាចាំបាច់ ដើម្បីធានារ៉ាប់រងលទ្ធភាពបានចំណីអាហារគ្រប់គ្រាន់សំរាប់ក្រុមនីមួយៗនៃក្រុមទន់ខ្សោយ ឬក្រុមបាត់បង់ប្រៀបដែលពោលខាងលើ និងសំរាប់តំបន់ដែល

យ៉ាប់យ៉ឺនជាងគេ និងដើម្បីរ៉ាប់រងនូវការអនុវត្តន៍នូវសិទ្ធិមានចំណីអាហារសំរាប់បុរស និងស្ត្រីទាំងឡាយ។ សូមប្រាប់វិធានការប្រកាន់យក និងបញ្ជាក់ពីគោលដៅ និងគោលចំណាំខាងការអាហារសំរាប់វាស់វែងការសំរេចបានសិទ្ធិនេះនៅក្នុងរយៈពេលមួយ។

(ង) សូមបញ្ជាក់ថា តើវិធានការត្រូវប្រកាន់យកតាមវិធីណា ដើម្បីលំអវិធីផលិត ការរក្សា និងចែកចាយម្ហូបអាហារដោយប្រើប្រាស់ឱ្យពេញទំហឹងនូវចំណេះដឹងខាងបច្ចេកទេស និងខាងវិទ្យាសាស្ត្រ ដែលជាវិធានការជួយឱ្យបានសំរេចនូវសិទ្ធិមានចំណីអាហារគ្រប់គ្រាន់ ឬវិធានការដែលបានបង្អាក់ការសំរេចបានសិទ្ធិនេះ។ សូមពិពណ៌នាពីឥទ្ធិពលនៃវិធានការទាំងនេះ លើវិស័យចិរភាពនៃអេកូឡូស៊ី និងលើការការពារ និងការរក្សាធនធានសំរាប់ផលិតអាហារ។

(ច) សូមប្រាប់ថា តើវិធានការណាខ្លះដែលត្រូវបានប្រកាន់យកដើម្បីផ្សព្វផ្សាយនូវចំណេះដឹងអំពីគោលការណ៍នៃការចិញ្ចឹមរាងកាយដោយអាហារ ហើយបញ្ជាក់ថា តើមានក្រុម ឬ ផ្នែកធំនៃសង្គមដែរឬទេ ដែលហាក់ដូចជានៅខ្វះចំណេះដឹងនេះនៅឡើយ។

(ឆ) សូមពិពណ៌នា អំពីវិធានការកែទំរង់ដីធ្លីដែលរដ្ឋាភិបាលរបស់អ្នកបានធ្វើ ដើម្បីឱ្យឃើញប្រាកដថាប្រព័ន្ធកសិកម្មត្រូវបានប្រើយ៉ាងមានប្រសិទ្ធភាព ដើម្បីជំរុញនូវសន្តិសុខចំណីអាហារក្នុងគ្រួសារ ដោយឥតធ្វើឱ្យមានផលអាក្រក់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ទាំងនៅក្នុងតំបន់ជនបទ ទាំងនៅទីប្រជុំជន ដោយគិត ដល់មាត្រា ៦ ទៅ ៨ នៃកតិកាសញ្ញានេះ។ សូមអធិប្បាយពីវិធានការដែលបានប្រកាន់យក :

i) ដើម្បីអនុម័តច្បាប់ស្របទៅតាមគោលដៅនេះ

ii) ដើម្បីអនុវត្តច្បាប់ជាធរមានឱ្យស្របទៅតាមគោលដៅនេះ

iii) ដើម្បីសំរួលការឃ្លាំមើលពីអង្គការរដ្ឋាភិបាល និងក្រៅរដ្ឋាភិបាល

(ជ) សូមពិពណ៌នា ហើយវាយតម្លៃវិធានការដែលរដ្ឋាភិបាលរបស់អ្នកបានប្រកាន់យក ដើម្បីធានាការចែករំលែកប្រកបដោយសមធម៌នូវផលិតកម្ម និងពាណិជ្ជកម្ម នូវធនធានខាងអាហារពិភពលោកទាក់ទងទៅនឹងសេចក្តីត្រូវការដោយគិតដល់បញ្ហានៃប្រទេសនាំចូល និងប្រទេសនាំចេញម្ហូបអាហារ។

## ៣. <u>សិទ្ធិមានលំនៅគ្រប់គ្រាន់</u>

(ក) សូមផ្តល់ពត៌មានជាស្ថិតិលំអិតស្តីពីស្ថានភាពលំនៅស្ថាននៅក្នុងប្រទេសរបស់អ្នក។

(ខ) សូមឱ្យពត៌មានលំអិតអំពី ក្រុមទន់ខ្សោយ និងក្រុមបាត់បង់ប្រៀប ទាក់ទងនឹងរឿងលំនៅស្ថាននៅក្នុងប្រទេសរបស់អ្នក។ ពិសេស បញ្ជាក់បង្ហាញ :

(i) ចំនួនបុគ្គល និងគ្រួសារឥតមានជំរក

(ii) ចំនួនបុគ្គល និងគ្រួសារដែលបច្ចុប្បន្ននេះមានជំរកត្រដាបត្រដួស ហើយឥតមានលទ្ធភាពបានផាសុកភាពជាមូលដ្ឋានដូចជាទឹក កំដៅ(បើសិនជាចាំបាច់)ការបោះចោលកាកសំណល់ អនាម័យ

អគ្គិសនី សេវាប្រៃសណីយ៍ផ្សេងៗ។ល។ (បើសិនជាអ្នកយល់ថា វត្ថុធាតុទាំងនេះ ត្រូវតែជាផាសុកភាពចាំបាច់នៅក្នុងប្រទេសរបស់អ្នក)។ សូមបញ្ចូលចំនួនមនុស្សដែលរស់នៅប្រជ្រៀតគ្នាក្នុងផ្ទះតូច ជ្រាំ មិនសូវរឹងមាំ ឬរស់ក្នុងល័ក្ខខ័ណ្ឌដែលបណ្តាលឱ្យមានផលអាក្រក់ដល់សុខភាព។

(iii) ចំនួនមនុស្សដែលបច្ចុប្បន្ននេះត្រូវបានចាត់ថា ជាអ្នករស់នៅក្នុងកន្លែងតាំងលំនៅ ឬជំរក ឆ "ខុសច្បាប់"។

(iv) ចំនួនមនុស្សដែលត្រូវបានដេញចេញក្នុងរយៈ ៥ ឆ្នាំចុងក្រោយនេះ និងចំនួនមនុស្សដែលសព្វថ្ងៃនេះខ្វះកិច្ចការពារខាងច្បាប់ណាមួយទល់នឹងការបណ្តេញចេញតាមទំនើងចិត្ត ឬការបណ្តេញដោយរូបភាពណាដទៃទៀត។

(v) ចំនួនមនុស្សដែលការចំណាយចំពោះលំនៅដ្ឋានរបស់គេ មានកំរិតខ្ពស់ជាងថ្លៃកំណត់ដោយរដ្ឋាភិបាលដែលល្មមលៃលកបាន ដោយផ្អែកទៅលើសមត្ថភាពបង់ថ្លៃ ឬ អត្រានៃ ចំណូល។

(vi) ចំនួនមនុស្សដែលចុះក្នុងបញ្ជីរង់ចាំទទួលលំនៅ ថេរវេលាមធ្យមនៃការរង់ចាំ និង វិធានការចាត់ដើម្បីរំលោះបញ្ជីនេះ និងដើម្បីជួយអ្នកមានឈ្មោះក្នុងបញ្ជី ឱ្យមានលំនៅជាបណ្តោះអាសន្ន។

(vii) ចំនួនមនុស្សដែលរស់នៅក្នុងប្រភេទលំនៅផ្សេងៗដូចជា អាគារសង្គមកិច្ច ឬ សាធារណៈ លំនៅឯកជន មនុស្សមានលំនៅខ្លួនឯង លំនៅ"ខុសច្បាប់" និងផ្សេងៗ ទៀត។

(គ) សូមផ្តល់នូវព័តិមានអំពីថាមានច្បាប់ដែលមានផលទៅលើការសំរេចបានសិទ្ធិមានលំនៅ ដែរឬទេ រួមមាន :

i) ច្បាប់ដែលឱ្យខ្លឹមសារដល់សិទ្ធិមានទីលំនៅ ក្នុងន័យដែលថាច្បាប់នេះ កំណត់ថាតើសិទ្ធិមានទីលំនៅនេះ មានធាតុផ្សំអ្វីខ្លះ។

ii) ច្បាប់ស្តីពីលំនៅស្ថាន ច្បាប់ស្តីពីមនុស្សឥតជំរក ច្បាប់ស្តីពីការរៀបចំសហគមន៍ក្រុង។ល។

iii) ច្បាប់ទាក់ទងទៅនឹងការប្រើប្រាស់ដី ការចែកចាយដី ការផ្តល់ដី នគរូបនីយកម្ម ការដកហូតដីដើម្បីផលប្រយោជន៍សាធារណៈរួមមាន បទបញ្ញត្តិស្តីពីការទូទាត់ ការធ្វើផែនការ គ្រប់គ្រងដីរួមមាននីតិវិធីនៃការចូលរួមរបស់សមាគមន៍។

iv) ច្បាប់ស្តីពី សិទ្ធិមានសន្តិសុខក្នុងការកាន់កាប់ដី សិទ្ធិមានកិច្ចការការពារទល់នឹងការ បណ្តេញចេញ សិទ្ធិហិរញ្ញប្បទាននៃលំនៅស្ថានការនិងគ្រប់គ្រងលើឈ្នួលផ្ទះ (ឬមានប្រាក់សំរាប់ជួយឧបត្ថម្ភការបង់ថ្លៃផ្ទះ) ភាពលៃលកបង់ថ្លៃលំនៅដ្ឋានបាន។ល។

v) ច្បាប់ទាក់ទងទៅនឹងបទបញ្ញាទាំងឡាយអំពីសំណង់ អំពីបទដ្ឋាន និងក្បួនសំណង់ ហើយនិងការជួយផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ។

vi) ច្បាប់ដែលហាមឃាត់ការរើសអើងតាមគ្រប់រូបភាពក្នុងវិស័យលំនៅដ្ឋាន រួមមាន ការរើសអើងចំពោះក្រុមដែលជាប្រពៃណីដែលអត់ត្រូវបានការពារ ។

vii) ច្បាប់ដែលហាមឃាត់ការបណ្តេញចេញតាមគ្រប់រូបភាព

viii) វិធានការនិតិបញ្ញត្តិដែលនិរាករណ៍ ឬកែទំរង់ច្បាប់ជាធរមានទាំងឡាយដែលធ្វើឱ្យខូចការសំរេចសិទ្ធិមានលំនៅស្ថាន ។

ix) ច្បាប់ដាក់កំរិតលើការទិញដីទុកលក់យកចំណេញ ពិសេសវិធីកេងយកចំណេញនេះមានផលអវិជ្ជមានលើការសំរេចសិទ្ធិមានលំនៅដ្ឋាននៅក្នុងគ្រប់ផ្នែកនៃសង្គម ។

x) វិធានការខាងនីតិបញ្ញត្តិដែលផ្តល់ឱ្យអ្នករស់នៅលើតំបន់ "ខុសច្បាប់" មានលិខិតកាន់កាប់ស្របច្បាប់ ។

xi) ច្បាប់ទាក់ទងទៅនឹងការធ្វើផែនការនៃបរិដ្ឋាន និងទាក់ទងទៅនឹងសុខភាពក្នុងលំនៅស្ថាន និងក្នុងការតាំងទីលំនៅរបស់មនុស្ស ។

ឃ. សូមឱ្យពត៌មាន អំពីវិធានការទាំងអស់ដែលត្រូវបានប្រកាន់យក ដើម្បីសំរេចសិទ្ធិលើលំនៅដ្ឋានរួមមាន :

i) វិធានការប្រកាន់យកដើម្បីលើកទឹកចិត្ត"យុទ្ធសាស្ត្រស្ថានីតិសម្បទា" ដែលអាស្រ័យដោយយុទ្ធសាស្ត្រនេះ បណ្តាអង្គការរបស់សហគមន៍ និង "ផ្នែកក្រៅប្រព័ន្ធ" អាចសាងសង់លំនៅដ្ឋាន និងសេវាដែលទាក់ទង ។ តើអង្គការបែបនេះ មានសេរីភាពនឹងដំណើរការឬទេ? ។ អង្គការទាំងនេះបានទទួលជំនួយពីរដ្ឋាភិបាលដែរឬទេ? ។

ii) វិធានការដែលរដ្ឋបានយកដើម្បីសាងសង់លំនៅដ្ឋាន និងបង្កើនការសាងសង់ដទៃទៀត ដែលមនុស្សអាចលៃលកជួលផ្ទះនៅបាន ។

iii) វិធានការប្រកាន់យកដើម្បីបណ្តោះចេញនូវដីដែលឥតប្រើប្រាស់ ឬប្រើប្រាស់មិនពេញលេញ ឬប្រើប្រាស់ខុស ។

iv) វិធានការខាងហិរញ្ញវត្ថុប្រកាន់យកដោយរដ្ឋ រួមមាន ការវាយលំអិតអំពីថវិកា ក្រសួងលំនៅដ្ឋាន ឬក្រសួងពាក់ព័ន្ធ ដោយគិតជាភាគរយនៃថវិកាជាតិ ។

v) វិធានការប្រកាន់យកដើម្បីធានាថា ជំនួយអន្តរជាតិសំរាប់លំនៅដ្ឋាន និងសំរាប់ការតាំងទីលំនៅរបស់មនុស្ស ត្រូវបានប្រើប្រាស់ដើម្បីបំពេញសេចក្តីត្រូវការរបស់ក្រុមដែលបាត់បង់ប្រៀបខ្លាំងជាងគេ ។

vi) វិធានការប្រកាន់យកដើម្បីលើកទឹកចិត្តការអភិវឌ្ឍន៍មជ្ឈមណ្ឌល ក្រុងតូចៗ ឬមធ្យម ពិសេសនៅជនបទ។

vii) វិធានការប្រកាន់យកជាអាទិ៍ក្នុងកម្លុងពេលកម្មវិធីរៀបចំទីក្រុងជាថ្មី គំរោងអភិវឌ្ឍន៍ជាថ្មី ការតម្លើងគុណភាពរមណីយដ្ឋាន កម្មវិធីរៀបចំការសំដែងអន្តរជាតិផ្សេងៗ (ល្បែងអូឡាំពិក, ពិពណ៌, សន្និសីទ។ល។) "យុទ្ធនាការធ្វើឱ្យទីក្រុងឆើតឆាយ" ។ល។ ដែលជាវិធានការ ដើម្បីការពារទល់នឹងការបណ្តេញចេញ, ធានាការសង់លំនៅឡើងវិញ ផ្អែកការព្រមព្រៀងគ្នាទៅវិញទៅមកដោយមនុស្សដែលរស់នៅលើ ឬ ក្បែរទីកន្លែងដែលប៉ះពាល់នោះ។

ង. នៅក្នុងកម្លុងពេលត្រូវរាយការណ៍ តើមានការផ្លាស់ប្តូរក្នុងនយោបាយជាតិ ក្នុងច្បាប់ និងការអនុវត្តន៍ដែលមានផលអវិជ្ជមានដល់សិទ្ធិមានលំនៅដ្ឋានគ្រប់គ្រាន់ ឬទេ?។ បើសិនជាមាន សូមពិពណ៌នាអំពីការផ្លាស់ប្តូរនោះ ព្រមទាំងវាយតម្លៃផលនៃការផ្លាស់ប្តូរនេះ។

៤. សូមផ្តល់សេចក្តីលំអិត អំពីការលំបាក ឬការខ្វះខាតដែលបានជួបប្រទះនៅក្នុងការធ្វើឱ្យបានសំរេចសិទ្ធិដែលចែងនៅក្នុងមាត្រា១១ និងវិធានការប្រកាន់យកដើម្បីកែការខ្វះខាតទាំងនោះ(បើសិនជាអ្នកមិនទាន់បានពិពណ៌នានៅក្នុងរបាយការណ៍នេះទេនោះ)។

៥. សូមបញ្ជាក់ពីតួនាទីរបស់ជំនួយឧបត្ថម្ភអន្តរជាតិក្នុងការធ្វើឱ្យបានសំរេចនូវសិទ្ធិដែលចែងក្នុងមាត្រា ១១។

**អត្ថបទនៃសេចក្តីអធិប្បាយទូទៅលេខ ៤ (១៩៩១)**

**សិទ្ធិមានទីលំនៅសមស្រប**

១. តាមមាត្រា ១១ (១) នៃកតិកាសញ្ញានេះ រដ្ឋជាភាគី "ទទួលស្គាល់សិទ្ធិរបស់បុគ្គលគ្រប់រូប ក្នុងការមានកំរិតជីវភាពសមស្របសំរាប់ខ្លួនឯងនិងគ្រួសារ រាប់បញ្ចូលទាំងការមានចំណីអាហារ សំលៀកបំពាក់ និងទីជម្រកសមស្រប និងសិទ្ធិក្នុងការធ្វើអោយប្រសើរឡើងជាបន្តបន្ទាប់នូវកំរិតជីវភាពរស់នៅ"។ សិទ្ធិ ទទួលបានទីជម្រកសមស្របដែលបែកចេញមកពីសិទ្ធិទទួលបានជីវភាពរស់នៅសមស្រប គឺជាសារៈសំខាន់ស្នូលក្នុងការអាស្រ័យផលសិទ្ធិទាំងឡាយក្នុងវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌។

២. គណៈកម្មាធិការមានលទ្ធភាពក្នុងការប្រមូលផ្តុំពតិមានមួយចំនួធំដែលទាក់ទិននឹងសិទ្ធិនេះ។ ចាប់ពីឆ្នាំ ១៩៧៩ មក គណៈកម្មាធិការនេះ និងបុព្វធិការីរបស់ខ្លួនបានពិនិត្យរបាយការណ៍ចំនួន ៧៥ ដែលទាក់ទិនដល់សិទ្ធិទទួលទីជម្រកសមស្រប។ គណៈកម្មាធិការបានចំណាយពេល ១ ថ្ងៃ ដើម្បីធ្វើការពិភាក្សាទូទៅលើបញ្ហានេះក្នុងសម័យប្រជុំលើកទី ៣ (សូមអានចំណុច E/១៩៨៩/២២ វាក្យខណ្ឌ ៣១២) និងក្នុងសម័យប្រជុំលើកទី៤ (E/១៩៩០/២៣ វាក្យខណ្ឌ ២៨១-២៨៥)។ លើសពីនេះ គណៈកម្មាធិការបានកត់សំគាល់យ៉ាងយកចិត្តទុក

ដាក់លើពតិមានដែលបានមកពី **ឆ្នាំអន្តរជាតិដើម្បីទីជម្រកសំរាប់ជនគ្មានទីជម្រក** (International Year of Shelter for Homeless)(១៩៨៧) ដោយរាប់ទាំង**យុទ្ធសាស្ត្រជាសកល ដើម្បីមានទីជម្រក ឆ្នាំ ២000** ដែលមហាសន្និបាតបានអនុម័តតាមសេចក្តីសំរេចលេខ ៤២/១៩៩ ចុះថ្ងៃទី ១១ ធ្នូ ឆ្នាំ ១៩៨៧។ គណៈកម្មាធិការក៏បានពិនិត្យរបាយការណ៍ទាក់ទិនជាច្រើនទៀត និងឯកសារផ្សេងៗ របស់គណៈកម្មការសិទ្ធមនុស្សនិងរបស់អនុគណៈកម្មការដើម្បីទប់ស្កាត់ការរើសអើង និងដើម្បីការពារអប្បរភាគជន។

៣. ទោះបីជាមានឧបករណ៍អន្តរជាតិជាច្រើន លើកឡើងពីទិដ្ឋភាពផ្សេងគ្នានៃសិទ្ធិទទួលបានទីជំរកសមស្របមាត្រា ១១ (១) នៃកតិកាសញ្ញានេះគឺជាបទបញ្ញត្តិពិស្តារបំផុត ហើយអាចប្រហែលជាបទបញ្ញត្តិដែលទាក់ទិនសំខាន់បំផុត។

៤. ទោះបីជា សហគមន៏អន្តរជាតិ ជារឿយៗបានបញ្ជាក់ឡើងវិញពីសារៈសំខាន់នៃការគោរពអោយពេញទំហឹងនូវសិទ្ធិមានទីជម្រកសមស្របក្តី តែក៏នៅមានគម្លាតដ៏ធំរវាងបទដ្ឋានទាំងឡាយដែលមាននៅក្នុងមាត្រា ១១ (១) នៃកតិកាសញ្ញានេះ និងស្ថានភាពជាក់ស្តែង ដែលកំពុងគ្របដណ្តប់នៅក្នុងតំបន់ជាច្រើនលើពិភពលោក។ ទន្ទឹមពេលដែលបញ្ហាជាច្រើនកំពុងមានជាពិសេសនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៏មួយចំនួន ដែលប្រឈមមុខនឹងបញ្ហាធនធាន និងបញ្ហាផ្សេងៗ គណៈកម្មាធិការក៏សង្កេតឃើញថាបញ្ហាគ្មានផ្ទះសម្បែង និងការគ្មានទីជម្រកមិនសមស្របនៅតែមាននៅក្នុងបណ្តាប្រទេសដែលមានសេដ្ឋកិច្ចលូតលាស់ខ្លាំងផងដែរ។ អង្គការសហប្រជាជាតិប៉ាន់ស្មានថា មានមនុស្សជាង ១០០ លាននាក់ដែលគ្មានផ្ទះសម្បែងនៅទូទាំងពិភពលោក ហើយមានមនុស្សជាង ១ កោដិនាក់មានទីជម្រកមិនសមស្រប។ គ្មានសញ្ញាណាមួយដែលបង្ហាញថា ចំនួននេះកំពុងចុះថយនោះទេ។ វាហាក់ដូចជាច្បាស់ថា គ្មានរដ្ឋជាភាគីណាមួយគេចផុតពីបញ្ហានោះទេ បើមិនមានបញ្ហាមួយក៏មានបញ្ហាមួយទៀតដែរទាក់ទងនឹងសិទ្ធិមានទីជម្រក ។

៥. ក្នុងករណីខ្លះ របាយការណ៍របស់រដ្ឋជាភាគីដែលត្រូវបានពិនិត្យដោយគណៈកម្មាធិការបានទទួលស្គាល់ ហើយបានពិពណ៌នាពីការលំបាកផ្សេងៗក្នុងការធានាឱ្យបាននូវសិទ្ធិមានទីជម្រកសមស្របនេះ។ ក៏ប៉ុន្តែ ពតិមានភាគច្រើនដែលផ្តល់ជូនមានលក្ខណៈមិនគ្រប់គ្រាន់ ជាហេតុធ្វើអោយគណៈកម្មាធិការទទួលមិនបាននូវរូបភាពច្បាស់អំពីស្ថានភាពពិតប្រាកដដែលមានក្នុងរដ្ឋនោះ។ ដូច្នេះ សេចក្តីអធិប្បាយទូទៅនេះមានគោលបំណងដើម្បីលើកបង្ហាញនូវបញ្ហាសំខាន់ៗដែលគណៈកម្មាធិការយល់ថាមានសារសំខាន់ទាក់ទិននឹងសិទ្ធិនេះ។

៦. សិទ្ធិមានទីជម្រកសមស្របត្រូវមានចំពោះជនគ្រប់រូប។ ថ្វីបើការយោងដល់ពាក្យ"សំរាប់ខ្លួនឯង និងគ្រួសារ" ឆ្លុះបញ្ចាំងនូវការសន្មត់ពីតួនាទីខាងភេទ និងលំនាំសកម្មភាពសេដ្ឋកិច្ចដែលត្រូវបានទទួលយក ជាទូទៅក្នុងឆ្នាំ ១៩៦៦ នៅពេលដែលកតិកាសញ្ញាត្រូវបានអនុម័ត ឃ្លានេះមិនអាចបកស្រាយក្នុងពេលបច្ចុប្បន្នដោយមានន័យថា ជាការកំហិតព្រំដែនទៅលើការអនុវត្តសិទ្ធិចំពោះបុគ្គលគ្រប់រូប ឬស្ត្រីមេគ្រួសារ ឬក្រុមមនុស្សផ្សេងៗ

ទៀតឡើយ។ ដូច្នេះ ទស្សនៈនៃពាក្យ"គ្រួសារ" ត្រូវតែបានយល់ដឹងតាមន័យដ៏ទូលំទូលាយមួយ។ លើសពីនេះ បុគ្គលគ្រប់រូប ព្រមទាំងគ្រួសារទាំងឡាយមានសិទ្ធិមានទីជម្រកសមស្របដោយមិនគិតពីអាយុ ស្ថានភាពសេដ្ឋកិច្ច ក្រុមឬសម្ព័ន្ធភាពដទៃទៀត ឬឋានៈ និងកត្តាផ្សេងៗឡើយ។ ជាពិសេស ការប្រើនូវសិទ្ធិទាំងនេះ ដោយអនុលោមតាមមាត្រា ២ (២) នៃកតិកាសញ្ញានេះ មិនត្រូវមានការរើសអើងតាមរូបភាពណាទាំងអស់។

៧. តាមទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមានទីជម្រកសមស្រប មិនត្រូវមានការបកស្រាយតាមន័យចង្អៀត ឬរិតត្បិតពេកនោះទេ ឧទាហរណ៍ រហូតដល់ថាលំនៅសមរម្យស្មើនឹងពាក្យមានត្រឹមតែដំបូលមួយគ្របពីលើក្បាល ឬចាត់ទុកថាទីជម្រកជារបស់ប្រើប្រាស់មួយមុខប៉ុណ្ណោះ។ ផ្ទុយទៅវិញត្រូវយល់ថាជាសិទ្ធិរស់នៅកន្លែងណាមួយប្រកបដោយសន្តិសុខ សន្តិភាព និងសេចក្តីថ្លៃថ្នូរ។ គំនិតនេះសមស្របក្នុងហេតុផលពីរយ៉ាង។ ហេតុផលទីមួយ សិទ្ធិមានទីជម្រកគឺផ្សាភ្ជាប់មិនដាច់ទៅនឹងសិទ្ធិមនុស្សផ្សេងទៀត និងគោលការណ៍មូលដ្ឋានផ្សេងៗដែលកតិកាសញ្ញានេះឈរលើ។ ដោយសិទ្ធិទាំងនេះកើតមកពី"សេចក្តីថ្លៃថ្នូរពីកំណើតរបស់មនុស្ស" ដូចដែលកតិកាសញ្ញាបានចែង ដូច្នេះទាមទារឱ្យមានការបកស្រាយពាក្យ"ទីជម្រក"ដោយគិតទៅដល់កត្តាសំរេចផ្សេងៗសំខាន់បំផុតគឺថាសិទ្ធិមានទីជម្រកត្រូវតែបានធានាដល់បុគ្គលគ្រប់រូប ដោយមិនគិតពីប្រាក់ចំណូល ឬធនធានសេដ្ឋកិច្ចឡើយ។ ហេតុផលទីពីរ យោងតាមមាត្រា ១១(១) ត្រូវតែបកស្រាយថាមិនត្រឹមតែមានទីជម្រកនោះទេតែត្រូវតែជាទីជម្រកសមស្របទៀតផង។ គណៈកម្មការស្តីពីការតាំងទីលំនៅ និងយុទ្ធសាស្ត្រសាកលដើម្បីទីជម្រកឆ្នាំ ២000 (Global Strategy for Shelter to the Year 2000) បានកំណត់ថា "ទីជម្រកសមស្រប មានន័យថា.... មានសិទ្ធិនៃជីវភាពឯកជនគ្រប់គ្រាន់ មានទំហំសមរម្យ មានសន្តិសុខគ្រប់គ្រាន់ មានពន្លឺ និងមានខ្យល់ចេញចូលគ្រប់គ្រាន់ មានហេដ្ឋារចនាសម្ព័ន្ធជាមូលដ្ឋានគ្រប់គ្រាន់ ហើយមានទីតាំងសមស្របទាក់ទងនិងការងារ និងមានផាសុកូបករណ៍ជាមូលដ្ឋានគ្រប់គ្រាន់ ហើយត្រូវមានតំលៃសមស្របដែលប្រជាជនអាចទទួលយកបាន"។

៨. ដូច្នេះ គោលគំនិតអំពីភាពសមស្រប គឺទាក់ទងយ៉ាងសំខាន់ទៅនឹងសិទ្ធិមានទីជម្រក ដោយសារគំនិតនេះបញ្ជាក់កត្តាមួយចំនួនដែលត្រូវគិតក្នុងការកំណត់ថា តើទីជម្រករបៀបណាដែលអាចចាត់ទុកថាជា"ទីជម្រកសមស្រប" ដែលជាគោលបំណងនៃកតិកាសញ្ញានេះ។ ថ្វីបើ ភាពសមស្របត្រូវបានកំណត់មួយផ្នែកទៅតាមកត្តាសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ធាតុអាកាស អេកូឡូស៊ី និងកត្តាផ្សេងៗទៀតក្តី គណៈកម្មាធិការ នៅតែជឿជាក់ថាអាចរកឃើញនូវទិដ្ឋភាពខ្លះនៃសិទ្ធិនេះដែលត្រូវតែគិតដល់ ដើម្បីកំណត់និយមន័យនៃពាក្យ"សមស្រប" ក្នុងបរិបទណាមួយ។ ទិដ្ឋភាពទាំងនេះរួមមាន :

(ក) សន្តិសុខគតិយុត្តនៃរបបកាន់កាប់ទ្រព្យសម្បត្តិ។ ការកាន់កាប់មានរូបភាពជាច្រើន រាប់បញ្ចូលទាំងការជួលកន្លែងស្នាក់នៅ(ឯកជន និងសាធារណៈ) ផ្ទះសម្បែងរួមគ្នា ការជួលផ្ទះ ការកាន់កាប់ជាកម្មសិទ្ធិ ការតាំងទីលំនៅក្នុងគ្រាអាសន្ន និងការតាំងទីលំនៅក្រៅផ្លូវការ រួមមានការកាន់កាប់ដីធ្លី ឬទ្រព្យសម្បត្តិ។ ទោះបីជាប្រភេទនៃការកាន់កាប់ជាអ្វីក៏ដោយ បុគ្គលគ្រប់រូបគួរមានសន្តិសុខក្នុងការកាន់កាប់ក្នុងកំរិតណាមួយ ដែលធានា

នូវការពារតាមផ្លូវច្បាប់ទល់នឹងការបណ្តេញចេញដោយ បង្ខំ ការរំខាន និងការគំរាមកំហែង ផ្សេងទៀត។ ដូច្នេះ រដ្ឋជាភាគីត្រូវចាត់វិធានការទាំងឡាយជា បន្ទាន់ក្នុងទិសដៅដើម្បីផ្តល់សន្តិសុខគតិយុត្តក្នុងការកាន់កាប់ដល់បុគ្គល និងគ្រួសារទាំងឡាយ ដែលកំពុងខ្វះខាតការការពារបែបនោះ ដោយធ្វើការពិគ្រោះយោបល់ត្រឹមត្រូវជាមួយបុគ្គល និងក្រុមទាំងឡាយដែលរងការប៉ះទង្គិចនោះ។

(ខ) ការមាន សេវាកម្ម សំភារៈ ផាសុកូបករណ៍ និងហេដ្ឋារចនាសម្ព័ន្ធ។ ទីជម្រកសមស្របគឺត្រូវមាន ផាសុកូបករណ៍សំខាន់មួយចំនួនសំរាប់សុខភាព សន្តិសុខ ផាសុកភាព និងការទទួលចំណីអាហារ។ អ្នកទទួលផល ពីសិទ្ធិមានទីជម្រកសមស្រប ត្រូវមានលទ្ធភាពក្នុងការប្រើប្រាស់ជានិរន្តនូវធនធានធម្មជាតិ និងធនធានសាធារណៈ ទឹកស្អាត ថាមពលសម្រាប់ដាំស្ល កំដៅ និងភ្លើងបំភ្លឺ អនាម័យ និងឧបករណ៍បោកគក់ មធ្យោបាយរក្សាទុកម្ហូប អាហារ ធុងសំរាម ប្រព័ន្ធលូទឹក និងសេវាកម្ម សង្គ្រោះបន្ទាន់ ។

(គ) ភាពអាចលៃលកបាន។ ការចំណាយហិរញ្ញវត្ថុសំរាប់ខ្លួនឯង ឬសំរាប់គ្រួសារ ពាក់ព័ន្ធនឹងទី ជម្រកគួរតែឋិតក្នុងកំរិតណាមួយដែលមិនគំរាមកំហែង ឬធ្វើឱ្យអន្តរាយដល់ការបំពេញបាននូវសេចក្តីត្រូវការជា មូលដ្ឋានផ្សេងៗនោះឡើយ។ រដ្ឋជាភាគីត្រូវចាត់វិធានការដើម្បីធានាថា ភាគរយនៃការចំណាយដែលទាក់ទង នឹងទីជម្រក ជាទូទៅត្រូវសមស្របទៅនឹងកំរិតនៃប្រាក់ចំណូល។ រដ្ឋជាភាគី គួរតែបង្កើតអោយមានមូលនិធិ ឧបត្ថម្ភក្នុងការតាំងទីជម្រក សំរាប់អ្នកទាំងឡាយណាដែលមិនមានលទ្ធភាពរកទីជម្រកសមស្របបានព្រមទាំង ទម្រង់ និងកំរិតហិរញ្ញប្បទាន ត្រូវគ្រប់គ្រាន់សំរាប់បំពេញសេចក្តីត្រូវការក្នុងការតាំងទីជម្រក។ អនុលោមតាម គោលការណ៍នៃភាពអាចលៃលកបាន អ្នកកាន់កាប់គួរតែបានការពារតាមគ្រប់មធ្យោបាយសមស្របទល់នឹង អត្រាថ្លៃឈ្នួលមិនសមស្រប ឬការតម្លើងថ្លៃឈ្នួលមិនសមស្រប។ ក្នុងសង្គមដែលយកសំភារៈធម្មជាតិធ្វើជាប្រភព សំភារៈដ៏សំខាន់សំរាប់សង់ទីលំនៅ រដ្ឋជាភាគីត្រូវចាត់វិធានការដើម្បីធានាថា សំភារៈទាំងនោះអាចរកបាននៅ ពេលដែលត្រូវការ។

(ឃ) ភាពអាចរស់នៅបាន។ ទីលំនៅសមស្របត្រូវតែជាលំនៅដែលអាចរស់នៅបាន ដោយផ្តល់ឱ្យអ្នក រស់នៅមានទំហំសមស្រប ហើយការពារពីភាពរងារ សើម ក្តៅ ភ្លៀង ខ្យល់ ឬ ការគំរាមកំហែង ផ្សេងទៀតដល់ សុខភាព ការពារទល់នឹងការគ្រោះថ្នាក់ពីការបាក់សំណង់ និងការកើតរោគផ្សេងៗ។ សុវត្ថិភាពខាងរាងកាយត្រូវ ធានាដល់អ្នកកាន់កាប់។ គណៈកម្មាធិការជំរុញឱ្យរដ្ឋជាភាគីអនុវត្តឱ្យ បានល្អិតល្អន់នូវ"គោលការណ៍ទីលំនៅមាន សុខភាពល្អ"ដែលរៀបចំឡើងដោយអង្គការសុខភាព ពិភពលោកក្នុងទស្សនៈថា ទីលំនៅជាកត្តាបរិស្ថានមួយ ដែលជាញឹកញាប់ទាក់ទងនឹងការឆ្លងជំងឺរាលដាល។ ឧទាហរណ៍ កាលណាទីលំនៅមិនសមស្រប ហើយជីវភាពរស់ នៅមិនគ្រប់គ្រាន់វានឹងបណ្តាលអោយមានអត្រាស្លាប់ និងអត្រាកើតជំងឺកាន់តែខ្ពស់ឡើងៗ ។

(ង) ភាពងាយរកបាន។ ទីលំនៅសមស្របគឺត្រូវតែងាយរកបានចំពោះ អ្នកណាដែលមានសិទ្ធិត្រូវបាន។ ក្រុមជនទាំងឡាយដែលបាត់បង់ប្រៀប ត្រូវបានផ្តល់ទាំងស្រុងនូវលទ្ធភាពប្រើប្រាស់ដោយស្មេរភាពនូវធនធាន

ទាំងឡាយសំរាប់ការមានទីលំនៅសមស្រប។ ដូច្នេះ ក្រុមជនដែលបាត់បង់ប្រៀប ដូចជា ជនចាស់ជរា កុមារ ជនពិការ បុគ្គលមានជំងឺមិនជា បុគ្គលមានផ្ទុកមេរោគហ៊ីវ បុគ្គលមានបញ្ហា សុខភាពជាប្រចាំ ជនវិកលចរិត បុគ្គលរងគ្រោះដោយមហន្តរាយធម្មជាតិ ជនរស់នៅក្នុងតំបន់មានគ្រោះថ្នាក់ និងក្រុមជនដទៃទៀត ត្រូវបានធានាឱ្យមានការពិចារណាជាអាទិភាពចំពោះបញ្ហាទីលំនៅ។ ទាំងច្បាប់ ទាំងគោលនយោបាយស្តីពីទីជម្រកត្រូវពិចារណាឱ្យបានល្អិតល្អន់ដល់សេចក្តីត្រូវ ការជាពិសេសខាងទីជម្រកសំរាប់ក្រុមជនទាំងនេះ។ នៅក្នុងរដ្ឋជាភាគីជាច្រើន ការបង្កើននូវលទ្ធភាពក្នុងការប្រើប្រាស់ដីធ្លីសំរាប់ជនឥតដីធ្លី ឬក្រុមជនក្រីក្រក្នុងសង្គម គឺជាទីដៅនយោបាយស្នូលមួយ។ កាតព្វកិច្ចជាក់ស្តែងរបស់រដ្ឋាភិបាល ចាំបាច់ត្រូវតែបង្កើតឡើងក្នុងទិសដៅដើម្បីធ្វើឱ្យសិទ្ធិរបស់បុគ្គលគ្រប់រូប ដើម្បីមានទីកន្លែងរស់នៅដោយសន្តិភាព និងសេចក្តីថ្លៃថ្នូរ កើតជារូបរាងឡើងដោយចាត់ទុកលទ្ធភាពមានដីថាជាអ្វីគេអាចទទួលបាន។

(ច) ទីតាំង។ ទីលំនៅសមស្របត្រូវឋិតក្នុងទីន្លែងដែលអនុញ្ញាតឱ្យមានការងាយស្រួលទៅរកទីកន្លែងការងារ សេវាកម្មសុខភាព សាលារៀន មណ្ឌលគាំពារទារក និងផាសុកូបករណ៍សង្គមផ្សេងៗទៀត។ ពិតណាស់ថាទាំងនៅទីក្រុងធំៗ និងតំបន់ជនបទមួយចំនួនដែលតម្លៃពេលវេលា និងហិរញ្ញវត្ថុ សំរាប់ចំណាយដើម្បីធ្វើដំណើរទៅមកកន្លែងធ្វើការអាចខ្ពស់ហួសហេតុសំរាប់គ្រួសារដែលក្រីក្រ។ ដូចគ្នានេះដែរ ទីជម្រកមិនត្រូវសាងសង់នៅតំបន់ដែលមានបរិយាកាសអាប់អួរ ឬនៅម្តុំដែលជាប្រភពនៃការបំពុលដែលគំរាមកំហែងដល់សិទ្ធិមានសុខភាពសំរាប់អ្នកតាំងទីជម្រកទេ។

Comment [C1]:

(ឆ) ភាពសមស្របខាងវប្បធម៌។ របៀបនៃការសាងសង់ទីលំនៅ សំភារៈសំណង់ដែលប្រើ និងគោលគំនិតនៃការជ្រើសរើសរបៀបសាងសង់(ម៉ូតផ្ទះ) ត្រូវផ្តល់នូវលទ្ធភាពគ្រប់គ្រាន់ដែលអាចបង្ហាញនូវអត្តសញ្ញាណ និងភាពចំរុះខាងវប្បធម៌។ សកម្មភាពទាំងឡាយដែលបង្កើនឆ្ពោះទៅរកការអភិវឌ្ឍន៍ ឬការធ្វើទំនើបកម្មក្នុងវិស័យលំនៅដ្ឋានគួរធានាថា ទិដ្ឋភាពវប្បធម៌នៃលំនៅដ្ឋានមិនត្រូវឱ្យបាត់បង់ និងគណនាទីកន្លែងបច្ចេក-វិទ្យាទំនើបៗ ជាការសមស្របត្រូវបានធានាដែរ។

៩ ដូចបានគូសបញ្ជាក់ខាងលើ គេមិនអាចមើលឃើញថា សិទ្ធិមានទីជម្រកសមស្របនៅដាច់ស្រឡះពីសិទ្ធិមនុស្សទាំងឡាយដែលចែងក្នុងកតិកាសញ្ញាអន្តជាតិទាំងពីរ និងឧបករណ៍អន្តរជាតិផ្សេងៗជាធរមានទេ។ ទាក់ទងនឹងរឿងនេះ យើងបានពោលរួចមកហើយអំពីគោលគំនិតស្តីពីសេចក្តីថ្លៃថ្នូរបស់មនុស្ស និងគោលការណ៍ស្តីពីការមិនរើសអើង។ លើសពីនេះទៀត ការអាស្រ័យផលពេញទំហឹងនូវសិទ្ធិដទៃទៀត ដូចជា សិទ្ធិបញ្ចេញយោបល់ សិទ្ធិបង្កើតសមាគម (សំរាប់អ្នកកាន់កាប់ និងក្រុមជនរស់នៅក្នុងសហគមន៍) សិទ្ធិមានទីលំនៅ និងសិទ្ធិចូលរួមក្នុងការធ្វើសេចក្តីសំរេចសាធារណៈ គឺជាការចាំបាច់ខានមិនបាន ប្រសិនបើគេចង់ឱ្យសិទ្ធិមានទីលំនៅសមស្របត្រូវបានសំរេច និងទ្រទ្រង់ដោយក្រុមទាំងអស់នៅក្នុងសង្គម។ ដូចគ្នា នេះដែរ សិទ្ធិរួចផុតពីការជ្រៀតជ្រែកដោយ

ទំនើងចិត្ត ឬមិនស្របច្បាប់ទៅលើភាពឯកជន គ្រួសារ លំនៅដ្ឋាន ឬការឆ្លើយឆ្លង ជាទិដ្ឋភាពមួយដ៏សំខាន់ក្នុងការឱ្យនិយមន័យដល់សិទ្ធិមានទីលំនៅសមស្រប ។

១០. ទោះជាការអភិវឌ្ឍន៍ របស់ប្រទេសណាមួយស្ថិតក្នុងសភាពបែបណាក៏ដោយ មានវិធានការច្បាស់លាស់មួយចំនួនដែលត្រូវចាត់ជាបន្ទាន់។ ដូចដែលបានទទួលស្គាល់នៅក្នុង "យុទ្ធសាស្ត្រជាសកល ដើម្បីមានទី ជំរក" និងនៅក្នុងការវិភាគអន្តរជាតិផ្សេងៗទៀត វិធានការជាច្រើនតម្រូវឱ្យមានការលើកស្ទួយសិទ្ធិមានទីលំនៅដែលទាមទារឱ្យរដ្ឋាភិបាលចៀសវាងការអនុវត្តមួយចំនួន និងធ្វើការប្តេជ្ញាចិត្តក្នុងការជួយសំរួលកិច្ចព្រមព្រៀង"ជួយខ្លួនឯង"របស់ក្រុមដែលរងផលប៉ះពាល់ ។ ក្នុងករណីដែលវិធានការណាមួយត្រូវបានគិតថា ហួសពីកំរិតធនធានអតិបរមាដែលរដ្ឋជាភាគីមាន ជាការសមស្របរដ្ឋត្រូវធ្វើសំណើយ៉ាងឆាប់ដែលអាចធ្វើទៅបាន ដើម្បីស្នើសុំសហប្រត្តិការអន្តរជាតិស្របតាមមាត្រា ១១ (១), ២២ និង ២៣ នៃកតិកាសញ្ញា ហើយត្រូវផ្តល់ពត៌មានដល់គណៈកម្មាធិការពីករណីនេះផង ។

១១. រដ្ឋជាភាគីនិមួយៗ ត្រូវផ្តល់អាទិភាពអោយបានល្អត្រឹមត្រូវដល់ក្រុមជនទាំងឡាយដែលកំពុងរស់នៅក្នុងលក្ខខ័ណ្ឌមិនអំណោយផលដោយផ្តល់ការយកចិត្តទុកដាក់ជាពិសេសដល់ពួកគេ។ ហេតុដូច្នេះ មិនត្រូវរៀបចំគោលនយោបាយ និងធ្វើច្បាប់ដើម្បីជាប្រយោជន៍ដល់ក្រុមជនមួយចំនួនដែលមានប្រៀប ហើយដោយអ្នកដទៃបាត់បង់ប្រៀបទេ។ គណៈកម្មាធិការដឹងថា កត្តាខាងក្រៅអាចប៉ះពាល់ដល់សិទ្ធិក្នុងការធ្វើអោយប្រសើរឡើងនូវកំរិតនៃជីវភាពរស់នៅ ហើយក្នុងបណ្តាលរដ្ឋជាភាគីមួយចំនួនស្ថានភាពទូទៅនៃកំរិតជីវភាពរស់នៅបានធ្លាក់ចុះក្នុងកំឡុងទសវត្សឆ្នាំ ១៩៨០ ។ ប៉ុន្តែ តាមការកត់សំគាល់របស់គណៈកម្មាធិការក្នុងសេចក្តីអធិប្បាយទូទៅលេខ ២ (១៩៩០) (E/១៩៩០/២៣ ឧបសម្ព័ន្ធ III) ទោះបី ជាមានបញ្ហាដែលបណ្តាលមកពីមជ្ឈដ្ឋានខាងក្រៅក៏ដោយ កាតព្វកិច្ចក្នុងកតិកាសញ្ញានៅតែបន្តអនុវត្តតទៅទៀត ហើយប្រហែលជារិតតែសំខាន់ទៅទៀតនៅពេលដែលសេដ្ឋកិច្ចឱនថយ។ គណៈកម្មាធិការឃើញថា ការចុះថយទូទៅនៃកំរិតជីវភាពរស់នៅ និងសភាពលំនៅដ្ឋាន ដោយសារការសំរេចចិត្តខាងគោលនយោបាយ និងខាងលើច្បាប់របស់រដ្ឋជាភាគី ហើយក្នុងពេលគ្មានវិធានការខាងសំណងគឺជាការមិនសមស្របទៅតាមកាតព្វកិច្ចក្នុងកតិកាសញ្ញា។

១២. ថ្វីបើ មធ្យោបាយសមស្របបំផុតដើម្បីសំរេចបានពេញលេញនូវការប្រើប្រាស់សិទ្ធិមានទីជម្រកសមស្របមានភាពខុសគ្នាពីរដ្ឋជាភាគីមួយទៅរដ្ឋមួយទៀត កតិកាសញ្ញាតម្រូវយ៉ាងច្បាស់ឱ្យរដ្ឋជាភាគីនីមួយៗ ចាត់វិធានការចំបាច់ណាក៏បានដើម្បីសំរេចគោលបំណងនេះ។ ការណ៍នេះនឹងតម្រូវស្ទើរតែខានមិនបានឱ្យមានការអនុម័តយុទ្ធសាស្ត្រជាតិស្តីពីការមានទីជម្រក ដូចមានចែងក្នុងកថាខ័ណ្ឌទី ៣២ នៃយុទ្ធសាស្ត្រជាសកលស្តីពីការមានទីជម្រកដែល "កំណត់ទិសដៅសំរាប់អភិវឌ្ឍន៍លក្ខខ័ណ្ឌនៃទីជម្រក បង្ហាញពីធនធានដែលមានដើម្បីសំរេចទិសដៅនេះ និងមធ្យោបាយប្រើប្រាស់ធនធានដែលមានប្រសិទ្ធភាពនិងថោកបំផុត និងចែងការទទួលខុសត្រូវ និងរយៈពេលសំរាប់អនុវត្តវិធានការចាំបាច់នេះ"។ ដើម្បីរក្សាភាពទាក់ទង និង ទាំងប្រសិទ្ធភាពនៃយុទ្ធសាស្ត្រនោះ

ហើយដើម្បីធានាការគោរពសិទ្ធិមនុស្សដទៃទៀត យុទ្ធសាស្ត្រនោះគួរមានការពិគ្រោះយោបល់អោយបានទូលំទូលាយ ហើយមានការចូលរួមពីជនគ្រប់រូបដែលរងផលប៉ះពាល់ ដោយរាប់ទាំងជនគ្មានផ្ទះសម្បែង ជនមានទីលំនៅមិនសមស្រប និងតំណាងរបស់ពួកគេ។ លើសពីនេះ វិធានការដទៃទៀតគួរត្រូវបានចាត់ដើម្បីធានាអោយមានការសម្របសម្រួលរវាងក្រសួងនានា អាជ្ញាធរក្នុងតំបន់ និងអាជ្ញាធរមូលដ្ឋាន ដើម្បីធ្វើឱ្យគោលនយោបាយដែលទាក់ទិននានាស៊ីសង្វាក់គ្នា (សេដ្ឋកិច្ច កសិកម្ម បរិដ្ឋាន ថាមពល។ល។) ស្របនឹងកាតព្វកិច្ចទាំងឡាយដូចមានក្នុងមាត្រា ១១ នៃ កតិកាសញ្ញានេះ ។

១៣. ការតាមដានដ៏មានប្រសិទ្ធិភាពទៅលើស្ថានភាពទាក់ទិននឹងទីលំនៅ គឺជាកាតព្វកិច្ចមួយផ្សេងទៀតដែលត្រូវបំពេញជាបន្ទាន់។ ដើម្បីឱ្យរដ្ឋជាភាគីបំពេញបាននូវកាតព្វកិច្ចរបស់ខ្លួនតាម មាត្រា ១១ (១) រដ្ឋនោះ ត្រូវបង្ហាញអោយឃើញជាអាទិថា ខ្លួនបានអនុវត្តរាល់វិធានការចាំបាច់ទាំងឡាយដោយខ្លួនឯងផ្ទាល់ ឬតាមកិច្ចសហ-ប្រត្តិការអន្តរជាតិ ដើម្បីធ្វើឱ្យអោយបានទំហំនៃភាពគ្មានទីជម្រក និងភាពមានទីជម្រកមិនសមស្របនៅក្នុងយុត្តាធិការរបស់ខ្លួន។ ក្នុងន័យនេះ គោលការណ៍ណែនាំទូទៅដែលបានកែសំរួលទាក់ទិននឹងទំរង់ និងខ្លឹមសារនៃរបាយការណ៍ដែលគណៈកម្មាធិការបានអនុម័ត (E/C.១២/១៩៩១/១) បញ្ជាក់ ពីការចាំបាច់"ក្នុងការផ្តល់ពត៌មានពិស្តាអំពីក្រុមជនទាំងឡាយក្នុងសង្គមដែលងាយរងគ្រោះ និងបាត់បង់ប្រៀប...ក្នុងសង្គមទាក់ទងនឹងបញ្ហាទីជម្រក"។ ជាពិសេស ពត៌មានត្រូវបញ្ចូលនូវចំនួនអ្នកគ្មានផ្ទះសម្បែង ចំនួនគ្រួសារ ចំនួនអ្នកមានទីលំនៅមិនសមស្របហើយមិនទាន់ទទួលបាននូវគ្រឿងផ្តល់ផាសុកភាពជាមូលដ្ឋានសំរាប់ការរស់នៅ ចំនួនអ្នកតាំងទីលំនៅ "មិនស្របច្បាប់" ចំនួនអ្នកតាំងទីលំនៅ ដែលនឹងត្រូវបណ្តេញចេញ និងក្រុមជនដែលទទួលប្រាក់ចំណូលទាប ។

១៤. វិធានការទាំងឡាយដែលបានរៀបចំឡើង ដើម្បីសំរេចបាននូវកាតព្វកិច្ចរបស់រដ្ឋជាភាគីទាក់ទិននឹងសិទ្ធិមានទីលំនៅសមស្របអាចជាវិធានការចំរុះសាធារណៈ និងឯកជន ដែលចាត់ទុកថាជាវិធានការសមស្រប។ ក្នុងខណៈដែលមានរដ្ឋមួយចំនួនមានថវិកាសាធារណៈអាចយកទៅចំណាយផ្ទាល់លើការសាងសង់ផ្ទះថ្មី នៅមានករណីជាច្រើនទៀត តាមបទពិសោធនបានបង្ហាញថា រដ្ឋាភិបាលគ្មានលទ្ធភាពបំពេញបានពេញលេញនូវការខ្វះខាតខាងទីលំនៅដោយមិនបានសាងសង់ទីលំនៅសាធារណៈ។ ត្រូវជំរុញឱ្យរដ្ឋជាភាគីមាន "យុទ្ធសាស្ត្រធ្វើឱ្យបាន" គួបផ្សំ និងការប្តេជ្ញាចិត្តពេញទំហឹងទៅតាមកាតព្វកិច្ចស្តីពីសិទ្ធិមានទីជម្រកសមស្រប។ តាមអត្ថន័យ រដ្ឋជាភាគីមានកាតព្វកិច្ចបង្ហាញថាវិធានការទាំងឡាយដែលត្រូវបានអនុវត្ត គឺមានលក្ខណៈគ្រប់គ្រាន់ដើម្បីសំរេចបាននូវសិទ្ធិដល់បុគ្គលគ្រប់រូបក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ដោយយោងទៅតាមធនធានអតិបរិមាដែលខ្លួនមាន។

១៥. មានវិធានការជាច្រើនចាំបាច់តម្រូវអោយមានការបំរុងទុកផ្នែកធនធាន និងគំនិតផ្តួចផ្តើមគោលនយោ-បាយជាទូទៅ។ ទោះជាយ៉ាងនេះក៏ដោយ ក្នុងបរិបទនេះ វិធានការនីតិបញ្ញត្តិ និងរដ្ឋបាលមិនគួរវាយតម្លៃថា

អត់ប្រយោជន៍នោះទេ។ "យុទ្ធសាស្ត្រជាសកលស្តីពីការមានទីជម្រក" (វាក្យខ័ណ្ឌ៦៦-៦៧) បានផ្តល់ការយកចិត្តទុកដាក់ ទៅលើប្រភេទនៃវិធានការដែលអាចយកមកអនុវត្តបាន និងទៅលើសារៈសំខាន់នៃវិធានការទាំងនោះ។

១៦. ក្នុងរដ្ឋមួយចំនួន សិទ្ធិមានទីលំនៅសមស្របត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ។ ករណីដូចនេះ គណៈកម្មាធិការមានការចាប់អារម្មណ៍ជាពិសេសក្នុងការស្វែងយល់ពីច្បាប់ និងការអនុវត្តន៍ជាក់ស្តែង។ គួរផ្តល់ទៅគណៈកម្មាធិ-ការនូវពត៌មានលំអិតស្តីពីករណីពិសេសនេះ និងវិធានការផ្សេងទៀតដែលបញ្ជាក់ថាសិទ្ធិមានទីជម្រកសមស្របនេះអាចសំរេចបាន។

១៧. គណៈកម្មាធិការយល់ថា ធាតុផ្សំជាច្រើននៃសិទ្ធិមានទីលំនៅសមស្រប ត្រូវយ៉ាងហោចណាស់ស៊ីសង្វាក់គ្នានឹងការផ្តល់ដំណោះស្រាយតាមផ្លូវច្បាប់ក្នុងប្រទេស។ ផ្អែកតាមប្រព័ន្ធច្បាប់ វិស័យនេះអាចរាប់បញ្ចូល ជាអាទិ៍ : (ក) ការតវ៉ាតាមផ្លូវច្បាប់ក្នុងគោលបំណងរារាំងការបណ្តេញចេញ ឬកំទេចចោលដែលបានគ្រោងទុកតាមការចេញអធិបញ្ញាពីតុលាការ, (ខ) នីតិវិធីដែលតម្រូវឱ្យមានការសងជំងឺចិត្ត កាលណាការបណ្តេញចេញនោះគឺខុសច្បាប់, (គ) ការតវ៉ាប្រឆាំងនឹងសកម្មភាពខុសច្បាប់ដែលធ្វើឡើង ឬ គ្រាំទ្រដោយម្ចាស់ផ្ទះ (ទោះបីជាផ្ទះសាធារណៈ ឬឯកជនក៏ដោយ) ទាក់ទិននិងកំរិតថ្លៃឈ្នួល ការថែទាំផ្ទះ និងការប្រកាន់ពូជសាសន៍ ឬការរើសអើងផ្សេងទៀត, (ឃ) ពាក្យចោទប្រកាន់ស្តីពីការរើសអើងណាមួយក្នុងការបែងចែក និងលទ្ធភាពក្នុងការទទួលបានទីលំនៅ, និង (ង) ការតវ៉ាប្រឆាំងនឹងម្ចាស់ផ្ទះទាក់ទិននឹង លក្ខខ័ណ្ឌទីលំនៅមិនសមស្រប និងគ្មានសុខភាព។ នៅក្នុងប្រព័ន្ធច្បាប់ខ្លះ គេអាចសាកល្បងធ្វើបណ្តឹងរួមក្រុម ក្នុងករណីមានការកើតឡើងយ៉ាងខ្លាំងនូវកំរិតនៃភាពគ្មានផ្ទះសម្បែង ។

១៨. ក្នុងន័យនេះ គណៈកម្មាធិការចាត់ទុកថាការបណ្តេញចេញដោយបង្ខំ ជាភស្តុតាងខាងក្រៅដែលមិនស្របនិងតម្រូវការរបស់កតិកាសញ្ញានេះតែម្តង ហើយការបណ្តេញនេះអាចគិតថាសមហេតុសមផលតែក្នុងកាលៈទេសៈពិសេស និងចាំបាច់បំផុត ហើយត្រូវស្របតាមគោលការណ៍ច្បាប់អន្តរជាតិដែលពាក់ព័ន្ធ ។

១៩. នៅទីបំផុត មាត្រា ១១ (១) បញ្ចប់ដោយកំណត់កាតព្វកិច្ចឱ្យរដ្ឋជាភាគីទទួលស្គាល់នូវ "សារៈសំខាន់នៃកិច្ចសហប្រតិបត្តិការអន្តរជាតិផ្អែកតាមគោលការណ៍ស្ម័គ្រចិត្តដោយសេរី "។ ជាធម្មតា មានជំនួយអន្តរជាតិតិចជាង ៥% ត្រូវបានប្រើផ្ទាល់សំរាប់ទីលំនៅ ឬការតាំងទីលំនៅ ហើយការសំរេចផ្តល់ដូច្នេះបានជួយតិចតួចណាស់ដើម្បីដោះស្រាយសេចក្តីត្រូវការខាងទីលំនៅសំរាប់ក្រុមជនដែលបាត់បង់ប្រៀប។ រដ្ឋជាភាគីទាំងអ្នកទទួល និងទាំងអ្នកផ្តល់ជំនួយ គួរធានាឱ្យមានថវិកាមួយភាគធំដើម្បីទុកសំរាប់បង្កើតលក្ខខ័ណ្ឌឆ្ពោះទៅរកការធ្វើឱ្យមនុស្សមួយចំនួនធំកាន់តែមានទីលំនៅសមស្រប។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិទាំងឡាយដែលជំរុញនូវវិធានការកែតម្រូវរចនាសម្ព័ន្ធ គួរធានាថា វិធានការទាំងនេះមិនបានធ្វើអោយអន់ថយនូវការអាស្រ័យផលនូវសិទ្ធិមានទីលំនៅសមស្រប។ ពេលគិតទៅដល់កិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិ រដ្ឋជាភាគីគួរប្រឹងប្រែងចង្អុលបង្ហាញនូវ

វិស័យនានាទាក់ទិននឹងសិទ្ធិមានទីលំនៅសមស្រប កាលណាថវិកាខាងក្រៅអាចនាំអោយមានប្រសិទ្ធភាពបំផុត។ សំណើទាំងនេះគួរពិចារណាឱ្យបានល្អិតល្អន់ដល់សេចក្តីត្រូវការ និងទស្សនៈរបស់ក្រុមជនដែលរងផលប៉ះពាល់។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)
## មនុស្សមានពិការភាព

៣៣. ក្រៅពីការចាំបាច់ត្រូវធានាថា បុគ្គលមានពិការភាពមានលទ្ធភាពទទួលអាហារគ្រប់គ្រាន់ លំនៅដ្ឋានដែលមានការសំរួលគ្រប់គ្រាន់(ដែលគ្មានឧបសគ្គដល់ជនពិការ)និងសេចក្តីត្រូវការជាមូលដ្ឋានឯទៀតៗ វាជាការចាំបាច់ត្រូវធានាផងដែរឱ្យមាន "សេវាទ្រទ្រង់ រួមមាន ឧបករណ៍ជំនួយ" សំរាប់ "បុគ្គលមានពិការភាព ដើម្បីជួយពួកគេឱ្យបង្កើនកំរិតឯករាជភាពរបស់គេក្នុងជីវភាពប្រចាំថ្ងៃ និងអនុវត្តសិទ្ធិរបស់ពួកគេ"។ សិទ្ធិមានសំលៀកបំពាក់គ្រប់គ្រាន់ក៏មានសារសំខាន់ពិសេសគួរកត់សំគាល់សំរាប់បុគ្គលមានពិការភាព ដែលមានសេចក្តីត្រូវការណាមួយផ្នែកសំលៀកបំពាក់ ដើម្បីងាយឱ្យពួកគេអាចមានតួនាទីពេញលេញ និងប្រកបដោយប្រសិទ្ធិភាពក្នុងសង្គម។ បើអាចធ្វើបាន ជំនួយផ្ទាល់ខ្លួនដ៏សមស្របសំរាប់ប្រការនេះ ក៏គួរត្រូវបានផ្តល់ផងដែរ។ ជំនួយនោះត្រូវអនុវត្តដោយមានលក្ខណៈ និងស្មារតីគោរពយ៉ាងពេញលេញនូវសិទ្ធិមនុស្សនៃបុគ្គលដែលពាក់ពន្ធ័។ ក្នុងន័យដូចគ្នានេះដែរ ដូចដែលបានកត់សំគាល់ដោយគណៈកម្មាធិការនៅវាក្យខ័ណ្ឌទី ៨ នៃសេចក្តីអធិប្បាយទូទៅលេខ ៤ (សម័យប្រជុំលើកទី ៦ ឆ្នាំ ១៩៩១) សិទ្ធិមានលំនៅដ្ឋានសមរម្យរួមមានសិទ្ធិស្តីពីលំនៅដ្ឋានដែលអាចសំរួលចលនា និងការប្រើប្រាស់របស់បុគ្គលមានពិការភាព ។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៦ (១៩៩៥)
## សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់

៣២. ក្នុងបណ្តាគោលការណ៍នានារបស់ អ.ស.ប. សំរាប់មនុស្សចាស់ គោលការណ៍ទី១ ដែលចុះនៅដើមផ្នែកដែលទាក់ទងឯករាជ្យភាពរបស់មនុស្សចាស់បានចែងថាៈ " មនុស្សចាស់ត្រូវមានលទ្ធភាពបានស្បៀងអាហារ ទឹក លំនៅដ្ឋាន សំលៀកបំពាក់ និងការថែទាំសុខភាពគ្រប់គ្រាន់ តាមរយៈការផ្តល់ចំណូល ការគាំទ្រគ្រួសារ និងសហគមន៏ និងការជួយដោយខ្លួនឯង"។ គណៈកម្មាធិការបានផ្តល់សារៈសំខាន់យ៉ាងធំដល់គោលការណ៍នេះ ដែលទាមទារសិទ្ធិមនុស្សចាស់ដែលមាននៅក្នុងមាត្រា ១១ នៃកតិកាសញ្ញានេះ។

៣៣. អនុសាសន៏លេខ ១៩ ដល់ ២៤ នៃផែនការសកម្មភាពអន្តរជាតិនៅទីក្រុង វីយ៉ែន ស្តីពីជរាភាពបញ្ជាក់ថា គេត្រូវមើលឃើញលំនៅដ្ឋានសំរាប់មនុស្សចាស់ឱ្យសំខាន់ជាងរបស់ដែលគេហៅថាជំរកទៅទៀត ហើយត្រូវគិតថា លើសពីតួរបស់វា លំនៅដ្ឋាននៅមានលក្ខណៈសំខាន់ខាងចិត្តសាស្រ្ត និងសង្គមទៀតដែលគេត្រូវគិតដល់។ ដោយហេតុនេះ គោលនយោបាយជាតិត្រូវជួយមនុស្សចាស់ដើម្បីឱ្យគាត់បន្តរស់នៅក្នុងផ្ទះរបសគាត់ឱ្យបានយូរដែលអាច

ធ្វើទៅបាន តាមរយៈជួសជុលឡើងវិញ ការអភិវឌ្ឍន៍ និងការកែលំអផ្ទះ និងការសំរបសំរួលឱ្យស៊ីគ្នានឹងសមត្ថភាពរបស់ជនទាំងនោះដើម្បីអាចប្រើប្រាស់ផ្ទះទាំងនោះបាន(អនុសាសន៍លេខ ១៩)។ អនុសាសន៍លេខ ២០ សង្កត់លើការចាំបាច់ដែលការធ្វើផែនការកសាងឡើងវិញ និងការអភិវឌ្ឍន៍ក្រុង ព្រមទាំងច្បាប់ត្រូវយកចិត្តទុកដាក់ពិសេសដល់បញ្ហារបស់មនុស្សចាស់ ដោយជួយឱ្យមនុស្សចាស់បានសមាហរណកម្មសង្គមរបស់គេ(គឺអាចឱ្យគេរួមរស់នៅក្នុងសង្គមជាមួយមនុស្សទូទៅបាន) ចំណែកឯអនុសាសន៍ទី ២២ សុំឱ្យគិតគូរដល់សមត្ថភាពមុខងាររបស់មនុស្សចាស់ ដើម្បីផ្តល់ឱ្យគាត់នូវបរិដ្ឋានរស់នៅ និងជួយសំរួលចល័តភាព និងគមនាគមន៍តាមរយៈមធ្យោបាយដឹកជញ្ជូនគ្រប់គ្រាន់ជូនគាត់ ។

## សេចក្តីអធិប្បាយ

បទបញ្ញត្តិនេះមានសារសំខាន់ជាស្នូលដល់គោលដៅរួមរបស់កតិកាសញ្ញា។ ទោះបីកថាខ័ណ្ឌទី២ លៃទុកកន្លែងមួយដោយឡែកដើម្បីនិយាយពីទិដ្ឋភាពមួយចំនួននៃសិទ្ធិដើម្បីបានចំណីអាហារគ្រប់គ្រាន់ក៏ដោយ ក៏មាត្រានេះទាំងមូលមានវិសាលភាពទូលំទូលាយ។ មាត្រានេះ គ្របដណ្តប់លើសិទ្ធិដើម្បីបានកំរិតជីវភាពគ្រប់គ្រាន់ សិទ្ធិបានការរីកចំរើនជាបន្តបន្ទាប់នូវលក្ខខ័ណ្ឌជីវិតរស់នៅ និងសិទ្ធិដើម្បីបានអាហារ សំលៀកបំពាក់ និងទីលំនៅគ្រប់គ្រាន់។

កាលពីអតីតកាល រដ្ឋដែលរាយការណ៍បានផ្តល់ពត៌មានបន្តិចបន្តួចអំពីបញ្ហាខ្លះនៃបញ្ហាទាំងនេះ ជាពិសេសសិទ្ធិដើម្បីបានកំរិតជីវភាពគ្រប់គ្រាន់ និងសិទ្ធិបានលំនៅគ្រប់គ្រាន់។ លើសនេះទៀត ពត៌មានស្ថិតិភាគច្រើន និងពត៌មានដទៃទៀតដែលបានផ្តល់នោះ គ្មានអ្វីច្រើនទេ ពីព្រោះវាខ្វះខាតការពន្យល់ក្នុងបរិបទណាមួយ ឬគ្មានលំអិតគ្រប់គ្រាន់។ ឧទាហរណ៍ ការទទួលបានអាហារក្នុងមនុស្សម្នាក់ៗ ដែលវាស់ជាចំនួនកាឡូរី មានប្រយោជន៍សំរាប់គោលបំណងខ្លះ ប៉ុន្តែពត៌មាននេះ មិនបាននិយាយអ្វីអំពីកំរិតនៃសិទ្ធិដែលបុគ្គលនានាទទួលបានទេ។ ដើម្បីធ្វើឱ្យពត៌មាននេះមានន័យចំពោះគណៈកម្មាធិការ ពត៌មានត្រូវបំបែកទៅតាមក្រុមប្រជាជនផ្សេងៗ(ឧទាហរណ៍ ស្ត្រី កុមារ ក្រុមជនជាតិភាគតិច។ល។) ហើយបញ្ជាក់អំពីកំរិតមធ្យមភាគជាតិដែលមានបញ្ហាអាហារមិនគ្រប់គ្រាន់ ឬអាហារមិនតាមរបប។ ក្នុងករណីភាគច្រើន ស្ត្រីច្រើនតែយ៉ាប់យឺនខ្លាំងជាងបុរសនោះ គណៈកម្មាធិការអំពាវនាវឱ្យរដ្ឋជាភាគីរាយការណ៍ឱ្យបានលំអិតអំពីទំហំដែលស្ត្រីបានអាស្រ័យផលនៃសិទ្ធិនីមួយៗ ហើយនិងអំពីវិធានការដែលបានប្រកាន់យក ឬកំពុងគ្រោង ដើម្បីពុះពារលើការរើសអើង និងវិសមភាពដែលមាន។

ដោយហេតុគោលការណ៍ណែនាំមានលក្ខណៈពិស្តារ ហើយនិយាយចំៗ ចំពោះសិទ្ធិនីមួយៗ នៅក្នុងមាត្រា ១១(១)ហើយនោះ គេមិនបាច់និយាយដដែលនៅទីនេះទេ។ តែទោះជាយ៉ាងនេះក្តី គេអាចកត់សំគាល់ថា ក្នុងន័យទូទៅយ៉ាងហោចគេត្រូវការពត៌មានប្រភេទដូចតទៅនេះ ទាក់ទងនឹងសិទ្ធិនីមួយៗ :

(ក) ការវាយតម្លៃលើស្ថានភាពបច្ចុប្បន្ន ដោយផ្តោតជាពិសេសលើស្ថានភាពរបស់សមាជិកទន់ខ្សោយ និងបាត់បង់ប្រៀបបំផុតនៃសង្គម។ របាយការណ៍ត្រូវផ្តល់លំអិតអំពីមធ្យោបាយដែលរដ្ឋាភិបាលប្រើដើម្បីបានពត៌មាន ដើម្បីផ្តល់ការពិពណ៌នាឱ្យបានជាក់លាក់ និងលំអិត។ ឧទាហរណ៍ របាយការណ៍ត្រូវពិពណ៌នាការស្ទង់អំពីអាហារជាតិ បើសិនជាការស្ទង់នេះបានធ្វើជាប្រក្រតី ឬ បើគ្មានការស្ទង់បែបនេះទេ ត្រូវបញ្ជាក់ថាតើ រដ្ឋាភិបាលធ្វើយ៉ាងណាឱ្យបានយល់ពីធាតុពិតនៃស្ថានភាពអាហាររបស់ប្រជាជន។ របៀបធ្វើដូចគ្នាដែលបានពោលមកនេះត្រូវអនុវត្តចំពោះការពិពណ៌នាអំពីស្ថានការណ៍ទាក់ទងនឹងកំរិតជីវភាព និងលំនៅដ្ឋានផងដែរ។

(ខ) ការបញ្ជាក់ពីការជឿនលឿនដែលបានសំរេចក្នុងរយៈពេលកន្លងទៅទាក់ទងនឹងសិទ្ធិនីមួយៗទាំងនេះ។ ឧទាហរណ៍ ការប្រៀបធៀបស្ថានការណ៍កាលពី១០ និង ៥ឆ្នាំកន្លងទៅជាមួយនឹងស្ថានការណ៍បច្ចុប្បន្នមានប្រយោជន៍សម្បើមណាស់។ កាលណាការរាយការណ៍នៅក្រោមកតិកាសញ្ញានេះមានភាពលំអិតគ្រប់គ្រាន់ ពត៌មាននេះត្រូវបង្ហាញឱ្យគណៈកម្មាធិការដោយស្វ័យប្រវត្តិតាមរយៈរបាយការណ៍ខួប ៥ឆ្នាំម្តងរបស់រដ្ឋជាភាគី។

(គ) ការបង្ហាញពីបញ្ហាសំខាន់ៗដែលបានធ្វើឱ្យរាំងស្ទះដល់ការសំរេចពេញលេញនូវសិទ្ធិនិមួយៗ។ ថ្វីបើ បញ្ហាទាំងនេះមិនអាចរៀបរាប់ឱ្យអស់ក៏ដោយ គោលបំណងនៃការបង្ហាញនេះគឺដើម្បីបង្ហាញថា រដ្ឋាភិបាលបានប្រឹងប្រែងវិភាគបញ្ហាដែលមាន។

(ឃ) ការបញ្ជាក់ជាទូទៅ អំពីប្រភេទនៃគោលនយោបាយដែលគិតទុក ដើម្បីឆ្លើយតបនឹងការខ្វះខាតបច្ចុប្បន្នដែលធ្វើឱ្យរាំងស្ទះការសំរេចបាននូវសិទ្ធិនិមួយៗ។ ថ្វីបើ វិធានការជាគោលនយោបាយ និងជាកម្មវិធីណាមួយដែលត្រូវបានអនុម័តជាបញ្ហាដែលរដ្ឋជាភាគីខ្លួនឯងត្រូវសំរេចក៏ដោយ គណៈកម្មាធិការចាំបាច់ចង់ដឹងថាគោលនយោបាយរបស់រដ្ឋាភិបាលត្រូវបានបង្កើតឡើងដោយពិតប្រាកដ ក្នុងគោលបំណងជំរុញឱ្យបានការសំរេចជាលំដាប់នូវសិទ្ធិដែលរាយការណ៍។ ការបង្ហាញពីគោលចំណាំសំរាប់វាស់វែងការសំរេចបានសិទ្ធិនីមួយៗនៃសិទ្ធិដែលទទួលស្គាល់ក្នុងមាត្រា ១១ រិតតែមានសារសំខាន់ជាពិសេសទាក់ទងក្នុងរឿងនេះ។

ក្នុងការរាយការណ៍អំពីសិទ្ធិបានសំលៀកបំពាក់គ្រប់គ្រាន់ បញ្ហាដែលគណៈកម្មាធិការមានការយកចិត្តទុកដាក់ជាសំខាន់នោះគឺថា តើមានឬមិនមានមនុស្សមួយចំនួនធំដែលគ្មានលទ្ធភាពបានសំលៀកបំពាក់ដែលគេត្រូវការមិនត្រឹមតែសំរាប់រស់នៅប៉ុណ្ណោះទេ ប៉ុន្តែដើម្បីបានអាស្រ័យនូវកំរិតជីវភាពគ្រប់គ្រាន់ផងដែរ។

ក្នុងការរាយការណ៍អំពីសិទ្ធិបានលំនៅដ្ឋានគ្រប់គ្រាន់ មន្ត្រីធ្វើរបាយការណ៍អាចប្រើប្រាស់ពត៌មានដែលរៀបរៀង និងគោលនយោបាយដែលបានអនុវត្តទាក់ទងនឹងការអនុម័ត "យុទ្ធសាស្ត្រលំនៅជាតិ"។ គោលការណ៍ណែនាំសំរាប់ការរៀបចំយុទ្ធសាស្ត្របែបនេះត្រូវបានយល់ព្រមដោយមហាសន្និបាត ហើយមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធនៃសេចក្តីសំរេចលេខ ៤៣/១៨១ ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ១៩៨៨ របស់មហាសន្និបាត។ សំរាប់រឿងនេះ ជាការសំខាន់ដែលរបាយការណ៍ត្រូវឆ្លើយទៅនឹងបញ្ហាជាក់លាក់ ដែលមានបង្ហាញនៅក្នុងសេចក្តីអធិប្បាយទូទៅលេខ ៤(១៩៩១)។

ចំណុចសំខាន់បំផុតដែលត្រូវកត់សំគាល់អំពីកថាខ័ណ្ឌទី២ គឺថា វិធានការនានាដែលបានរាយ ដូចជាការកែលំអវិធីផលិតជាដើម គឺជាការយកចិត្តទុកដាក់តែមួយរបស់គណៈកម្មាធិការ ឱ្យតែវិធានការនោះៗទាក់ទងទៅនឹងការជួយឱ្យបានសំរេចសិទ្ធិបានចំណីអាហារ។ ដូច្នេះ ជាឧទាហរណ៍ អាចមានមូលហេតុច្រើនក្នុងការកែទំរង់ប្រព័ន្ធកសិកម្ម ឬក្នុងការជំរុញឱ្យប្រើចំណេះដឹងខាងវិទ្យាសាស្ត្រ។ ប៉ុន្តែ បញ្ហាទាំងនេះ ចាំបាច់ត្រូវបរិយាយនៅក្នុងរបាយការណ៍របស់រដ្ឋជាភាគីតែកាលណាបញ្ហាទាំងនោះមានផលដែលអាចបង្ហាញបានទៅលើការអាស្រ័យផលនៃសិទ្ធិបានចំណីអាហារគ្រប់គ្រាន់។

មន្ត្រីធ្វើរបាយការណ៍ត្រូវកត់សំគាល់ថា សិទ្ធិដែលរៀបរាប់ក្នុងមាត្រា ១១ ក៏ត្រូវបានការពារដោយឧបករណ៍អន្តរជាតិដទៃទៀតដែរ។ ឧបករណ៍ទាំងនេះ រួមមាន មាត្រា៦(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា១១(២)និង១៤(២)(ឆ) និង(ជ)នៃអនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី មាត្រា៥ (ង)(iii)នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ។

## មាត្រា ១២

### អត្ថបទមាត្រា ១២

១. រដ្ឋជាភាគីទាំងឡាយនៃកតិកាសញ្ញានេះ ទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការទទួលបាននូវសុខភាពផ្នែករាងកាយ និងប្រាជ្ញាស្មារតីស្របទៅតាមកំរិតបទដ្ឋានខ្ពស់បំផុត ។

២. ដើម្បីឱ្យបានសំរេចទាំងស្រុងនូវសិទ្ធិខាងលើនេះ រដ្ឋជាភាគីទាំងឡាយត្រូវមានវិធានការចាំបាច់ដើម្បីៈ

(ក) ធ្វើការកាត់បន្ថយអត្រានៃទារកដែលស្លាប់ពីកំណើត ហើយនិងដើម្បីធ្វើអោយក្មេងចំរើនវ័យដោយមានសុខភាពល្អ ។

(ខ) ធ្វើឱ្យមានការរីកចំរើនគ្រប់ទិដ្ឋភាពខាងវិស័យអនាម័យផ្នែកឧស្សាហកម្ម និង បរិស្ថាន ។

(គ) ការការពារ ការព្យាបាល និងការត្រួតពិនិត្យរោគឆ្លង ជម្ងឺដែលកើតតាមតំបន់ និងជម្ងឺដែលទាក់ទងនឹងការប្រកបការងារ ព្រមទាំងជម្ងឺដំកាត់ផ្សេងៗទៀត។

(ឃ) ការបង្កើតល័ក្ខខ័ណ្ឌផ្សេងៗដើម្បីធានាចំពោះសេវាផ្នែកសុខភាព និងការយកចិត្តទុកដាក់ព្យាបាលជាចាំបាច់នៅពេលដែលប្រជាពលរដ្ឋមានជម្ងឺផ្សេងៗ។

### អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ១២ នៃកតិកាសញ្ញា

១. សូមផ្តល់ពតិមាន អំពី សុខភាពទាំងខាងសតិ ទាំងខាងផ្លូវកាយនៃប្រជាជនរបស់អ្នក ដោយគិតជារួម និងបំបែកទៅតាមក្រុមផ្សេងៗនៅក្នុងសង្គម។ តើស្ថានភាពសុខភាពបានប្រែប្រួលយ៉ាងណាខ្លះចំពោះក្រុមទាំងនេះក្នុងកាលកន្លងទៅ?។ បើសិនជារដ្ឋាភិបាលរបស់អ្នកទើបតែនឹងបានបញ្ជូនទៅអង្គការសុខភាពពិភពលោកនូវរបាយការណ៍ទាំងឡាយអំពីស្ថានភាពសុខភាពរបស់ប្រទេសអ្នក សូមនិយាយយោងទៅលើផ្នែកពាក់ព័ន្ធនៃរបាយ-ការណ៍ទាំងនោះ មិនចាំបាច់ធ្វើរបាយការណ៍ដដែលៗលើបណ្តាពតិមាននោះនៅទីនេះម្តងទៀតទេ។

២.	សូមបង្ហាញថា តើប្រទេសរបស់អ្នកមាននយោបាយជាតិចំពោះវិស័យសុខភាពឬទេ? ហើយក្នុងក្របខ័ណ្ឌនយោបាយនោះ តើរដ្ឋាភិបាលបានធ្វើការប្តេជ្ញាចិត្តដើម្បីយកលំនាំការថែទាំសុខភាពបឋមរបស់អង្គការសុខភាពពិភពលោកដែរឬទេ?។ បើសិនដូច្នេះមែន តើវិធានការអ្វីខ្លះ ដែលត្រូវបានប្រកាន់យកដើម្បីអនុវត្តកម្មវិធីទាំងនោះនៅក្នុងវិស័យថែទាំសុខភាពបឋម?។

៣.	សូមបញ្ជាក់ថា តើផលិតផលជាតិសរុប និងថវិកាជាតិ និង/ឬ តំបន់នៃប្រទេសអ្នក មានចំនួនប៉ុន្មានភាគរយដែលត្រូវបានចំណាយសំរាប់សុខភាព។ តើប៉ុន្មានភាគរយនៃធនធានទាំងនេះ ត្រូវបានបែងចែកសំរាប់ការថែទាំសុខភាពបឋម? ចុះកាលពី ៥ ឆ្នាំ ពី១០ ឆ្នាំមុនយ៉ាងណាដែរ?។

៤.	បើសិនជាអាចធ្វើទៅបាន សូមផ្តល់នូវសន្ទស្សន៍ដែលកំណត់ដោយអង្គការសុខភាពពិភពលោកទាក់ទងនឹងបញ្ហាដូចតទៅនេះ :

ក.	អត្រាស្លាប់នៃកុមារ( ជាបន្ថែមទៅលើតម្លៃរបស់ជាតិ សូមផ្តល់អត្រាតាមភេទ តាមជនបទ និងទីក្រុង ហើយបើអាចធ្វើទៅបាន ទៅតាមក្រុម សង្គម-សេដ្ឋកិច្ច ឬ តាមក្រុមជាតិពន្ធ។ សូមផ្តល់និយមន័យនៃពាក្យថា "ទីក្រុង/ជនបទ" និងការបែងចែកតំបន់ឯទៀត។)។

ខ.	លទ្ធភាពអាចប្រើប្រាស់ទឹកស្អាតនៃប្រជាជន (សូមបង្ហាញដាច់ៗពីគ្នានូវទិន្នន័យទាក់ទងទៅនឹងទីក្រុង និងទាក់ទងទៅនឹងស្រែចំការ)។

គ.	លទ្ធភាពចំពោះប្រជាជនចំពោះបរិក្ខាគ្រប់គ្រាន់ទាំងឡាយដើម្បីបង្ហូរលាមកចោល (សូមបង្ហាញដោយឡែកពីគ្នានូវទិន្នន័យទាក់ទងនៅទីក្រុង និងនៅជនបទ)។

ឃ.	បណ្តាកុមារដែលត្រូវបានចាក់ថ្នាំបង្ការរោគខាន់ស្លាក់ ក្អកមាន់ តេតាណូស កញ្ជ្រិល ស្លាប់ដៃជើង និងរបេង( សូមបង្ហាញដោយឡែកពីគ្នានូវទិន្នន័យទាក់ទងទៅនឹងទីក្រុង និងស្រែចំការ និងទិន្នន័យទៅតាមភេទ)។

ង.	អាយុរស់ជាមធ្យម( សូមបង្ហាញដាច់ៗពីគ្នានូវទិន្នន័យទាក់ទងទៅនឹងទីក្រុង និងទៅនឹងជនបទតាមក្រុមខាងសង្គម សេដ្ឋកិច្ច និងតាមភេទ)។

ច.	សមាមាត្រនៃប្រជាជន ដែលមានលទ្ធភាពទទួលការព្យាបាលពីសំណាក់បុគ្គលិកដែលមានការហ្វឹកហ្វឺននូវជំងឺ ឬរបួសទូទៅ ហើយដែលអាចផ្គត់ផ្គង់ឱសថចាំបាច់ៗចំនួន ២០ មុខក្នុងចំងាយពីកន្លែងរស់នៅប្រមាណមួយម៉ោងដោយថ្មើរជើង ឬដោយការធ្វើដំណើរ។

ឆ.	សមាមាត្រនៃស្ត្រីមានផ្ទៃពោះ ដែលមានលទ្ធភាពទទួលសេវាពីបុគ្គលិកដែលមានការហ្វឹកហ្វឺនក្នុងរយៈពេលពរពោះ និងសមាមាត្រស្ត្រីដែលសំរាលកូនដោយមានបុគ្គលិកប្រភេទនេះចាំថែទាំ។ សូមបង្ហាញនូវចំនួនម្តាយស្លាប់មុន ឬក្រោយពេលសំរាលកូនរួច។

ជ.	សមាមាត្រនៃទារកដែលអាចបានទទួលការថែទាំពីនៃបុគ្គលិកមានការហ្វឹកហ្វឺន។

( សូមបង្ហាញដាច់ៗពីគ្នានូវទិន្នន័យទាក់ទងទៅនឹងទីក្រុង និងទាក់ទងទៅនឹងជនបទ ហើយនិងទាក់ទងទៅនឹងបណ្តាក្រុមសង្គម-សេដ្ឋកិច្ច ចាប់ពីអក្សរ "ច" ទៅអក្សរ "ជ" ) ។

៥. យោងតាមការបែងលំអិតសន្ទស្សន៍ដែលប្រើនៅក្នុងកថាខ័ណ្ឌ ៤ ឬយោងតាមមធ្យោបាយដទៃទៀត តើគេអាចដឹងថា នៅក្នុងប្រទេសរបស់អ្នក មានប្រជាពលរដ្ឋក្នុងក្រុមណាមួយដែលមានស្ថានភាពសុខភាពដុនដាបខ្លាំងជាងបណ្តាប្រជាជនភាគច្រើនឬទេ? ។ សូមឱ្យនិយមន័យនៃក្រុមទាំងនេះឱ្យបានច្បាស់លាស់តាមដែលអាចធ្វើទៅបាន ហើយសូមផ្តល់ពតិមានលំអិតផងដែរ ។ បើសិនជាមាន តើភូមិភាគណាខ្លះនៃប្រទេសរបស់អ្នកដែលមានការយ៉ាប់យឺនជាងគេទាក់ទងសុខភាពរបស់ប្រជាពលរដ្ឋនៃភូមិភាគនោះ ។

ក. នៅក្នុងរយៈពេលដែលធ្វើរបាយការណ៍នេះ តើមានការផ្លាស់ប្តូរក្នុងនយោបាយរបស់រដ្ឋាភិបាលក្នុងច្បាប់ ហើយនិងការប្រតិបត្តិដែលជាការផ្លាស់ប្តូរដែលមានផលអវិជ្ជមានទៅលើស្ថានភាពសុខភាពរបស់ក្រុមឬតំបន់ទាំងនេះក្នុងវិស័យសុខភាពឬទេ? ។ បើសិនជាមានមែន សូមពិពណ៌នាអំពីការផ្លាស់ប្តូរទាំងនោះ និងពីអនុភាពរបស់វា ។

ខ. សូមបង្ហាញពីវិធានការដែលរដ្ឋាភិបាលចាត់ទុកថាជាការចាំបាច់ ដើម្បីកែលំអរស្ថានភាពក្នុងវិស័យសុខភាពទាំងផ្លូវកាយ ទាំងខាងផ្លូវសតិ នៃបណ្តាក្រុមទន់ខ្សោយ និងបាត់បង់ប្រៀប ឬនៅក្នុងតំបន់យ៉ាប់យឺនទាំងនោះ ។

គ. សូមពន្យល់ពីវិធានការនៃនយោបាយទូទៅអ្វីខ្លះ ដែលរដ្ឋាភិបាលរបស់អ្នកបានប្រកាន់យកដោយប្រើធនធានអតិបរមាដែលមានដើម្បីបានសំរេចនូវការលំអនោះ ។ សូមបង្ហាញទិសដៅ និងគោលចំណាំដែលបានកំណត់ទុកដើម្បីវាស់វែងលទ្ធផលនៃការសំរេចបានសិទ្ធិមានសុខភាពនៅក្នុងរយៈពេលមួយ ។

ឃ. សូមពិពណ៌នាពីអនុភាពនៃវិធានការទាំងនេះ ទៅលើស្ថានភាពនៃវិស័យសុខភាពរបស់ក្រុមទន់ខ្សោយ និងក្រុមបាត់បង់ប្រៀប ឬតំបន់យ៉ាប់យ៉ឺនដែលពិពណ៌នាមក ហើយរាយការណ៍អំពីជោគជ័យបញ្ហា និងការខ្វះខាតនៃវិធានការទាំងនេះ ។

ង. សូមពិពណ៌នា អំពីវិធានការទាំងឡាយដែលរដ្ឋាភិបាលរបស់អ្នកបានប្រកាន់យកដើម្បីបន្ថយអត្រាទារកស្លាប់ពីកំណើត និងអត្រាស្លាប់នៃកុមារ និងដើម្បីធានារ៉ាប់រងការរីកធំធាត់ល្អនៃកុមារ ។

ច. សូមបង្ហាញនូវវិធានការទាំងឡាយដែលរដ្ឋាភិបាលរបស់អ្នកប្រកាន់យក ដើម្បីលំអរាល់ទិដ្ឋភាពនៃអនាម័យ ឬបរិស្ថាន និងអនាម័យក្នុងកន្លែងការងារ ។

ឆ. សូមពិពណ៌នាអំពីវិធានាការប្រកាន់យកដោយរដ្ឋាភិបាលរបស់អ្នក ដើម្បីបង្កា ព្យាបាល និងទប់ទល់ជំងឺដែលឆ្លងរាតត្បាត ជំងឺឆ្លងអ្នកនៅជាមួយគ្នា ជំងឺទាក់ទងនឹងការងារ និងជំងឺផ្សេងៗ ។

ជ. សូមពិពណ៌នា អំពីវិធានការទាំងឡាយប្រកាន់យកដោយរដ្ឋាភិបាលដើម្បីធានាដល់សេវាសុខភាព និងការថែទាំសុខភាពនៅពេលណាមានជំងឺ ។

ឈ. សូមពិពណ៌នាអំពីអនុភាពនៃវិធានការគូសបញ្ជាក់ពីវគ្គ "ង" ទៅវគ្គ "ជ" ទៅលើស្ថានភាពនៃក្រុមទន់ខ្សោយ និងក្រុមបាត់បង់ប្រៀបនៅក្នុងសង្គមរបស់អ្នក និងនៅក្នុងតំបន់ដែលយ៉ាប់យ៉ឺនបំផុត។ សូមរាយការណ៍អំពីការលំបាកនិងបរាជ័យផង ព្រមទាំងអំពីលទ្ធផលវិជ្ជមានផងដែរ។

៦. សូមប្រាប់ពីវិធានាការប្រកាន់យកដោយរដ្ឋាភិបាលរបស់អ្នក ដើម្បីរាំរាប់រងកុំឱ្យថ្លៃថែរក្សាសុខភាពមនុស្សចាស់មានការប៉ះពាល់ទៅលើសិទ្ធិមានសុខភាពរបស់អ្នកទាំងនេះ។

៧. សូមប្រាប់ថា តើវិធានការអ្វីខ្លះដែលត្រូវប្រកាន់យកនៅក្នុងប្រទេសរបស់អ្នក ដើម្បីឱ្យមានការចូលរួមជាអតិបរមារបស់សហគមន៍នៅក្នុងការធ្វើផែនការ ការរៀបចំ ការដំណើរការ និងក្នុងការត្រួតត្រាលើការថែរក្សាសុខភាពបឋម។

៨. សូមប្រាប់អំពីវិធានការ ដែលត្រូវបានប្រកាន់យកនៅប្រទេសរបស់អ្នក ដើម្បីផ្តល់ការអប់រំអំពីបញ្ហាសុខភាពសំខាន់ៗ និងវិធីបង្កា និងទប់ទល់កុំឱ្យរាលដាល លើបញ្ហាសុខភាពទាំងនេះ។

៩. សូមបញ្ជាក់ពីតួនាទីនៃជំនួយអន្តរជាតិ ក្នុងការធ្វើឱ្យបានសំរេចពេលលេញនូវសិទ្ធិដែលចែងក្នុងមាត្រា ១២។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយ លេខ ៥ (១៩៩៤)

## ជនមានពិការភាព

៣៤. អនុលោមទៅតាមវិធានជាបទដ្ឋាន "រដ្ឋគប្បីធានាថា បុគ្គលមានពិការភាពជាពិសេសទារក និងកុមារ ត្រូវបានផ្តល់នូវកំរិតថែទាំសុខភាពស្មើគ្នាក្នុងប្រព័ន្ធដូចគ្នានឹងសមាជិកឯទៀតនៃសង្គម"។ សិទ្ធិមានសុខភាពផ្លូវកាយនិងសតិ ក៏នាំឱ្យមានសិទ្ធិមានលទ្ធភាពប្រើប្រាស់ និងទទួលប្រយោជន៍ពីសេវាពេទ្យ និង សង្គម ទាំងនោះរួមមានឧបករណ៍តំរង់ឆ្អឹង ដែលជួយអោយបុគ្គលមានពិការភាពអាចពឹងខ្លួនឯងបានបង្កាកុំឱ្យមានពិការភាពថែមទៀត និងទ្រទ្រង់ការរួមរស់ក្នុងសង្គមរបស់ពួកគេ។ ក្នុងន័យដូចគ្នានេះ បុគ្គលទាំងនោះគួរត្រូវបានផ្តល់នូវសេវាស្តាសម្បទា ដែលនឹងជួយពួកគេអោយ "ឈានទៅដល់ និងរក្សានូវឯករាជភាព និងការដំណើរការជីវិតរបស់គេក្នុងកំរិតខ្ពស់"។ រាល់សេវាទាំងនោះត្រូវផ្តល់ក្នុងលក្ខណៈមួយ ដែលបុគ្គលពាក់ពន្ធ័អាចរក្សាបាននូវការគោរពយ៉ាងពេញលេញនូវសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់ពួកគេ។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយ លេខ ៦ (១៩៩៥)

## សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់

៣៤. ក្នុងបំណងធ្វើឱ្យបានសំរេចសិទ្ធិរបស់មនុស្សចាស់ដើម្បីបានទទួលកំរិតសុខភាពផ្លូវកាយ និងសតិ គួរជាទីពេញចិត្តស្របតាមវាក្យខ័ណ្ឌ ១ មាត្រា ១២ នៃកតិកាសញ្ញានេះ រដ្ឋជាភាគីត្រូវពិចារណាដល់ខ្លឹមសារនៃអនុសាសន៍ពីលេខ ១ ដល់លេខ ១៧ នៃផែនសកម្មភាពអន្តរជាតិនៅទីក្រុងវីយែន ស្តីពីជរាភាព ដែលផ្តោតទាំងស្រុងលើការផ្តល់គោលការណ៍ណែនាំលើនយោបាយសុខាភិបាល ដើម្បីរក្សាការពារសុខភាពមនុស្សចាស់ និងអភិវឌ្ឍន៍ទស្សនវិស័យឱ្យបានទូលំទូលាយ រាប់ចាប់តាំងពីការទប់ស្កាត់ជម្ងឺ និងការស្តារសម្បទាឡើងវិញ រហូតដល់ការថែទាំដល់អ្នកជម្ងឺធ្ងន់ដល់ជីវិត ។

៣៥. ជាការច្បាស់ណាស់ដែលគេមិនអាចដោះស្រាយតាមរយៈការព្យាបាលនូវករណីជម្ងឺរាំរៃ និងគ្មានសង្ឃឹមដែលមានកាន់តែច្រើនឡើង និងសោហ៊ុយសំរាកពេទ្យដ៏ខ្ពស់។ ក្នុងន័យនេះ រដ្ឋជាភាគីត្រូវចងចាំថា ការរក្សាឱ្យមានស្ថានភាពសុខភាពល្អនៅពេលអាយុចាស់ទាមទារឱ្យមានការធ្វើវិនិយោគក្នុងកម្លុងពេលមួយជីវិត ជាពិសេសតាមរយៈការអនុម័តយករបៀបរបបរស់នៅប្រកបដោយសុខភាពល្អ( ម្ហូបអាហារ ការហាត់ប្រាណ និង ការបំបាត់បារី និងស្រា។ល។) ។ ការការពារតាមរបៀបត្រួតពិនិត្យជាប្រចាំទៅតាមសេចក្តីត្រូវការរបស់មនុស្សចាស់ មានតួនាទីសំខាន់បំផុត( ការស្តាសម្បទាក៏មានតួនាទីសំខាន់ដូចគ្នា) ដោយរក្សាសមត្ថភាពមុខងារ (សមត្ថភាពធ្វើការរបស់សរីរាង្គមនុស្ស) របស់មនុស្សចាស់ ដែលនាំឱ្យមានការថយចុះថ្លៃវិនិយោគខាងការថែទាំសុខភាព និងសេវាកម្មសង្គម។

## សេចក្តីអធិប្បាយ

យោងតាមមាត្រានេះ រដ្ឋធ្វើរបាយការណ៍ត្រូវផ្តោតជាពិសេសលើបញ្ហាទាំងពីរ។ បញ្ហាទីមួយ គឺកំរិតរួមនៃសុខភាពរបស់ប្រជាជនខាងផ្នែករាងកាយ និងផ្នែកសតិ។ បញ្ហាទីពីរ ទាក់ទងនឹងកំរិតដែលប្រជាជនមានលទ្ធភាពលៃលករកការថែទាំសុខភាពបាន។ គោលការណ៍ណែនាំសំរាប់ធ្វើរបាយការណ៍ ផ្តោតជាពិសេសលើការផ្តល់ពតិមានជាស្ថិតិផ្អែកលើសន្ទស្សន៍ដែលទទួលយកជាទូទៅសំរាប់សុខភាព ដែលកំណត់ដោយអង្គការសុខភាពពិភពលោក។ បើសិនជាពតិមាននេះមានជាស្រេចក្នុងរបាយការណ៍ដែលផ្តល់ឱ្យដោយអង្គការសុខភាពពិភពលោកហើយនោះ គេអាចយោងទៅពតិមាននោះ ឱ្យតែពតិមាននោះគេចែកចាយឱ្យគណៈកម្មាធិការដែរ។

ក៏ប៉ុន្តែ ថែមលើពតិមាននោះ គោលការណ៍ណែនាំក៏បញ្ជាក់ពីសារសំខាន់នៃការផ្តល់ពតិមានអំពីក្រុមណាមួយដែលស្ថានភាពសុខភាពរបស់គេយ៉ាប់យ៉ឺនខ្លាំងជាងសុខភាពរបស់ប្រជាជនភាគច្រើនផងដែរ។ ដូចគ្នានឹងបទបញ្ញត្តិដទៃទៀតនៃកតិកាសញ្ញានេះដែរ កង្វល់របស់គណៈកម្មាធិការ គឺត្រូវប្រាប់ឱ្យច្បាស់អំពីសេចក្តីលំអិតនៃស្ថានការណ៍ក្នុងការអនុវត្តន៍ជាក់ស្តែង ព្រមទាំងបានការបញ្ជាក់អំពីគោលនយោបាយ និងកម្មវិធីដែលបានអនុវត្តដើម្បី

បង្កើនកំរិតនៃការសំរេចបានសិទ្ធិនេះ។ ក្នុងន័យនេះ ការបង្ហាញពីគោលចំណាំ ឬគោលដៅក្នុងរយៈពេលណាមួយជាក់លាក់សំរាប់ការបង្កើននេះ អាចជួយគណៈកម្មាធិការក្នុងការវាយតម្លៃពីកំរិតនៃការប្រតិបត្តិតាមកាតព្វកិច្ចរបស់រដ្ឋជាភាគីក្រោមកតិកាសញ្ញានេះ។

គួររំលឹកថា សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្សទទួលស្គាល់យ៉ាងជាក់លាក់នូវ"សារសំខាន់នៃការទទួលរបស់ស្ត្រីនូវកំរិតខ្ពស់បំផុតនៃសុខភាពផ្លូវកាយ និងផ្លូវសតិ ក្នុងរយៈពេលនៃជីវិតរបស់គេ"។ សន្និសីទនោះ ក៏បានអះអាងជាថ្មីនូវ"សិទ្ធិរបស់ស្ត្រីដើម្បីបានការថែទាំសុខភាព ដ៏គ្រប់គ្រាន់និងងាយរកបាន ហើយនិងសិទ្ធិរបស់គេដើម្បីបានសេវាកម្មផែនការគ្រួសារដ៏ទូលំទូលាយ"។ ដូច្នេះ ជាការសំខាន់ពិសេសដែលរបាយការណ៍ក្រោមមាត្រា ១២ ត្រូវផ្តល់ពតិមានបំបែកលំអិតអំពីស្ថានភាពរបស់ស្ត្រីទាក់ទងទៅនឹងបញ្ហាសំខាន់ៗទាំងអស់។ ត្រូវគូសបញ្ជាក់អំពីវិធានការណាមួយដែលតំរង់ទៅរកការដោះស្រាយវិសមធម៌ និងភាពមិនគ្រប់គ្រាន់ក្នុងរឿងសុខភាពស្ត្រីដែលមានក្នុងពេលបច្ចុប្បន្ននេះ។

ជាទីបញ្ចប់ គួរសង្កេតថា វិធានការជាក់លាក់ដែលរាយនៅក្នុងផ្នែក(ក)ដល់(ឃ) នៃកថាខ័ណ្ឌ២ មិនទាន់អស់នៅឡើយទេ នៅមានវិធានការដទៃទៀតដែលអាចប្រកាន់យកដើម្បីធានាការសំរេចបានជាលំដាប់នូវសិទ្ធិបានសុខភាពផ្លូវកាយ និងផ្លូវសតិ។ ក្នុងន័យនេះ នៅពេលរាយការណ៍ត្រូវផ្តល់ការយកចិត្តទុកដាក់ដល់ការគំរាមកំហែងដទៃទៀតដែលទាក់ទង កើតឡើងដោយសារភាពកខ្វក់ និងបញ្ហាបរិស្ថានដទៃទៀត។ ថ្វីបើ កតិកាសញ្ញានេះមិនបានទទួលស្គាល់ដោយចំៗនូវសិទ្ធិដើម្បីបានសុខុមាលភាពខាងបរិស្ថានយ៉ាងនេះក៏ដោយ គេក៏ឃើញច្បាស់ថាសិទ្ធិបានសុខភាពក្តោបទិដ្ឋភាពជាច្រើននៃសិទ្ធិបានបរិស្ថានដែលមាន សុវត្ថិភាព និងមានសុខភាព។ ដូច្នេះគណៈកម្មាធិការបានស្វែងរកយ៉ាងជាប់លាប់នូវពតិមានសមស្របពីរដ្ឋជាភាគី ដែលបានដាក់របាយការណ៍មិនគ្រប់គ្រាន់ស្តីពីរឿងនេះ។ ស្ថានការណ៍ទាក់ទងនឹងជំងឺ HIV/AIDS ក៏មានសារសំខាន់ណាស់ដែរក្នុងរឿងសុខភាពនេះ។ ពតិមានត្រូវផ្តោតអំពីចំនួនមនុស្សដែលរងគ្រោះដោយជំងឺនេះ វិធានការដើម្បីផ្តល់ការថែទាំយ៉ាងសមស្របដល់ពួកគេ វិធានការបង្កា និងវិធានការនានា ដើម្បីធានាកុំឱ្យមានការរើសអើងចំពោះមនុស្សដែលជាប់មេរោគនេះ។

សិទ្ធិដើម្បីមានសុខភាព ក៏មានរៀបរាប់នៅក្នុងមាត្រា ១២ និង១៤(២)(ខ)នៃអនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី មាត្រា ៥ (ង)(iv) នៃអនុសញ្ញាអន្តរជាតិស្តីពីការរើសអើងពូជសាសន៍ និងមាត្រា ២៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ។

## មាត្រា ១៣

### អត្ថបទមាត្រា ១៣

១. រដ្ឋជាភាគីទាំងឡាយនៃកតិកាសញ្ញានេះ ទទួលស្គាល់សិទ្ធិបុគ្គលគ្រប់រូបដើម្បីទទួលការអប់រំ។ រដ្ឋទាំងនោះបានស្របមតិគ្នាថា ការសិក្សាអប់រំត្រូវដឹកនាំឆ្ពោះទៅរកការរីកចំរើននៃបុគ្គលិកលក្ខណៈរបស់មនុស្សសុភនិច្ឆ័យនៃសេចក្តីថ្លៃថ្នូររបស់មនុស្ស ហើយត្រូវពង្រឹងការគោរពសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន។ រដ្ឋទាំង

នោះបានស្រុបមតិគ្នាជាបន្តទៅទៀតថា ការសិក្សាអប់រំត្រូវធ្វើឱ្យមនុស្សទូទៅអាចមានសមត្ថភាពរួមចំណែកដោយប្រសិទ្ធិភាពនៅក្នុងសង្គមសេរីមួយ អាចបណ្តុះបណ្តាលនូវការយោគយល់គ្នា, ការអនុគ្រោះគ្នា និងមិត្តភាពរវាងប្រជាជាតិទាំងអស់ រវាងសាសន៍ទាំងអស់ រវាងជាតិពន្ធុទាំងអស់ រវាងក្រុមសាសនាទាំងអស់ ដើម្បីឱ្យអង្គការសហប្រជាជាតិបន្តសកម្មភាពក្នុងការរក្សាសន្តិភាពកាន់តែរីកចំរើនឡើង ។

២. រដ្ឋទាំងអស់ជាភាគីនៃកតិកាសញ្ញានេះ ទទួលស្គាល់ថា ដើម្បីអោយបានសំរេចជោគជ័យយ៉ាងបរិបូណ៌តាមគោលដៅនៃសិទ្ធិ (ក្នុងមាត្រា) នេះ :

(ក) ការអប់រំផ្នែកបឋមសិក្សាត្រូវតែមានជាដាច់ខាតសំរាប់មនុស្សគ្រប់រូបដោយមិនបាច់បង់ថ្លៃ

(ខ) ការអប់រំកំរិតមធ្យមសិក្សាតាមគ្រប់ទ្រង់ទ្រាយ ដោយរាប់បញ្ចូលទាំងវិស័យបច្ចេកទេស និងវិជ្ជាជីវៈកំរិតមធ្យមផង ត្រូវតែបើកជាទូទៅអោយមនុស្សទាំងអស់គ្នាអាចបានចូលរៀន ដោយប្រើគ្រប់មធ្យោបាយដែលសមស្រប ហើយជាពិសេសគឺការបើកកម្មវិធីសិក្សាដោយឥតយកឈ្នួលឱ្យបានកាន់តែច្រើនឡើងជាលំដាប់ ។

(គ) ឧត្តមសិក្សាក៏ត្រូវតែចំហរទ្វារឱ្យបានធំទូលាយស្មើៗគ្នាសំរាប់មនុស្សទាំងអស់ ដោយមានប្រើគ្រប់មធ្យោបាយដែលសមរម្យ ហើយជាពិសេសគឺការបើកកម្មវិធីសិក្សាដោយឥតយកឈ្នួលកាន់តែច្រើនឡើងជាលំដាប់ ។

(ឃ) ត្រូវខំលើកទឹកចិត្ត និងជំរុញអោយបានខ្លាំងក្លានូវការសិក្សាជាមូលដ្ឋានឱ្យបានទូលំទូលាយតាមតែអាចធ្វើបានដើម្បីឱ្យជ្រួតជ្រាបទៅដល់អ្នកដែលពុំទាន់បានរៀនសូត្រ ឬអ្នកដែលមិនទាន់រៀនចប់ថ្នាក់បឋមសិក្សា។

(ង) ការធ្វើឱ្យរីកចំរើនដល់ប្រព័ន្ធនៃមជ្ឈមណ្ឌលសិក្សាគ្រប់ជាន់ថ្នាក់ ត្រូវតែប្រព្រឹត្តទៅឱ្យបានយ៉ាងសកម្ម ប្រព័ន្ធអាហារូបករណ៍ដ៏គ្រប់គ្រាន់មួយត្រូវតែរៀបចំឡើង(សំរាប់សិស្សក្រីក្រ) ហើយនិងល័ក្ខខ័ណ្ឌផ្នែកសំភារៈសំរាប់បុគ្គលិកសិក្សាត្រូវតែបង្កើនគុណភាពជាលំដាប់ ។

៣. រដ្ឋជាភាគីទាំងអស់នៃកតិកាសញ្ញានេះ ធានានឹងគោរពដល់សេរីភាពរបស់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សក្នុងការជ្រើសរើសសាលារៀនឯទៀតៗក្រៅពីសាលារដ្ឋសំរាប់បុត្រធីតាខ្លួន ដើម្បីធានូវការអប់រំផ្នែកសាសនា និងការអប់រំសីលធម៌មួយ ដែលស្របទៅនឹងជំនឿផ្ទាល់របស់គេ។ ប៉ុន្តែសាលាទាំងអស់នោះ យ៉ាងហោចណាស់ត្រូវមានកម្មវិធីសិក្សាស្របទៅតាមកំរិតអប់រំអប្បបរិមាដែលរដ្ឋបានបញ្ញត្តិ ឬយល់ព្រម ។

៤. គេពុំអាចដកស្រង់ផ្នែកណាមួយនៃមាត្រានេះទៅបកស្រាយ ដើម្បីរារាំងដល់សេរីភាពនៃបុគ្គល ឬអង្គការនានាក្នុងការបង្កបង្កើត និងដឹកនាំមជ្ឈមណ្ឌលអប់រំផ្សេងៗឡើយ។ បុគ្គលនិងអង្គការទាំងនោះ មានសេរីភាពពេញទីក្នុងការបង្កើតមជ្ឈមណ្ឌលអប់រំទាំងនោះឱ្យតែស្របទៅតាមលំនាំគោលការណ៍ដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ១៣ នេះ និងស្របតាមសេចក្តីតម្រូវអោយកម្មវិធីសិក្សាក្នុងមជ្ឈមណ្ឌលទាំងនោះ យ៉ាងហោចណាស់ត្រូវឱ្យស្របតាមបទដ្ឋានអប្បបរមានៃវិស័យអប់រំ ដែលរដ្ឋបានបញ្ញត្តិ ។

**អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ១៣ នៃកតិកាសញ្ញា**

១. ក្នុងទស្សនៈធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិទទួលការអប់រំរបស់មនុស្សម្នាក់ៗ នៅក្នុងប្រទេសរបស់អ្នក ៖

(ក) តើរដ្ឋាភិបាលរបស់អ្នកបំពេញកាតព្វកិច្ចរបស់ខ្លួនយ៉ាងណាក្នុងការរ៉ាប់រងឱ្យមានបឋមសិក្សាខានមិនបាន ហើយដែលទាំងអស់គ្នាចូលរៀនបានដោយគ្មានបង់ថ្លៃ? (បើការអប់រំបឋមសិក្សាមិន មែនខានមិនបាន និង/ឬ មិនយកថ្លៃនោះទេ សូមមើលមាត្រា ១៤)។

(ខ) តើមធ្យមសិក្សារួមទាំងមធ្យមសិក្សាបច្ចេកទេស និងខាងវិជ្ជាជីវៈផង មានជាទូទៅ ហើយអាចចូលរៀនបានទាំងអស់គ្នាដែរឬទេ? តើការមិនយកថ្លៃចំពោះមធ្យមសិក្សាមានជាទូទៅ ឬមានកំរិត?

(គ) តើលទ្ធភាពចូលរៀនក្នុងថ្នាក់ឧត្តមសិក្សាមានដល់កំរិតណាដែរនៅក្នុងប្រទេសរបស់អ្នក? តើសោហ៊ុយត្រូវចំណាយនៅឧត្តមសិក្សាប៉ុណ្ណាដែរ? តើគេបានបង្កើតឱ្យមានប្រព័ន្ធការអប់រំដោយឥតយកថ្លៃ ដែរឬទេ ឬក៏កំពុងតែកំពុងអនុវត្តជាបណ្តើរៗ។

(ឃ) វិធានការអ្វីខ្លះ ដែលអ្នកបានប្រកាន់យកដើម្បីបង្កើតប្រព័ន្ធអប់រំមូលដ្ឋានសំរាប់អ្នកដែលឥតបានរៀននៅបឋមសិក្សា ឬរៀនពុំបានចប់បឋមសិក្សា។

បើរដ្ឋាភិបាលរបស់អ្នកទើបតែបានធ្វើរបាយការណ៍ជូនទៅ អ.ស.ប ឬជូនទៅស្ថាប័នជំនាញណាមួយអំពីស្ថានភាពសិទ្ធិចែងនៅក្នុងមាត្រា ១៣ សូមអ្នកនិយាយយោងទៅផ្នែកដែលពាក់ព័ន្ធនៃរបាយការណ៍នោះ ដោយមិនចាំបាច់និយាយដដែលៗឡើងវិញនៅក្នុងរបាយការណ៍នេះទេ។

២. តើការលំបាកអ្វីខ្លះ ដែលអ្នកបានជួបប្រទះក្នុងការធ្វើឱ្យបានសំរេចនូវសិទ្ធិមានការអប់រំក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងកថាខ័ណ្ឌ ១ ? តើរដ្ឋាភិបាលរបស់អ្នកបានកំណត់គោលដៅ និងបទដ្ឋានអ្វីខ្លះ នៅក្នុងរយៈពេលមួយចំពោះបញ្ហានេះ?

៣. សូមផ្តល់នូវស្ថិតិអំពីអក្ខរកម្ម អត្រានៃការចុះឈ្មោះរៀននៅក្នុងសិក្សាធិការមូលដ្ឋាន ដោយមានសេចក្តីបញ្ជាក់ពត៌មានអំពីតំបន់ជនបទពីការអប់រំមនុស្សពេញវ័យ និងការអប់រំជាបន្ត អត្រានៃការបោះបង់ការសិក្សានៅគ្រប់កំរិតនៃការសិក្សា ព្រមទាំងអត្រានៃអ្នកជាប់សញ្ញាប័ត្របញ្ចប់ការសិក្សានៅគ្រប់កំរិត (សូមប្រាប់ដាច់ៗពីគ្នាបើអាចធ្វើទៅបាននូវបណ្តាទិន្នន័យទាក់ទងទៅនឹងភេទទៅនឹងសាសនា។ល។)។ សូម ផ្តល់ផងដែរនូវពត៌មានទាំងឡាយលើវិធានការប្រកាន់យកដើម្បីលើកទឹកចិត្តអក្ខរកម្ម ដោយប្រាប់នូវទិន្នន័យ អំពីវិសាលភាពនៃកម្មវិធីប្រជាជនគោលដៅ ប្រភពហិរញ្ញវត្ថុ និងអត្រានៃការចុះឈ្មោះ រួចផ្តល់ស្ថិតិលើការទទួលសញ្ញាប័ត្រការបញ្ចប់

ការរៀនសូត្រ ដោយគិតទៅតាមក្រុមអាយុ ក្រុមភេទ ។ល។ សូមឱ្យព័ត៌មានពីលទ្ធផលជាវិជ្ជមាននៃបណ្តាវិធានការ ព្រមទាំងក្តីលំបាកទាំងឡាយហើយនិងបរាជ័យ ។

៤. សូមផ្តល់ព័ត៌មានទាំងឡាយអំពីអត្រាភាគរយនៃថវិកាជាតិ ឬ បើសិនជាមាន (ថវិកាតំបន់)ដែលបានចំណាយលើការអប់រំ។ សូមពិពណ៌នាអំពីប្រព័ន្ធនៃការសិក្សា ផ្តល់ព័ត៌មានពីសកម្មភាពសាងសង់សាលារៀនថ្មីៗ ពីចំងាយលំនៅស្ថានរបស់សិស្សទៅសាលារៀន ពិសេសនៅជនបទព្រមទាំងប្រតិទិនខាងការរៀនសូត្រ ។

៥. នៅក្នុងការជាក់ស្តែង តើសមភាពនៃការចូលរៀននៅគ្រប់កំរិតសិក្សា និងវិធានាការជំរុញអក្ខរកម្មបានដល់កំរិតណាដែរនៅក្នុងការជាក់ស្តែង? ឧទាហរណ៍ :

ក. តើអត្រារវាងបុរស និងស្ត្រីដែលរៀននៅបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា ហើយនិងការចូលរួមក្នុងសកម្មភាពជំរុញអក្ខរកម្មមានតួលេខប៉ុណ្ណា?

ខ. ទាក់ទងនឹងការអាស្រ័យផលពិតប្រាកដពីសិទ្ធិក្នុងការសិក្សាអប់រំនៅគ្រប់កំរិត និងសិទ្ធិក្នុងការចូលរួមក្នុងសកម្មភាពទាំងឡាយដែលប៉ងប្រាថ្នាជំរុញអក្ខរកម្ម តើមានក្រុមទន់ខ្សោយ និងក្រុមបាត់បង់ប្រៀបដែរឬទេ? ឧទាហរណ៍ សូមបញ្ជាក់ថាតើក្នុងកំរិតណាដែលកុមារី កូនក្នុងគ្រួសារដែលមានចំណូលទាប កុមារនៅជនបទ កុមារពិការរូបកាយឬសតិ កូននៃជនអន្តោប្រវេសន៍ និងនៃកម្មករពនេចរ កូនរបស់ក្រុមជាសមាជិកពូជសាសន៍ ភាសា សាសនា ឬអ្វីផ្សេងទៀត និងកូនរបស់អន្តោគ្រាម បានទទួលអាស្រ័យផលពីសិទ្ធិចេះអក្សរ និងទទួលការអប់រំចែងក្នុងមាត្រា ១៣ ដែរឬទេ?

គ. វិធានការណាខ្លះ ដែលរដ្ឋាភិបាលរបស់អ្នកប្រកាន់យក ឬគិតទុក ដើម្បីធានាសមភាពក្នុងការចូលរៀននៅគ្រប់កំរិតសិក្សាទាំងអស់នៅក្នុងប្រទេសរបស់អ្នក ដូចជាវិធានការប្រឆាំងការរើសអើង ការលើកទឹកចិត្តខាងហិរញ្ញវត្ថុ អាហារូបករណ៍ វិធានការស្តារអ្វីៗដែលក្រុមចាញ់ប្រៀបបានបាត់បង់កាលពីអតីត? សូមពិពណ៌នា ពីអនុភាពនៃវិធានការទាំងនេះ ។

ឃ. សូមពិពណ៌នាអំពីសម្បទាខាងភាសា ដែលផ្តល់ក្នុងគោលបំណងនេះ ដូចជាមានការបង្រៀនភាសាកំណើតដល់និស្សិត ។

៦. សូមមេត្តាពិពណ៌នា អំពីស្ថានភាពនៃបុគ្គលសិក្សានៅគ្រប់កំរិតនៃសិក្សាធិការនៅក្នុងប្រទេសរបស់អ្នក ដោយគិតដល់អនុសាសន៍ទាក់ទងនឹងស្ថានភាពបុគ្គលិកសិក្សាអនុម័តកាលពីថ្ងៃទី ៥ ខែតុលា ឆ្នាំ១៩៦៦ ដោយសន្និសីទអន្តររដ្ឋាភិបាល ពិសេសស្តីពីស្ថានភាពបុគ្គលិកសិក្សាអញ្ជើញឱ្យចូលរួមដោយយូណេស្កូ។ តើបៀវត្សរបស់លោកគ្រូ អ្នកគ្រូ ប្រៀបធៀបទៅនឹងបៀវត្សរបស់អ្នករាជការឯទៀតៗយ៉ាងណាដែរ ។ តើអត្រាប្រៀបធៀបនេះបានវិវត្តយ៉ាងណាដែរក្នុងកាលកន្លងទៅ? តើវិធានការណាខ្លះ ដែលត្រូវបានប្រកាន់យក ឬដែលត្រូវបានប្រមាណទុកដើម្បីលំអកំរិតជីវភាពរបស់បុគ្គលិកសិក្សា ។

៧.	នៅក្នុងប្រទេសរបស់អ្នក តើគ្រឹះស្ថានសិក្សានៅគ្រប់កំរិតប៉ុន្មានដែលឥតត្រូវបានបង្កើត និងគ្រប់គ្រងដោយរដ្ឋ មានប៉ុន្មានភាគរយ? មនុស្សដែលចង់បង្កើតគ្រឹះស្ថានសិក្សាធុននេះ ឬដែលចង់ចូលសាលាទាំងនោះ ជួបនឹងឧបសគ្គ និងការពិបាកដែរឬទេ?

៨.	នៅក្នុងរយៈពេលដែលត្រូវធ្វើរបាយការណ៍នេះ តើមានការផ្លាស់ប្តូរនយោបាយជាតិ ច្បាប់ និងការអនុវត្តន៍ដែលមានអនុភាពជាអវិជ្ជមានដល់សិទ្ធិដែលចែងនៅមាត្រា ១៣ ដែរឬទេ? បើមាន សូមពិពណ៌នាអំពីការផ្លាស់ប្តូរនោះព្រមទាំងឥទ្ធិពលនៃការប្រែប្រួលនោះផង។

៩.	សូមបញ្ជាក់ពីតួនាទីរបស់ជំនួយអន្តរជាតិក្នុងការធ្វើឱ្យបានសំរេចទាំងស្រុងនូវសិទ្ធិ ដែលចារិកក្នុងមាត្រា ១៣។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយ លេខ ៥ (១៩៩៤)**

**ជនដែលមានពិការភាព**

៣៥.	សព្វថ្ងៃនេះកម្មវិធីសាលានៅតាមប្រទេសជាច្រើនបានទទួលស្គាល់ថា បុគ្គលមានពិការភាពអាចទទួលបានការអប់រំយ៉ាងល្អប្រសើរតាមប្រព័ន្ធអប់រំទូទៅ។ ហេតុនេះ វិធានជាបទដ្ឋានចែងថា " រដ្ឋត្រូវទទួលស្គាល់គោលការណ៍មានឱកាសស្មើគ្នាសំរាប់កុមារ យុវជន និងមនុស្សពេញវ័យ ដែលមានពិការភាព ទទួលបានការអប់រំកំរិតបឋម មធ្យម និងឧត្តមសិក្សា ក្នុងបរិយាកាសសមាហរណកម្ម(ការរៀនចូលគ្នានៅក្នុងកន្លែងដូចគ្នារវាងសិស្ស ពិការ និងមិនពិការ)។ ដើម្បីអនុវត្តនូវវិធានការបែបនេះបាន រដ្ឋត្រូវធានាថា គ្រូបង្រៀនត្រូវបានហ្វឹកហ្វឺនឱ្យអប់រំកុមារមានពិការភាពនៅតាមសាលារៀនរយ ហើយត្រូវមានឧបករណ៍ក៏ដូចជាការគាំទ្រចាំបាច់ទាំងឡាយ ដើម្បីនាំបុគ្គលមានពិការភាពឱ្យដល់កំរិតអប់រំស្មើដូចគ្នានឹងពួកសិស្សមិនពិការដែរ។ ឧទាហរណ៍ ក្នុងករណីកុមារថ្លង់ ភាសាសញ្ញាក៏ត្រូវទទួលស្គាល់ជាភាសាមួយដោយឡែកដែលកុមារមានពិការភាពអាចប្រើប្រាស់ និង សារសំខាន់នៃភាសាបែបនេះ ក៏ទទួលស្គាល់ក្នុងបរិស្ថានសង្គមទូទៅដែរ។

**សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយ លេខ ៦ (១៩៩៥)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់**

៣៦.	វាក្យខ័ណ្ឌ ១ មាត្រា ១៣ នៃកតិកាសញ្ញាទទួលស្គាល់សិទ្ធិអប់រំរបស់មនុស្សគ្រប់រូប។ ក្នុងករណីមនុស្សចាស់ គេត្រូវមើលសិទ្ធិនេះពីរជ្រុងពីរផ្សេងគ្នា និងផ្សំគ្នាទៅវិញទៅមកៈ (ក)សិទ្ធិមនុស្សចាស់ដើម្បីទទួល

អត្ថប្រយោជន៍ពីកម្មវិធីអប់រំ និង(ខ)ការទាញយកអត្ថប្រយោជន៍នៃសមត្ថភាព និងបទពិសោធន៍របស់មនុស្ស ចាស់ជាគុណប្រយោជន៍ដល់យុវជនជំនាន់ក្រោយ ។

៣៧. ទាក់ទងនឹងទិដ្ឋភាពទីមួយ រដ្ឋជាភាគីត្រូវពិចារណាដល់ (ក)អនុសាសន៍នៅក្នុងគោលការណ៍ ១៦ របស់ សហប្រជាជាតិដែលសំដែងថា មនុស្សចាស់ត្រូវមានលទ្ធភាពទទួលបានកម្មវិធីសិក្សា និងការហ្វឹកហ្វឺនដ៏សមរម្យ ហើយដោយផ្អែកលើការត្រៀមខ្លួន សមត្ថភាព និងទឹកចិត្តរបស់គេត្រូវតែបានទទួលឱ្យចូលរៀនក្នុងកំរិតអប់រំផ្សេងៗតាមរយៈការអនុម័តវិធានការសមស្របទាក់ទងនឹងការហ្វឹកហ្វឺនអក្ខរកម្ម ការអប់រំប្រចាំជីវិត ការចូលសិក្សានៅសកលវិទ្យាល័យ។ល។ និង (ខ) អនុសាសន៍លេខ ៤៧ នៃផែនការសកម្មភាពអន្តរជាតិទីក្រុងវីយ៉ែនស្តីពីជរាភាពដែលស្របតាមគោលគំនិតនៃការអប់រំប្រចាំជីវិត ដែលប្រកាសឱ្យប្រើដោយអង្គការយូណេស្កូស្នើសុំឱ្យមានកម្មវិធីក្រៅប្រព័ន្ធនៅតាមសហគមន៍ និងមានលក្ខណៈដូចជា ការកំសាន្តសប្បាយសំរាប់មនុស្សចាស់ដើម្បីបង្កើតអារម្មណ៍ខ្លួនទីពឹងខ្លួន និងស្មារតីទទួលខុសត្រូវរបស់សមាគមន៍។ កម្មវិធីអស់ទាំងនេះ គួរតែបានការគាំទ្រពីរដ្ឋាភិបាលជាតិ និងអង្គការអន្តរជាតិ។

៣៨. ទាក់ទងនឹងការប្រើឱ្យបានជាប្រយោជន៍នូវសមត្ថភាព និងបទពិសោធន៍របស់មនុស្សចាស់ដូចបានពោលនៅក្នុងផ្នែកនៃអនុសាសន៍នៃផែនការសកម្មភាពអន្តរជាតិនៅទីក្រុងវីយ៉ែនស្តីពីជរាភាព ដែលទាក់ទង់ការងារអប់រំ (វាក្យខ័ណ្ឌ ៧៤-៧៦) គេត្រូវយកចិត្តទុកដាក់លើតួនាទីសំខាន់ដែលមនុស្សចាស់មានចំពោះសង្គមក្នុងឋានៈគាត់ជាអ្នកផ្សាយពត៌មាន ចំណេះដឹង ប្រពៃណី និង តម្លៃស្មារតី ហើយគេត្រូវចងចាំថាប្រពៃណីសំខាន់មិនឱ្យសាបសូន្យឡើយ។ អាស្រ័យហេតុនេះហើយ បានជាគណៈកម្មាធិការឱ្យសារសំខាន់ជាពិសេសដល់ខ្លឹមសារដែលមាននៅក្នុងអនុសាសន៍លេខ ៤៤ នៃផែនការដែលនេះដែលមានសេចក្តីថា " គេត្រូវបង្កើតឱ្យមានកម្មវិធីសិក្សាដែលមានមនុស្សចាស់ដើរតួនាទីជាគ្រូបង្រៀន និង ជាផ្សាយចម្លងចំណេះដឹង វប្បធមិ និង តម្លៃស្មារតី"។

## សេចក្តីអធិប្បាយ

មាត្រានេះទាក់ទងនឹងសិទ្ធិទទួលការអប់រំ នៅគ្រប់ទិដ្ឋភាពទាំងអស់។ ដូច្នេះ គណៈកម្មាធិការចង់ដឹងពត៌មានអំពីការអប់រំបឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា (តតិយភូមិ) និងការអប់រំមូលដ្ឋាន (ដែលជួនកាលហៅថា ការអប់រំសំរាប់"មនុស្សធំ")។ ក៏ប៉ុន្តែ មានការខុសឆ្គងយ៉ាងសំខាន់នៅក្នុងលក្ខណៈនៃកាតព្វកិច្ចទាក់ទងនឹងការអប់រំបឋមសិក្សា។ យោងតាមមាត្រា ១២(២)(ក) រដ្ឋជាភាគីត្រូវទទួលស្គាល់ថា ការអប់រំបឋមសិក្សាត្រូវតែទទួលខានមិនបាន ហើយត្រូវមានសំរាប់មនុស្សទាំងអស់ដោយឥតគិតថ្លៃ។ ប្រការដែលថា កាតព្វកិច្ចនេះត្រូវអនុវត្តជាបន្ទាន់ គឺមានគូសបញ្ជាក់ដោយបទបញ្ញត្តិនៃមាត្រា១៤(សូមមើលខាងក្រោម) ដែលតំរូវឱ្យរដ្ឋជាភាគីណាមួយមិនបានបំពេញកាតព្វកិច្ចនេះ ត្រូវចាត់វិធានការជាក់លាក់បំផុតឆ្ពោះទៅរកគោលដៅនោះ។ ភាពបន្ទាន់

នេះ ស្តែងឱ្យឃើញភាពផ្ទុយគ្នាស្រឡះជាមួយនឹងការសំរេចជាលំដាប់ ដែលបញ្ជាក់ដោយចំៗក្នុងករណីនៃការអប់រំនៅក៏រិតដទៃៗទៀត ។

របាយការណ៍ត្រូវផ្តល់ពត៌មានស្ថិតិណាមួយដែលមាន ហើយបញ្ជាក់ពីសន្ទស្សន៍ដែលកំណត់ឡើងដោយយូណេស្កូទាក់ទងនៅរឿងនោះ ។ បើរបាយការណ៍បានធ្វើរួចហើយក្រោមអាណត្តិនៃអនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងការអប់រំដែលអនុម័តដោយយូណេស្កូក្នុងឆ្នាំ១៩៦០ ត្រូវយោងទៅរបាយការណ៍នោះ ។ ក៏ប៉ុន្តែ ពត៌មានដែលតំរូវក្រោមអាណត្តិមាត្រា១៣ លាតសន្ធឹងហួសពីបញ្ហាមួយចំនួនដែលមាននៅក្នុងអនុសញ្ញានោះ ។

របាយការណ៍ក្រោមអាណត្តិមាត្រា ១៣ ត្រូវយកចិត្តទុកដាក់ជាពិសេសលើស្ថានភាពនៃក្រុមជនទន់ខ្សោយនិងបាត់បង់ប្រៀបនៅក្នុងសង្គម (ឧទាហរណ៍ កុមារនៅក្នុងក្រុមដែលមានចំណូលទាប កុមារនៅតំបន់ជនបទ កុមារដែលពិការផ្លូវកាយ ឬសតិ កុមារជាកូនជនអន្តោប្រវេសន្តន៍ ឬកូនកម្មករពនេចរ កុមារនៅក្នុងក្រុមភាសាពូជសាសន៍ សាសនា ឬ ជនជាតិភាគដទៃទៀត និងកុមាររបស់ជនអន្តោក្រាម) ។ ពត៌មានបែបនោះ ត្រូវពិពណ៌នាអំពីស្ថានភាពខាងផ្លូវច្បាប់ ឬផ្លូវរដ្ឋបាល ប៉ុន្តែក៏ត្រូវពិពណ៌នាអំពីស្ថានភាពក្នុងការអនុវត្តជាក់ស្តែងដែរ ។ ស្ថានភាពកុមារីទាក់ទងនឹងលទ្ធភាពក្នុងផ្លូវជាក់ស្តែង ដើម្បីឆក់យកឱកាសដែលមាននៅក្នុងទ្រឹស្តី គឺជាការយកចិត្តទុកដាក់ជាពិសេសរបស់គណៈកម្មាធិការដែរ ។ គណៈកម្មាធិការចង់ដឹងអំពីពត៌មានបំបែកទាក់ទងនឹងភាពខុសគ្នារវាងបុរសស្ត្រីនៅក្នុងគ្រប់ទំរង់នៃការអប់រំ ។

ក្នុងការរាយការណ៍អំពីការជឿនលឿនឆ្ពោះទៅរកគោលដៅនានាដែលកំណត់ក្នុងមាត្រា ១៣(២) រដ្ឋជាភាគីអាចពិចារណាដល់គោលការណ៍ និងគោលដៅ ដែលកំណត់នៅក្នុងសេចក្តីថ្លែងការណ៍ពិភពលោក ស្តីពីការអប់រំសំរាប់មនុស្សទាំងអស់ និងអត្ថបទអមសេចក្តីថ្លែងការណ៍នេះ គឺក្របខ័ណ្ឌសំរាប់វិធានការដើម្បីបំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងការអប់រំដែលអនុម័តដោយសន្និសីទពិភពលោកនៅឆុមធៀន ប្រទេសថៃ ខែមិនា ឆ្នាំ១៩៩០ ។ ក្នុងន័យនេះ កថាខ័ណ្ឌទី ៦ នៃក្របខ័ណ្ឌនេះ បញ្ជាក់ពីសេចក្តីសំខាន់នៃ "គោលដៅផ្សាភ្ជាប់ទៅនឹងពេលវេលា" ដែលមានអត្ថប្រយោជន៍សំរាប់ "ធ្វើឱ្យដឹងពីភាពប្រញាប់ និងសំរាប់ធ្វើជាគោលដើម្បីវាស់វែងការជឿនលឿននៃការអនុវត្តន៍និងការសំរេចផល" ។ វិធីនេះ ហាក់ដូចជាបញ្ជាស់គ្នានៅក្នុងបរិបទនៃការអនុវត្តមាត្រា ១៣ នៃកតិកាសញ្ញានេះ ។

កថាខ័ណ្ឌ ៣ និង ៤ នៃមាត្រានេះរំលេចឱ្យឃើញនូវការពឹងផ្អែកគ្នាទៅវិញទៅមកនៃសិទ្ធិទាំងពីរសំណុំដោយសង្កត់ធ្ងន់ថា កិច្ចប្រឹងប្រែងដើម្បីធានាការសំរេចសិទ្ធិទទួលការអប់រំមិនត្រូវអនុវត្តដោយបោះបង់ចោលសិទ្ធិដទៃទៀតនោះទេ ។ របាយការណ៍អំពីបទបញ្ញត្តិទាំងនេះមិនត្រឹមតែពិពណ៌នាអំពីបទបញ្ញត្តិច្បាប់ និងរដ្ឋបាល ដែលទាក់ទងនោះទេ ប៉ុន្តែត្រូវពិពណ៌នាអំពីស្ថានការណ៍ជាក់ស្តែងផងដែរ ។ ក្នុងករណីគ្មានសាលារៀនរបស់ស្ថាប័នក្រៅរដ្ឋាភិបាលទេនោះ ការពន្យល់ខ្លះអំពីរឿងនេះក៏សំខាន់ដែរ ។

សិទ្ធិទទួលការអប់រំក៏មាននិយាយនៅក្នុងមាត្រា ៥(ង)(v) នៃអនុសញ្ញាអន្តរជាតិស្តីពីការរើសអើងពូជសាសន៍ មាត្រា ៥(ក) និង ៥(ខ) មាត្រា ១០និង១៤(២)(ឃ)នៃអនុសញ្ញាស្តីពីការបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រី និងមាត្រា២៨ និង២៩ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## មាត្រា ១៤

### អត្ថបទមាត្រា ១៤

នៅពេលដែលចូលជាភាគីនៃកតិកាសញ្ញានេះ រដ្ឋនិមួយៗដែលមានសមត្ថភាពគ្រប់គ្រាន់អាចផ្តល់ជូនប្រជាពលរដ្ឋខ្លួនទាំងនៅតំបន់ទីក្រុង ទាំងនៅតំបន់ទឹកដីឯទៀត ក្រោមអំណាចច្បាប់ខ្លួនកាន់កាប់នូវការអប់រំថ្នាក់បឋមសិក្សាដោយខានមិនបាន ដោយឥតយកឈ្នួល ដោយធានាថា ក្នុងរយៈពេលពីរឆ្នាំ ត្រូវរៀបចំផែនការលំអិតមួយសំរាប់អនុវត្តប្រកបដោយវឌ្ឍនភាពសំរាប់រយៈពេលសមស្រប ដើម្បីកំណត់នៅក្នុងផែនការអំពីគោលការណ៍អប់រំ ដោយឥតគិតឈ្នួលសំរាប់មនុស្សទាំងអស់ក្នុងរយៈកាលប៉ុន្មានឆ្នាំទៅមុខ ។

### អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ១៤ នៃកតិកាសញ្ញា

បើសិនជានៅក្នុងប្រទេសរបស់អ្នក បឋមសិក្សាមិនទាន់បានជាអ្វីដែលមានលក្ខណៈខានមិនបាន និងឥតមានបង់ឈ្នួលទេនោះ សូមផ្តល់ពតិមានលំអិតអំពីផែនការសកម្មភាព ដើម្បីអនុវត្តជាលំដាប់ៗនូវ គោលការណ៍នេះក្នុងចំនួនឆ្នាំសមហេតុផលមួយដែលកំណត់ដោយផែនការនេះ។ ក្នុងការប្រតិបត្តិផែនការនេះ អ្នកបានប៉ះទង្គិចនឹងការលំបាកពិសេសៗអ្វីខ្លះ? សូមបញ្ជាក់ពី នាទីនៃជំនួយអន្តរជាតិចំពោះបញ្ហានេះ។

### សេចក្តីអធិប្បាយ

មាត្រានេះចាំបាច់ត្រូវរាយការណ៍ដោយរដ្ឋជាភាគីទាំងឡាយណានៃកតិកាសញ្ញានេះ ដែលមិនទាន់បានផ្តល់ការអប់រំបឋមសិក្សាដោយបង្ខំ និងដោយឥតគិតថ្លៃ ដល់ពលរដ្ឋរបស់ខ្លួន។ ដូច្នេះ មាត្រានេះក៏គ្របដណ្តប់លើរដ្ឋណាមួយដែលបានធ្វើដំណើរចេញពីប្រព័ន្ធអប់រំបឋមសិក្សាដោយបង្ខំ ដោយឥតគិតថ្លៃ ទៅកាន់ប្រព័ន្ធមួយដែលយកថ្លៃខ្លះ ទោះបីមូលហេតុនៃការដើរថយក្រោយនេះយ៉ាងណាក៏ដោយ។ ល័ក្ខខ័ណ្ឌដែលតំរូវថា ការអប់រំត្រូវតែ "ឥតគិតថ្លៃ"នោះមិនអាចបង្វែងបានទេ ដោយយកមកប្រើនូវរបប"ឈ្នួលប្រើប្រាស់"ដូចជា ថ្លៃបង់ខានមិនបានសំរាប់ការសាងសង់សាលារៀន ឬវិភាគទានចាំបាច់ខានមិនបានដទៃទៀតសំរាប់សេវាកម្មមូលដ្ឋាន។

របាយការណ៍ក្នុងក្របខ័ណ្ឌនៃមាត្រានេះ ត្រូវផ្តល់ចំណុចជាក់លាក់អំពី"ផែនការសកម្មភាពពិស្តារ"ដែលបានបង្កើតឡើង។ ផែនការនោះ ត្រូវឆ្លុះបញ្ចាំងឱ្យឃើញនូវវិធីមួយជំហានម្តងៗដែលប្រឌិតឡើងដើម្បីធានាថា

គោលដៅចាំបាច់នឹងបានទៅដល់ក្នុងរយៈពេលដ៏សមស្រប។ ការសន្មតទាក់ទងនឹងបទបញ្ញត្តិនេះគឺថា គ្រប់រដ្ឋ មិនថាស្ថានការណ៍ហិរញ្ញវត្ថុរបស់ខ្លួនយ៉ាប់យ៉ឺនប៉ុណ្ណា ឬមិនថាហេដ្ឋារចនាសម្ព័ន្ធសាលាបឋមសិក្សា មិនគ្រប់គ្រាន់ នៅពេលបច្ចុប្បន្នប៉ុណ្ណាក៏ដោយ រដ្ឋនោះត្រូវចាត់វិធានការជាបន្ទាន់ និងដោយប្រុងប្រយ័ត្នដើម្បីធានាថា ការអប់រំ បឋមសិក្សាមានសំរាប់មនុស្សគ្រប់គ្នា ព្រោះវាជារឿងសិទ្ធិ។ ដូចក្របខ័ណ្ឌសំរាប់វិធានការដើម្បីបំពេញសេចក្តី ត្រូវការជាមូលដ្ឋានខាងការអប់រំ( សូមមើលមាត្រា ១៣ ខាងលើ) ថ្លែងថា "ទិសដៅដែលអាចសង្កេតបាន និងវាស់ វែងបាន ជួយឱ្យគេវាយតម្លៃបានដោយសត្យានុម័តនូវការជឿនលឿន"។

## មាត្រា ១៥

**អត្ថបទនៃមាត្រា ១៥**

១. រដ្ឋជាភាគីទាំងអស់ទទួលស្គាល់នូវសិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងការ :

(ក) រួមចំណែកនៅក្នុងជីវភាពវប្បធម៌ ។

(ខ) ទទួលបាននូវអត្ថប្រយោជន៍ ពីការរីកចំរើនផ្នែកវិទ្យាសាស្ត្រ និងពីការអនុវត្តន៍នៃវិទ្យាសាស្ត្រ ទាំង នេះ ។

(គ) ទទួលបាននូវអត្ថប្រយោជន៍ពីការការពារផលប្រយោជន៍ ទាំងផ្នែកសម្ភារៈ និងស្មារតីនូវផលិតផល ដែលកើតចេញមកពីវិទ្យាសាស្ត្រ អក្សរសាស្ត្រ ឬសិល្បៈដែលខ្លួនគេជាអ្នកនិពន្ធ ។

២. រដ្ឋទាំងអស់ដែលជាភាគី ធានានិងចាត់វិធានការយ៉ាងណាដើម្បីឱ្យសំរេចបានយ៉ាងពេញលេញនូវសិទ្ធិនេះ ដោយរាប់បញ្ចូលទាំងវិធានការណ៍ចាំបាច់ក្នុងការថែរក្សា ការធ្វើឱ្យរីកចំរើន និងការផ្សព្វផ្សាយផ្នែកវិទ្យាសាស្ត្រ និងវប្បធម៌ផង។

៣. រដ្ឋជាភាគីទាំងអស់ ធានានិងគោរពដល់សេរីភាពដែលសំខាន់ជាចាំបាច់សំរាប់ការស្រាវជ្រាវវិទ្យាសាស្ត្រ និងសកម្មភាពនៃការបង្កបង្កើតគំនិតថ្មីៗ។

៤. រដ្ឋជាភាគីទាំងអស់ទទួលស្គាល់នូវផលប្រយោជន៍ទាំងពួង ដែលផុសចេញអំពីការជំរុញលើកទឹកចិត្ត និងពង្រីកកិច្ចទាក់ទង និងសហប្រតិបត្តិការរវាងជាតិមួយនិងជាតិមួយក្នុងវិស័យវិទ្យាសាស្ត្រ និងវប្បធម៌ ។

**អត្ថបទនៃគោលការណ៍ណែនាំ ស្តីពីមាត្រា ១៥ នៃកតិកាសញ្ញា**

១. សូមពិពណ៌នាពីវិធានការខាងនីតិបញ្ញត្តិ និងវិធានការដទៃទៀតដែលរដ្ឋាភិបាលរបស់អ្នកបានប្រកាន់យក ដើម្បីឱ្យមនុស្សម្នាក់ៗបានសំរេចសិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌តាមការពេញចិត្ត និងសំដែងចេញនូវវប្បធម៌ផ្ទាល់ របស់ខ្លួន។ ជាពិសេស សូមផ្តល់ពត៌មានទាំងឡាយលើចំណុចដូចតទៅ :

(ក) ការមានមូលនិធិបំរុងទុក ដើម្បីលើកស្ទួយការអភិវឌ្ឍន៍វប្បធម៌ និងការចូលរួមទាំងអស់គ្នាក្នុង ជីវភាពវប្បធម៌ រួមមានការគាំទ្រសាធារណៈដល់ការផ្តួចផ្តើមឯកជន។

(ខ) ហេដ្ឋារចនាសម្ព័ន្ធខាងស្ថាប័នចាត់ចែងឡើង ដើម្បីអនុវត្តនយោបាយជំរុញការចូលរួមរបស់ប្រជាជនក្នុងជីវភាពវប្បធម៌--ដូចជាមជ្ឈមណ្ឌលវប្បធម៌ សារមន្ទីរ បណ្ណាល័យ រោងល្ខោន កុន--និងចូលរួមនៅក្នុងសិល្បៈ និងសិប្បកម្មជាប្រពៃណី។

(គ) ការលើកស្ទួយអត្តសញ្ញាណខាងវប្បធម៌ ដោយសារនេះជាកត្តានៃការយល់គ្នាទៅវិញទៅមករវាងបុគ្គល ក្រុម ប្រជាជាតិ និងតំបន់ទាំងឡាយ។

(ឃ) ការជំរុញការយល់ដឹងនិងការអាស្រ័យផលមត៌កវប្បធម៌នៃក្រុមជាតិពន្ធ ជនជាតិភាគតិច និងជនអន្តោប្រវេសន៍។

(ង) តួនាទីនៃប្រព័ន្ធផ្សព្វផ្សាយពត៌មាន និងគមនាគមន៍ ក្នុងការលើកទឹកចិត្តឱ្យមានការចូលរួមក្នុងជីវភាពវប្បធម៌។

(ច) ការរក្សាការពារនិងការបង្ហាញមត៌កខាងវប្បធម៌របស់មនុស្សជាតិ។

ឆ) ការធ្វើច្បាប់ដែលការពារសេរីភាពនៃការបង្កបង្កើតស្នាដៃ និងការសំដែងខាងសិល្បៈ រួមមានសេរីភាពក្នុងការផ្សព្វផ្សាយលទ្ធផលទាំងពួងនៃសកម្មភាពទាំងនេះ ព្រមទាំងបញ្ជាក់ពីការរិតត្បិត ឬការកំណត់ព្រំដែនទៅលើសេរីភាពនេះ។

(ជ) ការអប់រំផ្នែកវិជ្ជាជីវៈនៅក្នុងវិស័យវប្បធម៌ និងសិល្បៈ។

(ឈ) វិធានការឯទៀតៗ ដើម្បីធានាការអភិរក្ស ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយវប្បធម៌។

សូមប្រាប់នូវអនុភាពជាវិជ្ជមាន ព្រមទាំងការលំបាក និងបរាជ័យទាំងឡាយ ពិសេសចំពោះក្រុមអន្តោប្រវេសន៍ និងក្រុមបាត់បង់ប្រៀបឯទៀតៗ និងក្រុមទន់ខ្សោយហួស។

២. សូមពិពណ៌នាពីវិធានការខាងនីតិបញ្ញត្តិ និងវិធានការផ្សេងៗទៀតដែលប្រកាន់យកដើម្បីធានាការប្រើសិទ្ធិរបស់ម្នាក់ៗ ដើម្បីទទួលផលពីវឌ្ឍនភាពនិងការអនុវត្តន៍ខាងវិទ្យាសាស្ត្រ រួមមាន វិធានការផ្តោតទៅរកការអភិរក្ស ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយវិទ្យាសាស្ត្រ។ ពិសេស សូមផ្តល់នូវពត៌មានលើចំណុចដូចតទៅនេះ :

(ក) វិធានការប្រកាន់យកដើម្បីម្នាក់ៗទទួលផលពីការអនុវត្តន៍នៃវឌ្ឍនភាពខាងវិទ្យាសាស្ត្រ រួមមានវិធានការទាំងឡាយសំរាប់ការពារមត៌កធម្មជាតិនៃមនុស្សជាតិ និងសំរាប់លើកស្ទួយដល់ការរក្សាទុកនូវបរិស្ថានបរិសុទ្ធនិងមានសុខភាព ព្រមទាំងពត៌មានអំពីហេដ្ឋារចនាសម្ព័ន្ធខាងស្ថាប័នដែលបានបង្កើតឡើងសំរាប់គោលបំណងនេះ។

(ខ) វិធានការប្រកាន់យកដើម្បីជំរុញការផ្សព្វផ្សាយពត៌មានពីវឌ្ឍនភាពទាំងឡាយខាងវិទ្យាសាស្ត្រ។

(គ) វិធានការប្រកាន់យកដើម្បីរារាំងកុំឱ្យយកវឌ្ឍនភាពខាងវិទ្យាសាស្ត្រ និងខាងបច្ចេកទេសទៅប្រើសំរាប់មូលហេតុផ្ទុយពីការអាស្រ័យសិទ្ធិទាំងអស់របស់មនុស្ស ពិសេសសិទ្ធិមានជីវិត មានសុខភាព មានសេរីភាពផ្ទាល់បុគ្គល និងមានជីវភាពឯកជន។

(ឃ) ការរិតត្បិតទាំងឡាយណា ដែលដាក់ទៅលើការប្រើសិទ្ធិនេះដោយបញ្ជាក់យ៉ាងលំអិតនៃបទបញ្ញត្តិខាងច្បាប់ដែលកំណត់ឱ្យមានការរិតត្បិតទាំងនេះ ។

៣. សូមពិពណ៌នា អំពីវិធានការខាងនីតិបញ្ញត្តិ និងវិធានការផ្សេងទៀតដែលប្រកាន់យក ដើម្បីធានារ៉ាប់រងការប្រើសិទ្ធិរបស់ម្នាក់ៗដើម្បីទទួលអត្ថប្រយោជន៍ពីការការពារផលប្រយោជន៍ខាងសីលធម៌ និងខាងសំភារៈដែលកើតមកពីស្នាដៃខាងវិទ្យាសាស្ត្រ ខាងអក្សរសាស្ត្រ អក្សរសិល្ប៍ ឬខាងសិល្បៈដែលគេជាអ្នកនិពន្ធ។ ជាពិសេស សូមផ្តល់ពតិមានអំពីវិធានការជាក់ស្តែងដែលផ្តោតទៅលើការអនុវត្តពេញទំហឹងនូវសិទ្ធិនេះ រួមមានការផ្តល់នូវល័ក្ខខ័ណ្ឌចាំបាច់សំរាប់សកម្មភាពខាងវិទ្យាសាស្ត្រ អក្សរសាស្ត្រ និងសិល្បៈ ហើយនិងការការពារសិទ្ធិកម្មសិទ្ធិបញ្ញាដែលជាលទ្ធផលនៃសកម្មភាពទាំងនេះ។ តើការលំបាកអ្វីខ្លះ ដែលជាឧបសគ្គដល់ការសំរេចយ៉ាងពេញលេញនូវសិទ្ធិនេះ?

៤. តើវិធានការណាខ្លះ ដែលរដ្ឋាភិបាលរបស់អ្នកបានប្រកាន់យកដើម្បីការអភិរក្ស ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយវិទ្យាសាស្ត្រ និងវប្បធម៌ ។ សូមពិពណ៌នា ជាពិសេសអំពី :

(ក) វិធានការថ្នាក់ធម្មនុញ្ញដែលបានប្រកាន់យកនៅក្នុងប្រព័ន្ធសិក្សាអប់រំជាតិ និងតាមរយៈការផ្តល់ពតិមាន ។

(ខ) វិធានការជាក់ស្តែងឯទៀតៗទាំងអស់ ដើម្បីលើកស្ទួយការអភិរក្ស ការអភិវឌ្ឍន៍ និងការផ្សព្វផ្សាយ ។

៥. សូមពិពណ៌នាអំពីវិធានច្បាប់ រដ្ឋបាល និងតុលាការ តាក់តែងឡើងដើម្បីគោរព និងការពារសេរីភាពដែលជាការចាំបាច់ខានមិនបានសំរាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងដើម្បីសកម្មភាពស្នាដៃ ពិសេស :

(ក) វិធានការដើម្បីជំរុញការប្រើសេរីភាពនេះ រួមមានការបង្កើតល័ក្ខខ័ណ្ឌទាំងអស់ និងមធ្យោបាយទាំងអស់ដែលចាំបាច់ខានមិនបានសំរាប់ការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងសំរាប់សកម្មភាព បង្កើតស្នាដៃនានា ។

(ខ) វិធានការប្រកាន់យកដើម្បីរ៉ាប់រងសេរីភាពខាងការប្តូរពតិមានវិទ្យាសាស្ត្រ បច្ចេកទេស និងវប្បធម៌ ការប្តូរទស្សនៈនិងបទពិសោធន៍រវាងអ្នកវិទ្យាសាស្ត្រ អ្នកនិពន្ធ អ្នកបង្កើតស្នាដៃ សិល្បករ និងបុគ្គលមានស្នាដៃដទៃទៀត និងស្ថាប័នរបស់គេរៀងៗខ្លួន ។

(គ) វិធានការប្រកាន់យកដើម្បីគាំទ្រសមាគមអ្នកប្រាជ្ញ បណ្ឌិតសភាវិទ្យាសាស្ត្រ សមាគម វិជ្ជាជីវៈសហជីពកម្មករ និងអង្គការនិងស្ថាប័នផ្សេងៗដែលមានកិច្ចការស្រាវជ្រាវខាងវិទ្យាសាស្ត្រ និងសកម្មភាពបង្កើតស្នាដៃនានា ។

តើមានការលំបាកអ្វីខ្លះដែលជាឧបសគ្គដល់ការសំរេចសេរីភាពនេះយ៉ាងពេញលេញ? ។

៦. សូមពិពណ៌នាអំពីវិធានការខាងនីតិបញ្ញត្តិនិងវិធានផ្សេងទៀតដែលតាមរយៈវិធានការទាំងនេះ រដ្ឋាភិបាលរបស់អ្នកលើកទឹកចិត្ត និងពង្រីកសហប្រតិបត្តិការ និងការទាក់ទងអន្តរជាតិនៅក្នុងវិស័យវិទ្យាសាស្ត្រ អក្សរសាស្ត្ររួមមានវិធានការទាំងឡាយដែលប្រកាន់យកដើម្បី ៈ

(ក) រដ្ឋមានការពាក់ព័ន្ធទាំងអស់ ប្រើបានជាអតិបរមានូវមធ្យោបាយទាំងអស់ដែលផ្តល់ឱ្យ ដោយសាររដ្ឋរបស់អ្នកជាភាគីនៃអនុសញ្ញា កិច្ចព្រមព្រៀង និងឧបករណ៍អន្តរជាតិ និងតាមតំបន់ក្នុងវិស័យ វិទ្យាសាស្ត្រ និងវប្បធម៌។

(ខ) អ្នកប្រាជ្ញ បណ្ឌិត អ្នកនិពន្ធ សិល្បករ និងមនុស្សផ្សេងៗទៀតចូលរួមក្នុងការធ្វើការ ស្រាវជ្រាវខាងវិទ្យាសាស្ត្រ ឬសកម្មភាពបង្កបង្កើតស្នាដៃ នៅក្នុងសន្និសិទ សិក្ខាសាលា ការប្រជុំសន្ទនាស្តីពីវិទ្យាសាស្ត្រ និងវប្បធម៌អន្តរជាតិ។

តើកត្តានិងការលំបាកអ្វីខ្លះ ដែលរំខានដល់ការពង្រីកសហប្រតិបត្តិការអន្តរជាតិ នៅក្នុងវិស័យនេះ។

៧. ក្នុងកម្លុងពេលធ្វើរបាយការណ៍នេះ តើមានការផ្លាស់ប្តូរណាមួយក្នុងនយោបាយជាតិ ច្បាប់ និងការអនុវត្តដែលមានផលជាអវិជ្ជមានលើសិទ្ធិដែលចែងក្នុងមាត្រា ១៥ ដែរឬទេ? បើមាន សូមពិពណ៌នាអំពីការផ្លាស់ប្តូរទាំងនេះ ហើយសូមវាយតម្លៃលើផលនៃការផ្លាស់ប្តូរទាំងនេះ។

៨. បើរដ្ឋាភិបាលអ្នកទើបតែបានបញ្ជូនរបាយការណ៍ទៅ អ.ស.ប. ឬស្ថាប័នជំនាញណាមួយស្តីអំពីសិទ្ធិមាននៅក្នុងមាត្រា ១៥ អ្នកគប្បីគ្រាន់តែនិយាយយោងទៅរបាយការណ៍នោះត្រង់ចំណុចដែលពាក់ព័ន្ធ ដោយមិនបាច់និយាយដដែលៗឡើងវិញនៅក្នុងរបាយការណ៍នេះទេ អំពីពត៌មានដែលត្រូវបានផ្តល់រួចហើយនោះទេ។

៩. សូមបញ្ជាក់ពីតួនាទីនៃជំនួយអន្តរជាតិក្នុងការធ្វើឱ្យបានសំរេចពេញលេញនូវសិទ្ធិទាំងឡាយ ដែលចែងនៅក្នុងមាត្រា ១៥។

## សេចក្តីដកស្រង់ពីអត្ថបទនៃសេចក្តីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)

## មនុស្សមានពិការភាព

៣៦. វិធានជាបទដ្ឋានចែងថា "រដ្ឋគប្បីធានានូវឱកាសដល់បុគ្គលមានពិការភាពប្រើប្រាស់សក្តានុពលឆ្នៃប្រឌិតសិល្បៈ និងបញ្ញារបស់ពួកគេមិនត្រឹមតែសំរាប់ជាប្រយោជន៍ផ្ទាល់ខ្លួនរបស់គេទេ ក៏ប៉ុន្តែសំរាប់ជាប្រយោជន៍នៃសហគមន៍ផងដែរ ទោះបីជានៅទីជនបទ ឬទីក្រុងក៏ដោយ...។ រដ្ឋត្រូវជំរុញឱ្យមានលទ្ធភាព និងការមានទីកន្លែងសំរាប់ការសំដែង និងសេវាវប្បធម៌។ ស្ថានភាពដូចគ្នានេះ ក៏ត្រូវអនុវត្តផងដែរនៅតាមទីកន្លែងនានាសំរាប់ការលំហែកំសាន្ត កីឡា និង ទេសចរណ៍ ។

៣៧. សិទ្ធិចូលរួមពេញលេញក្នុងជីវភាពវប្បធម៌ និងការកំសាន្តសំរាប់បុគ្គលមានពិការភាព ទាមទារបន្ថែមទៀតនូវការលុបបំបាត់របាំងគមនាគមន៍តាមដែលអាចធ្វើទៅបាន។ វិធានការមានសារប្រយោជន៍ក្នុងន័យនេះអាចរួមមាន "ការប្រើសៀវភៅចេះបញ្ចេញសំលេង ឯកសារសរសេរដោយភាសាសាមញ្ញ និងមានទម្រង់ និងពណ៌ច្បាស់លាស់សំរាប់បុគ្គលមានពិការភាពផ្នែកសតិ(និង)កម្មវិធីសំរួលផ្នែកទូរទស្សន៍ និងមហោស្រពសំរាប់មនុស្សថ្លង់។

៣៨. ដើម្បីជួយសំរបសំរួលការចូលរួមស្មើៗគ្នាក្នុងជីវភាពវប្បធម៌របស់បុគ្គលមានពិការភាព រដ្ឋាភិបាលគប្បីជូនដំណឹង និងធ្វើការអប់រំសាធារណៈជនអំពីពិការភាព ។ ជាពិសេស ត្រូវចាត់វិធានការបំបាត់អរិយាបថអគតិ ឬអបិយជំនឿចំពោះបុគ្គលមានពិការភាព ឧទាហរណ៍ ទស្សនៈដែលថាជំងឺឆ្កួតជ្រូកគឺជាព្រលឹងខ្មោចចូល ឬ កុមារមានពិការភាព គឺជាទម្រង់បណ្ដាសាមួយដល់គ្រួសារនេះ។ ក្នុងន័យដូចគ្នានេះ សាធារណៈជនគប្បីមានការអប់រំដើម្បីទទួលស្គាល់ថា បុគ្គលមានពិការភាពក៏មានសិទ្ធិដូចគ្នានឹងអ្នកឯទៀតដែរក្នុងការប្រើប្រាស់ភោជនីយដ្ឋានសណ្ឋាគារ មជ្ឈមណ្ឌលកំសាន្ត និងវប្បធម៌នានា ។

**សេចក្ដីដកស្រង់ពីអត្ថបទនៃសេចក្ដីអធិប្បាយទូទៅ លេខ ៥ (១៩៩៤)**

**សិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌របស់មនុស្សចាស់**

៣៩. ក្នុងវាក្យខ័ណ្ឌ ១ មាត្រា ១៥(ក)និង(ខ) នៃកតិកាសញ្ញា រដ្ឋជាភាគីទទួលស្គាល់សិទ្ធិមនុស្សម្នាក់ៗក្នុងការចូលរួមជីវភាពវប្បធម៌ និងអាស្រ័យផលនៃអត្ថប្រយោជន៍នៃការរីកចំរើនខាងវិទ្យាសាស្ត្រនិងការអនុវត្តន៍ខាងវិទ្យាសាស្ត្រ។ ចំពោះរឿងនេះ គណៈកម្មាធិការទទូចឱ្យរដ្ឋជាភាគីពិចារណាទៅដល់អនុសាសន៍ដែលមាននៅក្នុងគោលការណ៍នានារបស់អ.ស.ប. សំរាប់មនុស្សចាស់ និងជាពិសេសគោលការណ៍ទី៧ដែលចែងថាៈ "មនុស្សចាស់ត្រូវតែនៅរួមរស់នៅក្នុងសង្គមជានិច្ច ចូលរួមយ៉ាងសកម្មក្នុងការតាក់តែង និងអនុវត្តគោលនយោបាយនានា ដែលមានផលប៉ះពាល់ដោយផ្ទាល់លើសុខុមាលភាពរបស់គេ ហើយនិងចែកចាយចំណេះវិជ្ជា និងការប៉ិនប្រសប់របស់គេដល់ក្មេងជំនាន់ក្រោយ"។ ចំណែកគោលការណ៍ ១៦ ចែងថាៈ"មនុស្សចាស់ត្រូវ មានលទ្ធភាពទទួលបានធនធានផ្នែកអប់រំ វប្បធម៌ ស្មារតី និង ការលំហែ របស់សង្គម" ។

៤០. ដូចគ្នាដែរ អនុសាសន៍លេខ ៤៨ នៃផែនការសកម្មភាពអន្តរជាតិនៅទីក្រុងវីយែនស្ដីពីជរាភាព លើកទឹកចិត្តឱ្យរដ្ឋាភិបាល និង អង្គការអន្តរជាតិគាំទ្រកម្មវិធីនានាដែលមានគោលដៅផ្ដល់ឱកាសងាយស្រួលដល់មនុស្សចាស់បានចូលក្នុងមន្ទីរវប្បធម៌(សារមន្ទីរ មហោស្រព សាលប្រគុំដន្ត្រី រោងភាពយន្ត ។ល។)

៤១. អនុសាសន៍លេខ ៥០ បានសង្កត់លើការចាំបាច់របស់រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និងមនុស្សចាស់ខ្លួនឯងតែម្តង ក្នុងការប្រឹងប្រែងលុបបំបាត់រូបភាពជាអវិជ្ជមានរបស់មនុស្សចាស់ដែលកើតឡើងពីគំនិតបែងប្រភេទ ដោយសារមនុស្សចាស់ទទួលរងពិការភាពខាងផ្លូវកាយ និងចិត្តសាស្ត្រ មិនអាចធ្វើអ្វីដោយខ្លួនឯង និងមិនមានតួនាទី ឬឋានៈអ្វីនៅក្នុងសង្គម។ ការប្រឹងប្រែងទាំងនេះ ដែលត្រូវមានការចូលរួមពីប្រព័ន្ធពតិមាន និងស្ថាប័នអប់រំផង គឺជាការសំខាន់ណាស់ដើម្បីឱ្យកើតបានជាសង្គមមួយដែលឈានមុខគេក្នុងការធ្វើសមាហរណកម្មមនុស្សចាស់ឱ្យបានពេញលេញ ។

៤២. ចំពោះសិទ្ធិទទួលអត្ថប្រយោជន៍នៃការរីកចំរើនខាងវិទ្យាសាស្ត្រ និង ការអនុវត្តន៍វិទ្យាសាស្ត្រ រដ្ឋជាភាគីត្រូវពិចារណាទៅដល់អនុសាសន៍លេខ ៦០, ៦១, និង ៦២ នៃផែនការសកម្មភាពអន្តរជាតិនៅទីក្រុងវីយែន និងធ្វើការប្រឹងប្រែងដើម្បីលើកស្ទួយដល់ការស្រាវជ្រាវខាងទិដ្ឋភាពជីវវិទ្យា សតិ និងសង្គមនៃមនុស្សចាស់ និងស្រាវជ្រាវរកវិធីជួយទ្រទ្រង់សមត្ថភាពផ្នែកមុខងារ និងទប់ស្កាត់ និងពន្យាការចាប់ផ្តើមជម្ងឺរ៉ាំរ៉ៃ និងពិការភាព។ ចំពោះបញ្ហានេះ រដ្ឋ អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ត្រូវបង្កើតស្ថាប័នដែលមានឯកទេសខាងការបង្រៀនជរាវិទ្យា វិជ្ជាខាងការព្យាបាលជរាភាព និងចិត្តសាស្ត្រជរាភាព នៅក្នុងប្រទេសដែលមិនមានស្ថាប័នបែបនេះ។

## សេចក្តីអធិប្បាយ

គោលការណ៍ណែនាំចំពោះការតាក់តែងរបាយការណ៍ទាក់ទងនឹងមាត្រា ១៥ មានលក្ខណៈល្អិត ហើយជាក់លាក់គ្រាន់បើ។ ចំណុចសំខាន់ជាងគេដែលត្រូវលើកឡើងក្នុងគោលបំណងរបាយការណ៍គឺថា បញ្ហាបីខុសៗគ្នាច្រើនត្រូវបានដោះស្រាយនៅក្នុងមាត្រានេះ ហើយបញ្ហានីមួយៗត្រូវតែបានពិនិត្យឱ្យល្អិតល្អន់បន្តិចនៅក្នុងរបាយការណ៍របស់រដ្ឋ។ សិទ្ធិដែលគេពុំសូវរវីរវល់នៅក្នុងមាត្រានេះ ប្រហែលជាសិទ្ធិរបស់ម្នាក់ៗក្នុងការចូលរួមក្នុងជីវភាពវប្បធម៌។ នេះជាបទបញ្ញត្តិតែមួយក្នុងកតិកាសញ្ញាដែលឆ្លើយនឹងបញ្ហានេះដោយច្បាស់ៗ។ បើគិតដល់ការភ្ញាក់រលឹកធំឡើងៗចំពោះសារសំខាន់នៃអត្តសញ្ញាណ ខាងវប្បធម៌ ពិសេសសំរាប់ក្រុមនានាដូចជាជនជាតិភាគតិច ជនអន្តោគ្រាម អន្តោប្រវេសន៍ អ្នកដែលមានប្រពៃណីនិងឫសគល់ខាងវប្បធម៌ ប្លែកពីអ្វីដែលអ្នកភាគច្រើនមាន សិទ្ធិនេះជាញឹកញាប់មានសារសំខាន់បំផុត។ ថ្វីបើពតិមានទូទៅអំពីកម្មវិធីនិង សកម្មភាពជាវិជ្ជមាននៅក្នុងវិស័យវប្បធម៌មានសារសំខាន់នៅទីនេះក៏ដោយ គណៈកម្មាធិការមានការខ្វល់ខ្វាយជាពិសេសចង់ដឹងពីករណីដែលសិទ្ធិ នេះមិនបានទទួលក្នុងពេលបច្ចុប្បន្នដោយក្រុមផ្សេងៗក្នុងសង្គមនីមួយៗ។

ចំពោះសិទ្ធិឯទៀតៗដែលនិយាយនៅក្នុងមាត្រា ១៥ ការពិសោធន៍កន្លងមកបានបង្ហាញឱ្យឃើញថា មាននិន្នាការមួយដែលរបាយការណ៍របស់រដ្ឋជាភាគីរាយបញ្ជីច្បាប់មួយចំនួនតូច ព្រមទាំងកិច្ចព្រមព្រៀងជាអន្តរជាតិរួចហើយរដ្ឋនោះសន្និដ្ឋានថា ខ្លួនឯងបានបំពេញតាមសេចក្តីតំរូវនៃរបាយការណ៍រួចហើយ។ ដូចគ្នានិងបទបញ្ញត្តិឯ

ទៀត១នៃកតិកាសញ្ញាអញ្ចឹងដែរ រដ្ឋជាភាគីត្រូវចងចាំពីសារៈសំខាន់ក្នុងការបញ្ជាក់អំពីកត្តា និងការលំបាកនានា (បើសិនជាមាន) ដែលធ្វើឱ្យរាំងស្ទះដល់ការបានសំរេចពេញបរិបូរណ៍នូវសិទ្ធិទាំងនេះ។

សិទ្ធិទាំងនេះ ក៏មានពិពណ៌នានៅក្នុងមាត្រា ២៧ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ៥ (ង)(៦) នៃអនុសញ្ញាអន្តរជាតិស្តីពីការបំបាត់ការរើសអើងពូជសាសន៍, មាត្រា ១៣ (គ) នៃអនុសញ្ញាស្តីពីការបំបាត់ការរើស អើងប្រឆាំងនឹងស្ត្រី, និងមាត្រា ៣០ និង ៣១ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែរ។

## ខ. ការពិនិត្យរបាយការដោយគណៈកម្មានៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌

### (ក) <u>សមាសភាពនៃគណៈកម្មាធិការ</u>

ដូចបានជំរាបនៅខាងលើ កតិកាសញ្ញានេះមិនបានចែងចំ១ពីការបង្កើតគណៈកម្មាធិការមួយទទួលបន្ទុកជួយក្រុមប្រឹក្សា សេដ្ឋកិច្ច និងសង្គម នៅក្នុងការងារប្រគល់ឱ្យដោយអនុវត្តកតិកាសញ្ញានេះទេ។ ក្រុមប្រឹក្សាដំបូងឡើយ បានព្យាយាមបំពេញអាណត្តិរបស់ខ្លួនដោយផ្អែកលើការងាររបស់ក្រុមការងារសម័យប្រជុំ ដែលជាដំបូងមានសមាសភាពប្រតិភូក្រុមប្រឹក្សា រួចតមកមានអ្នកជំនាញខាងរដ្ឋាភិបាល។ ដោយតមកយល់ឃើញថាការរៀបចំបែបនេះមិនជាទីពេញចិត្ត ក្រុមប្រឹក្សាក៏បានសំរេចបង្កើតគណៈកម្មាធិការមួយដែលមានចំណុចច្រើនប្រហាក់ប្រហែលគ្នានឹងគណៈកម្មាធិការសិទ្ធិមនុស្ស ដែលត្រូវបានតែងតាំងឡើងដើម្បីឃ្លាំមើលការអនុវត្តកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

ឯកសារជាចាំបាច់ត្រូវបានអនុម័តឡើងដោយក្រុមប្រឹក្សានាឆ្នាំ ១៩៨៥ ហើយក្រោយមក ក្រោយពីបានត្រួត ពិនិត្យឡើងវិញយ៉ាងជ្រៅជ្រះ នាឆ្នាំ ១៩៩០ និង១៩៩៥ ក៏ត្រូវបានទទួលយល់ព្រមដោយក្រុមប្រឹក្សាទៅ។ នៅឆ្នាំ១៩៩៦ ក្រុមប្រឹក្សាបានពិចារណារិះរកមធ្យោបាយដែលតាមវិធី និងមធ្យោបាយទាំងនេះ ឋានៈគតិយុត្តជាផ្លូវការ (គឺមិនមែនត្រឹមតែឋានៈតាមហេតុជាក់ស្តែងនោះទេ) របស់គណៈកម្មាធិការត្រូវបានបង្កើតឡើងឱ្យស្របជាមួយនឹងឋានៈនៃអង្គភាពដទៃទៀតដែលបង្កើតឡើងដោយឧបករណ៍សិទ្ធិសញ្ញានានាដែលទាក់ទង។

ខាងក្រោមនេះ គេអាចបានឃើញនូវអត្ថបទដកស្រង់នៃសេចក្តីសំរេចចិត្ត ១៩៨៥/១៧ របស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច ចុះថ្ងៃទី ២៨ ខែឧសភា ឆ្នាំ១៩៨៥ ៈ

...

(ខ) គណៈកម្មាធិការមានសមាជិក ១៨ រូប ជាអ្នកជំនាញការដែលមានសមត្ថភាព ដែលគេទទួលស្គាល់ក្នុងវិស័យសិទ្ធិមនុស្ស ហើយដែលបំពេញនាទីក្នុងនាមខ្លួនម្នាក់១ផ្ទាល់ហើយសមាសភាពនេះ ត្រូវគិតយ៉ាងត្រឹមត្រូវដល់ការចែកទៅតាមភូមិសាស្ត្រប្រកបដោយសមធម៌ និងទៅតាមភាពតំណាងនៃប្រព័ន្ធខាងសង្គម និងខាងគតិយុត្តិ។ ដើម្បីទិសដៅនេះ កៅអី ១៥ នឹងត្រូវបានចែកដោយសមធម៌រវាងក្រុមខាងតំបន់ទាំងឡាយ រីឯកៅអី ៣ ទៀតនឹងត្រូវបានប្រគល់ទៅតាមការកើនឡើងនៃចំនួនសរុបនៃរដ្ឋជាភាគីក្នុងមួយក្រុមខាងតំបន់។

(គ) សមាជិកទាំងឡាយនៃគណៈកម្មាធិការនឹងត្រូវជ្រើសតាំងដោយក្រុមប្រឹក្សា តាមការបោះឆ្នោតជាសំងាត់លើបញ្ជីបេក្ខជន ដែលត្រូវបានឱ្យឈ្មោះមកដោយបណ្តារដ្ឋជាភាគីនៃកតិកាសញ្ញាអន្តរជាតិទាក់ទងទៅនឹងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងល័ក្ខខ័ណ្ឌដូចតទៅ :

i) សមាជិករបស់គណៈកម្មាធិការនឹងត្រូវបោះឆ្នោតជ្រើសតាំងសំរាប់អាណត្តិ ៤ ឆ្នាំ ហើយនិងត្រូវអាចបោះឆ្នោតជ្រើសតាំងថ្មីទៀតនៅពេលចប់អាណត្តិ បើសិនជាឱ្យឈ្មោះមកជាថ្មី

ii) ពាក់កណ្តាលនៃសមាជិករបស់គណៈកម្មាធិការនឹងត្រូវផ្លាស់ជាថ្មីរាល់រយៈពេល ២ ឆ្នាំម្តង ដោយគិតដល់ការចាំបាច់ និងការរក្សាទុកនូវការចែកតាមភូមិសាស្ត្រប្រកបដោយសមធម៌ដូចបានពោលនៅវគ្គ (១) ខាងលើ

iii) ការបោះឆ្នោតលើកទីមួយនឹងប្រព្រឹត្តទៅនៅឱកាសសម័យប្រជុំសាម័ញ្ញលើកទីមួយនាឆ្នាំ ១៩៨៦ នៃក្រុមប្រឹក្សា បន្ទាប់ពីការបោះឆ្នោតលើកទីមួយភ្លាម ប្រធានក្រុមប្រឹក្សាតាមការចាប់ឆ្នោតនឹងជ្រើសយកសមាជិក ៩ នាក់ ដែលអាណត្តិរបស់គេនឹងត្រូវចប់នៅដំណាច់ឆ្នាំទីពីរ

iv) អាណត្តិរបស់សមាជិកជាប់ឆ្នោតសំរាប់គណៈកម្មាធិការ ចូលជាធរមានពីថ្ងៃទី១ ខែមករា តាមការជាប់ឆ្នោតរបស់គេ ហើយផុតកំណត់នៅថ្ងៃទី៣១ ខែធ្នូ ក្រោយពីការបោះឆ្នោតរើសសមាជិកដែលត្រូវជំនួសនៅក្នុងគណៈកម្មាធិការ

v) ការបោះឆ្នោតក្រោយៗ ត្រូវធ្វើក្នុងរយៈពីរឆ្នាំម្តងនៅឱកាសសម័យប្រជុំសាមញ្ញលើកទីមួយរបស់ក្រុមប្រឹក្សា

vi) យ៉ាងតិចបួនខែមុនថ្ងៃបោះឆ្នោតណាមួយសំរាប់រើសសមាជិកចូលក្នុងគណៈកម្មាធិការ លោកអគ្គលេខាធិការសរសេរទៅអញ្ជើញរដ្ឋជាភាគីនៃកតិកាសញ្ញាទាំងអស់ឱ្យចង្អុលឈ្មោះបេក្ខជនសំរាប់ចូលជាសមាជិករបស់គណៈកម្មាធិការ ក្នុងរយៈ ៣ខែ មុនការបោះឆ្នោត លោកអគ្គលេខាធិការ ផ្ញើបញ្ជីឈ្មោះដែលត្រូវបានបញ្ជូនមកនោះដោយកត់ឈ្មោះបណ្តារដ្ឋជាភាគីដែលជាអ្នកបញ្ជូនឈ្មោះបេក្ខជន ហើយបញ្ចូលបញ្ជីនោះទៅក្រុមប្រឹក្សាយ៉ាងយូរមួយខែមុនថ្ងៃបោះឆ្នោតនីមួយៗ។

(ឃ) គណៈកម្មាធិការប្រជុំគ្នារៀងរាល់មួយឆ្នាំម្តងនៅ "ហ្សឺណែវ" ម្តងនៅ "ញូយ៉ក" ក្នុងរយៈពេលមិនលើសពី ៣ សប្តាហ៍ ហើយដោយយោលទៅលើចំនួនរបាយការណ៍ដែលគណៈកម្មាធិការត្រូវពិនិត្យ ។

(ង) សមាជិកគណៈកម្មាធិការនឹងទទួលប្រាក់បំណាច់ស្របទៅតាមថ្លៃដំណើរ និងប្រាក់បំណាច់សំរាប់រស់នៅដែលត្រូវបញ្ចូលទៅក្នុងបន្ទុកធនធានរបស់អង្គការសហប្រជាជាតិ (អ.ស.ប) ។

(ច) គណៈកម្មាធិការនឹងធ្វើរបាយការណ៍ជូនទៅក្រុមប្រឹក្សា អំពីសកម្មភាពរបស់ខ្លួន រួមមាន សេចក្តីសង្ខេបអំពីការពិនិត្យលើរបាយការណ៍របស់រដ្ឋជាភាគីនៃកតិកាសញ្ញាទាំងឡាយ ហើយនឹងធ្វើសេចក្តីផ្តល់យោបល់ និងសេចក្តីទូន្មានទូទៅផ្អែកលើអ្វីដែលបានពិនិត្យឃើញលើរបាយការណ៍ទាំងនោះ និងលើរបាយការណ៍របស់ស្ថាប័នជំនាញទាំងឡាយ ដើម្បីជួយក្រុមប្រឹក្សាក្នុងការបំពេញភារកិច្ចរបស់ខ្លួន ពិសេស អំពីអ្វីដែលចេញមកពីមាត្រា ២១ និង ២២ នៃកតិកាសញ្ញា។

(ឆ) អគ្គលេខាធិការនឹងចាត់ឱ្យធ្វើរបាយការណ៍លំអិតស្តីពីការពិភាក្សារបស់គណៈកម្មាធិការ រួចបញ្ជូនទៅក្រុមប្រឹក្សាជាមួយនឹងរបាយការណ៍របស់គណៈកម្មាធិការផងដែរ។ អគ្គលេខាធិការរំពៃយ៉ាងណាឱ្យគណៈកម្មាធិការមានបុគ្គលិក និងការរៀបចំកន្លែងការងារចាំបាច់ សំរាប់បំពេញភារកិច្ចដោយស័ក្តិសិទ្ធិ ដោយគិតដល់ការចាំបាច់សំរាប់រ៉ាប់រងនូវការឃោសនាគ្រប់យ៉ាងពីការងារទាំងឡាយរបស់ខ្លួន។

....

បេក្ខជនទាំងឡាយសំរាប់គណៈកម្មាធិការត្រូវបានឱ្យឈ្មោះដោយរដ្ឋជាភាគីនៃកតិកាសញ្ញា តែត្រូវបានបោះឆ្នោតជ្រើសតាំងដោយសមាជិកទាំងអស់នៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច។ ថ្វីបើតួនាទីរើសបេក្ខជនត្រូវបានប្រគល់ទៅរដ្ឋនានា — ដែលខ្លះជាភាគីរបស់កតិកាសញ្ញា ខ្លះទៀតមិនមែនជាសមាជិក — សមាជិកទាំងឡាយនៃគណៈកម្មាធិការមិនតំណាងរដ្ឋដែលខ្លួនកាន់សញ្ជាតិនោះទេ។ សមាជិកទាំងអស់ ត្រូវបានបោះឆ្នោតជ្រើសតាំងជាអ្នកជំនាញការឯករាជ្យ ហើយបំរើក្នុងគណៈកម្មាធិការក្នុងសមត្ថភាពផ្ទាល់ខ្លួន។

គណៈកម្មាធិការបោះឆ្នោតក្នុងចំណោមសមាជិករបស់ខ្លួន ជ្រើសតាំងការិយាល័យមួយដែលមានប្រធានម្នាក់ អនុប្រធានបីនាក់ និងអ្នកធ្វើរបាយការណ៍ម្នាក់។ អ្នកទាំងនេះបំរើការងារក្នុងអាណត្តិ ២ ឆ្នាំ ហើយមានសិទ្ធិឱ្យគេបោះឆ្នោតឱ្យម្តងទៀត។ គណៈកម្មាធិការតែងតែជួបប្រជុំគ្នានៅហ្សឺណែវជានិច្ច ព្រោះម្យ៉ាងមកពី អ.ស.ប មានការលំបាកខាងហិរញ្ញវត្ថុ ហើយម្យ៉ាងទៀតមកពីចំណូលចិត្តច្រើនឡើងដែលត្រូវប្រមូលផ្តុំសកម្មភាពរបស់អង្គការខាងសន្ធិសញ្ញាសិទ្ធិមនុស្សឱ្យនៅកន្លែងតែមួយគឺ ហ្សឺណែវ ជាជាងនៅញូយ៉ក។

### <u>(ខ) របៀបរបបការងាររបស់គណៈកម្មាធិការ</u>

ជាធម្មតា គណៈកម្មាធិការប្រជុំគ្នាម្តងក្នុងមួយឆ្នាំ ការប្រជុំមានថេរវេលាបីសប្តាហ៍ក្នុងខែឧសភា និងខែ វិច្ឆិកា ធ្នូ នៅក្រុងហ្សឺណែវ។ នីតិវិធីទាំងឡាយនៃការពិនិត្យរបាយការណ៍របស់រដ្ឋទាំងឡាយ — ដោយអនុវត្តតាមផ្នែកទី ៤ នៃកតិកាសញ្ញា និងសេចក្តីសំរេចចិត្ត និងសេចក្តីសំរេចដែលទាក់ទងនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ច-ត្រូវបានកើតមកពីវិធាននីតិវិធីរបស់គណៈកម្មាធិការ និងការអនុវត្តជាទម្លាប់របស់គេចាប់តាំងពីសម័យប្រជុំទីមួយ នាឆ្នាំ ១៩៨៧ របស់គេ។ ជាទូទៅ គណៈកម្មាធិការប្រឹងប្រែងអនុវត្តនីតិវិធីដែលប្រៀបបាននឹងនីតិវិធីរបស់អង្គការឯទៀត១ បង្កើតឡើងដោយអាស្រ័យឧបករណ៍អន្តរជាតិដោយសំរបទៅតាមធាតុពិសេសនៃការងារទាំងឡាយដែលត្រូវបានប្រគល់ឱ្យ។

គណៈកម្មាធិការពិនិត្យរបាយការណ៍របស់រដ្ឋជាភាគីនីមួយៗ នៅក្នុងការប្រជុំជាសាធារណៈចំពោះមុខតំណាងម្នាក់ ឬច្រើនគ្នារបស់រដ្ឋដែលមានការពាក់ព័ន្ធ។ រដ្ឋធ្វើរបាយការណ៍ត្រូវបានជូនដំណឹងជាមុន អំពីសម័យប្រជុំពិនិត្យរបាយការណ៍របស់ខ្លួន ព្រមទាំងថ្ងៃខែកំណត់សំរាប់ការពិនិត្យនេះ។ ការស្នើសុំតក់ក្រហល់របស់រដ្ឋឱ្យលើកការពិនិត្យពិចារណាលើរបាយការណ៍ដែលបានកំណត់ពេលពិចារណារួចហើយនោះ គឺធ្វើឱ្យរំខានយ៉ាងខ្លាំងដល់ភាគីទាំងអស់ដែលពាក់ព័ន្ធ ហើយបានបណ្តាលឱ្យមានបញ្ហាដល់គណៈកម្មាធិការក្នុងពេលកន្លងមក។ ដោយហេតុនេះ នយោបាយរបស់គណៈកម្មាធិការចាប់ពីសម័យប្រជុំលើកទី ៨ របស់ខ្លួនមក គឺមិនអនុញ្ញាតឱ្យស្នើសុំបែបនេះទេ ហើយគណៈកម្មាធិការនៅតែបន្តដំណើរការពិនិត្យពិចារណារបស់ខ្លួនលើរបាយការណ៍ដែលកំណត់រួចហើយ ទោះបីជាមានអវត្តមាននៃតំណាងរបស់រដ្ឋដែលពាក់ព័ន្ធក៏ដោយ។

បណ្តាអ្នកតំណាងរបស់រដ្ឋជាភាគីមានសិទ្ធិនឹងថ្លែងមតិបើក និងថ្លែងសេចក្តីសន្និដ្ឋានបិទជូនគណៈកម្មាធិ-ការ (សូមមើលអនុផ្នែក(ឃ)ខាងក្រោម)និងមានសិទ្ធិឆ្លើយតបទៅនឹងសំណួរដែលសួរនៅពេលពិនិត្យពិចារណារបាយការណ៍។ ដោយគិតដល់សារសំខាន់នៃតួនាទីដែលត្រូវបានប្រគល់ឱ្យ ចំពោះភ្នែកគណៈកម្មាធិការ ក៏ដូចជាចំពោះភ្នែករដ្ឋដែលមានការពាក់ព័ន្ធ អ្នកតំណាងគប្បីមានបទពិសោធន៍ មានឋានៈ និងជំនាញគ្រប់គ្រាន់ចាំបាច់ដើម្បីអាចឆ្លើយសំណួរ អំពីសិទ្ធិចែងនៅក្នុងកតិកាសញ្ញា។

មុនសម័យប្រជុំរបស់គណៈកម្មាធិការ ក្រុមការងារមានការប្រជុំមួយ ជាធម្មតាត្រូវប្រជុំគ្នាចំនួន ៥ ថ្ងៃ។ ក្រុមនេះមានមុខការកំណត់ជាមុននូវបញ្ហាដែលមានប្រយោជន៍ជាងគេយកមកជជែកជាមួយនឹងអ្នកតំណាងរដ្ឋជាភាគីមានការពាក់ព័ន្ធ។ ទិសដៅប្រាថ្នា គឺបង្កើនប្រសិទ្ធិភាពរបស់ប្រព័ន្ធ និងសំរួលការងាររបស់អ្នកតំណាងរដ្ឋទាំងឡាយ ដោយជូនដំណឹងជាមុនអ្នកតំណាងនោះអំពីបញ្ហាសំខាន់ដែលអាចត្រូវបានលើកឡើងនៅពេលពិនិត្យរបាយ-ការណ៍ដែលទាក់ទងដល់ខ្លួន។ ជាទូទៅ គេទទួលស្គាល់ថាភាពស្មុគ្រស្មាញ និងភាពប្លែកៗនៃបញ្ហាមួយចំនួនដែលចោទឡើងទាក់ទងនឹងការអនុវត្តន៍កតិកាសញ្ញាគឺជាហេតុផលដែលគេត្រូវផ្តល់លទ្ធភាពឱ្យរដ្ឋជាភាគីដើម្បីរៀបចំជាមុននូវចម្លើយរបស់ខ្លួនទៅនឹងសំណួរសំខាន់មួយចំនួនដែលលើកឡើងក្នុងរបាយការណ៍របស់រៀងខ្លួន។ ការសំរួលបែបនេះ អនុញ្ញាតឱ្យរដ្ឋជាភាគី អាចមានលទ្ធភាពនឹងផ្តល់ពតិមានជាក់ច្បាស់ និងលំអិត។

ស្តីអំពីវិធីធ្វើការងារ ក្នុងគោលបំណងធ្វើឱ្យមានប្រសិទ្ធិភាព ក្រុមការងារបានសំរេចរំលែកការទទួលខុសត្រូវដំបូងឱ្យសមាជិកម្នាក់ៗទទួលសិក្សាដោយល្អិតល្អន់នូវរបាយការណ៍មួយចំនួន ហើយដាក់ជូនទៅក្រុមការងារនូវបញ្ជីបញ្ហាបឋមៗ។ សេចក្តីសំរេចថា តើត្រូវចែករបាយការណ៍គ្នាពិនិត្យយ៉ាងណានោះ គឺផ្អែកមួយផ្នែក ទៅលើវិស័យជំនាញដែលសាមីសមាជិកចូលចិត្ត។ តមក សេចក្តីព្រាងបញ្ជីបញ្ហាមួយៗ ត្រូវបានពិនិត្យសាជាថ្មី និងបំពេញបន្ថែមតាមសេចក្តីសង្កេតរបស់សមាជិកឯទៀតៗនៃក្រុម។ ជាបង្ហើយ បញ្ជីត្រូវបានអនុម័តដោយក្រុមទាំងមូល។ វិធីនេះត្រូវបានអនុវត្តចំពោះរបាយការណ៍ដើម ក៏ដូចជារបាយការណ៍ខួប។

ជាកិច្ចត្រៀមរៀបចំសំរាប់ក្រុមការងារមុនបើកសម័យប្រជុំ គណៈកម្មាធិការបានសុំឱ្យលេខាធិការដ្ឋានទុកឯកសារវិភាគប្រទេស ព្រមទាំងឯកសារទាំងអស់ដែលទាក់ទង ដែលមានពតិមានទាក់ទងនឹងរបាយការណ៍

នីមួយៗដែលត្រូវពិនិត្យ សំរាប់ឱ្យសមាជិកគណៈកម្មាធិការប្រើប្រាស់តាមត្រូវការ។ សំរាប់គោលបំណងនេះ គណៈកម្មាធិការបានអញ្ជើញបុគ្គល ស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធឱ្យដាក់ជូនឯកសារដែលទាក់ទងនិងសមស្របទៅឱ្យលេខាធិការដ្ឋាន។ គណៈកម្មាធិការ ក៏បានសុំឱ្យលេខាធិការដ្ឋាន ធានាធ្វើយ៉ាងណាឱ្យប្រភេទនៃពត៌មានខ្លះ ត្រូវបានទុកដាក់ឱ្យចំសំណុំឯកសាររបស់វា។

ដើម្បីធានាថា គណៈកម្មាធិការបានទទួលពត៌មានគ្រប់គ្រាន់ដែលអាចធ្វើទៅបាន គណៈកម្មាធិការផ្តល់ឱកាសឱ្យអង្គការក្រៅរដ្ឋាភិបាលដាក់ជូនពត៌មានដែលទាក់ទងជូនដល់ខ្លួន។ អង្គការក្រៅរដ្ឋាភិបាល អាចធ្វើដូច្នេះបានជាលាយល័ក្ខអក្សរនៅពេលណាមួយ ស្របទៅតាមនីតិវិធីសមស្របរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម។ ក្រុមការងារមុនសម័យប្រជុំរបស់គណៈកម្មាធិការក៏បើកចំហទទួលយកការដាក់ជូនពត៌មានដោយផ្ទាល់ខ្លួន ឬដោយលាយល័ក្ខអក្សរពីអង្គការក្រៅរដ្ឋាភិបាលណាមួយ ឱ្យតែពត៌មាននោះទាក់ទងនឹងសាច់រឿងក្នុងរបៀបវារៈរបស់ក្រុមការងារ។ លើសពីនេះទៅទៀត គណៈកម្មាធិការលៃពេលភាគខ្លះនៃរសៀលដំបូងនៅក្នុងសម័យប្រជុំរបស់ខ្លួននីមួយៗ ដើម្បីឱ្យតំណាងពីអង្គការក្រៅរដ្ឋាភិបាលអាចផ្តល់ពត៌មានផ្ទាល់មាត់។ ពត៌មានបែបនេះ ត្រូវ : (ក) ផ្តោតជាក់លាក់ទៅលើបទបញ្ញត្តិនៃកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ (ខ)ទាក់ទងដោយត្រង់ៗទៅនឹងសាច់រឿងដែលគណៈកម្មាធិការកំពុងពិចារណា (គ)គួរឱ្យទុកចិត្តបាន និង(ឃ)មិនបំពាន។ កិច្ចប្រជុំដែលទាក់ទងរឿងនេះគឺចំហ ហើយមានសេវាបកប្រែឱ្យស្តាប់ផង ប៉ុន្តែ គេមិនកត់ចូលក្នុងកំណត់ហេតុសង្ខេបទេ។

គណៈកម្មាធិការ ស្នើសុំឱ្យលេខាធិការដ្ឋានធានាថា ធ្វើយ៉ាងណាឱ្យពត៌មានជាលាយល័ក្ខអក្សរដែលដាក់ជូនជាផ្លូវការដល់គណៈកម្មាធិការដោយបុគ្គល ឬអង្គការក្រៅរដ្ឋាភិបាលទាក់ទងទៅនឹងការពិចារណារបាយការណ៍របស់រដ្ឋជាភាគីណាមួយ មានជាស្រេចនិងឆាប់បំផុតដែលអាចធ្វើទៅបានសំរាប់ឱ្យតំណាងនៃប្រទេសដែលទាក់ទង។

គណៈកម្មាធិការបានសំរេចថានឹងធ្វើអ្វីៗទាំងអស់ដើម្បីបន្ថយចំនួនសំណួរចុះក្នុងបញ្ជីរៀបរយដោយក្រុមការងារ ហើយធ្វើយ៉ាងណាឱ្យសំណួរទាំងនោះឆ្លើយទៅនឹងប្រធានបទស្តីក្នុងកតិកាសញ្ញា។ បញ្ជីបញ្ហារៀបចំយ៉ាងនេះ ធ្វើរួចហើយត្រូវបានបញ្ជូនផ្ទាល់ទៅជូនបេសកកម្មអចិន្ត្រៃយ៍នៃរដ្ឋមានការពាក់ព័ន្ធ ដោយភ្ជាប់ទៅជាមួយផងនូវកំណត់មួយដែលបញ្ជាក់ជាពិសេសដូចតទៅ :

> *"បញ្ជីនេះមិនទាន់រៀបរាប់អស់ទេ ហើយមិនត្រូវបកស្រាយថា បញ្ជីនេះកំណត់ព្រំដែន ឬវិនិច្ឆ័យជាមុននូវប្រភេទ និងវិសាលភាពនៃសំណួរទាំងឡាយដែលបណ្តាសមាជិករបស់គណៈកម្មាធិការប្រាថ្នាចង់ឃើញលើកឡើងនោះទេ។ ក្រុមការងារមានជំនឿជាក់ថា ការសន្ទនាទ្វេភាគីក្នុងន័យស្ថាបនាដែលគណៈកម្មាធិការប្រាថ្នាចង់ធ្វើជាមួយនឹងអ្នកតំណាង រដ្ឋជាភាគីនឹងអាចមានការងាយស្រួល កាលបើបញ្ជីត្រូវបានចែកជូនមុនសម័យប្រជុំរបស់គណៈកម្មាធិការ"។*

ដើម្បីធ្វើឱ្យការសន្ទនាដែលគណៈកម្មាធិការស្វែងចង់បានឱ្យកាន់តែប្រសើរឡើង គណៈកម្មាធិការទទូច យ៉ាងខ្លាំងសុំឱ្យរដ្ឋជាភាគីនីមួយៗផ្តល់ការឆ្លើយតបជាលាយល័ក្ខអក្សររបស់ខ្លួន ទៅនឹងបញ្ហីបញ្ហា ហើយឆ្លើយតប ឱ្យបានគ្រប់គ្រាន់មុនពេលបើកសម័យប្រជុំធ្វើការពិចារណាលើរបាយការណ៍ ដើម្បីឱ្យសេចក្តីឆ្លើយតបនោះអាចគេ បកប្រែនិងចែកចាយឱ្យសមាជិកទាំងអស់នៃគណៈកម្មាធិការ។ ក្នុងករណី តំណាងរដ្ឋាភិបាលមកជួបប្រជុំជាមួយ គណៈកម្មាធិការដោយកាន់ចម្លើយជាលាយលក្ខណ៍អក្សរមកជាមួយ ដោយមិនបានផ្តល់ចម្លើយនោះជាមុន ការ សន្ទនានោះប្រហែលជាមិនបានលទ្ធផលគួរជាទីគាប់ចិត្តទេ ហើយកិច្ចការរបស់អ្នកតំណាងនឹងកាន់តែពិបាកខ្លាំង ឡើង។ ដោយសារមានករណីបែបនេះ គណៈកម្មាធិការប្រហែលជាមិនសប្បាយចិត្តទេ ហើយដូច្នេះ ការមិន សប្បាយចិត្តនេះ អាចនឹងឆ្លុះបញ្ចាំងនៅក្នុងសេចក្តីសង្កេតបញ្ចប់របស់គណៈកម្មាធិការ។

ដើម្បីអនុញ្ញាតឱ្យមានពេលគ្រប់គ្រាន់សំរាប់ដំណើរការដែលទាក់ទង ក្រុមការងារមុនសម័យប្រជុំជួបគ្នា នៅពេលចប់សម័យប្រជុំមុនៗ ដើម្បីត្រៀមរៀបចំឱ្យបានមុនបំផុតតាមដែលអាចធ្វើទៅបាន សំរាប់សម័យប្រជុំខាង ក្រោយ ហើយនឹងដើម្បីកាត់បន្ថយសោហ៊ុយធ្វើដំណើរ និងសោហ៊ុយដទៃទៀតដែលទាក់ទង។

លើសនេះទៅទៀត គណៈកម្មាធិការបានថ្លែងថា ក្នុងករណីដែលរបាយការណ៍របស់រដ្ឋជាភាគីមិនដាក់មក "ជ្រុលពេលហួសហេតុពេក"នោះគណៈកម្មាធិការនឹងពិចារណាអំពីស្ថានការណ៍ទាក់ទងនឹងការអនុវត្តន៍កតិកាសញ្ញា ដោយមិនបាច់មានរបាយការណ៍របស់រដ្ឋ។ គណៈកម្មាធិការបានគូសបញ្ជាក់ថា ខ្លួនចាត់ទុកថា ការនៅតែមិនរាយ ការណ៍របស់រដ្ឋជាភាគី នាំឱ្យនីតិវិធីត្រួតពិនិត្យទាំងមូលបាត់បង់ទំនុកចិត្ត ដែលជាហេតុធ្វើឱ្យរលំរលាយគ្រឹះរបស់ កតិកាសញ្ញា។ ចំពោះហេតុផលនេះ មានការសំរេចចិត្តក្នុងឆ្នាំ១៩៩០ ឱ្យចាប់ផ្តើមពិចារណាស្ថានការណ៍ទាក់ទងនឹង ការអនុវត្តន៍កតិកាសញ្ញាចំពោះរដ្ឋជាភាគីនីមួយៗដែលរបាយការណ៍ដំបូង ឬរបាយការណ៍ខួបរបស់គេហួសជ្រុល យ៉ាងខ្លាំង។ តមក គណៈកម្មាធិការបានអនុម័តយកនីតិវិធីមួយដែលមានបួនដំណាក់ការទាក់ទងនឹងករណីបែប នេះ។ ដំណាក់ការទីមួយ គឺការបង្ហាញឈ្មោះរដ្ឋជាភាគីណាមួយដែលរបាយការណ៍របស់ខ្លួនហួសជ្រុលពេកដោយ កត់ត្រាទៅតាមលំដាប់កាលប្បវត្តិ។ ដំណាក់ការទីពីរ គឺការជូនដំណឹងដល់រដ្ឋជាភាគីណាដែលគណៈកម្មាធិការចង់ ពិចារណាស្ថានការណ៍របស់រដ្ឋនោះនៅសម័យប្រជុំអនាគតជាក់លាក់មួយ។ ក្នុងករណីដែលរដ្ឋជាភាគីដែលពាក់ព័ន្ធ បញ្ជាក់ថា ខ្លួននឹងផ្តល់របាយការណ៍យ៉ាងឆាប់ដល់គណៈកម្មាធិការនោះ ប្រធានគណៈកម្មាធិការមានអំណាច លើកការពិចារណារបាយការណ៍នោះតែក្នុងមួយសម័យប្រជុំទេ តែមិនឱ្យយូរជាងនេះទេ។ ដំណាក់ការទីបី គឺគណៈកម្មាធិការត្រូវចាប់ដំណើរការពិចារណា ដោយមិនបាច់មានរបាយការណ៍ លើស្ថានភាពសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងប្រទេសនោះ ដោយពឹងផ្អែកលើការរៀបចំអត្ថបទព្រាងនៃការសង្កេតឃើញរបស់អ្នក រាយការណ៍ប្រចាំប្រទេសដែលពិគ្រោះជាមួយប្រភពទាំងអស់ដែលមាន។ ដំណាក់ការចុងក្រោយបង្អស់ គឺការ អនុម័តការសង្កេតឃើញចុងបញ្ចប់។

ក្នុងករណីមួយចំនួនធំ ដែលនីតិវិធីនេះត្រូវបានយកមកប្រើ រដ្ឋជាភាគីដែលយឺតមិនបានដាក់របាយ ការណ៍ជ្រុលពេលច្រើនពេកនោះ បានឆ្លើយតបយ៉ាងឆាប់ ហើយផ្តល់របាយការណ៍ឱ្យគណៈកម្មាធិការ។ ក្នុងករណី

ដែលរដ្ឋជាភាគីមិនផ្តល់របាយការណ៍ទាល់តែសោះនោះ គណៈកម្មាធិការបានបង្ហាញថា ខ្លួននឹងចាប់ធ្វើការពិនិត្យឱ្យបានខ្លាំងក្លានូវស្ថានការណ៍នេះ ហើយនិងមិនញញើតនឹងការអនុម័តយកវិធានការរិះគន់ខ្លាំង បើសិនជាការគួរ។

នៅពេលខ្លះ អង្គការក្រៅរដ្ឋាភិបាលបង្ហាញពត៌មានទៅគណៈកម្មាធិការ ដែលក្នុងពត៌មាននោះមានការចោទប្រកាន់អំពីការរំលោភបំពានលើកតិកាសញ្ញាពីសំណាក់រដ្ឋជាភាគី ហើយរដ្ឋនោះមិនមានរបាយការណ៍សំរាប់ឱ្យគណៈកម្មាធិការពិចារណា។ ក្នុងករណីបែបនេះ របៀបចាត់ការរបស់គណៈកម្មធិការគឺត្រូវធ្វើការវាយតម្លៃជាបឋម ថាពត៌មាននោះគួរជឿបានឬទេ ហើយថាតើ ពត៌មាននោះសមនឹងឱ្យយកចិត្តទុកដាក់ដែរឬយ៉ាងណា។ ពេលណាលក្ខណៈវិនិច្ឆ័យទាំងនេះត្រូវបានបំពេញហើយ គណៈកម្មាធិការនឹងស្នើសុំឱ្យរដ្ឋជាភាគីធ្វើអត្ថាធិប្បាយលើពត៌មាននោះនៅក្នុងបរិបទដែលរដ្ឋនោះបានរៀបចំធ្វើរបាយការណ៍ហើយ ឬក្នុងបរិបទដែលរបាយការណ៍នោះបានយឺតជ្រុលពេក ដែលគណៈកម្មាធិការស្នើសុំឱ្យរៀបចំ និងដាក់របាយការណ៍ឱ្យបានឆាប់ដែលមិនអាចធ្វើទៅបាន។

សេចក្តីសង្ខេប ទាន់សម័យនៃវិធីធ្វើការរបស់គណៈកម្មាធិការគឺមាននៅក្នុងរបាយការណ៍របស់គណៈកម្មា-ធិការ ហើយតំណាងរបស់រដ្ឋជាភាគីត្រូវបានប្រាប់ឱ្យអានរបាយការណ៍នោះ មុននឹងដាក់របាយការណ៍របស់ខ្លួនទៅគណៈកម្មាធិការ។

### (គ) ការសន្ទនាដោយស្ថាបនា

ការជជែកពិភាក្សារវាងសមាជិកគណៈកម្មាធិការ និងតំណាងរដ្ឋជាភាគីមានគោលដៅនឹងធ្វើឱ្យមានការសន្ទនាដោយស្ថាបនា និងលើកទឹកចិត្តគ្នាទៅវិញទៅមក។ ការសន្ទនានេះ ឥតមានលក្ខណៈតទល់គ្នាទេ គោលដៅសំខាន់នៃការសន្ទនានេះគឺ ជួយបណ្តារដ្ឋជាភាគីឱ្យបំពេញកាតព្វកិច្ចទាំងឡាយ និងយល់នូវអត្ថរសខ្លឹមសាររបស់បទបញ្ញត្តិនៃកតិកាសញ្ញា។ វាជាឱកាសសំរាប់ឱ្យគណៈកម្មាធិការប្រមើលមើលស្ថានភាពនៅក្នុងប្រទេស ដែលមានការពាក់ព័ន្ធដោយត្រួស១ ហើយធ្វើគ្រប់សេចក្តីសង្កេតដែលគេទាំងឡាយយល់ថា មានប្រយោជន៍លើរបៀបស័ក្តិសិទ្ធិជាងគេ ក្នុងការបំពេញកាតព្វកិច្ចទាំងឡាយដែលក្នុងកតិកាសញ្ញា។

ការសន្ទនានេះ ចំពោះគណៈកម្មាធិការ គឺជាមធ្យោបាយសំរាប់ពង្រីកប្រភពពត៌មានដែលគេអាចពឹងលើដើម្បីធ្វើការងាររបស់ខ្លួនបានល្អ។ ដូច្នេះ ក្រៅពីពត៌មានដែលគណៈកម្មាធិកាបានឃើញក្នុងរបាយការណ៍ទាំងឡាយដែលគេជូនមកនោះ គណៈកម្មាធិការក៏បានដកស្រង់ពីបណ្តារបាយការណ៍ដែលបានទទួលពីអង្គការ និងការទីភ្នាក់ងារផ្សេង១របស់ អ.ស.ប ដែលសកម្មក្នុងវិស័យសិទ្ធិរបស់មនុស្ស និងវិស័យអភិវឌ្ឍន៍ ហើយបានទទួលយកដោយអនុគ្រោះនូវបណ្តាពត៌មានក្នុងន័យស្ថាបនា ផ្តល់ឱ្យដោយអង្គការមិនមែនរដ្ឋាភិបាលផ្សេង១។

### (ឃ) ការបង្ហាញ និងការពិនិត្យរបាយការណ៍

នីតិវិធីដែលប្រកាន់យកដោយគណៈកម្មាធិការ បានវិវត្តច្រើនណាស់ចាប់តាំពីពេលដែលគណៈកម្មាធិការនេះធ្វើការប្រជុំសម័យឆ្នាំ ១៩៨៧។ អាស្រ័យហេតុនេះ នីតិវិធីនេះរហូតដល់សព្វថ្ងៃបានក្លាយជានីតិវិធីមួយ

ដែលគេទទួលយកទៅហើយ ថ្វីបើត្រូវកែប្រែឱ្យស្របទៅតាមបទពិសោធន៍កន្លងមក។ ការពិពណ៌នាដូចតទៅអំពីនីតិវិធីឆ្លុះបញ្ចាំងឱ្យឃើញនូវនីតិវិធីដែលប្រើដោយគណៈកម្មាធិការនៅសម័យប្រជុំទី១៤ នាឆ្នាំ១៩៩៦។

អ្នកតំណាងរដ្ឋជាភាគី ត្រូវបានអញ្ជើញឱ្យបង្ហាញរបាយការណ៍ ហើយនិងធ្វើសេចក្តីអធិប្បាយផ្តើម ហើយរៀបរាប់ត្រួសៗអំពីសេចក្តីឆ្លើយតបរបស់ខ្លួនទៅនឹងសំណួរក្នុងបញ្ជី ដែលក្រុមការងារត្រៀមការប្រជុំបានតាក់តែងឡើង។ បន្ទាប់មកគណៈកម្មាធិការចាប់ដំណើរការដោយសមាជិករបស់ខ្លួនតាំងសំណួរក្នុងមួយមាត្រាម្តងៗ ហើយបើចាំបាច់ឱ្យតំណាងទីភ្នាក់ងារជំនាញផ្តល់ពត៌មានបន្ថែម។ បន្ទាប់មកតំណាងរដ្ឋត្រូវបានលើកទឹកចិត្តឱ្យឆ្លើយតបជាបន្ទាន់ទៅនឹងសំណួរដែលអាចឆ្លើយបាន ហើយអ្នកតំណាងរដ្ឋអាចលើកទៅកិច្ចប្រជុំលើកក្រោយ ឬទៅថ្ងៃបន្ទាប់នូវចម្លើយចំពោះសំណួរស្មុគ្រស្មាញ ដូចជាសំណួរដែលទាមទារឱ្យធ្វើការស្រាវជ្រាវ ឬរកពត៌មានថែមទៀតពីប្រទេសរបស់ខ្លួន។ ពេលណាកិច្ចសន្ទនាមួយមាត្រាម្តងៗបានចប់សព្វគ្រប់ហើយ គេទុកពេលបន្ថែមទៀតសំរាប់ឱ្យអ្នកតំណាងឆ្លើយឱ្យបានជាក់ច្បាស់តាមដែលអាចធ្វើទៅបាន ទៅនឹងសំណួរដែលមិនបានឆ្លើយពីមុន។ សមាជិកគណៈកម្មាធិការមានសេរីភាពគ្រប់គ្រាន់ដើម្បីធ្វើអន្តរាគមនៅពេលណាក៏បាន ដើម្បីស្វែងរកការបញ្ជាក់ឱ្យច្បាស់ថែមទៀត។ គេបានព្រមព្រៀងជាទូទៅថា សំណួរណាដែលមិនអាចឆ្លើយបានគ្រប់គ្រាន់តាមរបៀបនេះទេ អាចឆ្លើយ បានទៀតដោយត្រូវផ្តល់ពត៌មានថែមទៀតជាលាយលក្ខណ៍អក្សរទៅឱ្យគណៈកម្មាធិការ បន្ទាប់ពីសម័យប្រជុំទៅ។

ដំណាក់ការចុងក្រោយបំផុតរបស់គណៈកម្មាធិការក្នុងការពិនិត្យរបាយការណ៍ គឺការព្រាង និងការអនុម័តលើសេចក្តីសង្កេតឃើញចុងក្រោយរបស់គណៈកម្មាធិការ។ ក្នុងកម្លុងពេលមួយថ្ងៃ ឬពីរថ្ងៃបន្ទាប់ពីការបញ្ចប់ការសន្ទនាជាមួយតំណាងរដ្ឋជាភាគីមក គណៈកម្មាធិការលៃទុកពេលខ្លីមួយសំរាប់ការប្រជុំក្នុងបន្ទប់ស្ងាត់ ដើម្បីឱ្យសមាជិកគណៈកម្មាធិការបញ្ចេញទស្សនៈដំបូងរបស់គេ។ សមាជិកដែលការទទួលខុសត្រូវជាបឋមក្នុងរឿងសាមុីរដ្ឋជាភាគី ត្រូវរៀបចំដោយមានជំនួយពីលេខាធិការដ្ឋានផង នូវសេចក្តីព្រាងសេចក្តីសង្កេតឃើញចុងក្រោយចំនួនសំរាប់ឱ្យគណៈកម្មាធិការពិចារណា។ រចនាសម្ព័ន្ធនៃសេចក្តីសង្កេតឃើញចុងក្រោយមានដូចតទៅ : សេចក្តីផ្តើម, ទិដ្ឋភាពវិជ្ជមាន, កត្តា និងសេចក្តីលំបាកដែលជាឧបសគ្គដល់ការអនុវត្តកតិកាសញ្ញា, កម្មវត្ថុសំខាន់ៗដែលគួរយកចិត្តទុកដាក់, និងសេចក្តីជូនយោបល់ និងអនុសាសន៍។ នៅដំណាក់ការក្រោយមកទៀត គណៈកម្មាធិការពិភាក្សាលើសេចក្តីព្រាងនៅក្នុងបន្ទប់សម្ងាត់ម្តងទៀត ក្នុងគោលបំណងអនុម័តសេចក្តីព្រាងតាមការមូលមតិ។

សេចក្តីសង្កេតឃើញចុងបញ្ចប់ត្រូវបានអនុម័តជាផ្លូវការនៅសម័យប្រជុំជាសាធារណៈនៅថ្ងៃចុងក្រោយបំផុត។ ពេលណាកិច្ចការនេះបានដល់ដំណាក់ការនេះហើយ សេចក្តីសង្កេតឃើញនេះត្រូវបានដាក់ឱ្យដឹងជាសាធារណៈ ហើយភាគីដែលមានផលប្រយោជន៍អាចទទួលបានឯកសារនៃសេចក្តីសង្កេតនេះបាន។ បន្ទាប់មក សេចក្តីសង្កេតនេះត្រូវបានបញ្ជូនទៅឱ្យរដ្ឋសាមុីជាភាគី ហើយបញ្ចូលទៅក្នុងរបាយការណ៍របស់គណៈកម្មាធិការ។ បើសិនជាគេចង់ធ្វើ រដ្ឋជាភាគីអាចឆ្លើយទៅនឹងសេចក្តីសង្កេតបញ្ចប់ណាមួយរបស់គណៈកម្មាធិការក្នុងបរិបទនៃពត៌មានបន្ថែមដែលគេផ្តល់ឱ្យគណៈកម្មាធិការ។

លទ្ធផលនៃការពិចារណារបស់គណៈកម្មាធិការ គឺស្រដៀងគ្នានឹងការពិចារណារបស់អង្គការបង្កើតដោយសន្ធិសញ្ញាដទៃទៀតដែរ។ ដូចបានកត់សំគាល់ខាងលើរួចមកហើយ គណៈកម្មាធិការទាំងមូលជាអ្នកតាក់តែងសេចក្តីសង្កេតឃើញចុងបញ្ចប់ ដែលត្រូវផ្ញើជូនដោយផ្ទាល់ទៅរដ្ឋជាភាគីនីមួយៗដែលផ្ញើរបាយការណ៍។ តមកសេចក្តីអធិប្បាយទាំងនេះ ត្រូវបានបោះពុម្ពផ្សាយនៅក្នុងរបាយការណ៍របស់គណៈកម្មាធិការ ទៅឱ្យក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គម ព្រមទាំងចែកចាយយ៉ាងទូលំទូលាយតាមមធ្យោបាយដទៃទៀតដែលសមស្រប។

ក្នុងស្ថានការណ៍ដែលគណៈកម្មាធិការចាត់ទុកថា ចាំបាច់ត្រូវមានពត៌មានបន្ថែមដើម្បីឱ្យគណៈកម្មាធិការអាចបន្តការសន្ទនានារបស់ខ្លួនជាមួយរដ្ឋជាគាគីដែលពាក់ព័ន្ធនោះ គេមានជំរើសច្រើនយ៉ាងដែលអាចនឹងប្រកាន់យក : (ក) គណៈកម្មាធិការអាចធ្វើការគូសបញ្ជាក់ថា បញ្ហាជាក់លាក់នានាត្រូវតែបរិយាយដោយលំអិតនៅក្នុងរបាយការណ៍ខួបខាងមុខរបស់រដ្ឋជាភាគី ដែលតាមធម្មតា ត្រូវដាក់ជូនក្នុងរយៈពេល ៥ ឆ្នាំម្តង។ (ខ) គណៈកម្មាធិការអាចចង់ដឹងជាពិសេសអំពីចេតនាជាក់លាក់របស់រដ្ឋជាភាគី ក្នុងការផ្តល់ពត៌មានបន្ថែមជាលាយ-លក្ខណ៍អក្សរ ជាពិសេស ក្នុងការឆ្លើយតបទៅនឹងសំណួរដែលសួរដោយសមាជិករបស់គណៈកម្មាធិការ។ (គ) គណៈកម្មាធិការអាចសុំឱ្យដាក់ជូនពត៌មានបន្ថែមដែលទាក់ទងទៅនឹងបញ្ហា ដែលគណៈកម្មាធិការរកឃើញក្នុងរយៈពេល ៦ ខែ ដើម្បីអាចឱ្យក្រុមការងារមុនសម័យប្រជុំអាចពិចារណាបាន។ ជាទូទៅ ក្រុមការងារអាចផ្ញើជូនចម្លើយណាមួយក្នុងបណ្តាចម្លើយដូចតទៅនេះទៅគណៈកម្មាធិការ : (១) ក្រុមការងារចាប់អារម្មណ៍នឹងពត៌មាននោះ (២) ក្រុមការងារនឹងអនុម័តលើសេចក្តីសង្កេតឃើញបញ្ចប់ជាក់លាក់ ដើម្បីឆ្លើយតបទៅនឹងពត៌មាននោះ (៣) បញ្ហានោះនឹងត្រូវតាមដានតាមរយៈការស្នើសុំពត៌មានបន្ថែមទៀត ឬ (៤) ប្រធានគណៈកម្មាធិការត្រូវតែបានអនុញ្ញាតឱ្យជូនដំណឹងដល់រដ្ឋជាភាគីនៅមុនសម័យប្រជុំខាងមុខថា គណៈកម្មាធិការនឹងលើកយកបញ្ហានោះយកមកពិភាក្សានៅសម័យប្រជុំខាងមុខ ហើយក្នុងគោលបំណងនេះ គណៈកម្មាធិការសូមស្វាគមន៍ដល់ការចូលរួមពីអ្នកតំណាងរដ្ឋជាភាគី។ (ឃ) គណៈកម្មាធិការអាចសំរេចថា ការទទួលពត៌មានបន្ថែមនេះត្រូវបន្ទាន់ ហើយស្នើសុំឱ្យរដ្ឋជាភាគីផ្តល់ពត៌មាននេះ ក្នុងរយៈពេលកំណត់ (ប្រហែលពីរទៅបីខែ)។ ក្នុងករណីនេះ ប្រធានគណៈកម្មាធិការ ដោយពិគ្រោះជាមួយសមាជិកនៃការិយាល័យ អាចត្រូវបានអនុញ្ញាតឱ្យតាមដានបញ្ហានោះបន្តជាមួយរដ្ឋជាភាគី បើមិនបានទទួលចម្លើយទាល់តែសោះ ឬទទួលដែរតែមិន ច្បាស់លាស់។

ក្នុងស្ថានការណ៍ដែលគណៈកម្មាធិការពិចារណាទៅឃើញថា ខ្លួនមិនបានពត៌មានដែលខ្លួនត្រូវការ ដោយផ្អែកលើនីតិវិធីថ្លែងខាងលើនេះទេ គណៈកម្មាធិការអាចសំរេចអនុម័តយកវិធីផ្សេងទៅវិញ។ ជាពិសេសគណៈកម្មាធិការអាចធ្វើសំណូមពរឱ្យរដ្ឋភាគីសាមីទទួលយកបេសកកម្មមួយដែលមានសមាជិកមួយ ឬពីររូបរបស់គណៈកម្មាធិការ។ គណៈកម្មាធិការបានធ្វើដូច្នោះរួចមកហើយចំពោះរដ្ឋភាគីពីរ។ សេចក្តីសំរេចបែបនេះនឹងត្រូវធ្វើលុះណាតែគណៈកម្មាធិការបានពេញចិត្តថាមិនមានវិធីគ្រប់គ្រាន់ដើម្បីជំនួសវិធីដែលបានពោលមកនេះ ហើយថាពត៌មានដែលគណៈកម្មាធិការមាននោះអនុញ្ញាតឱ្យប្រកាន់យកវិធីនោះ។ គោលបំណងនៃការទៅមើលដល់ទីកន្លែងនោះ គឺ : (ក) ដើម្បីប្រមូលពត៌មានចាំបាច់សំរាប់ឱ្យគណៈកម្មាធិការបន្តសន្ទនាដោយស្ថាបនារបស់ខ្លួនជាមួយរដ្ឋជា

ភាគី ហើយនិងដើម្បីឱ្យគណៈកម្មាធិការបំពេញមុខងាររបស់ខ្លួនស្របតាមកតិកាសញ្ញា ហើយ (ខ)ដើម្បីធ្វើជាមូលដ្ឋានមួយរិតតែទូលំទូលាយឡើង ផ្អែកលើមូលដ្ឋាននេះគណៈកម្មាធិការអាចអនុវត្តមុខងាររបស់ខ្លួនស្របទៅតាមមាត្រា ២២ និង ២៣ នៃកតិកាសញ្ញាទាក់ទងនឹងជំនួយបច្ចេកទេសនិងសេវាកម្មប្រឹក្សាយោបល់។ គណៈកម្មាធិការនឹងថ្លែងចំៗពីបញ្ហាដែលអ្នកតំណាងចង់ប្រមូលពតិមានពីប្រភពទាំងអស់ដែលមាន។ អ្នកតំណាងមានភារកិច្ចពិចារណាផងដែរថាតើ កម្មវិធីផ្តល់សេវាកម្មប្រឹក្សាយោបល់ ដែលគ្រប់គ្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សនោះអាចផ្តល់ជំនួយទាក់ទងនឹងបញ្ហាជាក់លាក់នៅចំពោះមុខបានដែរឬទេ។

នៅពេលបញ្ចប់ទស្សនកិច្ច អ្នកតំណាងនឹងរាយការណ៍ឱ្យគណៈកម្មាធិការ។ ដោយពិចារណាលើរបាយការណ៍ដែលបង្ហាញដោយអ្នកតំណាងរបស់ខ្លួន គណៈកម្មាធិការតាក់តែងសេចក្តីសន្និដ្ឋានទាំងនោះទាក់ទងទៅនឹងមុខងារមួយចំនួនធំដែលអនុវត្តដោយគណៈកម្មាធិការ រួមមាន មុខងារទាក់ទងនឹងការផ្តល់ជំនួយបច្ចេកទេស និងសេវាកម្មប្រឹក្សាយោបល់។ ក្នុងករណីដែលរដ្ឋភាគីសាមីមិនទទួលយកបេសកកម្មដែលស្នើឡើងនោះទេ គណៈកម្មាធិការនឹងពិចារណាធ្វើអនុសាសន៍អ្វីមួយដែលសមស្របជូនទៅក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម។

ជាងនេះទៅទៀត គណៈកម្មាធិការអនុម័តសេចក្តីអធិប្បាយទូទៅដែលមានលក្ខណៈទូទៅ ហើយមិនពោលដល់ស្ថានការណ៍នៅក្នុងរដ្ឋណាមួយជាក់លាក់ទេ។ គោលដៅនៃសេចក្តីអធិប្បាយទូទៅនេះគឺ : ដើម្បីធ្វើឱ្យបទពិសោធន៍ដែលបានមកទល់ពេលបច្ចុប្បន្នតាមរយៈការពិនិត្យរបាយការណ៍ទាំងនេះ បានជាផលប្រយោជន៍ដល់រដ្ឋជាភាគីទាំងអស់ ដើម្បីជួយ និងលើកស្ទួយកិច្ចអនុវត្តកតិកាសញ្ញាបន្តទៅទៀតរបស់គេ, ដើម្បីទាញអារម្មណ៍រដ្ឋជាភាគីឱ្យយកចិត្តទុកដាក់លើភាពមិនគ្រប់គ្រាន់ដែលបើកបង្ហើបឱ្យឃើញនៅក្នុងរបាយការណ៍មួយចំនួន, ដើម្បីជួយរដ្ឋជាភាគី អង្គការអន្តរជាតិ និងទីភ្នាក់ងារជំនាញ ដែលពាក់ព័ន្ធឱ្យបានសំរេចជាលំដាប់ និងដោយប្រសិទ្ធិភាពនូវការអនុវត្តន៍ពេញលេញ នូវសិទ្ធិ ដែលបានទទួលស្គាល់នៅក្នុងកតិកាសញ្ញា។ ក្នុងករណីចាំបាច់ គណៈកម្មាធិការអាចពិនិត្យសើរើ និងកែប្រែ សេចក្តីអធិប្បាយទូទៅរបស់ខ្លួនឡើងវិញ ដោយផ្អែកលើបទពិសោធន៍របស់រដ្ឋជាភាគី និងលើសេចក្តីសន្និដ្ឋានដែលទាញចេញពីបទពិសោធន៍នោះ។

មកទល់ពេលនេះ គណៈកម្មាធិការបានអនុម័តយកសេចក្តីអធិប្បាយទូទៅដូចតទៅនេះ : សេចក្តីអធិប្បាយទូទៅលេខ ១(១៩៨៩) ស្តីពីការធ្វើរបាយការណ៍របស់រដ្ឋជាភាគី, សេចក្តីអធិប្បាយទូទៅលេខ២(១៩៩០)ស្តីពីវិធានការណ៍ផ្តល់ជំនួយបច្ចេកទេសអន្តរជាតិ, សេចក្តីអធិប្បាយទូទៅលេខ៣(១៩៩០) ស្តីពីធម្មជាតិនៃកាតព្វកិច្ចរបស់រដ្ឋជាភាគី, សេចក្តីអធិប្បាយទូទៅលេខ៤(១៩៩១)ស្តីពីសិទ្ធិបានលំនៅដ្ឋានសមរម្យ, សេចក្តីអធិប្បាយលេខ៥(១៩៩៤)ស្តីពីសិទ្ធិនៃជនពិការភាព, និងសេចក្តីអធិប្បាយលេខ៦ (១៩៩៥)ស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គម និងវប្បធម៌ នៃមនុស្សចាស់។

គួរកត់សំគាល់អំពី <u>ទិវានៃការពិភាក្សាទូទៅ</u>។ នៅសម័យប្រជុំនីមួយៗ គណៈកម្មាធិការចំណាយពេលមួយថ្ងៃជាទូទៅ ថ្ងៃច័ន្ទ នៃអាទិត្យទី៣ ដើម្បីពិភាក្សាទូទៅលើសិទ្ធិពិសេសណាមួយ ឬលើទិដ្ឋភាពពិសេសណាមួយនៃកតិកាសញ្ញា។ គោលបំណងគឺមានពីរយ៉ាង : ទិវានេះជួយគណៈកម្មាធិការពង្រីកការយល់ដឹងរបស់ខ្លួនឱ្យកាន់តែ

ធំធេងអំពីបញ្ហាដែលទាក់ទង ហើយធ្វើឱ្យគណៈកម្មាធិការអាចលើកទឹកចិត្តឱ្យភាគីដែលយកចិត្តទុកដាក់ទាំងអស់ផ្តល់យោបល់ទៅលើការងាររបស់គណៈកម្មាធិការ។ បញ្ហាដូចតទៅនេះ ជាបញ្ហាដែលការពិភាក្សាត្រូវផ្តោតលើ : សិទ្ធិបានអាហារគ្រប់គ្រាន់(សម័យប្រជុំលើកទី ៣) សិទ្ធិបានលំនៅត្រឹមត្រូវ(សម័យប្រជុំលើកទី ៤)សន្ទស្សន៍ផ្នែកសេដ្ឋកិច្ចសង្គម(សម័យប្រជុំលើកទី ៦) សិទ្ធិចូលរួមក្នុងជីវភាពវប្បធម៌(សម័យប្រជុំលើកទី ៧) សិទ្ធិរបស់មនុស្សចំណាស់(សម័យប្រជុំលើកទី ៨) សិទ្ធិមានសុខភាព(សមយប្រជុំលើកទី ៩) តួនាទីនៃសុវត្ថិភាពសង្គម(សម័យប្រជុំលើកទី ១០)ការអប់រំសិទ្ធិមនុស្ស(សម័យប្រជុំលើកទី ១១) ការបកស្រាយ និងការអនុវត្តន៍ជាក់ស្តែងនូវកាតព្វកិច្ចរបស់រដ្ឋជាភាគី(សម័យប្រជុំលើកទី ១២) និងសេចក្តីព្រាងពិធីសារស្ម័គ្រចិត្តអមកតិកាសញ្ញា(សម័យប្រជុំលើកទី ១៣)។

លទ្ធផលនៃការងាររបស់គណៈកម្មាធិការដែលគេងាយរកបានបំផុតគឺ របាយការណ៍ដែលគណៈកម្មាធិការអនុម័តនៅដំណាច់សម័យប្រជុំនីមួយៗ សំរាប់បញ្ជូលទៅឱ្យក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម។ របាយការណ៍នោះមាន ជាអាទិ៍ សេចក្តីសង្ខេតបញ្ចប់ធ្វើដោយគណៈកម្មាធិការ, ផ្នែកមួយពិពណ៌នាអំពីវិធីធ្វើការរបស់គណៈកម្មាធិការ, ផ្នែកមួយសង្ខេបពីពិធីប្រជុំនៃទិវាពិភាក្សាទូទៅ ដែលជាទូទៅចំណាយសំរាប់សិទ្ធិជាក់លាក់ណាមួយ, និងអត្ថបទនៃសេចក្តីអធិប្បាយទូទៅអនុម័តដោយគណៈកម្មាធិការ។

លក្ខណៈខុសពីគេមួយនៃអាណត្តិរបស់គណៈកម្មាធិការដែលគេត្រូវយកចិត្តទុកដាក់នោះគឺ មាននៅក្នុងមាត្រា ២២ នៃកតិកាសញ្ញា។

## មាត្រា ២២

### អត្ថបទមាត្រា ២២

តាមរយៈការផ្តល់ជំនួយបច្ចេកទេស (របស់ខ្លួន) ទីប្រឹក្សាសេដ្ឋកិច្ច និងសង្គមកិច្ចអាចទាក់ទាញអារម្មណ៍អង្គការឯទៀតៗនៃអង្គការសហប្រជាជាតិ អង្គការសាខានានារបស់គេ និងទីភ្នាក់ងារឯកទេសរបស់ខ្លួន ដែលទាក់ទងនឹងការផ្តល់ជំនួយបច្ចេកទេសលើបញ្ហាដែលលើកឡើងក្នុងរបាយការណ៍ដូចរៀបរាប់ក្នុងជំពូកនេះ នៃកតិកាសញ្ញា ដែលអាចជាជំនួយដល់អង្គការនិងទីភ្នាក់ងារទាំងនេះក្នុងការសំរេច តាមសមត្ថកិច្ចរៀងៗខ្លួន ស្តីពីវិធានការអន្តរជាតិដែលត្រូវអនុវត្ត ដើម្បីរួមចំណែកធ្វើឱ្យការអនុវត្តន៍នៃកតិកាសញ្ញានេះកាន់តែមានប្រសិទ្ធិភាពជាលំដាប់ ។

### អត្ថបទនៃសេចក្តីអធិប្បាយទូទៅលេខ ២(១៩៩០)

### វិធានការផ្តល់ជំនួយបច្ចេកទេសអន្តរជាតិ

១. មាត្រា ២២នៃកតិកាសញ្ញា បានបង្កើតឱ្យមានយន្តការជាឧបករណ៍ ដែលក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គមអាចសុំឱ្យស្ថាប័នទាំងឡាយដែលពាក់ព័ន្ធនៃអង្គការសហប្រជាជាតិយកចិត្តទុកដាក់លើបញ្ហាណាមួយ ដែលចោទឡើងចេញពីរបាយការណ៍ដែលដាក់ជូនស្របតាមកតិកាសញ្ញានេះ " ដែលអាចជួយដល់ស្ថាប័នទាំងនោះក្នុងការធ្វើសេចក្តីសំរេចចិត្តណាមួយនៅក្នុងដែនសមត្ថកិច្ចរបស់រៀងៗខ្លួនអំពីការគួរមានវិធានការអន្តរជាតិនានា ដែល

ទំនងជារួមចំណែកដល់ការអនុវត្តន៍ជាលំដាប់នូវ...កតិកាសញ្ញានេះ"។ ថ្វីបើការទទួលខុសត្រូវជាបឋមក្រោមអំណាចនៃមាត្រា២២ត្រូវទម្លាក់ទៅឱ្យក្រុមប្រឹក្សាក្តី វាជាការសមស្របណាស់ដែល គណៈកម្មាធិការខាងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងការជូនយោបល់ និងជួយក្រុមប្រឹក្សាក្នុងរឿងនេះ។

២. ដោយអនុលោមតាមប្រការ ២២ អនុសាសន៍ទាំងឡាយអាចត្រូវបានគេបញ្ជូនទៅឱ្យ "អង្គភាពណាមួយរបស់អង្គការសហប្រជាជាតិ អង្គភាពសាខាអស់ទាំងនោះ ព្រមទាំងទីភ្នាក់ងារឯកទេសដែលពាក់ព័ន្ធនឹងការផ្តល់ជំនួយបច្ចេកទេស"។ គណៈកម្មាធិការយល់ឃើញថា ប្រការនេះ ត្រូវតែបានបកស្រាយក្នុងន័យរាប់បញ្ចូលអង្គភាព និងទីភ្នាក់ងារឯកទេសស្ទើរតែទាំងអស់នៃអង្គការសហប្រជាជាតិ ដែលពាក់ព័ន្ធនឹងទិដ្ឋភាពណាមួយនៃសហប្រតិ-បត្តិការអន្តរជាតិខាងវិស័យអភិវឌ្ឍន៍។ ដូច្នេះ វាជាការសមស្រប បើយោងទៅតាមប្រការ ២២នេះ ដែលថាគេត្រូវតែលើកយកអនុសាសន៍ទាំងអស់នោះដាក់ស្នើជូនជាអាទិ៍ទៅអគ្គលេខាធិការ, ទៅអង្គភាពសាខាអស់ទាំងនោះនៃក្រុមប្រឹក្សាដូចជាគណៈកម្មការសិទ្ធិមនុស្ស, គណៈកម្មការខាងការអភិវឌ្ឍន៍សង្គម និងគណៈកម្មាការខាងឋានៈរបស់ស្ត្រី, អង្គភាពដទៃទៀតដូចជា កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ, យូនីសែហ្វ, CDP, ទីភ្នាក់ងារនានា ដូចជាធនាគារពិភពលោក និងមូលនិធិរូបិយប័ណ្ណអន្តរជាតិ, ហើយនិងទីភ្នាក់ងារឯកទេសឯទៀតៗ ដូចជា អង្គការការងារអន្តរជាតិ, អង្គការស្បៀងអាហារ និងកសិកម្ម, យូណេស្កូ និង អង្គការសុខភាពពិភពលោក។

៣. មាត្រា ២២ អាចនាំឱ្យមានជាអនុសាសន៍ដែលមានលក្ខណៈជាគោលនយោបាយទូទៅ ឬជាអនុសាសន៍ដែលផ្តោតខ្លាំងទៅលើតែស្ថានការណ៍ជាក់លាក់ណាមួយ។ ក្នុងបរិបទទីមួយ តួនាទីដ៏ចំបងរបស់គណៈកម្មាធិការហាក់ដូចជាជំរុញឱ្យមានការខំប្រឹងប្រែងយកចិត្តទុកដាក់ឱ្យបានខ្លាំងឡើង ដើម្បីលើកស្ទួយសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពសហប្រតិបត្តិការអន្តរជាតិខាងវិស័យអភិវឌ្ឍន៍ដែលត្រូវផ្តើមធ្វើ ឬដោយមានការជួយឧបត្ថម្ភពីសំណាក់អង្គការសហប្រជាជាតិ ព្រមទាំងភ្នាក់ងារនានារបស់ខ្លួន។ នៅក្នុងន័យនេះ គណៈកម្មាធិការបានសង្កេតឃើញថា គណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សតាមសេចក្តីសម្រេចចិត្តរបស់ខ្លួនលេខ ១៩៨៩-១៣ ចុះថ្ងៃទី២ មីនា ១៩៨៩ បានអំពាវនាវឱ្យខាងគណៈកម្មាធិការ "ជួយគិតគូរដល់មធ្យោបាយនានាដែលទីភ្នាក់ងារនានានៃអង្គការសហប្រជាជាតិកំពុងបំរើការងារក្នុងវិស័យអភិវឌ្ឍន៍នោះ អាចនឹងរួមបញ្ចូលយ៉ាងមានប្រសិទ្ធិភាពបំផុតនូវវិធានការនានា ដែលបង្កើតឡើងក្នុងគោលបំណងលើកស្ទួយការគោរពពេញលេញនូវសិទ្ធិខាងសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ នៅក្នុងសកម្មភាពរបស់ពួកគេនោះ"។

៤ ជាការជាក់ស្តែងជាបឋម គណៈកម្មាធិការកត់សំគាល់ថា ការខំព្យាយាមរបស់ខ្លួនពិតជានឹងបានទទួលការជួយជ្រោមជ្រែង ហើយថាទីភ្នាក់ងារពាក់ព័ន្ធនានាពិតជានឹងបានជ្រួតជ្រាបខ្លាំងឡើង ប្រសិនបើគេទាំងអស់នោះ

ពិតជាមានការយកចិត្តទុកដាក់ទៅលើកិច្ចការរបស់គណៈកម្មាធិការមែន។ ទន្ទឹមនឹងការទទួលស្គាល់ថា ការយកចិត្តទុកដាក់បែបនេះអាចបង្ហាញឱ្យឃើញតាមរយៈវិធីច្រើនយ៉ាង គណៈកម្មាធិការសង្កេតឃើញថា វត្តមានរបស់អ្នកតំណាងពីស្ថាប័ននានានៃអង្គការសហប្រជាជាតិនៅសម័យប្រជុំ ៤ លើកដំបូងរបស់ខ្លួន គឺមានចំនួនតិចណាស់ លើកលែងជាពិសេសតែអង្គការការងារអន្តរជាតិ, យូណេស្កូ និងអង្គការសុខភាពពិភពលោកចេញ។ ទន្ទឹមគ្នានេះដែរ ឯកសារ និងពត៌មានទាក់ទងជាលាយលក្ខណ៍អក្សរត្រូវបានទទួលពីទីភ្នាក់ងារមួយចំនួនតូច។ គណៈកម្មាធិការយល់ឃើញថា ការយល់ដឹងកាន់តែជ្រៅជ្រះនូវភាពទាក់ទង (relevance) នៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌នៅក្នុងបរិបទនៃសកម្មភាពសហប្រតិបត្តិការ ខាងអភិវឌ្ឍន៍អន្តរជាតិនោះនឹងត្រូវបានជួយសំរួលយ៉ាងច្រើនតាមរយៈការប្រាស្រ័យគ្នាខ្លាំងឡើង រវាងគណៈកម្មាធិការនិងទីភ្នាក់ងារពាក់ព័ន្ធ។ យ៉ាងហោចណាស់, ទិវានៃការពិភាក្សាជាទូទៅលើបញ្ហាពិសេសណាមួយ ដែលគណៈកម្មាធិការចាត់ឱ្យមាននៅក្នុងសម័យប្រជុំនិមួយៗរបស់គណៈកម្មាធិការ គឺពិតជានឹងផ្ដល់ជូនឱកាសដ៏ប្រសើរសំរាប់ការប្ដូរយោបល់ដ៏មានសារប្រយោជន៍រវាងគ្នានិងគ្នាបាន។

៥. ពាក់ព័ន្ធទៅនឹងបញ្ហាទូលំទូលាយស្ដីពីការលើកស្ទួយការគោរពសិទ្ធិមនុស្ស នៅក្នុងបរិបទនៃសកម្មភាពអភិវឌ្ឍន៍នោះ គណៈកម្មាធិការមកទល់ពេលនេះបានសង្កេតឃើញថា មានភស្តុតាងដ៏ស្ដួចស្ដើងណាស់ដែលបញ្ជាក់ឱ្យឃើញថា ស្ថាប័នអង្គការសហប្រជាជាតិអស់នោះមានការខំប្រឹងប្រែងយ៉ាងពិតប្រាកដ។ នៅក្នុងរឿងនេះគណៈកម្មាធិការសង្កេតឃើញដោយពេញចិត្តនូវគំនិតផ្ដួចផ្ដើមរួមគ្នារបស់មជ្ឈមណ្ឌលសិទ្ធិមនុស្ស និងកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ដែលបានសរសេរទៅអ្នកតំណាងអង្គការសហប្រជាជាតិប្រចាំប្រទេស និងទៅមន្ត្រីតាមការិយាល័យតាមប្រទេសដទៃទៀត ដោយស្នើសុំឱ្យគេជួយផ្ដល់ជា "យោបល់ និងឱវាទដែលពាក់ព័ន្ធជាពិសេសទៅនឹងទម្រង់នៃសហប្រតិបត្តិការដែលអាចធ្វើទៅបាននៅក្នុងគំរោងការកំពុងអនុវត្ត (ដែលគេរកឃើញ) ដែលមានទិដ្ឋភាពសិទ្ធិមនុស្សនៅក្នុងនោះ ឬគំរោងការថ្មីដែលឆ្លើយតបទៅនឹងសេចក្ដីស្នើសុំជាក់លាក់របស់រដ្ឋាភិបាល"។ គណៈកម្មាធិការបានជ្រាបផងដែរថា អង្គការការងារអន្តរជាតិ បានខំប្រឹងប្រែងអត់ឈប់ឈរដើម្បីផ្សាភ្ជាប់នូវបទដ្ឋានសិទ្ធិមនុស្សរបស់ខ្លួន និងបទដ្ឋានពលកម្មអន្តរជាតិដទៃទៀតទៅនឹងសកម្មភាពសហប្រតិបត្តិការបច្ចេកទេសរបស់ខ្លួនដែរ។

៦. ពាក់ព័ន្ធទៅនឹងសកម្មភាពបែបនេះ មានគោលការណ៍ពីរដ៏សំខាន់។ គោលការណ៍ទីមួយ គឺថាចង្កោមពីរនៃសិទ្ធិមនុស្សមិនអាចបំបែកពីគ្នាបាន ហើយពឹងពាក់គ្នាទៅវិញទៅមក។ នេះគឺបានន័យថា បើគេប្រឹងប្រែងដើម្បីលើកស្ទួយចង្កោមមួយនៃសិទ្ធិ គេត្រូវតែលើកយកសិទ្ធិមួយចង្កោមទៀតមកគិតគូរផងដែរទើបបាន។ ទីភ្នាក់ងារអង្គការសហប្រជាជាតិដែលពាក់ព័ន្ធនឹងការលើកស្ទួយសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ នោះគួរតែខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើយ៉ាងណាឱ្យសកម្មភាពរបស់ខ្លួនស្របគ្នាជាទៀងទាត់ជាមួយនឹងការអាស្រ័យផលនៃសិទ្ធិពលរដ្ឋ និងនយោបាយ។ ក្នុងន័យជាអវិជ្ជមាន ការនិយាយនេះមានន័យថា ទីភ្នាក់ងារអន្តរជាតិនានាគួរតែចៀសវាងឱ្យផុតពីការពាក់ព័ន្ធនឹងគំរោងការណាដែលពាក់ព័ន្ធនឹងការប្រើកម្លាំងពលកម្មដោយបង្ខំជាដើម ដែលជាការផ្ទុយនិង

បទដ្ឋានអន្តរជាតិ ឬដែលលើកស្ទួយ ឬពង្រឹងការរើសអើងចំពោះបុគ្គល ឬក្រុមណាមួយដែលជាការមិនស្របនឹងបទបញ្ញត្តិនៃកតិកាសញ្ញានេះ ឬក៏ពាក់ព័ន្ធនឹងការបណ្តេញចេញពីទីតាំងលំនៅរបៀបជាខ្នាតធំ ដោយគ្មានផ្តល់នូវការការពារ និងសំណងដ៏សមស្រប។ ក្នុងន័យជាវិជ្ជមានវិញ គឺគេចង់និយាយថា នៅពេលណាដែលអាចធ្វើទៅបានទីភ្នាក់ងារទាំងនោះ ត្រូវតាំងខ្លួនជាគាំទ្រឱ្យគំនិតគំរោងការព្រមទាំងវិធីសាស្ត្រដែលធ្វើវិភាគទានមិនត្រឹមតែដល់ការរីកចំរើនសេដ្ឋកិច្ច ឬគោលដៅដែលកំណត់យ៉ាងទូលំទូលាយតែប៉ុណ្ណោះទេ តែថែមទាំងដល់ការអាស្រ័យផលខ្ពស់នៃសិទ្ធិមនុស្សទាំងអស់ដែរ។

៧ គោលការណ៍ទីពីរនៃភាពទាក់ទងទូទៅ (general relevance) គឺថាសកម្មភាពសហប្រតិបត្តិការខាងវិស័យអភិវឌ្ឍន៍មិនបានជួយធ្វើវិភាគទានដល់ការលើកស្ទួយការគោរពសិទ្ធិខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌ ដោយស្វ័យប្រវត្តិទេ។ សកម្មភាពជាច្រើនត្រូវបានគេចាត់ឱ្យមានឡើងក្នុងនាមជា "ការអភិវឌ្ឍន៍" ត្រូវបានគេទទួលស្គាល់នៅពេលក្រោយមកទៀតថា ជាសកម្មភាពដែលប្រឌិតឡើងខុស និងមានផលបញ្ច្រាស់ប្រឆាំងនឹងសិទ្ធិមនុស្ស។ ដើម្បីកាត់បន្ថយកុំឱ្យមានឧប្បត្តិហេតុដែលបង្កជាបញ្ហានានាបែបនេះនោះ គេគួរតែលើកយកបញ្ហាទាំងអស់ដែលបរិយាយនៅក្នុងកតិកាសញ្ញានេះ មកពិនិត្យពិចារណាឱ្យបានជាក់លាក់និងហ្មត់ចត់ បើសិនជាការសមស្របនិងអាចធ្វើទៅបាន។

៨ ថ្វីបើឃើញថា វាមានសារសំខាន់ក្នុងការដាក់បញ្ចូលបញ្ហាសិទ្ធិមនុស្សទៅក្នុងសកម្មភាពអភិវឌ្ឍន៍នោះក៏ដោយ វាជាការពិតដែលថា ការស្នើសុំឱ្យមានការដាក់បញ្ចូលបែបនេះ គឺវានៅតែស្ថិតនៅក្នុងក្រិតនៃគំនិតទូទៅនៅឡើយដដែល។ ដូច្នេះ ក្នុងកិច្ចខំប្រឹងប្រែងដើម្បីលើកទឹកចិត្តឱ្យគោលការណ៍ដែលមានចែងក្នុងមាត្រា ២២ នៃកតិកាសញ្ញានោះដើរបាន គណៈកម្មាធិការចង់ឱ្យស្ថាប័នពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ទៅលើវិធានការជាក់លាក់ដូចតទៅនេះ:

(ក) ដោយចាត់ទុកជាគោលការណ៍ទូទៅ ស្ថាប័ននិងទីភ្នាក់ងារអង្គការសហប្រជាជាតិពាក់ព័ន្ធនានាគួរតែទទួលស្គាល់យ៉ាងជាក់លាក់នូវទំនាក់ទំនងយ៉ាងជិតស្និទ្ធ ដែលគួរតែបង្កើតឱ្យមានរវាងសកម្មភាពអភិវឌ្ឍន៍ និងកិច្ចខំប្រឹងប្រែងទាំងឡាយដើម្បីលើកស្ទួយការគោរពសិទ្ធិមនុស្សក្នុងន័យទូទៅ និងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ក្នុងន័យដោយឡែក។ ចំពោះរឿងនេះ គណៈកម្មាធិការបានកត់សំគាល់ឃើញមានការខកខាននៃយុទ្ធសាស្ត្រនិមួយៗនៃយុទ្ធសាស្ត្រនៃទសវត្សនៃការអភិវឌ្ឍន៍ទាំងបីដំបូងរបស់អង្គការសហប្រជាជាតិ ដែលមិនបានទទួលស្គាល់នូវទំនាក់ទំនងនេះទេ ហើយដោយហេតុនេះ ទើបគណៈកម្មាធិការជំរុញឱ្យយុទ្ធសាស្ត្របែបនេះលើកទីបួនដែលនឹងត្រូវអនុម័តនៅឆ្នាំ ១៩៩០នោះ ចៀសវាងកុំឱ្យមានការខកខានដូច្នេះទៀត។

(ខ) ទីភ្នាក់ងារអង្គការសហប្រជាជាតិទាំងឡាយ ត្រូវលើកយកមកគិតគូរឱ្យបានហ្មត់ចត់នូវសំណើដោយលោកអគ្គលេខាធិការ ដែលមានក្នុងរបាយការណ៍នៃឆ្នាំ ១៩៧៩ ដែលតម្រូវឱ្យរៀបចំ "របាយការណ៍ស្តីពីផលទៅលើសិទ្ធិមនុស្ស" ដោយសារសកម្មភាពសហប្រតិបត្តិការអភិវឌ្ឍន៍ដ៏សំខាន់ៗទាំងអស់ ។

(គ) រាល់ការហ្វឹកហ្វឺន ឬ ការពន្យល់ដល់បុគ្គលិកគំរោងការនិងបុគ្គលិកដទៃទៀតរបស់ទីភ្នាក់ងារអង្គការសហប្រជាជាតិនានានោះ ត្រូវមានសមាសភាគមួយដែលទាក់ទងនឹងបទដ្ឋាន និងគោលការណ៍សិទ្ធិមនុស្ស ។

(ឃ) នៅរាល់ដំណាក់ការនៃគំរោងការអភិវឌ្ឍន៍ ការប្រឹងប្រែងគ្រប់យ៉ាងដើម្បីធានាសិទ្ធិទាំងឡាយដែលមានចែងនៅក្នុងកតិកាសញ្ញានេះគួរត្រូវបានយកមកគិតគូរឱ្យបានត្រឹមត្រូវ ។ ការប្រឹងប្រែងបែបនេះ ត្រូវតែមានជាឧទាហរណ៍នៅក្នុងការវាយតម្លៃជាដំបូងឱ្យបានដឹងច្បាស់នូវសេចក្តីត្រូវការជាអាទិភាព នៃប្រទេសណាមួយ ក្នុងការរាវរកគំរោងការណាមួយ ក្នុងការវាយប្លង់គំរោងការ ក្នុងការអនុវត្តន៍គំរោងការ និងការវាយតម្លៃគំរោងការជាចុងក្រោយរបស់ខ្លួន ។

៩ បញ្ហាមួយដែលគណៈកម្មាធិការមានការយកចិត្តទុកដាក់ ជាពិសេសនៅក្នុងការពិនិត្យពិចារណារបាយ-ការណ៍នានានៃប្រទេសជាភាគីនោះ គឺផលប៉ះពាល់អាក្រក់ដែលកើតមកពីបន្ទុកធ្ងន់ខាងប្រាក់បំណុល ព្រមទាំងផលអាក្រក់នៃវិធានការកែតំរង់ទៅលើការអាស្រ័យផលនៃសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ក្នុងប្រទេសជាច្រើន ។ គណៈកម្មាធិការបានទទួលស្គាល់ថា កម្មវិធីកែតំរង់នេះជាញឹកញយគឺត្រូវធ្វើចៀសមិនរួចទេ ហើយថាកម្មវិធីបែបនេះតែងតែមានការជូរចត់ ។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងកាលៈទេសៈបែបនេះការខំប្រឹងប្រែងដើម្បីការពារសិទ្ធិមូលដ្ឋានបំផុតខាងសេដ្ឋកិច្ច, សង្គម និងវប្បធម៌ រិតតែត្រូវការជាបន្ទាន់ណាស់ទៅទៀត គឺមិនមែនត្រូវបង្អង់ដែទេ ។ ប្រទេសជាភាគីកតិកាសញ្ញាទាំងឡាយ ព្រមទាំងទីភ្នាក់ងារពាក់ព័ន្ធរបស់អង្គការសហប្រជាជាតិត្រូវតែខិតខំឱ្យបានជាអតិបរមាដែលអាចធ្វើបាន ដើម្បីធានាថាការការពារបែបនេះត្រូវបានគេដាក់បញ្ចូលទៅក្នុងកម្មវិធី និងគោលនយោបាយនានាសំរាប់ជំរុញការកែតំរង់នោះ ។ វិធីសាស្ត្របែបនេះ (ដែលជួនកាលគេឱ្យឈ្មោះថា "ការកែតំរង់ទៅស្របជាមួយមុខមាត់មនុស្ស" ឬដែលហៅថាជាការលើកស្ទួយនូវ"ការអភិវឌ្ឍន៍ដោយយកមនុស្សជាគោល") តម្រូវថា គោលដៅនៃការការពារនូវសិទ្ធិនានារបស់ជនក្រីក្រ និងជនទទន់ខ្សោយត្រូវក្លាយទៅជាគោលដៅជាមូលដ្ឋាននៃការកែតំរង់សេដ្ឋកិច្ច ។ ក្នុងន័យដូចគ្នានេះដែរ, វិធានការអន្តរជាតិនានាដើម្បីដោះស្រាយវិបត្តិនៃបញ្ហាបំណុល គួរតែគិតឱ្យខ្លាំងទៅដល់ការចំាបាច់ត្រូវការពារសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ តាមរយៈជាអាទិ៍សហប្រតិបត្តិការអន្តរជាតិ ។ នៅក្នុងស្ថានការណ៍ជាច្រើន, បញ្ហានេះអាចចង្អុលទៅរកការចាំបាច់ឱ្យមានការផ្តួចផ្តើមគំនិតបន្ធូរបំណុល ។

១០ នៅទីបញ្ចប់ គណៈកម្មាធិការចង់ទាញការយកចិត្តទុកដាក់ទៅលើឱកាសដ៏សំខាន់ ដែលផ្តល់ឱ្យរដ្ឋជាភាគីស្របតាមមាត្រា ២២ នៃកតិកាសញ្ញានេះបង្ហាញនៅក្នុងរបាយការណ៍របស់ខ្លួននូវសេចក្តីត្រូវការពិសេសណាមួយដើម្បីសុំជំនួយបច្ចេកទេស ឬកិច្ចសហប្រតិបត្តិការខាងអភិវឌ្ឍន៍នេះ ។

## ខ. ការតាមដានបន្ត

របាយការណ៍របស់គណៈកម្មាធិការត្រូវបានដាក់ជូនឱ្យក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម សំរាប់ធ្វើការពិចារណា។ ជាងនេះទៀត របាយការណ៍នេះត្រូវបានចែកចាយយ៉ាងទូលំទូលាយទៅឱ្យអង្គការ អ.ស.ប ទៅឱ្យសមាជិកនៃអង្គការបង្កើតដោយសន្ធិសញ្ញាសិទ្ធិមនុស្សដទៃ និងទៅឱ្យសាធារជនទូទៅ។ កំណត់ហេតុសង្ខេបនៃពិធីប្រជុំរបស់គណៈកម្មាធិការជាមួយនឹងតំណាងរដ្ឋជាភាគី ក៏មានសំរាប់សាធារណជនប្រើប្រាស់បានដែរ។ តាមរបៀបនេះ លទ្ធផលនៃការសន្ទនាផ្ដោះផ្ដងរបស់រដ្ឋជាភាគីជាមួយគណៈកម្មាធិការក៏ត្រូវបានចែកចាយយ៉ាងទូលំទូលាយដែរ។

ក៏ប៉ុន្តែ ទិដ្ឋភាពនេះក្នុងរយៈពេលយូរទៅ មិនសំខាន់ដូចដំណើរការដែលរបាយការណ៍ត្រូវបានកំណត់ធ្វើឱ្យតមិនដាច់នៅកំរិតជាតិទេ។ គណៈកម្មាធិការបានប្រឹងប្រែងគ្រប់បែបយ៉ាងដើម្បីបញ្ជាក់ថា ការផ្ដោះប្ដូរទស្សនៈគ្នាពិតប្រាកដ និងតជាប់មិនដាច់នៅកំរិតជាតិស្ដីអំពីការអនុវត្តន៍កតិកាសញ្ញា គឺជាមធ្យោបាយដែលដែលមានសារសំខាន់បំផុត។ ដូច្នេះ រដ្ឋជាភាគីត្រូវបានតឿនឱ្យធ្វើយ៉ាងណាដើម្បីឱ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយបំផុតដែលអាចធ្វើបាននូវកតិកាសញ្ញាជាភាសាសមស្របទាំងអស់ និងដើម្បីជូនដំណឹងឱ្យគណៈកម្មាធិការបានដឹងអំពីកិច្ចប្រឹងប្រែងរបស់គណៈកម្មាធិការក្នុងរឿងនេះ។ លើសនេះទៀត គណៈកម្មាធិការបានស្វាគមន៍យ៉ាងកក់ក្ដៅដល់ការប្រើប្រាស់នីតិវិធីនៅថ្នាក់ជាតិ ដែលតាមនីតិវិធីនេះរដ្ឋាភិបាលត្រូវលើកទឹកចិត្តឱ្យមានការផ្ដល់មតិលើរបាយការណ៍ពីសំណាក់ប្រភពនានា រួមមានជាពិសេសដៃគូខាងសង្គមសំខាន់ៗនៅក្នុងប្រទេស។

តាមរយៈការតាមដានបន្តនៅថ្នាក់ជាតិ ជាការសំខាន់រដ្ឋាភិបាលត្រូវយកចិត្តទុកដាក់លើបញ្ហានីមួយៗដែលលើកឡើងក្នុងកម្លុងពេលគណៈកម្មាធិការធ្វើការពិនិត្យរបាយការណ៍របស់រដ្ឋាភិបាល។ បើសិនជាសមស្របវិធានការនីតិបញ្ញត្តិ រដ្ឋាភិបាល ឬវិធានការជានយោបាយ គួរតែប្រកាន់យកដើម្បីធានាថា កតិកាសញ្ញាត្រូវបានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ជាតិ និងក្នុងការអនុវត្តន៍ជាក់ស្ដែង។

## គ. របាយការណ៍ខួប

ខុសគ្នាពីអង្គការដែលបង្កើតឡើងដោយសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀត គណៈកម្មាធិការទទួលបន្ទុកសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ មិនបានអនុម័តយកនីតិវិធីផ្សេង សំរាប់គ្រប់គ្រងរបាយការណ៍ខួប ឬរបាយការណ៍តាមដានបន្ត ជានីតិវិធីខុសពី នីតិវិធីដែលគ្រប់គ្រងរបាយការណ៍ដំបូងដែលរដ្ឋជាភាគីបានដាក់ជូនឡើយ។ រឿងនេះឆ្លុះបញ្ចាំងឱ្យឃើញនូវការយកចិត្តទុកដាក់ជាសំខាន់របស់គណៈកម្មាធិការចំពោះការអនុវត្តជាទម្លាប់ ជាជាងចំពោះបែបបទគតិយុត្តិ និងល្បឿន ការប្ដូរស្ថានការណ៍ក្នុងនិយមន័យនេះ។

ទោះជាយ៉ាងណាក្ដី គណៈកម្មាធិការណ៍បានគូសបញ្ជាក់ថា ខ្លួនមិនសង្ឃឹមថា រដ្ឋជាភាគីលើកយកពតិមាននៅក្នុងរបាយការណ៍ដំបូងមកនិយាយដដែលនៅក្នុងរបាយការណ៍លើកក្រោយទៀតទេ ឱ្យតែស្ថានការណ៍នៅដដែលគ្មានការផ្លាស់ប្ដូរ។ ក៏ប៉ុន្តែ ថ្វីបើការនេះអាចអនុវត្តចំពោះឯកសារច្បាប់ និងឯកសារដទៃទៀតដែលមាននៅក្នុងប្រទេសមួយក្ដី គេហាក់ដូចជាមើលមិនឃើញថា ស្ថានការណ៍នៅក្នុងជីវិតជាក់ស្ដែងនឹងនៅដដែលគ្មានផ្លាស់ប្ដូរនោះ

ទេ នៅក្នុងរយៈពេល ៥ ឆ្នាំ។ ដូច្នេះ គេសង្ឃឹមថា របាយការណ៍ខួបក៏មានភាពលំអិតដូចជារបាយការណ៍ដំបូងដែរ។ គណៈកម្មាធិការមានសេចក្តីប្រាថ្នាចង់ទទួលពត៌មានដែលបរិយាយលំអិតនូវការផ្លាស់ប្តូរក្នុងពេលកន្លងមក ចាប់តាំងពីរបាយការណ៍មុនមក។ ជាងនេះទៀត របាយការណ៍ខួបត្រូវផ្តោតជាពិសេសលើការផ្តល់ពត៌មានទាក់ទងនឹងបញ្ហានានាដែលគួសបញ្ជាក់ដោយគណៈកម្មាធិការ នៅពេលពិនិត្យរបាយការណ៍លើកមុនរបស់រដ្ឋជាភាគី។ រឿងនេះអនុវត្តចំពោះបញ្ហាទាំងអស់ដែលបានពិពណ៌នាមកយ៉ាងវែង លើកលែងជាពិសេសតែបញ្ហាទាំងឡាយណាដែលគណៈកម្មាធិការបានស្នើសុំនៅក្នុងសេចក្តីសង្កេតឃើញចុងបញ្ចប់របស់ខ្លួន ឱ្យរដ្ឋជាភាគីរាយការណ៍ក្នុងបរិបទនៃរបាយការណ៍ខួបរបស់ខ្លួនខាងមុខ។